# ពុទ្ធបណិធាន

# សេចក្តីប្រាថ្នាជាព្រះពុទ្ធ

**អធិបតី ក្នុងការរៀបរៀង**

**បណ្ឌិត កុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា*

*និងជាប្រធានវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ*

*ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា*

**សូមថ្វាយព្រះរាជកុសល**

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**

**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**

**នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

**បពិត្រព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង**

*តាងនាមសមាជិក សមាជិកា ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងនាមទូលព្រះបង្គំ និងភរិយា ព្រមទាំងបុត្រ សូមលំឱនសិរសាដោយត្បូង ទូលព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពស់ខ្ពស់បំផុត។*

*ទូលព្រះបង្គំ យើងខ្ញុំ សូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំយើងខ្ញុំបានប្រែសម្រួល និងរៀបរៀងនូវសៀវភៅ* **ពុទ្ធបណិធាន** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។*

*បពិត្រព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមព្រះករុណាជាអម្ចាស់ ទ្រង់អនុមោទនា នូវមហាកុសល ដោយព្រះរាជហឫទ័យសោមនស្សដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំ យើងខ្ញុំ សូមបួងសួងដល់បារមី នៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ដឹងក្នុងលោកកន្លងមក បារមីនៃព្រះសម្មាសម្ពុទ្ធដែលនឹងត្រាស់ក្នុងអនាគត អានុភាពគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ប្រកបដោយព្រះរាជសុខភាពល្អ បរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណវាងវៃ ដើម្បីគង់*

*ប្រថាប់ជាមួយដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ ឱ្យទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរព ដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យ អនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ*
*ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៧ ខែតុលា ឆ្នាំ២០២៤*

**កុល ផេង**
**ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**និងជាប្រធានវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

# សូមថ្វាយព្រះរាជកុសល

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ

## ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង

*តាងនាមសមាជិក សមាជិកា ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញា-សាស្ត្រកម្ពុជា ក្នុងនាមទូលព្រះបង្គំ និងភរិយា ព្រមទាំងបុត្រ សូមលំឱនសិរសាដោយត្បូង ទូលព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំ យើងខ្ញុំ សូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំ យើងខ្ញុំបានប្រែសម្រួល និងរៀបរៀងនូវសៀវភៅ* **ពុទ្ធបណិធាន** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។*

*បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសល ដោយព្រះរាជហឫទ័យជ្រះថ្លា ដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំ យើងខ្ញុំ សូមឧទ្ទិសដល់បារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដែលបានត្រាស់ដឹងក្នុងលោកកន្លងមក បារមីនៃព្រះសម្មាសម្ពុទ្ធ ដែលនឹងត្រាស់ក្នុងអនាគត អានុភាពគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌*

*ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណវាងវៃ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់នៃប្រជានុរាស្ត្រ ឱ្យទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **សម្តេចព្រះមហាក្សត្រ** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ*
*ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៧ ខែតុលា ឆ្នាំ២០២៤*

**កុល ផេង**
**ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**និងជាប្រធានវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

# សូមគោរពជូនមហាកុសល

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**សម្ដេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

*តាងនាមសមាជិក សមាជិកា ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយា ព្រមទាំងបុត្រ សូមលំឱនកាយគោរពជូនសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្ដី ជ័យមង្គល វិបុលសុខគ្រប់ប្រការចំពោះ* **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពស់ខ្ពស់។*

*ខ្ញុំបាទសូមគោរពជូននូវមហាកុសល ដែលខ្ញុំបាទ យើងខ្ញុំ បានប្រែសម្រួល និងរៀបរៀង នូវសៀវភៅ* **ពុទ្ធបណិធាន** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។*

*សូម* **សម្ដេចតេជោ** *និង* **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ដោយសទ្ធាជ្រះថ្លា។*

*សូមគុណបុណ្យនៃព្រះរតនត្រ័យ និងបារមីនៃវត្ថុសក្ដិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សា និងប្រសិទ្ធពរជ័យជូន* **សម្ដេច** *ព្រមទាំង* **បុត្រា បុត្រី** *និង* **ចៅៗ** *ជាទីស្រឡាញ់របស់* **សម្ដេច** *សូមប្រកបដោយជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិក្នុងការពង្រឹងសុខសន្តិភាព និងការអភិវឌ្ឍ ឱ្យបានសម្បូរសប្បាយរុងរឿង តរៀងទៅ។*

*ខ្ញុំបាទសូមកោតសរសើរ ដោយសុទ្ធចិត្តនូវវីរភាព និងវីរិយភាពដ៏អង់អាចរបស់* **សម្ដេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្ដីសុខ សន្តិភាព និងការអភិវឌ្ឍ ជូន***ព្រះរាជាណាចក្រកម្ពុជា** *ដោយនាំមកនូវភាពចម្រុងចម្រើនរុងរឿងនាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគត។*

*សូម* **សម្តេចតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវឧត្តមពរ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។*

*ធ្វើនៅរាជធានីភ្នំពេញ*
*ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៧ ខែតុលា ឆ្នាំ២០២៤*

**ភូល ផេង**
**ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**និងជាប្រធានវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

# សូមគោរពជូនមហាកុសល

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចមហាបវរធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់**

*តាំងនាមសមាជិក សមាជិកា ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយា ព្រមទាំងបុត្រ សូមលំឱនកាយគោរពជូនសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការចំពោះ* **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវ ពេជ្រ ចន្ទមុនី ហ៊ុន ម៉ាណែត** *ជាទីគោរពដ៏ខ្ពស់ខ្ពស់។*

*ខ្ញុំបាទសូមគោរពជូននូវមហាកុសល ដែលខ្ញុំបាទ យើងខ្ញុំ បានប្រែសម្រួល និងរៀបរៀង នូវសៀវភៅ* **ពុទ្ធបណិធាន** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។*

*សូម* **សម្តេចធិបតី** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ដោយសទ្ធាជ្រះថ្លា។*

*សូមគុណបុណ្យនៃព្រះរតនត្រ័យ និងបារមីនៃវត្ថុសក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សា និងប្រសិទ្ធពរជ័យជូន* **សម្តេច** *ព្រមទាំង* **បុត្រា បុត្រី** *ជាទីស្រឡាញ់របស់* **សម្តេច** *សូមប្រកបដោយជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិក្នុងការពង្រឹងសុខសន្តិភាព និងការអភិវឌ្ឍ ឱ្យបានសម្បូរសប្បាយរុងរឿង តរៀងទៅ។*

*ខ្ញុំបាទសូមកោតសរសើរ ដោយសុទ្ធចិត្តនូវវីរភាព និងវិរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបន្តបំពេញនូវបេសកកម្ម ក្នុងការស្វែងរកសេចក្តីសុខ សន្តិភាព និងការអភិវឌ្ឍ ជូនព្រះរាជាណាចក្រកម្ពុជា ដោយនាំមកនូវភាពចម្រុងចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគត។*

*សូម* **សម្តេចធិបតី** *និង* **លោកជំទាវ** *ប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវឧត្តមពរ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។*

*ធ្វើនៅរាជធានីភ្នំពេញ*
*ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៧ ខែតុលា ឆ្នាំ២០២៤*

**កុល ផេង**
**ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**និងជាប្រធានវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

## បុព្វកថា

***ពុទ្ធបណិធាន*** *ជាដំណើររឿងតំណាលពីបុព្វជាតិ របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ កាលដែលព្រះអង្គយោនយកកំណើតជា* **ព្រះពោធិសត្វ** *មានប្រាជ្ញាច្រើន បានប្រតិបត្តិនូវពុទ្ធការកធម៌ មហាបដិញ្ញា៨បទ បារមី១០ មហាបរិច្ចាគ៥ និងអដ្ឋធម្មសមោធាន។*

***សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*** *បានសម្រេចចិត្តបកប្រែ និងរៀបរៀងនូវ* ***គម្ពីរពុទ្ធបណិធាន*** *នេះ ពីគម្ពីរភាសាបាលីជាច្រើន ក្នុងគោលបំណងដើម្បីៈ*

*១- ជាជំនួយដល់កម្មវិធីអប់រំជាតិ ក្នុងវិស័យព្រះពុទ្ធសាសនា*

*២- ជាឯកសារសិក្សាស្រាវជ្រាវ សម្រាប់ពុទ្ធសាសនិកជនទូទៅ*

*៣- ជាការអភិរក្ស ផ្សព្វផ្សាយអក្សរសាស្ត្រ វប្បធម៌ និងអរិយធម៌ខ្មែរ*

*៤- ជាកេរមរតក សម្រាប់តម្កល់ទុកជូនកុលបុត្រកុលធីតា ជំនាន់ក្រោយ*

*៥- ជាការផ្សព្វផ្សាយព្រះពុទ្ធសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យរីតតែបានទូលំទូលាយ។*

*វិធីក្នុងការបកប្រែ ពុំបានលើកយកមេពាក្យបាលីក្នុងគាថា មកដាក់ ហើយទើបប្រែពន្យល់នោះទេ គឺប្រែយកសេចក្តី ទាំងក្នុងបាលីគាថា ទាំងក្នុងសេចក្តីអធិប្បាយនៃអដ្ឋកថា ឱ្យក្លាយជាភាសាខ្មែរ ល្មមស្តាប់បានតែម្តង។*

***ពុទ្ធបណិធាន****នេះ ទោះបីក្រុមជំនុំបានត្រួតពិនិត្យលើខ្លឹមសារ ន័យ សេចក្តី អក្ខរ ឃ្លាល្បះ ដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នបំផុតក៏ដោយ ក៏គង់នៅសល់សេចក្តីខុសឆ្គងខ្លះ ដាក់ជាពុំខាន។*

*ត្រង់ចំណុចនេះ យើងខ្ញុំបាននឹកឃើញនូវចំណារ របស់សម្តេចព្រះមហាសុមេធាធិបតី* ***ជួន ណាត ជោតញ្ញាណោ*** *មួយប្រយោគថាៈ*

***"ធម្មតា ការងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើន ក៏តិចតួចពុំខាន នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន ព្រោះត្រូវ ជាគូគ្នានឹងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួច ក៏គង់អាចប្រើការកើត គ្រាន់បើជាងគ្មានសោះទៅដែរ"។***

*យើងខ្ញុំ សូមអភ័យទោសអំពីសម្នាក់លោកអ្នកប្រាជ្ញ កវីបណ្ឌិត ព្រឹទ្ធាចារ្យ និងលោកអ្នកអាន ជាទីគោរពទាំងអស់ ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។*

*ជាទីអវសាន របស់បុព្វកថានេះ ដោយអានុភាពនៃកុសល ដែលកើតពីការខិតខំប្រឹងប្រែង ឱ្យបានចេញជាស្នាដៃដ៏ប្រពៃនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសនូវផលបុណ្យ-មនុញ្ញផល ជូនចំពោះបុព្វបុរសខ្មែរ ដែលបានបូជាជីវិតក្នុងបុព្វហេតុជាតិ សូមបានទៅកាន់សុគតិភព។*

*សូមឥដ្ឋមនុញ្ញផល មានដល់មាតាបិតា ជីដូនជីតា បងប្អូន ព្រមទាំងញាតិសាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត ទាំងអតីត បច្ចុប្បន្ន និងអនាគត សូមមានសុខភាពល្អ អាយុយឺនយូរ កម្លាំងកាយមាំមួន ប្រាជ្ញាវាងវៃ កុំបីមានជំងឺតម្កាត់មកបៀតបៀន យាយី ធ្វើទុក្ខបុកម្នេញឱ្យដល់សេចក្តីលំបាកតិចតួចឡើយ ហើយសូមបានជាឧបនិស្ស័យកំពូល គឺការរួចផុតចាកវដ្តទុក្ខ ដល់នូវបរមសុខ ពោលគឺព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ។*

*ធ្វើនៅរាជធានីភ្នំពេញ*
*ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៧ ខែតុលា ឆ្នាំ២០២៤*

**ភុល ផេង**
**ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**និងជាប្រធានវិទ្យាស្ថានពុទ្ធិកសត្យបុត្រអន្តរជាតិ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

# សម្ភោធនីយកថា

***សៀវភៅ* ពុទ្ធបណិធាន** *ជាឯកសារដ៏មានសារៈសំខាន់មួយសម្រាប់ការសិក្សាស្រាវជ្រាវរបស់លោកអ្នកដែលចង់ដឹងពីរឿងរ៉ាវនៃការធ្វើសេចក្តីប្រាថ្នាជាព្រះពុទ្ធរបស់ព្រះពោធិសត្វ។ សៀវភៅនេះ សម្តែងពី**បណិធាន** (សេចក្តីតាំងទុកទូទៅ, សេចក្តីប្រាថ្នា; វិ.**បណិធិយតេតិ បណិធានំ**។) របស់ព្រះពោធិសត្វ ដែលព្រះអង្គប្រាថ្នាឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ ដោយរាប់ចាប់តាំងពី**បឋមចិត្តុប្បាទ** រហូតដល់ការតាំងចិត្តប្រាថ្នាជាព្រះពុទ្ធជាដំបូង(មនោបណិធាន) ក្នុងសម្នាក់ព្រះ**ពុទ្ធព្រហ្មទេវៈ** នឹងត្រូវបំពេញសេចក្តីព្យាយាមបន្ត អស់ **៧ អសង្ខេយ្យកប្ប** និងរហូតដល់ការបញ្ចេញវាចាប្រាថ្នាជាព្រះពុទ្ធជាដំបូង (វចីបណិធាន) ក្នុងសម្នាក់ព្រះ**ពុទ្ធបុរាណសក្យមុនី** នឹងត្រូវបំពេញសេចក្តីព្យាយាមបន្ត អស់ **៩ អសង្ខេយ្យកប្ប** ទៀត។ រួចហើយ ព្រះពោធិសត្វត្រូវបានទទួលពុទ្ធព្យាករណ៍ជាដំបូងក្នុងសម្នាក់ព្រះ**ពុទ្ធទីបង្ករ** នឹងត្រូវបំពេញសេចក្តីព្យាយាម តទៅ អស់ **៤ អសង្ខេយ្យ និង ១សែនកប្ប** ថែមទៀត ទើបបានត្រាស់ដឹង។*

***ពុទ្ធបណិធាន សេចក្តីប្រាថ្នាជាព្រះពុទ្ធ មាន ៤ ដំណាក់កាលធំៗ គឺ ៖***

***១-មុន២០អសង្ខេយ្យ និង ១សែនកប្ប** ចាប់តាំងពីបឋមចិត្តុប្បាទ។*

***២-មនោបណិធាន** សេចក្តីប្រាថ្នាជាព្រះពុទ្ធដោយចិត្តក្នុងសម្នាក់ព្រះពុទ្ធជាដំបូង មាន៧អសង្ខេយ្យកប្ប។*

***៣-វចីបណិធាន** សេចក្តីប្រាថ្នាជាព្រះពុទ្ធដោយវាចាក្នុងសម្នាក់ព្រះពុទ្ធជាដំបូង មាន៩អសង្ខេយ្យកប្ប។*

***៤-កាយវាចាមនោបណិធាន** សេចក្តីប្រាថ្នាជាព្រះពុទ្ធដោយកាយវាចាចិត្តក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ មាន៤អសង្ខេយ្យ និង ១សែនកប្ប។*

*ខ្ញុំព្រះករុណា ខ្ញុំបាទ មានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលលោកតាបណ្ឌិត* **ករុល ផេង** *និងសហការី បានព្យាយាមបកប្រែនិងរៀបរៀងនូវសៀវភៅ* **ពុទ្ធបណិធាន** *នេះឡើង សម្រាប់ជាឯកសារសិក្សាស្រាវជ្រាវទូទៅដល់ពុទ្ធសាសនិកជន ជាពិសេសលោកអ្នកដែលប្រាថ្នាពុទ្ធភូមិ ។ សៀវភៅ* **ពុទ្ធបណិធាន** *នេះ បានដាក់*

ឯកសារយោងជាច្រើន មានទាំងបិដក អដ្ឋកថា ដីកា និងគម្ពីរបករណ៍ទាំងឡាយផ្សេងៗ ដើម្បីឱ្យសិក្ខាកាមបានយល់ច្បាស់ និងអាចចូលទៅមើលដោយផ្ទាល់នូវគម្ពីរទាំងនោះ។

ជាអវសាន ខ្ញុំព្រះករុណា ខ្ញុំបាទ ក៏សូមអរគុណយ៉ាងក្រៃលែង ចំពោះលោកតាបណ្ឌិត **ភុល ផេង** និងក្រុមការងារទាំងអស់ ដែលបានចូលរួមខ្នះខ្នែងសហការ ក្នុងការរៀបចំធ្វើសៀវភៅនេះតាំងពីដើម រហូតដល់ចប់ ។

ថ្ងៃ ៤ រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃចន្ទ ទី១៧ ខែមីនា ឆ្នាំ២០២៥

**អធិការបតីរងនៃវិទ្យាស្ថានពុទ្ធិកសក្យបុត្រអន្តរជាតិ**

**សោម វណ្ណៈ**

# មាតិកា

## ជំពូកទី១: ពាហិរនិទាន

## រឿងរ៉ាវមុន២០អសង្ខេយ្យ និង ១សែនកប្ប

## មាន២និទាន គឺ ពាហិរនិទាន និង អជ្ឈត្តិកនិទាន


*ពាហិរនិទាន មាន៣ជាតិ អជ្ឈត្តិកនិទាន មាន១ជាតិ* ទំព័រទី១

*ជាតិទី១: មាតុរុទ្ធកនាវិក ឬ នាយនាវិកចិញ្ចឹមមាតា* ទំព័រទី៣

*ជាតិទី២: ព្រះបាទគជប្បិយៈ ឬ ព្រះបាទសត្តុត្តាសនកទមកៈ* ទំព័រទី១២

*ជាតិទី៣: ព្រហ្មឥសី* ទំព័រទី២៧

*សិទ្ធត្ថតេលទាយិកាពជបុត្តី ឬ ព្រះរាជបុត្រីថ្វាយប្រេងគ្រាប់ស្ពៃ*

*ចំពោះព្រះសម្មាសម្ពុទ្ធបុរាណទីបង្ករ* ទំព័រទី៣៧


## ជំពូកទី២: មហានិទាន

## (មនោបណិធាន មាន៧អសង្ខេយ្យ)


*សត្តាសង្ខ្យេយ្យកថា* ទំព័រទី៦៣

*មហានិទាន មាន១ជាតិ ព្រះបាទអតិទេវៈ* ទំព័រទី៦៤


## ជំពូកទី៣: អតិទូរេនិទាន

## (វចីបណិធាន មាន៩អសង្ខេយ្យ)


*នវាសង្ខ្យេយ្យវាចិកកថា* ទំព័រទី៨១

*អតិទូរេនិទានមាន១ជាតិ*

*ព្រះបាទសាគលចក្កវត្តិរាជ* ទំព័រទី៨៣


## ជំពូកទី៤: អវិទូរេនិទាន

## (កាយវាចាមនោបណិធាន មាន៤អសង្ខេយ្យ ១សែនកប្ប)

## អវិទូរេនិទាន


*កាយវាចាមនោបណិធានចតុអសង្ខ្យេយ្យកថា* ទំព័រទី១១៨

*តណ្ហង្ករពុទ្ធុប្បាទ* ទំព័រទី១១៩

មេធង្ករពុទ្ធប្បវត្តិ ទំព័រទី១១៦
សរណង្ករពុទ្ធប្បវត្តិ ទំព័រទី១១៧
ទីបង្ករពុទ្ធប្បវត្តិ ទំព័រទី១១៨
សុមេធបណ្ឌិតទទួលពុទ្ធព្យាករណ៍ ទំព័រទី១១៩

## ជំពូកទី៥:
## កោណ្ឌញ្ញពុទ្ធប្បវត្តិ រហូតដល់ កស្សបពុទ្ធប្បវត្តិ

កោណ្ឌញ្ញពុទ្ធប្បវត្តិ ទំព័រទី១៥៤
មង្គលពុទ្ធប្បវត្តិ ទំព័រទី១៥៩
សុមនពុទ្ធប្បវត្តិ ទំព័រទី១៦៤
រេវតពុទ្ធប្បវត្តិ ទំព័រទី១៧០
សោភិតពុទ្ធប្បវត្តិ ទំព័រទី១៧៥
អនោមទស្សិពុទ្ធប្បវត្តិ ទំព័រទី១៨១
បទុមពុទ្ធប្បវត្តិ ទំព័រទី១៨៦
នារទពុទ្ធប្បវត្តិ ទំព័រទី១៩១
បទុមុត្តរពុទ្ធប្បវត្តិ ទំព័រទី១៩៨
សុមេធពុទ្ធប្បវត្តិ ទំព័រទី២០៣
សុជាតពុទ្ធប្បវត្តិ ទំព័រទី២០៨
បិយទស្សិពុទ្ធប្បវត្តិ ទំព័រទី២១៥
អត្ថទស្សិពុទ្ធប្បវត្តិ ទំព័រទី២២១
ធម្មទស្សិពុទ្ធប្បវត្តិ ទំព័រទី២២៦
សិទ្ធត្ថពុទ្ធប្បវត្តិ ទំព័រទី២៣០
តិស្សពុទ្ធប្បវត្តិ ទំព័រទី២៣៤
បុស្សពុទ្ធប្បវត្តិ ទំព័រទី២៣៩
វិបស្សិពុទ្ធប្បវត្តិ ទំព័រទី២៤៤

*សិខិពុទ្ធប្បវត្តិ* *ទំព័រទី២៤៩*
*វេស្សភូពុទ្ធប្បវត្តិ* *ទំព័រទី២៥៤*
*កកុសន្ធពុទ្ធប្បវត្តិ* *ទំព័រទី២៥៩*
*កោនាគមនពុទ្ធប្បវត្តិ* *ទំព័រទី២៦៤*
*កស្សបពុទ្ធប្បវត្តិ* *ទំព័រទី២៧០*
*មហាបដិញ្ញា៨បទ* *ទំព័រទី២៧៦*

## ជំពូកទី៦:
## គោតមពុទ្ធប្បវត្តិ និង យសោធរាថេរី

*ព្រះសមណគោតម និងប្រវត្តិសង្ខេបរបស់ព្រះនាងពិម្ពា យសោធរាថេរី*
*ព្រមទាំងបុព្វចរិយាព្រះនាងពិម្ពា យសោធរាថេរី*

*គោតមពុទ្ធប្បវត្តិ* *ទំព័រទី២៧៨*
*ពុទ្ធបកិណ្ណកកណ្ឌ* *ទំព័រទី២៨១*
*គាថាសម្ដែងអំពីចំនួនព្រះសម្មាសម្ពុទ្ធ* *ទំព័រទី២៨៦*
*សម្ពុទ្ធេគាថា* *ទំព័រទី២៩០*
*ប្រវត្តិសង្ខេប របស់ព្រះនាងពិម្ពា យសោធរា* *ទំព័រទី២៩៣*
*ចន្ទកិន្នរីជាតក* *ទំព័រ៣០៨*
***យសោធរា ថេរិយាបទាន*** *(បុព្វចរិយា*
*របស់ព្រះនាងពិម្ពា យសោធរា កន្សែរសារពេជ្រ)* *ទំព័រទី៣៥០*
***យសោធរាបមុខទសភិក្ខុនីសហស្សអបទាន***
*(បុព្វចរិយា របស់ភិក្ខុនី១ម៉ឺនអង្គ ដែលមាន*
*ព្រះនាងយសោធរា ជាប្រមុខ)* *ទំព័រទី៣៦៤*
***យសោធរាបមុខអដ្ឋារសភិក្ខុនីសហស្សអបទាន***
*(បុព្វចរិយា របស់ភិក្ខុនី១ម៉ឺន៨ពាន់អង្គ*
*ដែលមានព្រះនាងយសោធរា ជាប្រមុខ)* *ទំព័រទី៣៦៧*

**យសវតីបមុខអដ្ឋារសភិក្ខុនីសហស្សាបទាន**
*(អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន)* ទំព័រទី៣៧៦
**ចតុរាសីតិភិក្ខុនីសហស្សអបទាន**
*(ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន)* ទំព័រទី៣៧៨
**ធម្មរុចិត្ថេរាបទាន** *(រឿងមេឃតាបសជាមិត្ត*
*របស់សុមេធបណ្ឌិត)* ទំព័រទី៣៨៤
*ឯកសារយោង* ទំព័រទី៣៩០

# ពុទ្ធបណិធាន
## ជំពូកទី១ ពាហិរនិទាន

## មាន ៣ និទានកថា

**មាតុរុទ្ធរកនាវិក** *ជាតិទី១*

**ព្រះបាទគជប្បិយ** *ជាតិទី២*

**ព្រហ្មឥសី** *ជាតិទី៣*

## និទានទាំងបីនេះ ជាសេចក្តីប្រាថ្នាជាព្រះពុទ្ធ

## ក្រៅព្រះពុទ្ធសាសនា

ពុទ្ធបណិធាន

# សេចក្ដីប្រាថ្នាជាព្រះពុទ្ធ

*រឿងរ៉ាវមុន២០អសង្ខេយ្យ និង១សែនកប្ប*

*មាននិទាន២ គឺពាហិរនិទាន និងអជ្ឈត្តិកនិទាន*

*ពាហិរនិទាន មាន ៣ ជាតិ*

***ជាតិទី១***

*ក្នុងកំណើតជា*

## មាតុរុទ្ធរកនាវិក

*នាយនាវិកចិញ្ចឹមមាតា*

*គឺជា*

*សេចក្ដីប្រាថ្នាជាព្រះពុទ្ធលើកដំបូង*

*ក្រៅព្រះពុទ្ធសាសនា*



នេះកាលព្រះពោធិសត្វតាំងប្រាថ្នាជាព្រះពុទ្ធជាលើកដំបូង

## ជាតិទី១ ក្នុងកំណើតជា មាតុបោសកនាគ

ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ ព្រះពោធិសត្វនៃយើងកើតក្នុងត្រកូលក្រីក្រមួយនៅដែនគន្ធារៈ លុះចម្រើនវ័យធំហើយ ត្រូវបានមាតាបិតាសុំឱ្យយកភរិយា តែលោកប្រកែកមិនព្រម។

ដោយហេតុមាតាបិតាសុំឱ្យយកប្រពន្ធរឿយៗយ៉ាងនេះ មាណពក៏បាននិយាយថា៖

"បពិត្រលោកឪពុកអ្នកម្ដាយ នៅក្នុងផ្ទះរបស់ពួកយើងគ្មានវត្ថុមានតម្លៃជាមាស ឬប្រាក់នោះឡើយ ដូច្នេះ កូននឹងមិនយកប្រពន្ធទេ កូននៅប្រណិប័តន៍បម្រើលោកឪពុក អ្នកម្ដាយរហូតដល់អស់ជីវិត"។

ក្រោយមក បិតារបស់មាណពក៏បានធ្វើកាលកិរិយា រួចមាតារបស់មាណពក៏បាននិយាយនឹងកូនទៀតថា៖

"ចូរកូនយកភរិយា មកជួយគ្រប់គ្រងផ្ទះចុះ"។

តែមាណពមិនព្រមទទួលធ្វើតាមដដែល ហើយមាណពមិនប្រមាទ លោកតែងចូលទៅក្នុងព្រៃរកឧស បេះបន្លែ និងផ្លែឈើ ដើម្បីលក់យកប្រាក់មកចិញ្ចឹម និងថែទាំមាតា។

ថ្ងៃមួយ ពេលដែលមាណព ចូលទៅក្នុងព្រៃធ្វើការដូចធម្មតា តែដោយហត់នឿយព្រោះសេចក្ដីស្រេកឃ្លានផង រងកម្ដៅព្រះអាទិត្យផង និងការរែកឧសធ្ងន់ផង ក៏បានចូលទៅជ្រកក្រោមដើមជ្រៃមួយដើម ដែលដុះនៅជិតមាត់ច្រាំងទន្លេគង្គា រួចមាណពក៏បានដាក់អម្រែកចុះដើម្បីសម្រាកបន្តិច ហើយក៏លង់លក់នៅទីនោះទៅ។

**ពុទ្ធបណិធាន**

លុះគ្រាភ្ញាក់ឡើង មាណពបានគិតពិចារណាថា ពេលនេះ អាត្មាអញនៅក្មេង មានកម្លាំង អាចអត់ធន់ចំពោះការលំបាក ព្រោះកម្តៅបែបនេះជាដើមបាន តែនៅពេលអាត្មាអញទ្រុឌទ្រោមកម្លាំង ចាស់ ឬឈឺ ពេលនោះប្រាកដជាមិនអាចអត់ធន់ នឹងការលំបាក យ៉ាងនេះបានទេ។ ណ្ហើយចុះ! យើងនឹងទៅសុវណ្ណភូមិ ជាមួយនឹងពួកពាណិជទាំងឡាយ ដើម្បីរកមាសប្រាក់មកចិញ្ចឹមមាតា ឱ្យមានសេចក្តីសុខ។

គិតដូច្នោះហើយ មាណពទុកអម្រែកនៅទីនោះ រួចចូលទៅរកពួកពាណិជ ហើយអង្គុយក្នុងសម្នាក់ពាណិជជាប្រធាន។

ចំណែកប្រធានពាណិជ ឃើញមាណពចម្លែក ដែលមកកាន់សម្នាក់ខ្លួនក៏បានសួរថា៖

"នែអ្នក! អ្នកមកអំពីទីណា ហើយមកទីនេះមានការអ្វី"?

មាណព កាលនឹងធ្វើការអធិប្បាយឱ្យជាក់ច្បាស់ ទើបពោលគាថា ថា៖

"ឧលិង្គោ ជានិហំ សាមិ, អមុតាមស្មា អាគតោ;
សចេ មំ អនុកម្បេសិ, តយា សទ្ធឹ គមិស្សហំ"។

"បពិត្រលោកនាយ ខ្ញុំសព្វថ្ងៃនេះ ជាមនុស្សក្រីក្រលំបាកណាស់ ដើរមកអំពីស្រុកឯណោះ បើលោកនាយអនុគ្រោះ ខ្ញុំសូមទៅធ្វើការជាមួយលោក"។

នាយនាវិក ជាប្រធានពាណិជ បានស្តាប់ពាក្យនោះ រួចឃើញមាណពបរិបូណ៌ដោយកម្ពស់ និងកម្លាំង គាត់កើតសោមនស្សត្រេកអរ ហើយពោលគាថាតបថា៖

"សាធុ តាត សុភាសេសិ, ទិប្បំ ឯហិ មមន្តិកោ;
យត្តកំ វេតនំ តុយ្ហំ, តត្តកំ តេ ទទាមហំ។
អញ្ញម្បិ បរិព្វយំ ទេមិ, យថា ត្វំ ជនមិច្ឆសិ;
តេហិ តាត សុខំ ជីវ, យាវជីវំ យទិច្ឆកំ"។

"នៃអ្នក! ល្អណាស់ អ្នកនិយាយត្រូវហើយ សូមអ្នកប្រញាប់មកកាន់សម្នាក់ខ្ញុំចុះ តម្លៃខ្លួនរបស់អ្នកមានចំនួនប៉ុនណា ខ្ញុំនឹងឱ្យតម្លៃខ្លួនចំនួនប៉ុណ្ណោះ ដល់អ្នក។

ខ្ញុំនឹងឱ្យស្បៀង និងវត្ថុដទៃទៀតផង តាមដែលអ្នកប្រាថ្នា សូមអ្នកមកនៅឱ្យសប្បាយ តាមសេចក្ដីប្រាថ្នារបស់អ្នកចុះ"។

មាណព បានស្ដាប់ដូច្នោះហើយ ក៏សំពះលាប្រធាននាវិក ប្រញាប់ត្រឡប់ទៅកាន់ដើមជ្រៃ ហើយគិតថា **បើយើងនឹងទៅសុវណ្ណភូមិតាមនាវាបាត់ តើបានអ្នកណា នឹងនៅមើលថែទាំមាតា? ការគិតនេះមិនសមគួរសោះ យើងនឹងទៅសួរមាតាជាមុនសិន បន្ទាប់មក នឹងសម្រេចចិត្តជាក្រោយ។**

មាណព បានវេកអម្រែកទៅផ្ទះ ធ្វើកិច្ចដែលគប្បីធ្វើទាំងពួងស្រេចបាច់ ទើបបរិភោគអាហារ រួចមាណពបានចូលទៅថ្វាយបង្គំមាតា ហើយពោលយ៉ាងនេះថា៖

"អម្ម បពិត្រអ្នកម្ដាយ ពួកពាណិជ មកកាន់ទីនេះដោយទូកនឹងទៅកាន់សុវណ្ណភូមិ។ ចំណែកកូនឥឡូវនេះ នៅក្មេងមានកម្លាំង អាចធ្វើការងារដែលមានសភាពបែបនេះបាន តែនៅពេលកូនទ្រុឌទ្រោមកម្លាំង ឬចាស់ទៅ ឬពេលឈឺ កូននឹងធ្វើអ្វីមិនបាន។

អាស្រ័យហេតុដូច្នោះ ខ្ញុំនឹងទៅសុវណ្ណភូមិជាមួយពួកពាណិជ

*ទាំងឡាយដែលត្រូវចេញដំណើរទៅពេលដ៏ខ្លីខាងមុខនេះ"។*

*មាតារបស់មាណព លុះបានស្តាប់ពាក្យនោះហើយ ក៏បានពោលថា៖*

*"នែកូនមាសម្តាយ ជីវិតរបស់ម៉ែជាប់នឹងកូន ព្រោះហេតុនេះ បើកូនប្រាថ្នាទៅទីណា ម៉ែនឹងទៅទីនោះ ជាមួយកូនដែរ"។*

*មាណពបានស្តាប់ពាក្យនោះរួច មានចិត្តត្រេកអរ ថ្វាយបង្គំមាតា ហើយទៅកាន់សម្នាក់នាយពាណិជម្តងទៀត និងពោលយ៉ាងនេះថា៖*

*"បពិត្រលោកនាយ ខ្ញុំមិនអាចទៅតែម្នាក់ឯងបានទេ បើលោកនាយឱ្យមាតារបស់ខ្ញុំ ទៅជាមួយដែរ ទើបខ្ញុំទៅជាមួយពួកលោកបាន។ ព្រោះមាតារបស់ខ្ញុំជាស្ត្រីមេម៉ាយ គាត់ចាស់ ក្រីក្រ កំព្រាបុត្រធីតា និងចៅ អ្នកដទៃក្រៅអំពីខ្ញុំមិនមាន ហើយគាត់មិនមានញាតិណាម្នាក់នោះទេ។*

*ដូច្នេះ ទើបខ្ញុំមិនអាចលះបង់គាត់ ហើយទៅចោលគាត់បានឡើយ"។*

*ពាណិជ ស្តាប់ពាក្យនោះហើយ កើតសោមនស្ស បានពោលថា៖*

*"**សាធុ សាធុ** អ្នកអើយ ចូរអ្នកទៅនាំមាតារបស់អ្នកមកឱ្យប្រញាប់ចុះ ខ្ញុំនឹងឱ្យស្បៀង ដល់គាត់ផងដែរ"។*

*ព្រះពោធិសត្វ មានចិត្តត្រេកអរ ថ្វាយបង្គំពាណិជនោះ រួចត្រឡប់ទៅផ្ទះ រៀបចំយកវត្ថុប្រើប្រាស់បន្តិចបន្តួចជាប់ខ្លួន ហើយនាំមាតាទៅកាន់សម្នាក់នាយពាណិជវិញ។*

*ចំណែកនាយពាណិជ ក៏មានចិត្តត្រេកអរ ហើយផ្តល់ស្បៀងដល់ព្រះពោធិសត្វ និងឱ្យស្នាក់នៅទីនោះអស់ពីរបីថ្ងៃ។ ក្នុងកាលដែលត្រូវលើកជណ្តើរសំពៅឡើង នាយពាណិជឱ្យគេហៅមាណពមក ហើយពោលថា៖*

*"នៃអ្នកកំលោះ ចាប់ពីពេលនេះទៅ ទ្រព្យរបស់ខ្ញុំទាំងអស់ក្ដី ស្បៀងសម្រាប់ដំណើរផ្លូវក្ដី នាវាក្ដី ខ្ញុំសូមប្រគល់ឱ្យជាភារៈដល់អ្នកហើយ។ រួចចាប់ពីពេលនេះទៅ កិច្ចការទាំងអស់ ជាភារៈរបស់អ្នកហើយ"។*

*ពោលដូច្នេះហើយ នាយពាណិជ ក៏ផ្ដល់នូវអ្វីទាំងអស់ ដែលគួរគប្បីឱ្យដល់មាណព។*

*ចាប់ពីពេលនោះមក មាណពបានធ្វើកិច្ចការទាំងអស់លើនាវា តាមការប្រគល់របស់នាយនាវិក។*

*ក្នុងថ្ងៃដែលលើកដណ្ដើរនាវា ព្រះពោធិសត្វបានអញ្ជើញមាតា ឱ្យឡើងលើនាវា ហើយបើកចេញទៅ ជាមួយនឹងពួកពាណិជទាំងឡាយ។*

*សំពៅរបស់ពាណិជ បានធ្វើដំណើរដោយសុខសប្បាយ អស់រយៈពេល៧ថ្ងៃ, តែនៅថ្ងៃទី៨ មានខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង នៅកណ្ដាលមហាសមុទ្រ ធ្វើឱ្យដាច់ខ្សែក្ដោងនាវាអស់ និងបណ្ដាលឱ្យសំពៅបាក់បែកខ្ទុះខ្ទាយ ហើយនាវាក៏បានលិចចូលទៅក្នុងមហាសមុទ្រ។*

*គ្រានោះ ពាណិជទាំងអស់ ក៏ភ័យនឹងមហន្តរាយចំពោះមុខហើយជួបនឹង**វិប្បការ**[១] ផ្សេងៗ ដែលកើតដល់ជីវិតរៀងៗខ្លួន។*

*ខណៈដែលមាណព ហែលដើម្បីរក្សាជីវិត បានប្រមាណពីរទៅបីហត្ថពីកន្លែងដែលលិចសំពៅ បានរលឹកដល់មាតា រួចក៏ហែលត្រឡប់មកសម្លឹងរក*

---

*[១](ន.)(បា.សំ.)សេចក្ដីមើលងាយ, ការមាក់ងាយ មាក់ងោក, ការធ្វើឱ្យប្រទះអន្តរាយ, ការធ្វើឱ្យគេបានសេចក្ដីទុក្ខលំបាក, សេចក្ដីព្យាបាទ, ការធ្វើអាក្រក់ទៅរក, អំពើអាក្រក់: **ធ្វើវិប្បការ, មានវិប្បការ, ប្រទះវិប្បការ**។*

*មើល ទើបឃើញមាតាកំពុងតោងក្តារ១បន្ទះ។*

*មាណព ហែលមករកមាតា តម្កល់មាតាទុកលើករបស់ខ្លួន ហើយខំហែលឆ្លងមហាសមុទ្រ ដែលពោរពេញដោយរលកធំៗបន្តបោកប្រដេញ ព្រោះខ្យល់ព្យុះ គួរឱ្យភ័យខ្លាចជាពន់ពេក ពេញផ្ទៃមហាសាគរ។*

*ក្នុងកាលនោះ មហាព្រហ្ម ដែលមានអាយុ១៦,០០០កប្ប ឋិតនៅ* ***អកនិដ្ឋភូមិ***[២] *បានដឹងថាកន្លងអស់មួយអសង្ខេយ្យទៅមុខ ពុំមានព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើយ។*

*លោកបានពិចារណា សម្លឹងរកមើលជន ដែលមានសមត្ថភាពអាចបំពេញនូវ****ពុទ្ធការកធម៌***[៣] *បាន។*

*មហាព្រហ្ម បានឃើញមាណពដ៏អង់អាច កំពុងលះបង់ជីវិត ដើម្បីជួយសង្គ្រោះមាតារបស់ខ្លួន ទើបត្រិះរិះថា* ***មហាបុរសនេះ មិនគិតដល់មហា-សមុទ្រ ដែលជ្រៅមិនមានទីបំផុតមើលមិនឃើញច្រាំងខាងនាយ សុខចិត្តលះបង់ជីវិតរបស់ខ្លួន ប្រាថ្នាចម្លងមាតារបស់ខ្លួនតែប៉ុណ្ណោះ បុរសមានវិរិយៈខ្លាំងបែបនេះ ទើបមានសមត្ថភាពនឹងបំពេញនូវពុទ្ធការកធម៌បាន។***

*គិតដូច្នេះហើយ មហាព្រហ្ម ក៏ជ្រែកចូលទៅក្នុងសរីរៈ របស់មាណព ហើយញុំាង* ***ចេតោបណិធាន***[៤] *នូវភាពជាព្រះពុទ្ធឱ្យកើតមានឡើង។*

---

[២] *(ន.)(បា.សំ.)ឈ្មោះឋានសុទ្ធាវាសជាន់ទី៥:* ***ឋានអកនិដ្ឋ;ហៅអកនិដ្ឋា****ក៏បាន(ម.ព.* ***សុទ្ធាវាស*** *ក្នុងពាក្យ****សុទ្ធ*** *ទៀតផង)។ បើរៀងភ្ជាប់ពីដើមសព្ទដទៃ អ.ថ.អៈ កៈនិត-ឋៈ, ដូចជា****អកនិដ្ឋព្រហ្ម*** *(ព្រហ្មក្នុងឋានអកនិដ្ឋៈ)។*

[៣] *(ន.)(បា.សំ.)ជាការកសាងបារមី របស់ព្រះពោធិសត្វ មានបារមី១០ជាដើម។*

[៤] *(ន.)(បា.សំ.) មានពោធិចិត្តកើតឡើង គឺសេចក្តីប្រាថ្នាដោយចិត្ត ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។*

*នៅគ្រានោះ ឈ្មោះថាបុគ្គលដទៃក្នុងអនន្តចក្រវាលក្តី ក្នុងចក្រវាលនេះក្តី ដែលមានកម្លាំង មានញាណ មានសមត្ថភាព ដើម្បីបំពេញនូវពុទ្ធការកធម៌ដូចជាមាណព ជាមហាបុរសនេះ រមែងមិនមាន ទើបមហាព្រហ្មជាន់សុទ្ធាវាសនោះ ចូលជ្រែកក្នុងសរីរៈ របស់មហាបុរស ហើយញ៉ាំងចេតោបណិធានឱ្យកើតមានឡើង។*

*ពេលនោះ មហាបុរស ដែលចិញ្ចឹមមាតា ត្រូវកម្លាំងរលកបោកបក់ស្ទើរនឹងលិចធ្លាក់ទៅបាតសមុទ្រម្តងៗទៅហើយ តែបន្ទាប់ពីមហាព្រហ្មជ្រែកចូលហើយ ក៏គិតឡើងថា* ***ប្រសិនបើអាត្មាអញមិនធ្វើសច្ចកិរិយាមួយទេ អាត្មាអញនឹងស្លាប់ជាមួយនឹងមាតារបស់អញក្នុងកណ្តាលសមុទ្រនេះឯង ព្រោះហេតុនោះ យើងនឹងធ្វើសច្ចកិរិយាមួយ។***

*គិតដូច្នេះហើយ ទើបញ៉ាំងចិត្តយ៉ាងនេះ ឱ្យកើតឡើងម្តងទៀតថា៖*

**"ពុទ្ធោ ពោធេយ្យំ, មុត្តោ មោចេយ្យំ, តិណ្ណោ តារេយ្យំ"។**

***"យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង,យើងរួចផុតហើយនឹងឱ្យអ្នកដទៃរួចផុតផង, យើងឆ្លងផុតហើយ នឹងឱ្យអ្នកដទៃឆ្លងផុតផង"។***

*កាលញ៉ាំងចិត្ត ឱ្យកើតឡើងយ៉ាងនេះហើយ ព្រះពោធិសត្វក៏ហែលឆ្លងមហាសមុទ្រ ដោយសេចក្តីព្យាយាមដ៏ធំ បានដល់ច្រាំងសមុទ្រក្នុងរយៈពេលត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ដោយអាស្រ័យទេវតាជាអ្នកជួយនាំមុខផង។*

*បន្ទាប់មក មាណពបាននាំមាតាទៅកាន់ស្រុកមួយ ហើយរស់នៅទីនោះ ដោយទំនុកបម្រុង មើលថែទាំចិញ្ចឹមមាតា ដរាបដល់អស់ជីវិត។*

**ពុទ្ធបណិធាន**

*ក្រោយពេល ដែលមាណពអស់ជីវិត លោកក៏បានទៅបដិសន្ធិក្នុងទេវលោក ចំណែកមាតារបស់លោក ក៏ទៅកើតតាមយថាកម្មរបស់ខ្លួនដែរ។*

បឋមបណិធាជាយំ *នេះឯង ជា***បឋមបណិធាន**។

*ព្រោះហេតុនោះ ទើបលោកពោលថា ព្រះដ៏មានព្រះភាគ ត្រាស់ដឹងហើយថ្មីៗ នាសប្តាហ៍ទី៨ ខណៈទ្រង់ប្រថាប់ នៅនឹងដើមអជបាលនិគ្រោធ ក្នុងកាលព្រហ្មមកអារាធនា ហើយរំលឹកពាក្យ ដែលទ្រង់ចាំ ដោយគាថា ថា៖*

"ពុទ្ធោហំ ពោធយិស្សាមិ, ឥតិយំ បត្ថនំ កតំ;
តេន បត្តោម្ហិ សម្ពុទ្ធោ, ហន្ទ ពោធេមិ ចាណិនំ។
មុត្តោហំ មោចយិស្សាមិ, ឥតិយំ បត្ថយំ កតំ;
តេន មុត្តោម្ហិ សំសារា, ហន្ទ មោចេមិ ចាណិនំ។
តិណ្ណោហំ តារយិស្សាមិ, ឥតិយំ បត្ថនំ កតំ;
តេន តិណ្ណោម្ហិ សំសារា, ហន្ទ តារេមិ ចាណិនំ"។

*យើងបានធ្វើសេចក្តីប្រាថ្នាណា ទុកថា៖*

***"យើងត្រាស់ដឹងហើយ នឹងប្រៀនប្រដៅអ្នកដទៃឱ្យត្រាស់ដឹងផង ឥឡូវនេះ យើងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ក៏ព្រោះសេចក្តីប្រាថ្នានោះម៉្លោះហើយ យើងនឹងញ៉ាំងសត្វទាំងឡាយឱ្យត្រាស់ដឹងដែរ។***

*យើងបានធ្វើសេចក្តីប្រាថ្នាណាទុកថា* ***យើងរួចផុតហើយនឹងញ៉ាំងអ្នកដទៃឱ្យរួចផុតផង ឥឡូវយើងបានរួចផុតចាកសង្សារវដ្តហើយ ក៏ព្រោះសេចក្តីប្រាថ្នានោះ ម៉្លោះហើយ យើងនឹងញ៉ាំងសត្វទាំងឡាយឱ្យរួចផុតដែរ។***

*យើងបានធ្វើសេចក្តីប្រាថ្នាណាទុកថា* ***យើងឆ្លងផុតហើយនឹងញ៉ាំងអ្នកដទៃឱ្យឆ្លងផុតផង ឥឡូវយើងបានឆ្លងផុតចាកសង្សារវដ្ត ក៏ព្រោះ***

*សេចក្ដីប្រាថ្នានោះ ម៉្លោះហើយ យើងនឹងញ៉ាំងសត្វទាំងឡាយឱ្យរួចផុតសង្សារវដ្ដដែរ"។*

*ទោះបីជាលើកទី១ នៃសេចក្ដីប្រាថ្នា ដោយ***ចេតោបណិធាន** *ដើម្បីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្ដី ព្រះពោធិសត្វបានបំពេញនូវមហាកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះមាតារបស់លោក។ ជាពិសេស លោកបានបីបាច់ ថែទាំមាតារហូតអស់មួយជីវិត សូម្បីកិរិយាក៏លោកមិនប្រាថ្នាដែរ ដែលនេះគឺជាគុណធម៌មួយដ៏ចម្បង ហើយត្រង់ចំណុចនេះមានសុភាសិតបានពោលទុកថា៖*

"**កតញ្ញុតា ធម្មជនកស្ស បធានំ ហោតិ អភិមូលដ្ឋានំ**"។

*មានន័យថា "***កតញ្ញូ** *ជាមូលដ្ឋានគ្រឹះ(មូលដ្ឋានដ៏ខ្ពង់ខ្ពស់) នៃការសាងគុណធម៌ទាំងឡាយ"។*

**កតញ្ញុតា លោកេ ធម្មមូលា កតញ្ញុតា**
**លោកេ បធានកា កតញ្ញុតាយ សន្តិយា**
**សព្វបុញ្ញញ្ច វិជ្ជតិ។**

*កតញ្ញូតាធម៌ជាឫសគល់នៃធម៌ទាំងឡាយក្នុងលោក, កតញ្ញូតាធម៌ជាប្រធាននៃធម៌ទាំងឡាយក្នុងលោក, ក៏បុណ្យទាំងពួងរមែងមានក្នុងកតញ្ញូតាធម៌។*
**សម្គាល់៖** *ជាតិជាតួអង្គ នៃរាល់ព្រះពោធិសត្វ សុទ្ធតែជាអ្នកមានកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះអ្នកមានគុណ មានមាតា បិតា ជាដើម ទើបធ្វើឱ្យលោកអាចប្រតិបត្តិនូវពុទ្ធការកធម៌ គឺការកសាងទសបារមី ដើម្បីនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។*

*ការពណ៌នា ក្នុងបាទគាថា ថា* **គណ្ឌាររជ្ជេ មាតុបុដ្ឋាកោ** *នេះ ចប់ដោយបរិបូណ៌ត្រឹមប៉ុណ្ណេះ។*

# ជាតិទី ២ ក្នុងកំណើតជា

# ព្រះបាទគជប្បិយៈ

# ឬ

# ព្រះបាទសត្ថុត្តាសនកទមកៈ

## ព្រះពោធិសត្វ សង្វេគនឹងរាគៈ របស់ដំរីចុះប្រេង

## រួចប្រាថ្នាជាព្រះពុទ្ធ

## ជា

## សេចក្ដីប្រាថ្នា ជាព្រះពុទ្ធលើកទី២

## ក្រៅព្រះពុទ្ធសាសនា



ព្រះបាទសត្តុត្តាសនកទមកៈ
ព្រះពោធិសត្វ សង្វេគនឹងរាគៈ របស់ដំរីចុះប្រេង
រួចប្រាថ្នាជាព្រះពុទ្ធ គឺជា សេចក្តីប្រាថ្នា ជាព្រះពុទ្ធលើកទី២

## ជាតិទី ២ ក្នុងកំណើតជាព្រះបាទគជប្បិយៈ

*ចំណោរតមកទៀត ព្រះពោធិសត្វបានចុតិចាកទេវលោក មកបដិសន្ធិក្នុងរាជត្រកូលក្នុងក្រុងពារាណសី ដែលកាលនោះមានឈ្មោះថា***សិរិមតីនគរ**។

*ក្រោយពេលព្រះរាជបិតាសោយទិវង្គត ព្រះពោធិសត្វក៏បានទទួលរាជាភិសេក ជាព្រះមហាក្សត្រ ក្នុងនគរនោះ។*

*ដោយតេជះបារមីរបស់ព្រះពោធិសត្វ បានធ្វើឱ្យព្រះរាជាទូទាំងសកលជម្ពូទ្វីប បាក់បបខ្ចបខ្ចាច នាំគ្នារៀបចំបណ្ណាការមកថ្វាយ ហើយផ្លាស់វេនគ្នាមកបម្រើ តាមវារៈរៀងៗខ្លួនដោយខ្លួនឯង ។ ទើបបានធ្វើឱ្យព្រះពោធិសត្វមានព្រះនាមថា* ***ព្រះបាទសត្តុត្តាសនកទមកៈ**។*

*ព្រះពោធិសត្វ ទ្រង់ជាអ្នកចូលចិត្តល្បែងប្រជល់ដំរី ម៉្លោះហើយនៅពេលដែលព្រះអង្គបានទទួលដំណឹងថា មានដំរីនៅទីណាៗ ក្នុងដែនរាជាណាចក្ររបស់ព្រះអង្គ មិនថាជាវេលាថ្ងៃ ឬយប់ ស្ដេចក៏យាងទៅទីនោះៗ ដើម្បីទៅទាក់ដំរី ហើយនាំមកកាន់ព្រះរាជនគរ សម្រាប់ទ្រង់លេងហត្ថិកីឡា ហេតុនោះទើបទ្រង់ប្រាកដព្រះនាមមួយទៀតថា* ***ព្រះបាទគជប្បិយៈ**។*

*សម័យថ្ងៃមួយ មានព្រានព្រៃម្នាក់បានចូលទៅក្នុងព្រៃ ដើម្បីបរបាញ់ម្រឹគជាដើម រួចនៅពេលដែលត្រាច់ទៅខាងនេះ ខាងនោះ មិនបានសត្វអ្វីមួយ ហើយមិនអាចត្រឡប់មកផ្ទះរបស់ខ្លួនដោយដៃទទេ ទើបព្រានដើរតាមស្នាមដានជើងម្រឹគ កន្លងហួសផ្លូវមនុស្ស ចូលទៅក្នុងព្រៃជ្រៅ។*

ព្រានព្រៃ បានឃើញដំរីដ៏ធំមួយ ដែលប្រាកដដូច**អញ្ជនបព៌ត**[៥] មានភ្លុកពណ៌ដូចប្រាក់ មាន**ពោង**[៦] ដូចកំពូលភ្នំ មានប្រមោយដូចដំរី**ឯរាវ័ណ**[៧] មានកន្ទុយដូចកន្ទុយសត្វ**ចាមរី**[៨] មានប្រមោយ ដែលមានពណ៌ដូចគ្នានឹងមាស ប្រាកដស្មើនឹងដំរី**គិរិមេខលា**[៩]។

ព្រានគិតថា **យើងត្រាច់សព្វព្រៃ អស់កាលមានប្រមាណប៉ុណ្ណោះ ក៏មិនធ្លាប់ឃើញដំរីបែបនេះទេ យើងត្រាច់អស់មួយថ្ងៃហើយក៏មិនបាននូវទន្សាយ ម្រឹគ ទន្សង ឬសត្វទទា សូម្បីមួយ ឥឡូវ បើយើងសម្លាប់ដំរីនេះ កាត់យកភ្លុករបស់វាទៅលក់ យើងនឹងបានទ្រព្យបន្តិចបន្តួចប៉ុណ្ណោះ តែបើយើងត្រឡប់មកផ្ទះ ដោយដៃទទេ បុត្រធីតារបស់យើង នឹងរស់នៅដូចម្តេចកើត?**

ពេលនោះ ព្រានក៏សម្រេចចិត្តថា **ណ្ហើយចុះ យើងនឹងមិនសម្លាប់ដំរី**

---

[៥](ន.)(បា.សំ.)ភ្នំដែលរុំព័ទ្ធដោយវល្លិបែតង់ដ៏ស្រទន់។

[៦](ន.)សរីរប្រទេសដំរីនៅត្រង់ក្បាល មានសណ្ឋានជាពក២ដុំ ប៉ោងចេញទ្រផាង។

[៧](ន.)(បា.សំ.)ឈ្មោះដំរីមានក្បាល៣ ជាព្រះទីន័ងព្រះឥន្ទ(ទេវបុត្តនិម្មិត)។

[៨](ន.)(បា.សំ.)ជាសត្វចតុប្បាទមួយប្រភេទ មានរោមវែងៗ សម្បុរសស្រោបខ្លួន មានសំណុំកន្ទុយសត្រសូលភ្លឺថ្លា មានរូបសណ្ឋានស្រដៀងនឹងសត្វក្របី ប៉ុន្តែមាឌតូចជាងសត្វក្របី មានកំណើតនៅក្នុងប្រទេសត្រជាក់ ដូចជាប្រទេសទីបេត៍ជាដើម គេច្រើនយកសំណុំសក់កន្ទុយរបស់សត្វនេះធ្វើជាសែ៊រ ហៅថា វាលវីជិនី តាមរជ្ជប្រពៃណី តាំងពីបុរាណកាលរៀងមក ហើយវាលវីជិនី ត្រូវបានរាប់បញ្ចូល ក្នុងរាជកកុធភណ្ឌទាំង៥ឈ្មោះ។ ចាមរី ជាសត្វប្រយ័ត្នជានិច្ច មិនឱ្យសក់កន្ទុយរបស់វា ប្រឡាក់ប្រឡូសឡើយ។

[៩] (ប៉ុ.) ឈ្មោះដំរីនៃមារ ។

*នេះទេ យើងនឹងធ្វើដំរីនេះ ឱ្យក្លាយជាបណ្ណាការរបស់យើងថ្វាយដល់ព្រះរាជា ដោយពណ៌នានូវលក្ខណសម្បត្តិរបស់ដំរី និងប្រាប់ទីកន្លែងនេះ ធ្វើដូច្នេះយើងនឹងបានទ្រព្យច្រើន។*

*គិតដូច្នេះហើយ ព្រានព្រៃនោះបានកំណត់នូវភ្នំ កំណត់ព្រៃ កំណត់ដើមឈើ កំណត់ស្រះ ឱ្យជាសញ្ញា ដើម្បីប្រយោជន៍ដល់ការមកលើកក្រោយ ហើយត្រឡប់ទៅផ្ទះ។*

*គ្រានោះ មានបុរសអ្នកក្រុងម្នាក់បានចូលទៅក្នុងព្រៃ ព្រោះករណីយកិច្ចអ្វីមួយ គាត់ឃើញព្រានព្រៃនោះ ត្រឡប់មកវិញដោយដៃទទេ ក៏ពោលថា៖*

*"នៃសម្លាញ់ ហេតុអ្វីថ្ងៃនេះអ្នកត្រឡប់មកវិញដោយដៃទទេ តើបុត្រធីតា របស់អ្នក នឹងរស់ដូចម្តេច? ពួកគេនឹងស្លាប់"។*

*ព្រានព្រៃ ពោលថា៖*

*"នៃលោកម្ចាស់ ខ្ញុំត្រាច់ក្នុងព្រៃសព្វអស់ហើយ មិនបានសត្វអ្វីឡើយ តែខ្ញុំបានឃើញដំរីមួយ ដែលមានតម្លៃកាត់ថ្លៃមិនបាន បើលោកអាចធ្វើសេចក្តីអនុគ្រោះដល់ខ្ញុំ សូមនាំខ្ញុំទៅកាន់សម្នាក់ព្រះរាជាជាមួយលោក ហើយទូលថ្វាយដំណឹងនេះដល់ព្រះរាជា"។*

*បុរសអ្នកក្រុង បានស្តាប់ពាក្យរបស់ព្រានព្រៃហើយ មានចិត្តត្រេកអរ លះបង់ការងាររបស់ខ្លួន នាំព្រានព្រៃចូលទៅក្នុងព្រះនគរហើយឋិតនៅត្រង់រាជទ្វារ និងសុំឱ្យអាមាត្យទូលថ្វាយដំណឹងនោះដល់ព្រះរាជា។*

*ព្រះរាជា ទ្រង់បានជ្រាប ក៏បានឱ្យគេហៅព្រានព្រៃចូលគាល់ រួចត្រាស់សួរថា៖*

"នៃនាយព្រាន ដំរីបែបនោះ អ្នកបានឃើញ ពិតមែនឬ"?

ព្រានព្រៃ ក៏ក្រាបទូលនូវភិនភាគនៃដំរី ដែលដល់ព្រមដោយលក្ខណៈទាំងអស់ ថ្វាយព្រះរាជា។

ព្រះរាជា ទ្រង់បានប្រទានសក្ការៈ ដល់ជនទាំងពីរ និងបញ្ជូនទ្រព្យយ៉ាងច្រើនទៅផ្ទះនាយព្រាន រួចទ្រង់ត្រាស់បញ្ជាព្រានព្រៃនោះ ធ្វើជាអ្នកនាំផ្លូវ ហើយស្ដេចនាំអង្គសេនាទាំងពួង យាងទៅ។

ព្រានព្រៃ នាំពលសេនាមាត្យ ទៅតាមលំដាប់សញ្ញា ដែលខ្លួនធ្វើទុក ក៏បានដល់កន្លែងនោះ។

ព្រះរាជា ឱ្យពួកហ្មួចងដំរី នាំទៅកាន់ព្រះនគរ ហើយហៅនាយហត្ថាចារ្យ ដែលជាប្រធានឱ្យចូលគាល់ រួចធ្វើសក្ការៈដល់នាយហត្ថាចារ្យនោះ និងត្រាស់យ៉ាងនេះថា៖

"នៃនាយហត្ថាចារ្យ យើងអាចលេង**នក្ខត្តកីឡា**[១០] ដោយដំរីនេះបានយ៉ាងណា សូមអ្នកញ៉ាំងដំរីនេះ ហ្វឹកហាត់ឱ្យល្អយ៉ាងនោះ រួចនាំមកកាន់សម្នាក់យើង ក្នុងរវាង៧-៨ថ្ងៃ"។

នាយហត្ថាចារ្យ នាំដំរីនោះទៅកាន់ផ្ទះរបស់ខ្លួន ហើយបង្វឹកញ៉ាំងដំរីឱ្យហ្វឹកហាត់បានល្អ រួចយកមកថ្វាយព្រះរាជា ក្នុងរវាង៧-៨ ថ្ងៃ។

ព្រះរាជាទតឃើញដំរី ដែលត្រូវនាយហត្ថាចារ្យបង្វឹកល្អហើយ ក៏ឱ្យគេ

---

[១០](ន.)(បា.សំ.) កិរិយាលេងនូវនក្ខត្តឫក្ស។

*ប្រដាប់តាក់តែងដំរីនោះ ដោយហត្ថាលង្ការទាំងពួង ដើម្បីប្រយោជន៍ធ្វើជាដំរីមង្គល ទើបទ្រង់យាងគង់មង្គលហត្ថីនោះដោយមាន***ចតុរង្គ**[១១] ***សេនា***ចោមរោមស្តេចធ្វើប្រទក្សិណនគរ ញ៉ាំងមួយថ្ងៃឱ្យកន្លងទៅ។*

*ក្នុងចំណែកនៃរាត្រីទី១៤ មានហ្វូងដំរីជាច្រើន មកអំពីព្រៃ ចូលទៅកាន់រាជឧទ្យាន បានធ្វើឧទ្យានទាំងមូលឱ្យខ្ទេចខ្ទីជាលម្អិតតូចធំ ហើយបន្ទោបង់នូវមូត្រ និងលាមក រួចចេញទៅ។*

*នាពេលជិតភ្លឺ នាយឧទ្យានបាលបានទៅកាន់រាជឧទ្យាន បានឃើញបំណែកតូចធំ រួចក៏ទៅកាន់សម្នាក់ព្រះរាជាក្នុងឱកាសដែលទ្រង់ទើបយាងមកពីប្រទក្សិណនគរ ដើម្បីយាងព្រះអង្គមកទតមើលដោយពោលយ៉ាងនេះថា៖*

*"ក្នុងចំណែកនៃរាត្រីនេះ មានហ្វូងដំរីជាច្រើនមកអំពីព្រៃចូលទៅក្នុងព្រះរាជឧទ្យាន រួចមុនពេលចេញទៅវាបានធ្វើឱ្យបុប្ផារាម និងផលារាមទាំងឡាយ ឱ្យបាក់បែកជាចំណែកតូចធំ ខ្ទេចខ្ទីអស់"។*

*ព្រះរាជា ទ្រង់បានជ្រាបនូវដំណឹងនោះហើយ ទ្រង់មិនយល់ហេតុការណ៍ ទើបស្តេចយាងគង់លើមង្គលហត្ថី ដើម្បីទតព្រះរាជឧទ្យាន។*

*គ្រានោះ ព្រះរាជាបានទតឃើញព្រះរាជឧទ្យាន មានបំណែកតូចធំអំពីចម្ងាយ ហើយទ្រង់យាងចូលទៅ ទ្រង់បានយាងទតសព្វទិសទី។*

*មង្គលហត្ថី ធុំក្លិនមេដំរី កើតសេចក្តីស្រវឹងដោយកាម ទើបកម្រើករាងកាយញ៉ាំងហ្មដំរីដែលជិះត្រង់កឱ្យធ្លាក់ចុះ ហើយទម្លាយកំពែងរត់ចេញទៅ។*

---

[១១] **ចតុរង្គ** *( គុ., ន. ) [ចៈ តុរ៉ង់ ឬ --រ៉ុង]  ( សំ., បា. ) ដែលមានអង្គ ៤; កងទ័ពមានអង្គ ៤ គឺ កងទ័ពដំរី, កងទ័ពសេះ, កងទ័ពរថ ឬរទេះ, កងទ័ពថ្មើរជើង ។*

*ពេលនោះ ព្រះរាជាទ្រង់កាន់កង្វេរដោយអង្គឯង ទោះបីទាញដោយកម្លាំងអង្គឯងយ៉ាងណា ក៏មិនអាចធ្វើឱ្យដំរី ត្រឡប់វិញបានឡើយ។*

*ព្រះរាជា ទ្រង់ឃ្លាតចាកពីពួកសេនាទាំងអស់ ហើយគង់នៅលើកដំរីដែលរត់ទៅដល់ព្រៃធំ និងហត់នឿយ លំបាកព្រះកាយពលយ៉ាងខ្លាំង។*

*ចំណែកឯពួកសេនា ទោះបីជាបំបោលសេះស្ទុះលឿនទៅតាមក្រោយយ៉ាងណាក្តី ក៏មិនអាចតាមទាន់ព្រះទីនាំងរបស់ព្រះអង្គ ទើបនាំគ្នាធ្វើដំណើរទៅតាមដានជើងដំរីនោះ។*

*ព្រះរាជា យាងរហូតកន្លងផុតផ្លូវមនុស្ស ដោយមិនអាចកំណត់ទិសបាន ទ្រង់គិតយ៉ាងនេះថា* ***បើយើងមិនលះបង់ដំរីនេះទេ នៅពេលដំរីនេះប្រយុទ្ធជាមួយនឹងដំរីដទៃ ក្នុងពេលណាមួយ ក្នុងពេលនោះ ជីវិតរបស់យើងរមែងមិនមាន បើអ៊ីចឹង នឹងមានប្រយោជន៍អ្វី ដោយដំរីនេះ?***

*គ្រានោះ នៅពេលដែលដំរី បោលទៅដល់ខាងក្រោមដើមឧទុម្ពរដ៏ធំមួយ មានមែកសាខាសំយុងធ្លាក់ចុះមកខាងក្រោម ព្រះរាជាទ្រង់តោងមែកនោះ ដោយលះបង់ដំរី ឡើងគង់លើមែកឈើ សោយផ្លែឧទុម្ពរ ហើយគង់ប្រថាប់នៅលើដើមឈើនោះ។*

*ចំណែកពួកសេនា ធ្វើដំណើរទៅតាមដានជើងដំរី ហើយបន្លឺសំឡេងប្រកូកប្រកាស ក្នុងរយៈចម្ងាយកន្លះយោជន៍ម្តងៗ។*

*ព្រះរាជា បានទ្រង់ព្រះសណ្តាប់ឮសំឡេងរបស់ពួកសេនាហើយ ទ្រង់ក៏ធ្វើសំឡេងតប។*

*ពួកសេនា បានឮរាជសព្ទរបស់ព្រះរាជាហើយ ក៏ប្រញាប់ស្ទុះទៅយ៉ាង*

*រហ័សដល់កន្លែង ដែលព្រះរាជាគង់ រួចបានយាងទ្រង់ចុះអំពីដើមឈើ ប្រគំតួយ័តន្ត្រីទាំងពួង និងយាងព្រះអង្គ រាជនិវត្តន៍ទៅកាន់ព្រះនគរវិញ។*

*ចំណែកព្រះរាជា កាលចូលទៅក្នុងព្រះនគរហើយ ស្ដេចយាងឡើងកាន់មហាវាំង ប្រថាប់លើ**សីហាសនៈ**[១២] ត្រាស់បញ្ជាឱ្យហៅ នាយហត្ថាចារ្យចូលគាល់។*

*ទ្រង់បានត្រាស់សួរថា៖*

*"នែហត្ថាចារ្យ អ្នកប្រាថ្នាសម្លាប់យើងឬ"?*

*នាយហត្ថាចារ្យ បានស្ដាប់ព្រះតម្រាស់ហើយ ទូលថា៖*

*"បពិត្រព្រះសម្មតិទេព ព្រះអង្គត្រាស់យ៉ាងនេះព្រោះហេតុអ្វី? ដំរីនោះ ខ្ញុំព្រះអង្គ បានបង្វឹកល្អក្រៃលែងហើយ វាទៅយ៉ាងនេះដោយសេចក្ដីក្ដៅក្រហាយ រសាប់រសល់ព្រោះរាគៈ កាលណាវាបំពេញកិច្ចរួចវានឹងត្រឡប់មកវិញក្រាបទូល"។*

*ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនោះរួច ទ្រង់ត្រាស់ថា៖*

*"បើដូច្នេះ ដំរីនឹងមិនទាន់មកដរាបណា ចូរអ្នកនៅក្នុងទីនេះចុះ បើដំរីវាត្រឡប់មកក្នុងទីនេះ យើងនឹងប្រទានទ្រព្យច្រើនដល់អ្នក តែបើវាមិនមក ជីវិតរបស់អ្នកនឹងមិនមាន"។*

*រួចហើយ ទ្រង់បានត្រាស់បង្គាប់ឱ្យពលសេនា រក្សានាយហត្ថាចារ្យ នៅក្នុងទីនោះឯង។*

*ឯមង្គលហត្ថីនោះ បានចូលទៅក្នុងហ្វូងដំរីព្រៃ ហើយញ៉ាំង**មនោរថ**[១៣]*

---

[១២] *(ន.)(បា.សំ.)អាសនៈរចនាជារូបសត្វសីហ ឬសត្វតោ, កន្លែងអង្គុយរបស់ព្រះរាជា។*

*របស់ខ្លួនជាមួយនឹងមេដំរី ឆ្អែតស្កប់ស្កល់ក្នុងរវាង៧ថ្ងៃរួចក៏ត្រឡប់មកវិញ និងចូលទៅនៅក្នុងរោងរបស់ខ្លួន ដូចធម្មតា។*

*នាយហត្ថាចារ្យ ក្រោកឡើងក្នុងពេលជិតភ្លឺ ឃើញដំរីក្នុងហត្ថិសាលា ក៏ទៅកាន់សម្នាក់ព្រះរាជា ក្រាបទូលថ្វាយព្រះរាជា ថា៖*

*"បពិត្រព្រះសម្មតិទេព មង្គលហត្ថីនោះ បានមកវិញហើយ"។*

*ព្រះរាជា បានព្រះសណ្តាប់ពាក្យនោះ ទ្រង់ចុះចាកប្រាសាទដោយរហ័ស យាងទៅកាន់ហត្ថិសាលា ឃើញមង្គលហត្ថី ទ្រង់ស្ទាបអង្អែលប្រមោយដំរី ហើយត្រាស់ថា៖*

*"នែនាយហត្ថាចារ្យ ព្រោះហេតុអ្វីបានជាដំរី ដែលអ្នកហ្វឹកហាត់ទូន្មានល្អហើយ មានសភាពបែបនេះ កាលយើងប្រើកង្វេរទាញវា ដោយកម្លាំងរបស់ខ្លួនយ៉ាងណា ក៏មិនអាចឱ្យដំរីនេះ ត្រឡប់វិញបាន"?*

*នាយហត្ថាចារ្យ ទូលថា៖*

*"បពិត្រព្រះសម្មតិទេព ហេតុអ្វីព្រះអង្គ មានព្រះរាជបន្ទូលយ៉ាងនេះ?*

***ឈ្មោះថារាគៈ រមែងមុតស្រួចជាងកង្វេរ រាគៈជាធម្មជាតក្តៅជាងភ្លើងកាចសាហាវជាងពិសរបស់នាគ។***

*បពិត្រព្រះសម្មតិទេព ព្រោះហេតុនោះ ទើបព្រះអង្គមិនអាចបង្ក្រាប់បញ្ជាដំរីនេះ ឱ្យវិលត្រឡប់វិញបាន"។*

*ព្រះរាជា ទ្រង់ត្រាស់សួរថា៖*

*"ចុះឥឡូវនេះ ព្រោះហេតុអ្វី ទើបវាត្រឡប់មកដោយខ្លួនឯង?"*

---

*១៣(ន.)(បា.សំ.)សម្រេចបំណង ក្នុងទីនេះគឺ បានសម្រេចបំណង ជាមួយនឹងមេដំរី។*

ហត្ថាចារ្យទូលថ្វាយតបថា៖

"បពិត្រព្រះសម្មតិទេព ដំរីត្រឡប់មកវិញនេះព្រោះកម្លាំងមន្ត និង ឱសថ ដែលទូលព្រះបង្គំប្រើ"។

ព្រះរាជាត្រាស់ថា៖

"បើយ៉ាងនោះ ចូរអ្នកសម្ដែងកម្លាំងមន្ត និងឱសថ ឱ្យយើងទតមើល"។

ហត្ថាចារ្យទូលថា៖

"បពិត្រព្រះសម្មតិទេព ទូលបង្គំ សូមទទួលព្រះរាជបញ្ជា"។

នាយហត្ថាចារ្យ បានឱ្យគេនាំដុំដែកដ៏ធំមួយ រួចហៅជាងដែកមកដុតដែកនោះ កើតជាដុំភ្លើង ដែលប្រាកដដូចរងើកភ្លើងរុងរឿងឆេះសន្ធោសន្ធៅ កៀបដោយដង្កាប់ រួចរាយមន្តរបស់ខ្លួន ហើយហៅដំរីមក ព្រមទាំងពោលថា៖

"នែមហាគជេន្ទ្រ ចូរអ្នកចាប់ដុំដែកនេះឱ្យជាប់ បើដរាបណាយើងមិនទាន់ពោលថាលែង ដរាបនោះចូរអ្នកកុំលែង"។

មង្គលហត្ថី លាប្រមោយចាប់ដុំដែក មូរទុកក្នុងប្រមោយរបស់ខ្លួនយ៉ាងមាំ មិនហ៊ានលែងដុំដែកនោះ ព្រោះភ័យខ្លាចនាយហត្ថាចារ្យ។

ព្រះរាជា ឃើញព្រឹត្តិការណ៍នោះហើយ ទ្រង់បញ្ជាទៅនាយហត្ថាចារ្យឱ្យបង្គាប់ដំរីបោះដុំដែកចោល ព្រោះខ្លាចដំរីស្លាប់។

លំដាប់នោះ សេចក្ដីសង្វេគដ៏ខ្លាំងបានកើតឡើងដល់ព្រះរាជា ទ្រង់ព្រះតម្រិះថា "**អហោ រាគោ អតិចណ្ឌោ មហាឃោរោ ពហុបទ្ទវោ, *ឱគួរឱ្យសង្វេគអ្វីម្ល៉េះទេ រាគៈនេះកាចសាហាវឃោរឃៅក្រៃលែង មានឧបទ្រពច្រើន។***

**តំ បន រាគំ និស្សាយ ឥមេ សត្តា សំសារសមុទ្ទេ និមុគ្គា, *ព្រោះអាស្រ័យរាគៈនេះហើយ សត្វទាំងឡាយ រមែងជាអ្នកលិចចុះក្នុងសមុទ្រ គឺសង្សារវដ្ត។***

រាគំ និស្សាយ វីធានិ ចាបកម្មានិ កត្វា មហានិរយេសុ បច្ចន្តិ, *ព្រោះអាស្រ័យរាគៈ សត្វទាំងឡាយ នាំគ្នាធ្វើបាបកម្មមានប្រការផ្សេងៗ ហើយរមែងឆេះក្នុងមហានរក (៨រណ្ដៅ)។*

អដ្ឋវីសុត្តរសតេសុ ឧស្សទនិរយេសុ បច្ចន្តិ, *ព្រោះអាស្រ័យរាគៈ សត្វទាំងឡាយ រមែងឆេះក្នុងឧស្សទនរកទាំង១២៨ រណ្ដៅ។*

បេតលោកេសុ ឧប្បជ្ជន្តិ, *ព្រោះអាស្រ័យរាគៈ សត្វទាំងឡាយ រមែងកើតក្នុងបេតលោក (កើតជាប្រេត)។*

អនេកវិធេសុ តិរច្ឆានគតេសុ ឧប្បជ្ជន្តិ” *ព្រោះអាស្រ័យរាគៈ សត្វទាំងឡាយ រមែងកើតក្នុងកំណើតសត្វតិរច្ឆាន មានសភាពផ្សេងៗ ច្រើនជាអនេក។*

*ដូច្នេះហើយ ទ្រង់ក៏ត្រាស់គាថាទាំងឡាយនេះថា៖*

“រាគាតុរេនិមេ សត្តា, បិតា បុត្តំ វិឃាតតិ;
បុត្តោ ច បិតរំ ហន្តិ, មាតា មារេតិ ធីតរំ។
រាគាតុរេនិមេ សត្តា, ធីតា មារេតិ មាតរំ;
ភតា ច ភគិនឹ ហន្តិ, ភគិនី ឃាតេតិ ភាតរំ។
ភាគិនេយ្យោ មាតុលំ ហន្តិ, មាតុលោ ហន្តិ ភាគិនេយ្យំ;
សាមិកោ ភរិយំ ហន្តិ, ភរិយា ឃាតេតិ សាមិកំ;
អញ្ញអញ្ញម្បិ ឃាតេន្តិ, បគេវ ឥតរេ ជនេ។
រាគាតុរេនិមេ សត្តា, ជនជញ្ញុំ វិធំសយុំ;
យសំ កិត្តឹ វិធំសេន្តិ, អកិត្តឹ ជនយន្តិច។
រាគាតុរេនិមេ សត្តា, សុខា ហាយន្តិ សព្វធា;
នស្សន្តិ កុសលា ធម្មា, សុគតិមគ្គំ និវារយុំ។
រាគាតុរេនិមេ សត្តា, លោភទោសវសំ គតា;
ពជ្ឈន្តិ ភវសំសារេ, អចាយំ វិនិចាតិកា។

រាគាតុរេថិមេ សត្តា, សីលំ ជាសេន្តិ សុព្វតា;
សមាធិភាវជាឈាន- អន្តរាយករា សជា។
រាគាតុរេថិមេ សត្តា, អនុភោន្តិ ថិរយំ ពហុ;
បហាយិមំ គមិស្សាមិ, យថាហំ សុគតឹ វជេ”។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ* សត្វទាំងឡាយនេះ គឺ បិតារមែងសម្លាប់បុត្រ, ចំណែកបុត្ររមែងសម្លាប់បិតា, មាតារមែងសម្លាប់ធីតា។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ* សត្វទាំងឡាយនេះ គឺ ធីតារមែងសម្លាប់មាតា, ចំណែកបងប្អូនប្រុសរមែងសម្លាប់បងប្អូនស្រី, បងប្អូនស្រីរមែងសម្លាប់បងប្អូនប្រុស។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ* ក្មួយរមែងសម្លាប់ឪពុកមាឬឪពុកធំ, ឪពុកមាឬឪពុកធំរមែងសម្លាប់ក្មួយ, ស្វាមីរមែងសម្លាប់ភរិយា, ភរិយារមែងសម្លាប់ស្វាមី, សត្វទាំងឡាយ (ជាញាតិ) រមែងសម្លាប់នូវគ្នានឹងគ្នា នឹងពោលទោប្ចីដល់ជនក្រៅនេះ។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ* សត្វទាំងឡាយនេះរមែងធ្វើទ្រព្យនិងគ្រាប់ពូជឲ្យវិនាស សត្វទាំងឡាយរមែងធ្វើកិត្តិយសឲ្យវិនាស រមែងធ្វើកេរ្តិ៍ឈ្មោះអាក្រក់ឲ្យកើតឡើង។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ* សត្វទាំងឡាយរមែងសាបសូន្យចាកសេចក្តីសុខសព្វកាល រមែងវិនាសចាកកុសលធម៌ នឹងរារាំងផ្លូវទៅសុគតិ។

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ សត្វទាំងឡាយរមែងលុះក្នុងអំណាចនៃលោភៈនិងទោសៈ រមែងជាប់នៅក្នុងការវិលវល់ស្លាប់កើតក្នុងភព និងជាអ្នកធ្លាក់ទៅកាន់អបាយ។*

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ សត្វទាំងឡាយនេះគឺ សត្វអ្នកមានវត្តល្អរមែងវិនាសនូវសីល ជាអ្នកធ្វើអន្តរាយដល់សមាធិភាវនា និងឈាន ក្នុងកាលទាំងពួង។*

*ព្រោះសេចក្តីក្តៅក្រហាយរសាប់រសល់ដោយរាគៈ សត្វទាំងឡាយនេះរមែងប្រសព្វសោយទុក្ខក្នុងនរកដ៏ច្រើន (ដូច្នេះ) យើងនឹងលះបង់រាគៈនេះដោយប្រការដែលយើងនឹងទៅកាន់សុគតិឲ្យបាន។*

*ព្រះរាជា ឃើញទោសរបស់កិលេសមានប្រមាណប៉ុណ្ណោះហើយ ទ្រង់ប្រទានភោគសម្បត្តិយ៉ាងច្រើនដល់នាយហត្ថាចារ្យ រួចទ្រង់ព្រះតម្រិះថា* "ឥមេ សត្តេ កេន ធម្មេន សំសារទុក្ខតោ មោចយិស្សាមិ, ឋបេត្វា ពុទ្ធការកធម្មេ អញ្ញោ ធម្មោ ជាម ឧត្ថិ, តស្មា អហំ ពុទ្ធបណិធានំ ករិស្សាមិ"។

"*យើងនឹងញុំាងសត្វទាំងឡាយនេះ ឱ្យរួចចាកសំសារទុក្ខ ដោយធម៌អ្វីហ្ន៎, បើវៀរចាកពុទ្ធការកធម៌ហើយ ឈ្មោះថាធម៌ដទៃរមែងមិនមាន, ព្រោះហេតុនោះ យើងនឹងធ្វើពុទ្ធបណិធាន ដែលជាសេចក្តីប្រាថ្នាឱ្យបានត្រាស់ជាព្រះពុទ្ធ*"។

*ព្រះរាជា ញុំាងចិត្តឱ្យកើតឡើង ធ្វើមនោបណិធាន ដែលជាសេចក្តីប្រាថ្នាដោយចិត្តថា៖*

"ពុទ្ធោហំ ពោធយិស្សាមិ, មុត្តោហំ មោចយេ បរេ;
តិណ្ណោហំ តារយិស្សាមិ, សំសារោឃមហព្ភយា"។

"*យើង នឹងត្រាស់ដឹងជាព្រះពុទ្ធ យើងរួចផុតហើយ នឹងញុំាងអ្នកដទៃ*

**ពុទ្ធបណិធាន**

*ឱ្យរួចផុតផង យើងឆ្លងចាកភ័យធំ គឺអន្ទង់សំសារវដ្ដហើយ នឹងឱ្យអ្នកដទៃ ឆ្លងផុតអន្ទង់សំសារវដ្ដទៅផង"។*

*ព្រះរាជា ធ្វើមនោបណិធាន យ៉ាងនេះហើយ ទ្រង់លះបង់រាជសម្បត្តិ យាងចូលទៅកាន់ព្រៃហិមពាន្តតែមួយព្រះអង្គឯង ទ្រង់បួសជាឥសី រស់នៅក្នុងទីនោះរហូតអស់ព្រះជន្ម កាលទ្រង់អស់ព្រះជន្មហើយ ក៏បានទៅកើតក្នុងទេវលោក។*

ឥជំ វត្វា មហារាជា, ភូមិចាលោ ជិសម្បតិ;
រជ្ជំ ហិត្វាន បព្វជិ, ជាតោ ធេត្វារ ពន្ធជំ។

*ព្រះមហារាជា ជាភូមិបាល ទ្រង់ជាធំក្នុងទិស ទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទ្រង់លះបង់ដែនហើយសាងផ្នួស ដូចជាដំរី ដែលកាត់ផ្ដាច់នូវទន្ទីងគឺចំណងហើយទៅដូច្នោះឯង។*

*កថានេះ ឈ្មោះថា កថាពោលដោយការកើតឡើងនៃចិត្តលើកទី២ ដើម្បីភាពជាព្រះពុទ្ធ របស់ព្រះពោធិសត្វ ដោយអំណាចនៃការតាំងសេចក្ដីប្រាថ្នាដោយចិត្តរបស់ខ្លួនឯងប៉ុណ្ណោះ ដូចពណ៌នាមកដូច្នេះឯង។*

*ការពណ៌នាក្នុងបាទគាថាថា: សត្តុត្តាសជកាជមកា តជម្បិយោ នេះ ចប់ដោយបរិបូណ៌ហើយ ដោយប្រការដូច្នេះ។*

# ជាតិទី៣
# ក្នុងកំណើតជា
# ព្រហ្មឥសី

## ព្រះពោធិសត្វឃើញមេខ្លាប្រាថ្នាស៊ីកូន
## លោកមានសេចក្តីសង្វេគ រួចលោតពីលើកំពូលភ្នំ
## លះបង់រាងកាយឱ្យខ្លាស៊ី ដើម្បីប្រាថ្នាជាព្រះពុទ្ធ

## សេចក្តីប្រាថ្នាជាព្រះពុទ្ធលើកទី ៣
## ក្រៅព្រះពុទ្ធសាសនា



ព្រះពោធិសត្វឃើញមេខ្លាប្រាថ្នាស៊ីកូន
លោកមានសេចក្ដីសង្វេគ រួចលោតពីលើកំពូលភ្នំ
លះបង់រាងកាយឱ្យខ្លាស៊ី ដើម្បីប្រាថ្នាជាព្រះពុទ្ធ

## ជាតិទី៣ ក្នុងកំណើតជា ព្រហ្មឥសី

*ចំណោរក្រោយមកទៀត ព្រះពោធិសត្វ ចុតិចាកទេវលោកមកបដិសន្ធិក្នុងផ្ទះនៃព្រាហ្មណ៍ជាប្រធាន នា**ព្រាហ្មណគ្រាម ឈ្មោះហលិទ្ទិយៈ**។*

*កន្លងទៅ១០ខែ ព្រះពោធិសត្វ ក៏ប្រសូតចេញចាកផ្ទៃមាតា មានសម្បុរដូចមាស ដោយហេតុនោះទើបញាតិទាំងឡាយ ដាក់ឈ្មោះព្រះពោធិសត្វ ថា **ព្រហ្មកុមារ**។*

*កាលចម្រើនវ័យធំ បានសិក្សារៀនសូត្រវិជ្ជាសម្រាប់ពួកព្រាហ្មណ៍ ហើយក៏បានសម្រេចនូវ**ត្រៃវេទ**[១៤]និង**វិជ្ជា១៨ប្រការ**[១៥] ព្រោះភាពជាអ្នកមានបញ្ញាច្រើន ហើយក្នុងលំដាប់នោះ មានមាណពជាព្រាហ្មណ៍ចំនួន៥០០នាក់ បានមកសិក្សារៀនសូត្រត្រៃវេទ ក្នុងសម្នាក់ព្រហ្មកុមារ។*

---

[១៤] ***ត្រៃវេទ*** (--*វេទៈ ឬ--វេត*) ន. (*សំ. ត្រិវេទ ឬ ត្រៃវេទ*; *បា. តិវេទ*) *វេទ ៣ ការរួបរួមឬប្រជុំនៃវេទ ៣ គឺ ឫគ្វេទ ឬ ឥរុវេទ ១, យជុវេទ ឬ យជ្ជុវេទ ១, សាមវេទ ១* (ម. ព. *វេទ*) ។

[១៥] ***វិជ្ជា ១៨ ប្រការ*** *គឺ* **សុតិ** *សព្ទសាស្ត្រ អក្សរសាស្ត្រ ស្តីពីភាសាផ្សេងៗ១,* **សម្មុតិ** *ធម្មសាស្ត្រ ស្តីអំពីគោលការណ៍វិនិច្ឆ័យក្តីរបស់ព្រះរាជាឬរបស់ហ្លួង១,* **សង្ខ្យា** *សង្ខ្យាសាស្ត្រ ស្តីពីគោលការណ៍រាប់ចំនួន១,* **យោគា** *យោគសាស្ត្រ ស្តីពីការប្រើវត្ថុមន្តអាគម ជាការធានាថា នឹងមិនកើតមានគ្រោះភ័យផ្សេងៗ នាពេលអនាគត១,* **នីតិ** *នីតិសាស្ត្រ ស្តីអំពីប្រការដែលព្រះរាជានិងប្រជារាស្ត្រនៅលើលោកគួរប្រព្រឹត្ត១,* **វិសេសិកា** *សាស្ត្រដែលស្តីអំពីការប្រើឧបករណ៍ មានឧបករណ៍ថ្ងឹង, ធ្វើសសរ វិជ្ជាសំណង់ជាដើម១,* **គណិកា** *គណិតសាស្ត្រ១,* **គន្ធព្វា** *វិជ្ជារាំរបាំច្រៀង ប្រគំតន្ត្រី១,* **តិកិច្ឆា** *វេជ្ជសាស្ត្រ១,* **ឆតុព្វេទា** *ឬ* **ចតុព្វេទា** *វេទទាំង៤ គឺ ឥរុវេទ សាម-វេទ យជុវេទ អាថព្វណវេទ១,* **បុរណា** *បុរាណវិទ្យា១,* **ឥតិហាសា** *ប្រវត្តិវិទ្យា,* **ជោតិសា** *ព្យាករណសាស្ត្រ១,* **មាយា** *មាយាសាស្ត្រ១,* **កោតុ** *ឬ* **ហេតុ** *វិជ្ជាស្តីអំពីនិមិត្តហេតុល្អនិមិត្តហេតុអាក្រក់១,* **មន្តនា** *វិជ្ជាទស្សន៍ទាយពីអ្វីដែលចង់ដឹង ជាសាស្ត្ររបស់ពួកពិទ្យាធរ១,* **យុទ្ធា** *យុទ្ធសាស្ត្រ ឬវិជ្ជាស្តីអំពីការធ្វើសង្គ្រាម១,* **ឆន្ទសា** *ឆន្ទសាស្ត្រ* (*ឆន្ទសត្ថ*) *ឈ្មោះគម្ពីរ*

**ពុទ្ធបណិធាន**

មិនយូរប៉ុន្មាន មាតាបិតារបស់ព្រហ្មកុមារ ក៏បានធ្វើកាលកិរិយា ហើយបន្ទាប់ពីបានធ្វើ**បេតកិច្ច**[១៦]ដល់មាតាបិតារួច ព្រហ្មកុមារក៏ហៅមាណព ជាព្រាហ្មណ៍ទាំង៥០០នាក់មក រួចឱ្យសិក្សានូវសិក្ខា ដែលគប្បីសិក្សាទាំងពួង ដល់ពួកគេ ហើយឱ្យទ្រព្យសម្បត្តិទាំងពួងក្នុងផ្ទះរបស់ខ្លួន ជាទានមិនមានសល់ និងផ្ដល់ឱវាទដល់មាណពទាំង៥០០នាក់ មុនពេលចេញទៅបួសជាឥសី។

ទោះបីមាណពទាំង៥០០នាក់នោះ ធ្វើសេចក្ដីគោរពអង្វរ និងឃាត់ យ៉ាងណាក៏ដោយ ក៏ព្រះពោធិសត្វនៅតែលះបង់ផ្ទះសម្បែង ចាកចេញតែម្នាក់ឯង ទៅបួសជាឥសី អាស្រ័យនឹងភ្នំឈ្មោះ**ឯរកៈ** ដែលកាលនោះមានឈ្មោះថា **ភ្នំមណ្ឌៈ** កាលព្រះពោធិសត្វចេញសាងផ្នួសហើយ មាណពដទៃជាច្រើន ក៏ទៅបួសតាមក្នុងសម្នាក់ព្រះពោធិសត្វដែរ។

ព្រះពោធិសត្វ លោកញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅដោយបរិភោគមើមឈើ និងផ្លែឈើ ក្នុងព្រៃជាអាហារ។

រីឯមាណពរបស់ព្រាហ្មណ៍ទាំង៥០០ កាលបើមាតាបិតាស្លាប់ទៅតាមលំដាប់ ក៏បានមកបួសក្នុងសម្នាក់ព្រះពោធិសត្វ ហើយពួកឥសីទាំងនោះ បន្ទាប់ពីបានរៀនកសិណបរិកម្ម ក្នុងសម្នាក់ព្រះពោធិសត្វរួចហើយ ក៏ទៅកាន់ទីដែលខ្លួនពេញចិត្ត ភាវនា ចម្រើនកសិណបរិកម្ម និងបានញ៉ាំងឈានឱ្យកើត

---

សំដែងអំពីដំណើរបែបបទកាព្យខាងភាសាសំស្ក្រឹត មានសាវិត្ថិសាស្ត្រជាប្រមុខនៃឆន្ទសាស្ត្រទាំងពួង១។

[១៦] (ន.)(បា.សំ.)កិច្ចវត្តប្រតិបត្តិ ដែលកតញ្ញូជនជាបុត្ត ធីតា ត្រូវធ្វើ ក្រោយមរណកាលរបស់មាតាបិតា, កិច្ចត្រូវធ្វើបុណ្យហើយឧទ្ទិសជូនទៅប្រេត។

ឡើង ជាអ្នកមានឈានមិនសាបសូន្យ ហើយនៅពេលស្លាប់ទៅ ក៏បានទៅកើតក្នុងព្រហ្មលោក។

ចំណែកឥសី ជាព្រាហ្មណ៍ទាំង៥០០នាក់ បានមកនៅជាមួយព្រះពោធិសត្វ ព្រោះសេចក្តីស្រឡាញ់ក្នុងកាលមុន ហើយក្នុងចំណោមសិស្សទាំងនោះ សិស្សម្នាក់ ដែលជាប្រធាននៃសិស្សទាំងអស់របស់ព្រះពោធិសត្វ គឺជាតួអង្គ **ព្រះពោធិសត្វមេត្តេយ្យៈ** (ព្រះសិអារ្យមេត្រីពោធិសត្វ)។

ថ្ងៃមួយ កាលឥសីទាំងអស់ទៅកាន់ទិសផ្សេងៗ ដើម្បីស្វែងរកផលាផល ព្រះពោធិសត្វបានហៅសិស្សដែលជាប្រធានមក រួចឱ្យឡើងលើភ្នំមណ្ឌៈជាមួយ ដើម្បីស្វែងរកផលាផល ហើយក្នុងកាលស្វែងរកផលាផលជាមួយនឹងប្រធានសិស្សនោះ លោកបេះផ្លែឈើមិនបានទាល់តែសោះ ក៏សម្លឹងមើលមកជើងភ្នំបានឃើញមេខ្លាមួយ ដែលទើបនឹងកើតកូនបានប្រមាណបីថ្ងៃ។

នៅពេលនោះ មេខ្លាមិនអាចអត់ទ្រាំនឹងគម្លានបាន វាក៏សម្តែងអាការៈបម្រុងនឹងស៊ីកូន ដែលកំពុងប្រឡែងជាមួយខ្លួន។

ព្រះពោធិសត្វឃើញមេខ្លា ដែលមានសេចក្តីប្រាថ្នានឹងស៊ីកូននោះហើយ លោកគិតថា អហោ ជិរត្ថុ វត សំសារេ, ឯសា ហិ អត្តនោ ជីវិតំ រក្ខនត្ថាយ អត្តនោ លោហិតតោ ជាតេ បុត្តេ ខាទិតុកាមា អយំ។

***ឱ!សំសារវដ្ត គួរឱ្យខ្លាចណាស់តើ ព្រោះថា មេខ្លានេះ មានសេចក្តីប្រាថ្នានឹងស៊ីកូន ដែលកើតអំពីលោហិតនៃខ្លួន ដើម្បីរក្សាជីវិតរបស់ខ្លួន។***

គ្រាគិតដូច្នេះហើយ ទើបព្រះពោធិសត្វ ហៅប្រធានសិស្ស ឱ្យមកជិតហើយពោលថាៈ

*“នែសិស្សសម្លាញ់ ចូរអ្នកស្វែងរកសាច់ ដែលជាសំណល់របស់សត្វសីហៈ ឬជាសំណល់របស់សត្វ**ហត្ថិលិង្គ**[១៧] ជាដើមលើកំពូលភ្នំទាំងអស់ បើបាន ចូរប្រញាប់មក យើងនឹងឱ្យជាចំណី ដល់មេខ្លានោះ”។*

*ប្រធានសិស្ស ត្រូវអាចារ្យបញ្ជូន ទើបទៅស្វែងរកសាច់សំណល់ ទូទាំងកំពូលភ្នំ។*

*ក្នុងវេលាដែលប្រធានសិស្ស មិនទាន់ត្រឡប់មកដល់ ព្រះពោធិសត្វក៏ពិចារណាអត្តភាពរបស់ខ្លួន ហើយពោលយ៉ាងនេះថា៖*

“អយំ សក្កាយឆកហេ, គតិ បច្ចន្តនិស្សិតោ;
ជាតិភយពហុត្រាសោ, ជរាចោរវិលុម្បកោ។
ព្យាធិព្យគ្ឃកុលាភាសោ, មច្ចុបព្វតមទ្ធនោ;
សោកសន្តាបពហុលោ, បរិទេវពហុបទ្ទវោ។
ទុក្ខោ ចរណសម្បន្នោ, ទោមនស្សភយាកុលោ;
ឧចាយាសបិឡាករណោ, កោរលោ ទុក្ខវត្តុកោ។
រាគហត្ថិកុលាភាសោ, ទោសាវសវិសាលយោ;
មោហភូតគណាកិណ្ណោ, កោធរក្ខសសេវិតោ។
ឧបនាហវាឡពហុលោ, មក្ខកុម្ភណ្ឌសេវិតោ;
បលាសចោរចរិតោ, ឥស្សាបច្ចត្ថិកាកុលោ។
ទុច្ចរិតបរិភេ, វិសមលោភបុរក្ខិតោ;
ឆន្ទរាគមហាយោធោ, មិច្ឆាធម្មវិនិច្ឆយោ។

---

[១៧] *(ន.)(បា.សំ.)សត្វបក្សីមួយប្រភេទ មាឌធំសម្បើម មានរូបសណ្ឋានស្រដៀងនឹងដំរី មានចំពុះ មានក្រញ៉ាំជើងធំមាំ មានចំអេងស្លាបធំវែង អាចឆាបឆក់សត្វធំៗ មានម្រឹគជាដើម យកធ្វើជាចំណី របស់វាបាន មានកំណើត និងទីលំនៅនាទ្រូងព្រៃហេមពាន្ត វាតែងហើរចេញមករកឆាបឆក់ចំណី ឯប្រទេសជិតៗព្រៃហេមពាន្តម្តងម្កាល។*

អវណ្ណាទុក្ខនុ្ទពហុលោ,　　វិតក្កមក្ខិតាកុលោ;
មនគន្ធព្វពហុលោ,　　បមាទគណាសេវិតោ។
ទិដ្ឋិនិស្សន្ទពហុលោ,　　អនុសយព្រាហ្មណាយោ;
សំយោជនមហាមច្ចោ,　　រក្ខតិ នគរំ សទា។
ឯវ ឧត្រាសពហុលោ,　　សក្កាយនគរោ អហំ;
តត្ថ អញ្ញាតោ រាជា,　　វដ្ដំ ការេតិ ឥស្សរោ”។

“នគរគឺ**សក្កាយៈ** (រាងកាយ) នេះ អាស្រ័យនឹងជាយដែនគឺ**គតិ** (ភូមិជាទីទៅរបស់សត្វ), ច្រើនទៅដោយភ័យគឺ**ជាតិ** (កំណើត), មានចោរគឺ**ជរា** (ការចាស់គ្រាំគ្រា) ប្លន់ហើយ។

ជាទីនៅរបស់ត្រកូលខ្លាគឺ**ព្យាធិ** (ជំងឺ), មានភ្នំគឺ**មច្ចុ** (សេចក្ដីស្លាប់) យាយី, ច្រើនទៅដោយសេចក្ដីក្ដៅក្រហាយគឺ**សោក** (សេចក្ដីឈឺផ្សាចិត្ត), មានឧបទ្រពគឺ**បរិទេវៈ** (ការយំខ្សឹកខ្សួល) ច្រើន។

ដល់ព្រមដោយក្បាលខ្មោចគឺ**ទុក្ខ** (សេចក្ដីលំបាកកាយ), លាយទ្បំដោយភ័យគឺ**ទោមនស្ស** (សេចក្ដីលំបាកចិត្ត), មាន**ឧបាយាសៈ** (សេចក្ដីចង្អៀតចិត្ត) ធ្វើការបៀតបៀន, ជាទីតាំងនៃសេចក្ដីទុក្ខតែម្យ៉ាង។

ជាទីនៅរបស់ត្រកូលដំរីគឺ**រាគៈ** (តម្រេកជាសេចក្ដីរីករាយត្រេកត្រអាលចំពោះកាម), ធំធេងដោយអំណាចនៃ**ទោសៈ** (ការប្រទូស្តឬកំហឹង), រោយរាយដេរដាសកុះករ ប្រទ្បូកប្រទ្បំដោយពួកភូតគឺ**មោហៈ** (សេចក្ដីវង្វេងឬសេចក្ដីល្ងង់), ដែលអារក្សគឺ**កោធៈ** (សេចក្ដីក្រោធ) សេពហើយ។

ច្រើនទៅដោយសត្វសាហាវគឺ**ឧបនាហៈ** (ការចងគំនុំ), ដែលពួកកុម្ភណ្ឌគឺ**មក្ខៈ** (រមិលគុណ) សេពហើយ, ដែលចោរគឺ**បលាសៈ** (វាយ

*ឫកប្រៀបផ្ទឹម ឬប្រណាំងវាសនា) ត្រាច់ទៅហើយ, ដែលរឹករវប្រឫក ប្របល់ដោយសត្រូវគឺ**ឥស្សា** (សេចក្ដីច្រណែន)។*

*ឡោមព័ទ្ធដោយ**ទុច្ចរិត** មាន**វិសមលោភៈ** (លោភៈមិនស្មើគឺរំពៃចង់បានមិនរើសមុខ) ជាខាងដើម មាន**នទ្ធិរាគៈ** (សេចក្ដីតម្រេកដោយអំណាចនៃភាពភ្លើតភ្លើន) ជាមេទាហាន, មាន**មិច្ឆាធម្មៈ** (សេចក្ដីតម្រេកខុសធម៌ដូចប្រុសស្រឡាញ់ប្រុស ស្រីស្រឡាញ់ស្រី) ជាអ្នកវិនិច្ឆ័យ។*

*ច្រើនទៅដោយក្លិនអាក្រក់គឺ**ការតិះដៀល**, ដែលរឹករវដែលប្រឫកប្របល់ដោយ**វិតក្កៈ** (តម្រិះ), ច្រើនទៅដោយគន្ធពួគឺ**មទៈ** (សេចក្ដីស្រវឹង), ត្រូវគណៈគឺ**បមាទៈ** (សេចក្ដីប្រមាទ) សេពហើយ។*

*ច្រើនទៅដោយអាចម៌កំបាំងគឺ**ទិដ្ឋិ** (ការយល់ខុស), ជាទីអាស្រ័យរបស់ព្រាហ្មណ៍គឺ**អនុស័យ** (កិលេសដេកត្រាំក្នុងចិត្ត), មានមហាមាត្យគឺ**សំយោជនៈ** (កិលេលជាគ្រឿងចងសត្វទុកក្នុងភព) រមែងរក្សានគរសព្វកាល ។*

*យើងជា**សក្កាយនគរ** ដែលច្រើនទៅដោយ**ឧត្រាសៈ** គឺសេចក្ដីភ័យខ្លាចយ៉ាងនេះ ព្រះរាជាដែលជាធំ ជាអ្នកមិនដឹង រមែងសោយរាជ្យក្នុងនគរគឺសក្កាយៈនោះ"។*

*ព្រះពោធិសត្វ កាលពិចារណាធម៌ ក្នុងរាងកាយរបស់ខ្លួនក្នុងកាលឈររង់ចាំការមកដល់របស់សិស្សយ៉ាងនេះហើយ ទើបគិតទៀតថា **យើងនឹងរំដោះសត្វទាំងឡាយ ដែលកំពុងសោយទុក្ខ មានប្រការផ្សេងៗ ច្រើនជាអនេក មានសភាពបែបនេះ ឱ្យរួចចាកទុក្ខដោយធម៌អ្វីហ្ន៎។***

ខណៈនោះ ព្រះអង្គក៏បានឃើញពុទ្ធការកធម៌[១៨] ដោយអំណាចនៃការបានសន្សំមកអំពីអតីតជាតិ។

ព្រះពោធិសត្វ កាលគិតឃើញយ៉ាងនោះ ក៏គិតបន្តថា បុគ្គលកាលមិនធ្វើពុទ្ធការកធម៌ ដែលជាធម៌ធ្វើបានដោយលំបាកទេ មិនលះបង់នូវវត្ថុ ដែលលះបង់បានដោយលំបាកទេ មិនផ្តល់នូវវត្ថុដែលឱ្យបានដោយលំបាកទេ គឺមិនអាចត្រាស់ជាព្រះពុទ្ធបានឡើយ។

ព្រោះហេតុចិត្តនេះ ដែលយើងកំណត់ទុក ដើម្បីភាពជាព្រះពុទ្ធ គឺអាស្រ័យសរីរៈ ដែលមានទោសច្រើន តាំងនៅមិនបានយូរ ហើយមិនមែនជាសការៈមានអារម្មណ៍តែមួយពេល ដើម្បីឱ្យជាប្រយោជន៍ដល់សព្វសត្វ។

យើងនឹងលះបង់រាងកាយរបស់យើងដល់មេខ្លានោះ ដរាបទាន់ចិត្តនៅជ្រះថ្លា ទានដទៃក្រៅពីនេះ នឹងមានប្រយោជន៍អ្វីដល់យើង?

រួចហើយព្រះពោធិសត្វ បានធ្វើចេតោបណិធាន ដើម្បីភាពជាព្រះពុទ្ធយ៉ាងនេះថា៖

"ឥមិនា បុញ្ញកម្មេន, ពុទ្ធោ ហោមិ អនាគតេ;
សំសារទុក្ខតោ សត្តេ, សម្បាបេស្សាមិ និព្ពុតំ"។

"ដោយបុញ្ញកម្មនេះ ក្នុងកាលអនាគត សូមឱ្យខ្ញុំបានត្រាស់ជាព្រះពុទ្ធ ខ្ញុំនឹងញ៉ាំងសត្វទាំងឡាយ ឲ្យដល់នូវសេចក្តីរំលត់ ផុតចាកទុក្ខក្នុងសំសារវដ្ត"។

ព្រះពោធិសត្វកាលនឹងឱ្យខ្លួនដឹងច្បាស់ ទើបពោលយ៉ាងនេះទៀតថា៖

"ជាតុស្សរ មេ អនុមោទន្តុ, ឱភោ ឋរា ច បព្វតា;

---

[១៨] (ន.)(បា.សំ.)ជាធម៌ ដែលធ្វើឱ្យបានត្រាស់ជាព្រះពុទ្ធ គឺបារមី១០។

**ពុទ្ធបណិធាន**

ឥន្ទោ ព្រហ្មា ច បជាបតិ ច, សោមោ យមោ វេស្សវណោ រាជា;
សព្វេ ទេវានុមោទន្តុ, យមិទំ បុញ្ញំ មយា កតំ។

*"សូមនរជនទាំងពីរ ព្រះបព្វតា (ទេវតានៅលើភ្នំ) ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះបជាបតី ព្រះសោម ព្រះយម ស្តេចវេស្សវ័ណ និងព្រះរាជាទាំងឡាយ ចូរអនុមោទនាចំពោះខ្ញុំដែលជាអ្នកឲ្យទាន សូមទេវតាទាំងពួងអនុមោទនាបុណ្យដែលខ្ញុំបានធ្វើហើយចុះ"។*

*ព្រះពោធិសត្វ គ្រាពោលយ៉ាងនេះហើយ ក្នុងកាលសិស្សនៅមិនទាន់មក លោកក៏បានលោតអំពីកំពូលភ្នំឈ្មោះមណ្ឌៈ ធ្លាក់ចុះមកដល់មាត់មេខ្លា។*

*មេខ្លា ឃើញរាងកាយរបស់ព្រះពោធិសត្វ ធ្លាក់ចុះមកអំពីកំពូលភ្នំ ទើបលះបង់កូនរបស់ខ្លួន ហើយមកស៊ីសាច់ព្រះពោធិសត្វជាចំណីជំនួសវិញ។*

*ដោយបុញ្ញកម្មនោះ ព្រះពោធិសត្វ ចុតិចាកអត្តភាពនោះហើយបាន ទៅកើតក្នុងទេវលោក។*

*ក្នុងខណៈនោះ ទេវតាទាំងឡាយមានព្រះឥន្ទ្រ និងព្រះព្រហ្មជាដើម ឱ្យសាធុការ ដល់ព្រះពោធិសត្វ។*

*កថានេះឈ្មោះថា កថាពោលដោយសេចក្តីកើតឡើងនៃចិត្តលើកទី៣ ដើម្បីភាពជាព្រះពុទ្ធ របស់ព្រះពោធិសត្វ ដោយអំណាចនៃការតាំងសេចក្តីប្រាថ្នាដោយចិត្តរបស់ខ្លួនឯងប៉ុណ្ណោះ ដូចពណ៌នាមកដូច្នេះឯង។*

*ការពណ៌នាក្នុងបាទគាថាថាៈ* ព្យគ្ឃិយា សកមជាសិ ព្រហ្មឥសិ *នេះ ចប់បរិបូណ៌ហើយ ដោយប្រការដូច្នេះ។*

# អដ្ឋុត្តិកនិទាន
# មានមួយនិទាន

# សិទ្ធត្ថគោលទាយិកាភរាជបុត្តី
## ព្រះរាជបុត្រីថ្វាយប្រេងគ្រាប់ស្ពៃ

## សេចក្ដីប្រាថ្នាជាព្រះពុទ្ធលើកទី៤

## ក្នុងព្រះពុទ្ធសាសនា

# ពុទ្ធបណិធាន


សិទ្ធត្ថតេលទាយិកា រាជបុត្តី ព្រះរាជបុត្រីថ្វាយប្រេងគ្រាប់ស្ពៃ
គឺជា សេចក្តីប្រាថ្នាជាព្រះពុទ្ធ លើកទី៤

## សិទ្ធត្ថគេលទាយិកាពរាជបុត្រី
## ព្រះរាជបុត្រីថ្វាយប្រេងគ្រាប់ស្ពៃ

បានឮមកថា ព្រះពោធិសត្វរបស់យើងទាំងឡាយ វិលវល់ស្លាប់កើត នៅក្នុងទេវលោក និងមនុស្សលោកច្រើនរយជាតិ ហើយទើបបានមកកើតក្នុងត្រកូលជាងមាស ក្នុងកប្បមួយឈ្មោះបុណ្ណរិកៈ។ ព្រះពោធិសត្វកាលចម្រើនវ័យធំហើយ ជាអ្នកឈ្លាសក្នុងការងារជាងទង។

គ្រានោះ មានមហាសេដ្ឋីម្នាក់ឈ្មោះ**ទណ្ឌករៈ** ដែលមានបុត្រីម្នាក់ឈ្មោះ**កាញ្ចនវតី** ចម្រើនវ័យធំឡើងមួយអន្ទើដោយបរិវារ រួចក្នុងកាលអាយុ១៦ ឆ្នាំ នាងជានារីមានរូបល្អស្រស់ស្អាតក្រៃលែង។

នៅតំបន់ខាងលិចនៃស្រុករបស់លោកសេដ្ឋី**ទណ្ឌករៈ** មានមហាសេដ្ឋីម្នាក់ទៀតឈ្មោះ**វិសាល** ជាមិត្រសម្លាញ់ នៃសេដ្ឋី**ទណ្ឌករៈ**។

វិសាលសេដ្ឋី បានមកសូមស្ដីដណ្ដឹងធីតា**កាញ្ចនវតី**នៃសេដ្ឋី**ទណ្ឌករៈ** យកមកធ្វើជាកូនប្រសាររបស់ខ្លួន។

មហាសេដ្ឋីទណ្ឌករៈ ក៏បានឱ្យគេហៅព្រះមហាសត្វ ដើម្បីមកធ្វើគ្រឿងអលង្ការ សម្រាប់ធីតានៃលោក។

ខណៈនោះ មហាសេដ្ឋី បានឱ្យព្រះពោធិសត្វចូលទៅកាន់ប្រាសាទជាន់ក្រោម ហើយពោលនឹងព្រះពោធិសត្វថា៖

"នៃជាងមាសដ៏ចម្រើន ប្រសិនបើអ្នកគ្រាន់តែឃើញជើង តើអ្នកអាចនឹងធ្វើគ្រឿងអលង្ការ បានដែរឬទេ?"

ព្រះពោធិសត្វ ពោលថា៖

*"បពិត្រលោកម្ចាស់ ខ្ញុំអាចធ្វើបាន"។*

*ទណ្ឌករសេដ្ឋី ពោលថា៖*

*"បើដូច្នោះ ចូរអ្នកសម្គាល់ជើងនោះ រួចធ្វើអលង្ការចុះ"។*

*រួចទណ្ឌករសេដ្ឋី បង្ហាញអវយវៈតែជើង និងម្រាមដៃរបស់ធីតានៃខ្លួន ដល់ព្រះពោធិសត្វ ដែលជាអ្នកទទួលយកមាសចំណែកខ្លះទៅហើយ សម្រាប់ជាឈ្នួលនៃការធ្វើគ្រឿងអលង្ការ។*

*ចំណែកធីតានាងគិតថា* ***មាតាបិតា របស់យើងបង្ហាញត្រឹមតែម្រាមដៃ នៅចំពោះមុខជាងមាស តើមានរឿងហេតុអ្វីអេះ?***

*ខណៈនោះឯង នាងសម្លឹងរកមើលព្រះមហាសត្វ តាមប្រហោងរនាប ឃើញរូបសម្បត្តិរបស់ព្រះពោធិសត្វ រួចក៏មានចិត្តប្រតិព័ទ្ធ ហើយត្រូវកាមរាគៈគ្របសង្កត់ខ្លួនភ្លាម។*

*នាងក៏បានសរសេរសំបុត្រថា៖*

*"បើលោកមានសេចក្ដីត្រូវការខ្ញុំ នៅចំណែកទិសខាងលិចមានដើមម៉ែ-សាក់ទល់នឹងផ្ទះធំមួយ រួចក្នុងវេលាល្ងាច អ្នកឡើងលើដើមម៉ែសាក់នោះ សសៀរទៅតាមមែក ចំណែកខ្ញុំ នឹងមករកអ្នកក្នុងពេលយប់ រួចខ្ញុំនឹងអភិរម្យ ត្រេកត្រអាលជាមួយនឹងលោក"។*

*ហើយនាងក៏ទម្លាក់សំបុត្រនោះ ទៅលើក្បាលជាងទង។*

*កំលោះជាងទងឃើញសំបុត្រហើយ បើកមើល រួចនៅស្ងៀមធ្វើការងារដូចធម្មតា។*

*ក្នុងវេលាល្ងាច ព្រះពោធិសត្វ ធ្វើការងាររួចហើយ លោកទៅកាន់ផ្ទះ*

របស់ខ្លួន ផ្ទុតទឹក និងបរិភោគបាយ ហើយកាលព្រះសុរិយាអស្តង្គត លោកក៏ឡើងលើដើមម៉ៃសាក់ អង្គុយផ្អែកនឹងដើមម៉ៃសាក់ សម្លឹងមើលផ្លូវជាដំណើរមករបស់នាងកុមារីកាញ្ចនវតី។

ចំណែក**កាញ្ចនវតី** នាងជាអ្នកប្រណិប័តន៍មាតាបិតា ហើយនៅពេលដរាបណាមាតាបិតា មិនទាន់ឈានចុះការលង់លក់ ដរាបនោះនាងក៏មិនចេញមក ។

លុះកាលមាតាបិតា ចូលសម្រាន្តលង់លក់ហើយ **កាញ្ចនវតី** ក្រោកសន្សឹមៗ កាន់យកបាយស្រូវសាលី លាយដោយសាច់ និងសម្ល៉ឈ្ងុយឆ្ងាញ់ ដាក់ក្នុងកញ្ចប់ឱ្យពេញ ហើយចុះចាកប្រាសាទ ទៅកាន់កន្លែងណាត់ជួបជាមួយនឹងកំលោះជាងទង។

ពេលមកដល់ **កាញ្ចនវតី** បានសម្លឹងរកមើលព្រះពោធិសត្វ ដឹងថាលោកដេកលក់ហើយ នាងក៏មិនដាស់ឱ្យក្រោកឡើងទេ ព្រោះថាក្នុងសម័យកាលនោះ នាងបានទទួលដំណឹងថា អ្នកណាធ្វើមនុស្ស ដែលដេកលក់ឱ្យក្រោកឡើង អ្នកនោះរមែងធ្លាក់ក្នុងមហានរកអស់១កប្ប។ ព្រោះហេតុនាងបានដឹងរឿងនោះ អំពីសម្នាក់មាតាបិតារបស់នាង ទើបនាងមិនដាស់ព្រះមហាសត្វឱ្យក្រោកឡើង ព្រោះខ្លាចធ្លាក់នរក។

បន្ទាប់មក នាងបានបេះស្លឹកម៉ៃសាក់ មកទ្រាប់កញ្ចប់បាយ ជិតកំលោះជាងទង រួចត្រឡប់ចេញទៅវិញ ហើយក្នុងកាលដែលនាងទៅដល់ទ្វារប្រាសាទ ព្រះមហាសត្វភ្ញាក់ឡើងឃើញកញ្ចប់បាយគិតថា **ឥឡូវនេះនាងបានមកហើយ**

**ពុទ្ធបណិធាន**

រួចលោកងាកមើលខាងនេះខាងនោះ ឃើញនាងដើរចូលទៅក្នុងប្រាសាទ លោកមានវិប្បដិសារៈ ក៏កាន់យកកញ្ចប់បាយទៅផ្ទះរបស់ខ្លួនវិញ។

ថ្ងៃស្អែក កាលព្រះអាទិត្យរះឡើង ព្រះពោធិសត្វ ធ្វើការងាររបស់ខ្លួនដូចរាល់ថ្ងៃ។

ចំណែកនាងកុមារី សរសេរសំបុត្រដូចថ្ងៃមុននោះម្តងទៀត និងបន្ថែមថា **សូមលោកកុំដេកលក់ដូចថ្ងៃមុនទៀត** រួចទម្លាក់លើក្បាល របស់ជាងទង។

ព្រះមហាសត្វមើលសំបុត្រ រួចធ្វើការងារក្នុងអាការៈធម្មតា ហាក់បីដូចជាមិនដឹងរឿងអ្វីកើតឡើង។

កាលព្រះសុរិយាអស្តង្គតទៅ ព្រះពោធិសត្វ ទៅកាន់ទីនោះ ហើយក៏ដេកលង់លក់ម្តងទៀត។

ចំណែកស្រីក្រមុំកាញ្ចនវតី បានទៅហើយ ដោយន័យដែលបានពោលហើយនោះឯង ឃើញនូវការដេកលក់របស់ជាងទង នាងក៏ត្រឡប់ទៅវិញដោយទុកបាយកញ្ចប់ឱ្យ ដូចលើកមុន។

រីឯព្រះមហាសត្វភ្ញាក់ឡើង ឃើញវត្ថុនោះហើយ ក៏កាន់យកទៅផ្ទះរបស់ខ្លួន ដូចថ្ងៃមុនដែរ។

ក្នុងថ្ងៃទី៣ នាងកាញ្ចនវតី ឃើញព្រះពោធិសត្វដេកលក់ ដូចថ្ងៃមុនទៀត។

នាងកាញ្ចនវតី ដោយត្រូវសេចក្តីសោក គ្របសង្កត់យ៉ាងខ្លាំង ក៏ពោលគាថា យ៉ាងនេះថាៈ

"អយំបិ កុមារោ បិយោ, មជាចោ'ភិរម្មណិយោ;
សន្និវាសា បុរេ នត្ថិ, និច្ឆាយនបពុជ្ឈកោ។
មោឃំ តេ វីរិយំ ហោតិ, មោឃោ មេ ហោតិ វីរិយោ;
គច្ឆ អយ្យ យថាសុខំ, មយ្ហំ បរិវត្តិ នត្ថិ"។

"កុមារសូម្បីនេះ ជាទីស្រឡាញ់ ជាទីពេញចិត្ត ដែលគួរឱ្យអភិរម្យ ត្រេកអរ យ៉ាងណាក៏ដោយ តែសន្និវាស គឺការរួមរស់ក្នុងភពមុន ជាមួយនឹងគេ រមែងមិនមាន ព្រោះហេតុនោះ ទើបគេដេកលក់។ សេចក្តីព្យាយាមរបស់គេ គឺទទេ សេចក្តីព្យាយាមរបស់ខ្ញុំ ក៏ទទេ បពិត្រលោកដ៏ចម្រើន ចូរលោកនៅជាសុខចុះ ការត្រឡប់មករបស់ខ្ញុំ រមែងមិនមានឡើយ"។

យុវតីបានពោលនូវគាថាដូច្នោះហើយ ដាក់កញ្ចប់បាយចុះ រួចធ្វើដំណើរចេញទៅ ដោយមិនវិលត្រឡប់មកទីនោះទៀតឡើយ។

កាលនាងទៅដល់ទ្វារប្រាសាទ ព្រះពោធិសត្វ ភ្ញាក់ឡើងសម្លឹងមើល ឃើញតែផ្លូវល្ហល្ហេវ។

ជាងទងវ័យក្មេង ជាអ្នកត្រូវកាមរាគៈគ្របសង្កត់ ក៏ពោលគាថាយ៉ាងនេះថា៖

"អភិរូបាយំ កុមារី, ឧស្សជីយា មនោរមា;
ចោទិតោ កោន កាម្មេន, និច្ឆាយឹ បុប្ផមូលកោ។
បុរេ បុញ្ញំ កតំ នត្ថិ, តេនម្ហិ ជារិមសង្គម្ម;
ជានកាលេ ន សោហម្ហិ, សេដ្ឋិនោ ជាទុមោខជំ;
ជារិជិដ្ឋមត្តា ជានិ, តាយ សទ្ធឹ ន រមាមហំ"។

*"យុវតីនេះ មានរូបល្អស្អាត គួរជាទីទស្សនា ជាទីមនោរម្យ ខ្ញុំត្រូវកម្មអ្វី ដាស់តឿន បានជាដេកលក់ នៅគល់ដើមម៉ៃសាក់។*

*ពួកយើង គង់មិនបានធ្វើបុណ្យរួមគ្នាក្នុងកាលមុន ព្រោះហេតុនោះ ទើបខ្ញុំមិនបានសមាគម នឹងនារីបែបនោះ ហើយក្នុងវេលាបរិច្ចាគទាន គង់មិនមានខ្ញុំនៅផង ទាំងមិនបានអនុមោទនាទានរបស់នាង ឥឡូវនេះ ទើបបានត្រឹមតែឃើញនារីប៉ុណ្ណោះ តែមិនបានត្រេកត្រអាលរីករាយ ជាមួយនាង"។*

*ព្រះពោធិសត្វ ពោលគាថានេះរួច ក៏កាន់យកអាហារ ដែលយុវតីនោះទុកឱ្យ ហើយចេញទៅ។*

*ស្អែកឡើង លោកវិសាលសេដ្ឋី បានដឹកអង្ករស្រូវសាលី៥០០រទេះ ប្រេង៥០០រទេះ ទឹកដោះជូរ និងទឹកដោះស្រស់១,០០០រទេះ រួមទាំងសាច់ម្រឹគ គោ ក្របី ជ្រូក ចៀម ត្រី សាច់១,០០០រទេះ បញ្ជូនទៅផ្ទះរបស់ទណ្ឌករសេដ្ឋី។*

*លោកវិសាលសេដ្ឋី ឱ្យគេប្រដាប់តាក់តែងបុត្ររបស់ខ្លួន ឱ្យឡើងជិះយាន រួចបញ្ជូនទៅជាមួយនឹងបរិវារទាំងឡាយ។ រីឯខ្លួនលោកក៏ឡើងលើរថដ៏ប្រសើរ ដែលវិចិត្រដោយរតនៈ៧ប្រការ ធ្វើដំណើរទៅកាន់ផ្ទះរបស់ទណ្ឌករ-មហាសេដ្ឋី ជាមួយនឹងបរិវារយ៉ាងច្រើន។*

*សេដ្ឋីទាំងពីរនោះ បានរៀបចំពិធីអាវាហមង្គលបុត្រ ប្រុសស្រី រួចរៀបចំពិធីជប់លៀងអស់រយៈពេល១ខែ ហើយកាលជាទីបញ្ចប់នៃខែ ទើបលោកសេដ្ឋីវិសាលនាំបរិវាររបស់ខ្លួន ត្រឡប់ទៅស្រុករបស់លោកវិញ។*

*ចំណែកព្រះពោធិសត្វ ឃើញស្ថានភាពដូច្នេះ ក៏បានគិតយ៉ាងនេះថា*

យុវតីនេះជាស្រីដែលជាទីស្រឡាញ់ ឈ្មោះថាបុរសដែលប្រាកដដូចយើង គួរនឹងបានការដល់ព្រមបរិបូណ៌ដោយនាង។

យើងគួរនឹងបានជួបព្រះមហាឧបរាជ អាស្រ័យដោយនាំយកនូវគ្រឿងបណ្ណាការខ្លះទៅថ្វាយ។

គិតដូច្នេះហើយ ព្រះពោធិសត្វ ធ្វើគ្រឿងអលង្ការខ្លះ ដែលវិចិត្រដោយកែវមណី និងកែវមុក្តា ដែលសមគួរដល់ព្រះរាជា ហើយយកបណ្ណាការនោះទៅថ្វាយព្រះមហាឧបរាជ។

មហាឧបរាជ បានឃើញគ្រឿងបណ្ណាការនោះហើយ មានព្រះទ័យត្រេកអរក្រៃលែង ក៏សួរទៅកាន់ជាងទងថា៖

"នែអ្នកដ៏ចម្រើន អ្នកថ្វាយគ្រឿងបណ្ណាការនេះដល់យើងព្រោះហេតុអ្វី"?

ព្រះពោធិសត្វក៏បានប្រាប់រឿងរ៉ាវទាំងអស់ ថ្វាយព្រះមហាឧបរាជ។

មហាឧបរាជពោលថា៖

"នែអ្នកដ៏ចម្រើន អ្នកកុំគិតច្រើនអី យើងមានឧបាយ ដែលធ្វើឱ្យអ្នកបានជួបជាមួយនឹងសេដ្ឋីធីតានោះ"។

បន្ទាប់មកឧបរាជ ឱ្យគេប្រដាប់តាក់តែងព្រះពោធិសត្វដោយគ្រឿងអលង្ការទាំងពួង និងកាន់យកភេទជាស្ត្រី ហើយនាំទៅឡើងជិះលើកដំរី រួចព្រះមហាឧបរាជអង្គឯងក៏គង់លើកដំរីដែរ ហើយធ្វើដំណើរហែហមដោយពលរេហ៍ជាច្រើន ឆ្ពោះទៅកាន់ផ្ទះរបស់ទណ្ឌករសេដ្ឋី។

កាលកំពុងគង់លើកដំរីនោះ ព្រះមហាឧបរាជ បានឱ្យសេនាហៅមហា

សេដ្ឋីមក ហើយពោលយ៉ាងនេះថា៖

"នែមហាសេដ្ឋីដ៏ចម្រើន សុវណ្ណប្រាសាទនេះ ជារបស់អ្នកណា"?

ទណ្ឌាករសេដ្ឋី ពោលថា៖

"បពិត្រព្រះអង្គម្ចាស់ ប្រាសាទនេះជារបស់ធីតានៃទូលបង្គំ"។

ឧបរាជ ពោលថា៖

"នែមហាសេដ្ឋីដ៏ចម្រើន បើយ៉ាងនោះ ដោយយើងត្រូវមហារាជ ដែលជាព្រះបិតា បញ្ជូនទៅកាន់ជនបទ ដើម្បីបង្ក្រាបចោរភ័យ យើងសូមផ្ញើអនុជារបស់យើង ទុកនឹងធីតារបស់លោក រហូតដល់វេលាដែលយើងត្រឡប់មក ហើយនៅវេលាដែលយើងត្រឡប់មកដល់ ទើបនាំអនុជារបស់យើងនោះ ត្រឡប់ទៅវិញ"។

មហាសេដ្ឋី ស្តាប់ពាក្យនោះហើយ ពោលយ៉ាងនេះថា៖

"ធីតារបស់ខ្ញុំ មានស្វាមីហើយ ចំណែកអនុជារបស់ព្រះអង្គម្តេចឡើយអាចនៅជាមួយនឹងធីតា របស់ទូលបង្គំបានទៅ"។

មហាឧបរាជ ពោលថា៖

"ម្នាលមហាសេដ្ឋី អនុជារបស់យើង នឹងនៅជាមួយធីតារបស់លោក ដោយវៀរស្វាមីរបស់នាង ឱ្យទៅនៅកន្លែងផ្សេងរហូតដល់ពេល ដែលយើងត្រឡប់មកពីបង្ក្រាបសត្រូវវិញ"។

សេដ្ឋី ទទួលពាក្យថា៖

"សូមទទួលព្រះឱង្ការ ព្រះអង្គម្ចាស់មហាឧបរាជ"។

រួចហើយ សេដ្ឋីឱ្យហៅធីតារបស់ខ្លួនមកប្រាប់រឿងរ៉ាវទាំងអស់ ហើយឱ្យនាងនៅបែកពីស្វាមី។

ចំណែកមហាឧបរាជ ក៏បញ្ជូនជាងទងចូលទៅនៅក្នុងប្រាសាទនៃនាងកាញ្ចនទេវីដែលទើបតែនឹងរៀបអាពាហ៍ពិពាហ៍ថ្មីៗ។

បន្ទាប់មក មហាឧបរាជក៏ពោលថា៖

"ម្នាលមហាសេដ្ឋី អនុជារបស់យើង មិនធ្លាប់សោយអ្វីផ្ដេសផ្ដាស លោកកុំបញ្ជូនអ្វីឱ្យព្រះនាងសោយ មិនធ្លាប់មានភីលៀង លោកកុំបញ្ជូនភីលៀង កុំឱ្យព្រះនាងចេញទៅនៅក្នុងទីដទៃ កុំឱ្យអ្នកដទៃណាចូលទៅក្នុងប្រាសាទ សូម្បីតែស្វាមីនៃធីតារបស់លោកក៏ដោយ"។

មហាសេដ្ឋី ពោលតបថា៖

"សូមព្រះអង្គកុំព្រួយអី អ្វីៗគ្រប់យ៉ាង ជាភារៈរបស់ទូលបង្គំ"។

ចំណែកព្រះមហាឧបរាជ បានបញ្ជាគ្រប់យ៉ាងឱ្យជាភារៈរបស់លោកសេដ្ឋីហើយ ទើបទ្រង់យាងចេញទៅ។

តាំងអំពីពេលនោះមក ព្រះពោធិសត្វក៏បានអភិរម្យ រួមរស់ជាមួយនឹងនាងកាញ្ចនវតី មិនមានអ្នកណាមួយដឹងហេតុការណ៍នោះឡើយ រហូតអស់៣ខែ ទើបព្រះមហាឧបរាជ ត្រឡប់មកនាំជាងទង ចេញទៅវិញ។

ចំណែកព្រះមហាសត្វពេលនោះ មានញាណមិនទាន់ចាស់ក្លា ត្រូវមោហៈបិទបាំងគ្របសង្កត់ ជាអ្នកសូន្យទទេព្រោះរាគៈជាដើមហេតុ បានសេពប្រពន្ធរបស់អ្នកដទៃ (ដាច់សិក្ខាបទទី៤ គឺកាមេ) រួចកាលចុតិចាកអត្តភាពនោះ ក៏បានទៅកើតក្នុងអវីចិមហានរក។

ដោយអំណាច**អបរាបរិយវេទនីយកម្ម** ដែលនៅសេសសល់ ក៏បានសោយមហាទុក្ខ ក្នុងមហានរកអស់១៤កប្បជារឿយៗ។

ពិតមែនហើយ សមដូចលោកពោលពាក្យនេះទុកថា៖

"រាគាតុរេបិមេ សត្តា, អនុភោន្តិ និរយំ ពហុ;
វឌ្ឍន្តិ ភវសំសារំ, សទ្ធម្មំ អវិជានតោ"។

*ប្រែថា៖*

*"ព្រោះសេចក្ដីក្ដៅក្រហាយរសាប់រសល់ដោយរាគៈ សត្វទាំងឡាយនេះរមែងប្រសព្វនរកយ៉ាងច្រើន, ព្រោះជាអ្នកមិនដឹងនូវព្រះសទ្ធម្ម **ភវ-សំសារ**ទាំងឡាយរមែងចម្រើន"។*

*ព្រះពោធិសត្វ ចុតិចាកមហានរកនោះហើយ ដោយអំណាចវិបាកកម្មដែលនៅសេសសល់ ត្រូវសោយទុក្ខធំ ដោយការកើតជា "នបុំសកៈ" គឺមនុស្សមិនមានភេទ កើតជាស្រី ជាបុរស ជាសត្វលា ជាសត្វគោ ដែលត្រូវគេគ្រៀវ ឬដំពង ជាមនុស្សគ ថ្ងង់អំពីកំណើត មួយប្រភេទៗ៥០០ជាតិ។*

*ព្រះពោធិសត្វ ដល់នូវភាពជាស្រីអស់៥០០ជាតិ ហើយការកើតជាស្រីក្នុងភពកំណើតជា**សិទ្ធត្ថតេលទាយិការាជបុត្តី** នេះជាជាតិចុងបំផុត នៃវិបាកកម្មរបស់ជាងទង។*

*នាកាលនោះ ក្នុង**សារមណ្ឌកប្ប** មាននគរមួយឈ្មោះ**រម្មវតី** ព្រះរាជាព្រះនាម **សុប្បបុត្ត** ជាស្ដេចសោយរាជ្យប្រកបដោយធម៌ដ៏ប្រពៃក្នុងនគរនោះ។*

*បុត្រច្បង របស់ព្រះបាទសុប្បបុត្តនោះ បានត្រាស់ដឹងជាព្រះសម្មា-សម្ពុទ្ធ ព្រះនាម**បុរាណទីបង្ករ**។*

*ព្រះពោធិសត្វនៃយើង ត្រាច់អន្ទោល ក្នុងទេវតាមនុស្ស ដោយអបរា-*

បរិយវេទនីយកម្ម ក៏ចុតិចាកទេវលោក កើតក្នុងរាជត្រកូល បានជាអនុជារួម វិមានរបស់ព្រះសម្មាសម្ពុទ្ធបុរាណទីបង្ករ រួចក្នុងថ្ងៃកាន់យកនូវឈ្មោះ ញាតិទាំងឡាយបានដាក់នាមថា**សុមិត្តា**។

គ្រានោះ ព្រះបុរាណទីបង្ករពោធិសត្វ បំពេញបារមីទាំងឡាយអស់ ១៦អសង្ខេយ្យ និងមួយសែនកប្ប ហើយក្នុងកប្បមួយឈ្មោះថា**សារមណ្ឌៈ** ទ្រង់កាន់យកបដិសន្ធិ ក្នុងផ្ទៃព្រះនាង**ចន្ទទេវី** ជាអគ្គមហេសីរបស់ព្រះបាទ **សុប្បបុត្ត** ក្នុងរាជត្រកូល។

កាលកន្លងទៅបាន១០ខែ ព្រះនាងចន្ទទេវី ក៏ប្រសូតព្រះរាជបុត្រ។

ព្រះរាជកុមារនោះ វ័យច្រើនហើយតាមលំដាប់ ទ្រង់រស់នៅក្នុងព្រះរាជវាំងអស់ជាង១០,០០០ឆ្នាំ ឃើញនិមិត្តទាំង៤ រួចចេញសាងមហាភិនេស្រ្កមណ៍ តាំងសេចក្តីព្យាយាមអស់៧ថ្ងៃ បានសម្រេចសព្វញ្ញុតញាណ។

គ្រានោះ មនុស្សទាំងឡាយ មានព្រះរាជាជាប្រធាន នាំគ្នាទំនុកបម្រុងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបច្ច័យទាំងឡាយ៤។

ពេលនោះ ព្រះ**បច្ឆិមទីបង្ករពោធិសត្វ**[១៧] កើតក្នុងព្រាហ្មណ៍ត្រកូល ដែលមានទ្រព្យច្រើន មានភោគៈច្រើន លោកឃើញទោសក្នុងកាមទាំងឡាយ លះបង់ផ្ទះ បួសក្នុងព្រះពុទ្ធសាសនា ជាអ្នកមានអភិញ្ញា៥ និងសមាបត្តិ៨។

ថ្ងៃមួយ ព្រះបច្ឆិមទីបង្ករពោធិសត្វ ឃើញសិរីសម្បត្តិរបស់ព្រះសម្មា-

---

[១៧] **បញ្ជាក់:** ព្រះ**បច្ឆិមទីបង្ករពោធិសត្វ** គឺជាព្រះពោធិសត្វដែលនឹងបានត្រាស់ដឹងជាព្រះ**ពុទ្ធទីបង្ករ**, ហើយព្រះពុទ្ធទីបង្ករគឺជាព្រះពុទ្ធដែលបានព្យាករ**សុមេធបណ្ឌិត**។

**ពុទ្ធបណិធាន**

*សម្ពុទ្ធបុរាណទីបង្ករ ដែលមានព្រះសង្ឃចោមរោមហើយក៏គិតឡើងថា* ***ព្រះសម្មាសម្ពុទ្ធបុរាណទីបង្ករ ដែលព្រះសង្ឃសាវកចោមរោមហើយ រមែងស្រស់ស្អាត ហើយព្រះអង្គបានញុំាំងសត្វទាំងឡាយនេះ ឱ្យរួចផុតចាកទុក្ខក្នុងសំសារវដ្តយ៉ាងណា យើងគប្បីបានជាព្រះពុទ្ធក្នុងកាលជាអនាគត យ៉ាងនោះដែរ។***

*ព្រះពោធិសត្វនោះ គិតយ៉ាងនេះហើយ កាន់យកបាត្ររបស់ខ្លួន ត្រាច់បិណ្ឌបាតប្រេងទូទាំងសកលនគរ នាំយកប្រេងយ៉ាងច្រើនបូកលាបបរិវេណទាំងអស់របស់ព្រះដ៏មានព្រះភាគ ដោយវត្ថុក្រអូប៤មុខ ហើយបូជាព្រះដ៏មានព្រះភាគ ដោយប្រទីបទាំងឡាយច្រើនពាន់ដួងរហូតសព្វរាត្រី។*

*កាលរាត្រីកន្លងទៅ ក្នុងកាលដែលភិក្ខុទាំងឡាយ នាំគ្នាមកកាន់សម្នាក់ព្រះមានព្រះភាគហើយ ព្រះពោធិសត្វនោះ ក៏ធ្វើការបូជាប្រទីបដល់ព្រះភិក្ខុសង្ឃ រួចដើរទៅកាន់សម្នាក់ព្រះមានព្រះភាគទៀត ហើយបង្អោនកាយក្រាបចុះ ជិតព្រះបាទព្រះសម្ពុទ្ធ ធ្វើនូវ* ***បណិធាន*** *យ៉ាងនេះថា៖*

> "ភន្តេ ឥមិនា ទីបបូជានុភាវេន យថា ត្វំ ទីបង្ករោ នាម ពុទ្ធោ ហុត្វា សព្វសត្តេ មោចេសិ, តថាហំ អបិ អនាគតេ សព្វសត្តេ មោចនត្ថាយ ទីបង្ករោ នាម ពុទ្ធោ ភវិស្សាមិ"។
>
> *"បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាព្រះពុទ្ធ ព្រះនាមទីបង្ករ ទ្រង់ញុំាំងសព្វសត្វ ឱ្យរួចផុតចាកទុក្ខយ៉ាងណា ដោយអានុភាពនៃការបូជាប្រទីបនេះ ក្នុងកាលទៅអនាគត សូមឱ្យខ្ញុំព្រះអង្គ បានជាព្រះពុទ្ធ ព្រះនាមទីបង្ករ ដើម្បីប្រយោជន៍ដល់ការញុំាំងសព្វសត្វ ឱ្យរួចផុតចាកទុក្ខយ៉ាងនោះដែរ"។*

ព្រះសាស្តា ព្រះនាមបុរាណទីបង្ករ ស្តាប់ពាក្យនោះហើយ ទ្រង់បញ្ជូនអនាគតំសញ្ញាណ ពិចារណាមើល ឃើញភាពសម្រេចនៃអធិការ របស់ភិក្ខុនោះ កាលទ្រង់ប្រថាប់ កណ្តាលភិក្ខុសង្ឃនោះឯង ព្យាករភិក្ខុនោះថា៖

"អយំ ភិក្ខវេ ភិក្ខុ តថាគតំ ច ភិក្ខុសំឃញ្ច បទីបបូជំ កត្វា បណិធានំ ការេតិ, សោ អនាគតេ ឥតោ កប្បសតសហស្សាធិកសោឡស-អសង្ខ្យេយ្យមត្ថកេ អហំ វិយ ទីបង្ករោ នាម សម្មាសម្ពុទ្ធោ ភវិស្សតិ"។

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ធ្វើការបូជាប្រទីបដល់ព្រះតថាគត និងភិក្ខុសង្ឃ ហើយធ្វើបណិធាន ក្នុងកាលជាអនាគត តអំពីនេះទៅ១៦ អសង្ខេយ្យ និង១សែនកប្ប ភិក្ខុនេះនឹងបានជាព្រះសម្មាសម្ពុទ្ធ ព្រះនាមទីបង្ករ ដូចតថាគតដែរ"។

ភិក្ខុនោះ បានទទួលព្យាករណ៍ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ រួចចាប់អំពីពេលនោះមក លោកតែងត្រាច់បិណ្ឌបាតប្រេងជានិច្ច ហើយធ្វើការបូជាប្រទីប ដល់ព្រះដ៏មានព្រះភាគ។

ថ្ងៃមួយ លោកត្រាច់បិណ្ឌបាតប្រេងក្នុងនគរទាំងមូល ហើយបានប្រថាប់ជិតទ្វាររាជវាំង។

គ្រានោះ រាជបុត្រី កំពុងប្រថាប់ក្នុងនិវេសន៍ លើប្រាសាទជាន់ទី៧ បានឃើញភិក្ខុដែលឈរជិតទ្វាររាជវាំង ក្នុងវិកាលក៏គិតថា **ភិក្ខុនេះ មកឈរជិតទ្វាររាជវាំងក្នុងវិកាល គង់នឹងមិនមែនមក ដើម្បីប្រយោជន៍ដល់កត្តឡើយ គឺប្រាកដជាមក ដើម្បីប្រយោជន៍ដទៃ**។

ព្រះតម្រិះរួចហើយ ព្រះនាងបញ្ជូនអ្នកបម្រើម្នាក់ ដោយប្រាប់ថា **ចូរអ្នកទៅសួរដល់ហេតុ ដែលលោកម្ចាស់និមន្តមកបិណ្ឌបាតនៅពេលនេះ**។

**ពុទ្ធបណិធាន**

*អ្នកបម្រើទៅហើយ ស្ដាប់ការនិមន្តមករបស់ភិក្ខុនោះ គឺត្រូវការបិណ្ឌ-បាតប្រេង ទើបទៅប្រាប់ព្រះរាជធីតា។*

*ព្រះរាជធីតា ស្ដាប់ពាក្យនោះហើយ ក៏បាននិមន្តព្រះថេរៈមកគង់លើអាសនៈ ថ្វាយបង្គំ ហើយយកថានមាសមួយដាក់ប្រេងគ្រាប់ស្លែពេញ ហើយដាក់លើសីសៈ ញុំាងចិត្តឱ្យកើតឡើងថា៖*

"យថា មម ភាតា សព្វសត្តហិតត្ថាយ ពុទ្ធោ ជាតោ,
តថាហំបិ អនាគតេ សព្វសត្តហិតត្ថាយ ពុទ្ធោ ភវិស្សាមិ,
មយ្ហំ ពុទ្ធភូតកាលេ 'សិទ្ធត្ថោ'តិ នាម ហោតុ"។

*"ព្រះរៀមរបស់ខ្ញុំម្ចាស់ បានជាព្រះពុទ្ធ ដើម្បីប្រយោជន៍ដល់សព្វសត្វយ៉ាងណា ខ្ញុំក៏សូមឱ្យបានជាព្រះពុទ្ធ ដើម្បីប្រយោជន៍ដល់សព្វសត្វក្នុងកាលជាអនាគតក៏យ៉ាងនោះដែរ ក្នុងកាលដែលខ្ញុំបានជាព្រះពុទ្ធ សូមឱ្យមានព្រះនាមថា* ***សិទ្ធត្ថៈ****"។*

*ព្រះនាង យាងទៅកាន់សម្នាក់ភិក្ខុនោះ ដាក់ភាជនៈប្រេងអំពីសីសៈរួចដួសប្រេងដាក់ក្នុងបាត្ររបស់ព្រះថេរៈ ហើយពោលយ៉ាងនេះថា៖*

"ភន្តេ ឥមិនា តេលទានេន មម បត្ថនា សមិជ្ឈតុំ, ឥមំ មម ភាតុនោ បូជំ ករោហិ, មម វចនេន ឯវំ វទេហិ រាជបុត្តី ភគវតោ ចានេ សិរសា វន្ទតិ, តុយ្ហំ ភគិនិ ឥមិនា សិទ្ធត្ថតេលទានេន អនាគតេ ពុទ្ធោ ភវិតុំ ឥច្ឆតិ, ពុទ្ធភូតកាលេបិ ឥមិនា សិទ្ធត្ថតេលទានេន មម នាម ហោតូតិ, ឯវំ បណិធានំ ករោតិ"។

"បពិត្រលោកម្ចាស់ ដោយការថ្វាយប្រេងនេះ សូមសេចក្តីប្រាថ្នា របស់ខ្ញុំបានសម្រេច សូមលោកម្ចាស់ នាំយកប្រេងនេះទៅធ្វើការបូជាព្រះរៀមរបស់ខ្ញុំចុះ។

សូមក្រាបទូល តាមពាក្យរបស់ខ្ញុំយ៉ាងនេះថា **ព្រះរាជបុត្រី ក្រាបថ្វាយបង្គំព្រះបាទរបស់ព្រះមានព្រះភាគ ដោយសិរសា ដោយការថ្វាយប្រេងគ្រាប់ស្ពៃនេះ ប្អូនស្រីរបស់ព្រះអង្គប្រាថ្នាឱ្យបានជាព្រះពុទ្ធ។**

**ក្នុងកាលបានជាព្រះពុទ្ធ សូមមានព្រះនាមថា សិទ្ធត្ថៈ ដោយសិទ្ធត្ថ-តេលទាន គឺការថ្វាយប្រេងគ្រាប់ស្ពៃ ហើយទូលថា ប្អូនស្រីរបស់ព្រះអង្គ ធ្វើសេចក្តីប្រាថ្នា យ៉ាងនេះ**"។

ព្រះរាជបុត្រី ទ្រង់ត្រាស់យ៉ាងនេះហើយ បានថ្វាយសារ ដល់ព្រះថេរៈ ដើម្បីថ្វាយដល់ព្រះសម្មាសម្ពុទ្ធ។

ព្រះថេរៈ ទទួលសាររបស់ព្រះរាជធីតាហើយ កាន់យកបាត្រក្រោកចាកអាសនៈនិមន្តទៅកាន់វិហារ (អារាម) របស់ព្រះសម្មាសម្ពុទ្ធបុរាណទីបង្ករ។

ក្នុងថ្ងៃនោះ ព្រះថេរៈ បានធ្វើការបូជាប្រទីបច្រើនក្រៃលែង ហើយធ្វើសេចក្តីបណិធានរបស់ខ្លួន ដែលបានប្រាថ្នាមកហើយ ថ្វាយបង្គំព្រះភគវន្ត រួចពោលយ៉ាងនេះថា៖

"បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះព្រះរាជធីតា ជាប្អូនស្រីនៃព្រះអង្គបានថ្វាយប្រេង ខ្ញុំព្រះអង្គបានធ្វើការបូជាប្រទីបមានប្រមាណប៉ុណ្ណោះ

*ដោយប្រេងនោះ។ ព្រះរាជធីតា បានតាំងប្រាថ្នាជាព្រះពុទ្ធ ដោយការថ្វាយប្រេងគ្រាប់ស្ពៃនេះ ព្រះនាងបានតាំងសេចក្ដីប្រាថ្នាយ៉ាងនេះថា ក្នុងវេលាបានជាព្រះពុទ្ធសូមឱ្យមាននាមថា* ***សិទ្ធត្ថៈ*** *ដោយការថ្វាយប្រេងគ្រាប់ស្ពៃ"។*

*ហើយព្រះថេរៈ ទូលសួរព្រះដ៏មានព្រះភាគថា៖*

*"សេចក្ដីប្រាថ្នា របស់ព្រះរាជធីតា នឹងបានសម្រេចឬទេ"?*

*ព្រះសាស្ដា ស្ដាប់ពាក្យនោះហើយ ត្រាស់នឹងភិក្ខុនោះថា៖*

*"ម្នាលភិក្ខុ ឥឡូវនេះ អនុជារបស់តថាគត ឋិតនៅក្នុងភាពជាស្រី មិនអាចទទួលពុទ្ធព្យាករណ៍ទេ"។*

*ព្រះថេរៈ សួរថា៖*

*"បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី បានជាអ្នកឋិតនៅក្នុងភាពជាស្ត្រី មិនអាចទទួលពុទ្ធព្យាករណ៍បាន"?*

*ព្រះសាស្ដា ត្រាស់តបថា៖*

*"ម្នាលភិក្ខុ ឈ្មោះថា**ពុទ្ធករណធម៌** ជាធម៌ធ្វើបានដោយក្រក្រៃលែង ត្រូវបំពេញបារមីទាំងឡាយ ហើយប្រាថ្នាភាពជាព្រះពុទ្ធ ដោយ**មនោបណិធាន**អស់វេលា៧អសង្ខេយ្យ ដោយ**វចីបណិធាន**អស់៩អសង្ខេយ្យ។ ត្រូវមានសេចក្ដីព្យាយាមមាំ ធ្វើការតាំងសេចក្ដីប្រាថ្នាមាំ ទើបអាចបំពេញលក្ខណសម្បត្តិជា**អដ្ឋធម្មសមោធាន**បាន ពោលគឺការប្រជុំព្រមនៃធម៌៨ប្រការ ប្រជុំព្រមគ្នាបានហើយ ក្នុងកាលនោះ នឹងអាចទទួលការព្យាករណ៍បាន"។*

*សួរថា* ***អដ្ឋធម្មសមោធាន*** *នោះ ជាអ្វី?*

*ឆ្លើយថា* ***អដ្ឋធម្មសមោធាន*** *នោះ ជា៖*

មនុស្សត្តំ លិង្គសម្បត្តិ, ហេតុ សត្ថារទស្សនំ;
បព្វជ្ជា គុណសម្បត្តិ, អធិការោ ច ឆន្ទតា;
អដ្ឋធម្មសមោធានា, អភិនីហារោ សមិជ្ឈតិ។

*អភិនីហារ រមែងសម្រេចបាន ព្រោះអដ្ឋធម្មសមោធាន ជាការប្រជុំព្រម នៃធម៌៨ប្រការគឺ៖*

១. ***មនុស្សត្តំ*** *ភាពជាមនុស្ស*

២. ***លិង្គសម្បត្តិ*** *ការដល់ព្រមដោយភេទជាបុរស*

៣. ***ហេតុ*** *ហេតុគឺឧបនិស្ស័យត្រូវបានព្រះអរហត្ត និង ហេតុសម្បទា ដែលបានធ្វើសេចក្ដីប្រាថ្នាដោយ មនោបណិធាន និង វចីបណិធានអំពីមុន*[២០]

៤. ***សត្ថារទស្សនំ*** *ការបានជួប បានឃើញព្រះសាស្ដាផ្ទាល់*

៥. ***បព្វជ្ជា*** *បានបួសជាបព្វជិត*

៦. ***គុណសម្បត្តិ*** *ការដល់ព្រមដោយគុណ គឺបានសមាបត្តិ៨ និង អភិញ្ញា៥*

៧. ***អធិការោ*** *ការធ្វើដ៏ក្រៃលែង គឺហ៊ានលះបង់ជីវិត ដើម្បីព្រះពុទ្ធ*

៨. ***ឆន្ទតា*** *ភាពជាអ្នកមានឆន្ទៈប្រាថ្នាព្រះសព្វញ្ញុតញ្ញាណ។*

---

[២០] ហេតូតិ មនោវចីបណិធានបុព្វិកា ហេតុសម្បទា។ **ហេតូតិ** មនោវចីបណិធាន-សិទ្ធិយា សទ្ធិំ បុព្វហេតុសម្បទា។ *(ឧបរិបណ្ណាសដីកា អនុបទវគ្គ ពហុធាតុកសុត្តវណ្ណនា, ឯកកនិបាតដីកា អដ្ឋានបាឡិ ទុតិយវគ្គវណ្ណនា, នេត្តិប្បករណដីកា បដិនិទ្ទេសវារវណ្ណនា វិចយ-ហារសម្បាតវណ្ណនា)*

**ពុទ្ធបណិធាន**

***សេចក្តីអធិប្បាយ៖***

*សេចក្តីប្រាថ្នា រមែងសម្រេចដល់បុគ្គល ដែលតាំងនៅក្នុងភាពជាមនុស្ស ហើយការប្រាថ្នាជាព្រះពុទ្ធ មិនសម្រេចដល់សត្វទាំងឡាយ ដែលតាំងនៅក្នុងជាតិជាគ្រុឌ ជានាគ ជាទេវតា ឬជាព្រហ្មឡើយ។*

*សេចក្តីប្រាថ្នា រមែងសម្រេចដល់សត្វលោក ដែលត្រូវតែជាមនុស្ស ដែលមានភេទជាបុរសប៉ុណ្ណោះ មិនមែនសម្រេចដល់ស្ត្រី ឬបណ្ឌកៈគឺខ្ទើយ ឧភតោ-ព្យញ្ជនកៈគឺមនុស្សមានភេទពីរ និង នបុំសកៈគឺមនុស្សមិនមានភេទឡើយ។*

*សេចក្តីប្រាថ្នា រមែងសម្រេចដល់បុរសនោះសោត ក៏ត្រូវជាបុរស ដែលដល់ព្រមដោយបារមី និងជា* **តិហេតុកបដិសន្ធិ** (បដិសន្ធិដោយហេតុ៣គឺ *អលោភៈ អទោសៈ អមោហៈ) ដែលអាចសម្រេចអរហត្តផល ក្នុងអត្តភាពនោះ មិនមែនសម្រេចដល់បុរសដទៃក្រៅពីនេះឡើយ។*

*បើបុរស ប្រាថ្នាក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់មានព្រះជន្មគង់នៅប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេចបាន, សេចក្តីប្រាថ្នាក្នុងសម្នាក់ព្រះមានព្រះភាគ ដែលបរិនិព្វានហើយ ក្នុងទីជិតព្រះចេតិយ ត្រង់គល់ពោធិព្រឹក្ស រមែងមិនបានសម្រេចឡើយ។*

*សេចក្តីប្រាថ្នា រមែងសម្រេចដល់បុរស ដែលប្រាថ្នាក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ត្រូវតែជាបុរស ដែលបានបួស ក្នុងពួកតាបស ជាកម្មកិរិយវាទី ឬបួសក្នុងសម្នាក់ភិក្ខុទាំងឡាយប៉ុណ្ណោះ មិនមែនសម្រេចដល់បុរស ដែលតាំងនៅក្នុងភេទគ្រហស្ថឡើយ។*

*រីអ្នកបួស ជាបុគ្គលអ្នកបួស ដែលបានគុណវិសេស មានឈានសមាបត្តិ និងអភិញ្ញាប៉ុណ្ណោះ សេចក្តីប្រាថ្នា រមែងសម្រេចដល់បុគ្គលនោះ មិនសម្រេចដល់បុគ្គលក្រៅពីនេះឡើយ។*

សូម្បីអ្នកដល់ព្រមដោយអធិការ បុគ្គលណាលះបង់ជីវិតរបស់ខ្លួនដល់ព្រះពុទ្ធទាំងឡាយបាន សេចក្ដីប្រាថ្នារបស់បុគ្គលនោះ រមែងសម្រេចដោយអធិការនេះប៉ុណ្ណោះ មិនសម្រេចដល់បុរសដទៃក្រៅនេះ ។

សូម្បីបុគ្គលដល់ព្រមដោយអភិនីហារ ក៏ត្រូវមានឆន្ទៈ (សេចក្ដីប្រាថ្នាពេញចិត្ត) វាយាមៈ (សេចក្ដីព្យាយាម) ឧស្សាហៈ (ឧស្សាហ៍ខ្មីឃ្មាត) និងបរិយេដ្ឋិ (ការស្វែងរក) ដ៏ក្រៃលែង ដើម្បីប្រយោជន៍ដល់ពុទ្ធករណធម៌ សេចក្ដីប្រាថ្នារមែងសម្រេចដល់បុរសដែលមានសភាពបែបនេះប៉ុណ្ណោះ មិនសម្រេចដល់បុរសដទៃក្រៅនេះ ។

ក្នុងរឿងនោះ មានឧឧបមា នៃភាពជាអ្នកមានឆន្ទៈធំ ដូចនេះថា ៖

បើបុគ្គលណាអាចហែលឆ្លងផ្ទៃចក្រវាលទាំងមូល ដែលមានទឹកហូរជាខ្សែតែមួយរហូតដល់ច្រាំង ដោយកម្លាំងដ៏ខ្លាំងរបស់ខ្លួន បុគ្គលនោះ រមែងបានដល់ភាពជាព្រះពុទ្ធ។

ឬថា បុគ្គលណាអាចកាយផ្ទៃចក្រវាលទាំងអស់ ដែលដេរដាសព្រោងព្រាតដោយគុម្ពឬស្សី ដែលមានបន្ទា ហើយញាំញី រួចដើរទៅដោយជើងរហូតដល់ត្រើយបាន បុគ្គលនោះ រមែងដល់ភាពជាព្រះពុទ្ធ។

ឬថា បុគ្គលណាអាចវាយប្រហារផ្ទៃចក្រវាលទាំងអស់ ដោយកាំបិត ហើយដើរនឹងជើងជាន់ផ្ទៃចក្រវាល ដែលដេរដាសដោយលំពែងមិនមានចន្លោះ ហើយទៅដល់ត្រើយបាន រមែងបានដល់ភាពជាព្រះពុទ្ធ។

ឬថា បុគ្គលណា អាចប្រើជើងជាន់ឈ្លី នូវផ្ទៃចក្រវាលទាំងមូល ដែលពេញដោយរងើកភ្លើង និងអណ្ដាតភ្លើង ហើយទៅដល់ត្រើយបាន បុគ្គលនោះ រមែងបានដល់ភាពជាព្រះពុទ្ធ។

**ពុទ្ធបណិធាន**

*បុគ្គលណា មិនសម្គាល់រឿងទាំងនេះថា ជារឿងធ្វើបានដោយក្រ សូម្បីត្រឹមតែមួយ ជាអ្នកប្រកបដោយឆន្ទៈដ៏ធំ ឧស្សាហៈដ៏ធំ និងសេចក្ដីព្យាយាមដ៏ធំថា យើងហែលឆ្លងចក្រវាលនោះទាំងអស់ ឬយើងនឹងទៅដោយជើងរហូតដល់ត្រើយ សេចក្ដីប្រាថ្នារបស់បុគ្គលរមែងសម្រេច សេចក្ដីប្រាថ្នារបស់បុគ្គលក្រៅពីនេះ មិនបានសម្រេចឡើយ។*

*ដូច្នេះហើយ ព្រះសាស្ដាត្រាស់ថា៖*

*"អនុជារបស់តថាគត ឋិតនៅក្នុងភាពជាស្ត្រីយ៉ាងនេះ រមែងមិនបានទទួលពុទ្ធព្យាករណ៍ទេ"។*

*ភិក្ខុនោះ ស្ដាប់ព្រះតម្រាស់នោះហើយ ទូលសួរព្រះភគវន្តថា៖*

*"បពិត្រព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ អនុជារបស់ព្រះអង្គនឹងបានជាព្រះពុទ្ធ ឬមិនបាន"?*

*លំដាប់នោះ ព្រះដ៏មានព្រះភាគបុរាណទីបង្ករ ពិចារណាដោយអតីតំសញ្ញាណ ជាញាណពិចារណាទៅក្នុងអតីតកាលឃើញសេចក្ដី ដែលព្រះរាជធីតា តាំងសេចក្ដីប្រាថ្នា ភាពជាព្រះពុទ្ធទុក និងដោយអំណាចនៃការតាំងសេចក្ដីប្រាថ្នាដោយចិត្តទុកក្នុង៣អត្តភាពក្នុងអតីតកាល។*

*រួចហើយ ទ្រង់ពិចារណា ដោយអនាគតំសញ្ញាណ ជាញាណពិចារណាទៅក្នុងអនាគតកាល ត្រួតមើលទៀតក៏បានឃើញ ព្រះរាជធីតានោះ អាចនឹងបំពេញពុទ្ធការកធម៌ទាំងឡាយ ក្នុងអនាគតកាលបាន។*

*ព្រះសាស្ដា ទ្រង់ឃើញហើយ ទើបត្រាស់នឹងភិក្ខុនោះថា៖*

*"ម្នាលភិក្ខុ ក្នុងអនាគត កន្លងទៅ ១៦អសង្ខេយ្យ និង១សែនកប្ប រាប់អំពីកប្បនេះទៅ អ្នកនឹងត្រាស់ដឹងជាព្រះពុទ្ធព្រះនាមថា**ទីបង្ករ** ដូចតថាគត*

ដែរ ក្នុងកាលនោះអ្នកនឹងព្យាករប្អូនស្រីរបស់តថាគត ប្អូនស្រីរបស់តថាគត នឹងបានទទួលព្យាករណ៍ ក្នុងសម្នាក់របស់អ្នក”។

កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រះថេរៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ក្រោកចាកអាសនៈ ធ្វើប្រទក្សិណ ហើយចូលទៅរកព្រះរាជធីតាសុមិត្តាដល់ក្នុងព្រះរាជវាំង ហើយពោលរឿងទាំងអស់ ដែលព្រះអង្គបានស្តាប់បន្ទូលរបស់ព្រះដ៏មានព្រះភាគ ដល់ព្រះនាង។

ព្រះរាជធីតា ស្តាប់រឿងនោះហើយ ទ្រង់កើតបីតិសោមនស្ស ជាពន់ពេករួចពោលនឹងភិក្ខុនោះថា៖

“បពិត្រលោកម្ចាស់ដ៏ចម្រើន តាំងតែពីពេលនេះតទៅ លោកម្ចាស់មិនបាច់និមន្តទៅកាន់សម្នាក់អ្នកដទៃទេ សូមលោកម្ចាស់មេត្តាទទួលប្រេងក្នុងសម្នាក់ របស់ខ្ញុំព្រះករុណាតែប៉ុណ្ណោះ”។

ដូច្នេះហើយ ព្រះរាជធីតា បវារណាដោយនិច្ចបវារណា។

ចាប់តាំងអំពីពេលនោះមក ព្រះថេរៈទទួលប្រេងគ្រាប់ស្ពៃក្នុងសម្នាក់ព្រះរាជធីតា នាំយកទៅធ្វើការបូជាដោយប្រទីបដល់ព្រះពុទ្ធ និងព្រះសង្ឃក្នុងព្រះវិហារ។

រៀងរាល់ព្រឹក ព្រះរាជបុត្រីក៏បានឱ្យគេកាន់យកនូវខាទនីយៈ ភោជនីយៈដ៏ប្រណីតយ៉ាងច្រើន និងផ្កាកម្រង គ្រឿងក្រអូបព្រមទាំងបរិក្ខារផ្សេងៗ ជាដើម ទៅកាន់ព្រះវិហារជាមួយនឹងបរិវារ និងញុំាងភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន បានបរិបូរណ៍គ្រប់ៗកាល។

**ពុទ្ធបណិធាន**

*ចាប់អំពីពេលនោះមក ព្រះនាងមានសេចក្តីនឿយណាយក្នុងភាពជាស្ត្រី បានឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម និងប្រព្រឹត្តព្រហ្មចរិយធម៌ដ៏ប្រពៃ។*

*ព្រះនាងធ្វើកុសលកម្មយ៉ាងនេះ រហូតដល់អស់ជីវិត។ កាលអស់អាយុជីវិតហើយ ព្រះនាងបានទៅកើតក្នុងទេវលោក។*

*ការពណ៌នាក្នុងបាទគាថាថា* **រាជបុត្តី សិទ្ធត្ថតេលមទាសិ** *នេះ ចប់ដោយបរិបូណ៌ ត្រឹមតែប៉ុណ្ណោះ។*

# ជំពូកទី២:
# មនោបណិធាន មាន ៧ អសង្ខេយ្យ ឈ្មោះថា
# មហានិទាន

## មានមួយនិទានកថា

## រឿងព្រះបាទអតិទេវ:

## សេចក្ដីប្រាថ្នាជាព្រះពុទ្ធក្នុងចិត្តលើកទី ១
## ចំពោះព្រះភក្ត្ររបស់
## ព្រះសម្មាសម្ពុទ្ធព្រហ្មទេវ:



ក្នុងកំណើតជា ព្រះបាទអតិទេវៈ
គឺជាសេចក្តីប្រាថ្នាជាព្រះពុទ្ធខាងក្នុងចិត្តលើកទី ១
ចំពោះព្រះភក្ត្ររបស់ ព្រះសម្មាសម្ពុទ្ធ ព្រះនាមព្រហ្មទេវៈ

## សត្តាសង្ខ្យេយ្យកថា

*ឥឡូវនេះ កាលផ្តើមពណ៌នា* ***មហានិទានកថា*** *លោកបានពោលពាក្យនេះថា៖*

"ចិន្តិតំ សត្តាសង្ខ្យេយ្យំ, វាចិកំ នវាសង្ខ្យេយ្យំ;
សតសហស្សាធិកានិ, ចត្តារិ អសង្ខ្យេយ្យានិ។
កាយវាចាមនសាហិ, បូរេត្វាន វ ចារមី;
សព្វាចារមី បូរេត្វា, ពុទ្ធត្តំ សមុបាគមិ"។

*"ព្រះពោធិសត្វចូលដល់ភាពជាព្រះពុទ្ធ ដែលត្រូវប្រាថ្នាដោយចិត្ត ៧ អសង្ខ្យេយ្យ, ប្រាថ្នាដោយវាចា ៩ អសង្ខ្យេយ្យ, បំពេញបារមីទាំងពួង ៤ អសង្ខ្យេយ្យ ក្រៃលែងដោយសែនកប្ប ដោយការប្រើកាយ វាចា និងចិត្តប្រាថ្នា"។*

*បណ្តាអសង្ខ្យេយ្យទាំងនោះ ឈ្មោះថា៧អសង្ខ្យេយ្យ ដែលព្រះពោធិសត្វចូលដល់ភាពជាព្រះពុទ្ធ ដោយការប្រើចិត្តប្រាថ្នា ជាយ៉ាងណា?*

*៧អសង្ខ្យេយ្យ នោះ គឺ៖*

"នន្ទោ សុនន្ទោ បឋវី, មណ្ឌោ ធរណី សាគរោ;
បុណ្ឌរីកោតិ ឥមេ សត្ត, អសង្ខ្យេយ្យា បកាសិតា"។

*"អសង្ខ្យេយ្យទាំង៧នេះ លោកបានប្រកាសទុកថា នន្ទអសង្ខ្យេយ្យ១ សុនន្ទអសង្ខ្យេយ្យ១ បឋវីអសង្ខ្យេយ្យ១ មណ្ឌអសង្ខ្យេយ្យ១ ធរណីអសង្ខ្យេយ្យ១ សាគរអសង្ខ្យេយ្យ១ បុណ្ឌរីកអសង្ខ្យេយ្យ១"។*

*បណ្តាពាក្យទាំងនោះ ពាក្យថា នន្ទោ បានដល់ ឈ្មោះថា នន្ទអសង្ខ្យេយ្យ ជាអសង្ខ្យេយ្យខាងដើម នៃអសង្ខ្យេយ្យទាំង៧ នោះ។*

## អតិទេវរាជវត្ថុ
## រឿង ព្រះបាទអតិទេវ

*ក្នុងកាលនោះ ព្រះពោធិសត្វ ផុតចាកភាពជាស្ត្រី ព្រោះវិបាក ជាគ្រឿងហូរចេញពីការថ្វាយប្រេងគ្រាប់ស្ពៃ ហើយបានកើតជាទេវបុត្រ មានឫទ្ធិ និងអានុភាពច្រើន ក្នុងទេវលោកជាន់តុសិត ដែលមានអាយុ៥៧កោដិ ៦លានឆ្នាំ។*

*ព្រះអង្គតាំងនៅក្នុងទេវលោក ជាន់តុសិត ដរាបដល់អស់អាយុ ហើយវិលវល់ស្លាប់កើតក្នុងទេវលោក និងមនុស្សលោក ក្នុងកប្បមួយ ដែលមានឈ្មោះថា**សារៈ** ក្នុងអសង្ខេយ្យ ដែលមានឈ្មោះថា**នន្ទៈ** លោកចុតិចាកទេវលោក ហើយកើតក្នុងរាជត្រកូល ក្នុងនគរ ដែលមានឈ្មោះថា**ករកណ្ណៈ**។*

*កាលរាជព្រះរាជបិតា កន្លងផុតទៅ ព្រះពោធិសត្វ ក៏បានទទួលរាជាភិសេកជាព្រះរាជា មានព្រះនាមថា**អតិទេវៈ** ឬអតិទេព ទ្រង់សោយរាជ្យប្រកបដោយធម៌។*

*ព្រះបាទអតិទេវៈ ដែលបុរោហិតឱ្យសិក្សាហើយ ទ្រង់គ្រប់គ្រងរាជ្យដោយការបំពេញនូវ**ចក្កវត្តិវត្ត**[២១]។*

---

[២១](ន.)(បា.សំ.)*វត្ត ដែលស្តេចចក្រពត្តិត្រូវប្រព្រឹត្ត ហៅថា ចក្កវត្តិវត្ត* មាន ១០ ឬ ១២ គឺ៖

| | |
|---|---|
| ១. អន្តោជនស្មឹ ពលកាយេបិ | *វត្តបដិបត្តិ ចំពោះជនខាងក្នុង គឺបុត្រភរិយា និងចំពោះពួកពល* |
| ២. ខត្តិយេសុ | *វត្តបដិបត្តិចំពោះពួកក្សត្រិយ៍ចំណុះ* |
| ៣. អនុយន្តេសុ | *វត្តបដិបត្តិចំពោះពួកជនចុះចូល* |
| ៤. ព្រាហ្មណគហបតិកេសុ | *វត្តបដិបត្តិ ចំពោះពួកព្រាហ្មណ៍ និងគហបតី* |
| ៥. នេគមជានបទេសុ | *វត្តបដិបត្តិចំពោះពួកអ្នកនិគម និងអ្នកជនបទ* |
| ៦. សមណព្រាហ្មណេសុ | *វត្តបដិបត្តិចំពោះពួកសមណៈ និងព្រាហ្មណ៍* |

*គ្រានោះ ព្រះមេត្តេយ្យពោធិសត្វ គឺព្រះសិអារ្យមេត្រី កើតជាអាមាត្យធំឈ្មោះ**សិរិគុត្ត** ជាអ្នកប្រៀនប្រដៅអត្ថ និងធម៌របស់ព្រះបាទអតិទេវៈ។*

*ក្នុងកាលនោះ ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះនាមថា**ព្រហ្មទេវៈ**[២២] ស្ដេចឧប្បត្តិកើតឡើងក្នុងកប្ប ដែលមានឈ្មោះថា**សារៈ** ក្នុង**នន្ទអសង្ខេយ្យ**នោះ។*

*ព្រះសម្មាសម្ពុទ្ធព្រហ្មទេវៈអង្គនោះ ស្ដេចយាងទៅកាន់ស្ថានទីប្រកាស**ធម្មចក្កប្បវត្តនសូត្រ**[២៣] ដែលព្រះពុទ្ធគ្រប់ព្រះអង្គ មិនលះបង់ ក្នុងទីជិត**ករកណ្ឌនគរ** ដើម្បីប្រកាសធម្មចក្កប្បវត្តនសូត្រ។*

*ព្រះរស្មីនៃសរីរៈរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ផ្សាយទៅទូទាំងករកណ្ឌនគរ ប្រាកដដូចជាព្រះសុរិយា១,០០០ដួង។*

*ខណៈ ដែលព្រះរាជាអតិទេវៈ ប្រថាប់លើរាជបល្ល័ង្ក ក្នុងផ្ទៃប្រាសាទជាន់លើ សិរិគុត្តមហាមាត្យ អង្គុយខាងមុខព្រះរាជា។*

---

| | |
|---|---|
| ៧. មិគបក្ខីសុ | *វត្តបដិបត្តិចំពោះពួកម្រឹគ និងបក្សី* |
| ៨. អធម្មការប្បដិក្ខេបោ | *ការហាមប្រព្រឹត្តអំពើអធម៌* |
| ៩. អធនានំ ធនានុប្បទានំ | *ការឱ្យទានដល់អ្នកមិនមានទ្រព្យ* |

១០. សមណព្រាហ្មណោ ឧបសង្កមិត្វា បញ្ហាបុច្ឆនំ *ការចូលទៅរកសមណព្រាហ្មណ៍សួរបញ្ហា។*

*(សុមង្គលវិលាសិនី ចក្កវត្តិសុត្តវណ្ណនា, មនោរថបូរណី ទុតិយចក្កានុវត្តនសុត្តវណ្ណនា)*

[២២] (ន.)(បា.សំ.) *ព្រះពុទ្ធព្រះនាមព្រហ្មទេវៈ ឃើញមានជួបក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថេរិយាបទានថាៈ*

ព្រហ្មទេវញ្ច សម្ពុទ្ធំ,        គោតមំ លោកនាយកំ;
អញ្ញេសំ លោកនាថានំ,        សង្គមំ តេ ពហុំ មយា។

*ខ្ញុំមានការគប់រកព្រះលោកនាថទាំងឡាយ ដទៃច្រើនអង្គ ព្រោះអាស្រ័យនូវព្រះសម្ពុទ្ធព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធ ព្រះនាមគោតម ដែលជាព្រះលោកនាយក។*

[២៣] **ធម្មចក្កប្បវត្តនសូត្រ** (ធ័ម-មៈច័ក-ក័បប៉ៈវ៉ត-តៈន៉ៈសូត) ន. (បា.--*សុត្ត; សំ. ធម៌ចក្រប្រវត៌នសូត្រ) ឈ្មោះសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម្មចក្ក។*

**ពុទ្ធបណិធាន**

*ព្រះរាជា ឃើញពន្លឺសរីរៈ ដែលជះមកខាងមុខនគរ ទ្រង់មិនជ្រាបថាជាទេវតា ឬជាមនុស្ស ក៏មានការភ័យខ្លាច កាយញាប់ញ័រ ប្រាថ្នានឹងធ្លាក់ចាកសីហាសនៈ។*

*គ្រានោះ សិរិគុត្តមហាមាត្យ ឃើញអាការៈរបស់ព្រះរាជាហើយ កាលសម្លឹងមើលតាម**សីហបញ្ជរ**[២២] ក៏បានឃើញព្រះតថាគតដែលញ៉ាំងនគរឱ្យភ្លឺរុងរឿង ទ្រង់មានសិរីប្រដាប់ដោយ**មហាបុរិសលក្ខណៈ**ទាំង៣២[២៣] និងបរិបូណ៌ដោយ**អនុព្យញ្ជនៈ៨០**[២៤] ទ្រង់មានសរីរកាយទាំងអស់រុងរឿង ដូចជាបុគ្គលប្រើជារទឹកមាស ស្រោចស្រពក្នុងទីទាំងឡាយ មាននគរ ផ្ទះប្រាសាទ កូដាគារខ្លោងទ្វារកំពែង អារាម និងឧទ្យាន ជាដើម។*

*សិរិគុត្តអាមាត្យឃើញហើយ ដឹងថាជាព្រះពុទ្ធ ព្រោះខ្លួនធ្លាប់ឃើញព្រះពុទ្ធទាំងឡាយ ច្រើនរយមកហើយអំពីកាលមុន និងព្រោះខ្លួនធ្លាប់ធ្វើបណិធានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ ជាច្រើនមកហើយ។*

*គ្រាដឹងយ៉ាងនេះហើយ សិរិគុត្តអាមាត្យ ក៏ពោលនឹងព្រះរាជាថា៖*

---

[២២]***សីហបញ្ជរ*** (ព. ប្រ.) *បង្អួចរបស់លោកអ្នកមានអានុភាពដូចសីហៈ គឺបង្អួចដំណាក់ឬប្រាសាទរបស់ក្សត្រិយ៍ទ្រង់ពជ្យ : ព្រះរាជាទ្រង់ប្រថាប់ក្បែរសីហបញ្ជរ។ ឬ បង្អួចមានរង្វង់ដូចជាទ្រង់ជំហរសីហៈ ។*

[២៣](ន.)(បា.សំ.) *លក្ខណៈ៣២យ៉ាង លើរូបកាយនៃមហាបុរស គឺបុរសអស្ចារ្យក្នុងលោក មានទំនាយថា បើនៅជាគ្រហស្ថ នឹងបានជាស្ដេចចក្រពត្តិ បើចេញទៅបួសនឹងបានត្រាស់ជាព្រះពុទ្ធ (មហាបុរិសលក្ខណៈទាំង៣២យ៉ាងនោះ មាននិយាយក្នុងលក្ខណសូត្រ និងព្រហ្មាយុសូត្រ ខាងព្រះសុត្តន្តបិដក ព្រះពុទ្ធសាសនា)។*

[២៤](ន.)(បា.សំ.)*លក្ខណៈតូចៗ ឬលក្ខណៈរាយរង នៃអវយវៈនាសព៌ាង្គកាយ របស់មហាបុរស គឺព្រះសព្វញ្ញុពុទ្ធ និងចក្កវត្តិរាជ។*

"បពិត្រមហារាជ សូមព្រះអង្គកុំភ័យ អ្នកដែលមកនោះមិនមែនសត្វដទៃទេ នោះជាព្រះសព្វញ្ញូសម្មាសម្ពុទ្ធ"។

សិរិគុត្តអាមាត្យ ក្រាបទូលហើយ កាលនឹងប្រកាសពុទ្ធគុណដល់ព្រះរាជានោះ ទើបលាដៃស្តាំ ពោលគាថាទាំងឡាយនេះថា៖

"ឯស ពុទ្ធោ មហារាជ, លោកេ ឧត្តមបុគ្គលោ;
សព្វលោកហិតត្ថាយ, លោកេ ឧប្បជ្ជិ សោ ជិនោ។
អរហំ សុគតោ លោកេ, ភគវា លោកចារគូ;
វិជ្ជាចរណសម្បន្នោ, វិមុត្តិ បរិនាយកោ។
ជេដ្ឋោ សម្មាភិសម្ពុទ្ធោ, សេដ្ឋោ បុរិសសារថិ;
សត្ថា ទេវមនុស្សានំ, ពុទ្ធោ អប្បដិបុគ្គលោ។
សព្វលោកហិតោ ពន្ធុ, សទ្ធម្មរតនាលយោ;
សត្តានមនុកម្បាយ, ជាតោ ជាថោ ទីបង្ករោ។
ចក្ខុនិជ្ជេសុ កុសលោ, ធម្មស្សាមិ តថាគតោ;
មច្ចុទេយ្យវិមោក្ខាយ, ធម្មំ ទេសេសិ ចក្ខុមា។
ទេសេសិ សព្វចាណិនំ, ទយាបន្នោ មហាមុនិ;
ធម្មាលោកំ បកាសេតិ, ចក្ខុមន្តានំ ឧត្តមោ"។

"បពិត្រមហារាជ អ្នកដែលមកនោះ ជាព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរក្នុងលោក ព្រះជិនស្រីអង្គនោះ ឧប្បត្តិឡើងក្នុងលោក ដើម្បីប្រយោជន៍ និងក្តីចម្រើន ដល់សត្វលោកទាំងពួង។

ព្រះអង្គ ជាព្រះអរហន្ត ទ្រង់មានដំណើរល្អ ជាព្រះភគវា ទ្រង់ដល់ត្រើយនៃលោក ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាអ្នករួចផុត ទ្រង់ជាបរិនាយក ។

ព្រះអង្គជាចម្បង ជាសម្មាភិសម្ពុទ្ធ ទ្រង់ប្រសើរ ជាអ្នកទូន្មាននូវបុរស ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ជាអ្នកត្រាស់ដឹង ទ្រង់មិនមានបុគ្គលប្រៀបស្មើ។

ព្រះអង្គ ជាអ្នកធ្វើប្រយោជន៍ដល់សត្វលោកទាំងពួង, ទ្រង់ជាផៅពង្ស

ព្រះអង្គ ជាទីអាស្រ័យនៃរតនៈគឺព្រះសទ្ធម្ម ទ្រង់កើតឡើង ដើម្បី

អនុគ្រោះសត្វទាំងឡាយ ទ្រង់ជាទីពឹង ជាអ្នកធ្វើនូវទីពឹង។

ព្រះអង្គ ជាអ្នកឈ្វាសក្នុងធម៌ ដែលឃើញដោយចក្ខុ ជាព្រះធម្មស្សាមី

ជាព្រះតថាគត ជាអ្នកមានចក្ខុ ទ្រង់សម្តែងធម៌ ដើម្បីសេចក្តីរួចផុត ចាក

សេចក្តីស្លាប់។

ព្រះអង្គ សម្តែងធម៌ដល់សព្វសត្វ ជាព្រះមហាមុនី ទ្រង់មានសេចក្តី

ករុណា ទ្រង់ប្រកាសពន្លឺ គឺព្រះធម៌ ទ្រង់ជាអ្នកប្រសើរ នៃអ្នកមានចក្ខុ

ទាំងឡាយ"។

អាមាត្យឈ្មោះសិរិគុត្ត ពណ៌នាគុណព្រះតថាគត យ៉ាងនេះហើយ កាលនឹងសម្តែងព្រះនាម របស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ទើបពោលយ៉ាងនេះទៀតថា៖

"អយញ្ច ខោ មហារាជ, ព្រហ្មទេវោ តថាគតោ;
កាសេន្តោ វីថិយា មជ្ឈេ, បស្សថេតំ បុនប្បុនំ"។

"បពិត្រមហារាជ ព្រះតថាគត ដែលរុងរឿងនៅកណ្តាលវិថីនេះ មាន

ព្រះនាមថាព្រហ្មទេវៈ សូមព្រះអង្គ ទតមើលព្រះតថាគតនោះ ឱ្យ

រឿយៗចុះ"។

ក្នុងរវាងចន្លោះពាក្យ របស់សិរិគុត្តអាមាត្យនោះឯង ព្រះតថាគត ក៏យាង មកដល់ដោយលំដាប់។

*សិរិគុត្តអាមាត្យ ឃើញព្រះតថាគត យាងមកដល់ហើយ ក៏ក្រាបទូលពាក្យនេះ នឹងព្រះរាជាទៀតថាៈ*

*"បពិត្រមហារាជ សូមស្ដេចក្រោកឡើងចាកអាសនៈ ចូរព្រះអង្គ ធ្វើការទទួលដំណើរព្រះតថាគត"។*

*សួរថា ព្រោះហេតុអ្វី?*

*ឆ្លើយថា ព្រោះថាៈ*

សតំ ហត្ថី សតំ អស្សា, សតំ អស្សតរីរថា;

សតំ កញ្ញាសហស្សានិ, អាមុក្កមណិកុណ្ឌលា;

ឯកស្ស បទវីតិហារស្ស, កលំ នាគ្ឃន្តិ សោឡសឹ។

*ដំរីមួយរយ សេះមួយរយ រថទឹម ដោយសេះអស្សតរមួយរយ នាងកញ្ញាពាក់កុណ្ឌល ជាវិការៈនៃកែវមណីមួយពាន់នាក់ ក៏មិនដល់ថ្លៃមួយចំណិតនៃជំហានមួយ ដែលគេចែកឱ្យ ជាចំណែកដប់ប្រាំមួយៗដងឡើយ[២៧]។*

*គាថាទាំងឡាយនេះ ព្រះមេត្តេយ្យពោធិសត្វ ឈ្មោះសិរិគុត្តបានពោលទុក ក្នុងពេលដែលព្រះតថាគត ព្រហ្មទេវៈស្ដេចឧប្បត្តិឡើង។*

*ព្រះរាជា ស្ដាប់ពាក្យនោះហើយ ទ្រង់ប្រញាប់ក្រោកឡើង មិនអាចកំណត់ស្ថានទីទាំងឡាយ មានទ្វារ និងជណ្ដើរជាដើម ព្រោះកើតបីតិ ដែលមានប្រភេទ៥ ធ្វើឱ្យព្រះអង្គ ធ្លាក់ចុះតាមបង្អួច ដែលមានរាងដូចសីហៈ។*

*ដោយអានុភាពនៃសទ្ធា របស់ព្រះរាជានោះ ផ្កាឈូកធំប្រមាណប៉ុនកង់រទេះពណ៌ស ផុសឡើងទទួលព្រះរាជា។*

---

[២៧] *សំយុត្តនិកាយ សគាថវគ្គ បិដកលេខ ៣០ ទំព័រ ២២៣។*

**ពុទ្ធបណិធាន**

ព្រះរាជាចុះចាកផ្កាឈូក យាងដោយព្រះបាទ ទៅសម្នាក់ព្រះតថាគត ទ្រង់បូជាដោយផ្កាម្ទិះ និងទ្រង់ថ្វាយឧបករណ៍ទាន សូម្បីដទៃ ទ្រង់ថ្វាយបង្គំព្រះមានព្រះភាគ ដោយបញ្ចង្គប្រតិស្ឋាន ហើយទ្រង់ធ្វើ**ចេតោបណិធាន** យ៉ាងនេះថា៖

"យថា ច ត្វមបិ ជាថ, ពុទ្ធោ ពោធេសិ ចាណិនំ;
តថេវាហំ ពុទ្ធោ លោកេ, ពោធយិស្សាមិ ចាណិនំ។
យថា ច ត្វមបិ ជាថ, មុត្តោ មោចេសិ ចាណិនំ;
តថាហំ មុត្តោ សំសារា, មោចយិស្សាមិ ចាណិនំ។
យថា ច ត្វមបិ ជាថ, តិណ្ណោ តារេសិ ចាណិនំ;
តថេវ តិណ្ណោ សំសារា, តារយិស្សាមិ ចាណិនំ"។

"បពិត្រព្រះលោកនាថ ដូចយ៉ាងថា ព្រះអង្គទ្រង់ត្រាស់ដឹងហើយ ទ្រង់ញុំាងសត្វទាំងឡាយ ឱ្យត្រាស់ដឹងផងយ៉ាងណា ខ្ញុំព្រះអង្គត្រាស់ដឹងក្នុងលោក នឹងញុំាងសត្វទាំងឡាយ ឱ្យត្រាស់ដឹងក៏យ៉ាងនោះដែរ។

បពិត្រព្រះលោកនាថ ដូចយ៉ាងថា ព្រះអង្គរួចផុតហើយ ទ្រង់ញុំាងសត្វទាំងឡាយ ឱ្យរួចផុតផងយ៉ាងណា ខ្ញុំព្រះអង្គ រួចផុតចាកសំសារវដ្តហើយ នឹងញុំាងសត្វទាំងឡាយឱ្យរួចផុត ក៏យ៉ាងនោះដែរ។

បពិត្រព្រះលោកនាថ ដូចយ៉ាងថា ព្រះអង្គឆ្លងផុតហើយ ទ្រង់ញុំាងសត្វទាំងឡាយ ឱ្យឆ្លងផុតផងយ៉ាងណា ខ្ញុំព្រះអង្គ ឆ្លងផុតចាកសំសារវដ្តហើយ នឹងញុំាងសត្វទាំងឡាយឱ្យឆ្លងផុត ក៏យ៉ាងនោះដែរ"។

ព្រះរាជា គ្រាញុំាងចិត្តឱ្យកើតឡើងយ៉ាងនេះហើយ ក្នុងខណៈនោះ

ទ្រង់ជាអ្នកមានព្រះទ័យត្រេកអរ ដោយធម្មកថារបស់ព្រះមានព្រះភាគ ស្ដេចក្រោកចាកអាសនៈ ធ្វើប្រទក្សិណព្រះមានព្រះភាគ ហើយយាងចូលទៅក្នុងរាជបុរី។

ចាប់តាំងពីពេលនោះមក ព្រះរាជាតែងឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ជាអ្នកត្រេកអរសេពក្នុងកុសលធម៌ ហើយទ្រង់ធ្វើ**ចិត្តបណិធាន**រឿយៗ។

ចំណែកព្រះតថាគត ព្រហ្មទេវៈ ទ្រង់ធ្វើពុទ្ធកិច្ចទាំងអស់ហើយ ទ្រង់ក៏បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ។

សូម្បីក្នុង**នន្ទអសង្ខេយ្យ**នោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយដទៃ **៤,៩៩៩**[២៨] ព្រះអង្គកើតឡើង ។ ព្រះពោធិសត្វរបស់យើងទាំងឡាយ និងព្រះនាងយសោធរា ជាអ្នកមានឆន្ទៈស្មើគ្នា មានសេចក្ដីពេញចិត្តដូចគ្នា (ដែលកើតហើយៗក្នុងសម័យកាលព្រះពុទ្ធទាំងនោះ) បានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ**មនោបណិធាន**។

តេន វុត្តំ អបទានេ– ព្រោះហេតុនោះ ទើបព្រះនាងពោលទុកអបទានថាៈ

ព្រហ្មទេវញ្ច សម្ពុទ្ធំ, គោតមំ លោកនាយកំ;
អញ្ញេសំ លោកនាថានំ, សង្គមំ តេ ពហុំ មយា។

ខ្ញុំមានការគប់រកព្រះលោកនាថទាំងឡាយ ដទៃច្រើនអង្គ (ព្រោះអាស្រ័យ) នូវព្រះសម្ពុទ្ធ ព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធព្រះនាមគោតម ដែលជាព្រះលោកនាយក។

(យសោធរាថេរីយាបទាន បិដកលេខ ៧៦ ទំព័រ ១៧៩ តែមានការប្រែផ្សេង)

---

[២៨]**ព្រះពុទ្ធដទៃ ៤,៩៩៩ អង្គ**នេះ ដោយវៀរព្រះពុទ្ធព្រហ្មទេវៈ បើរាប់ទាំងព្រះ**ពុទ្ធព្រហ្មទេវៈ**ផងក្នុង**នន្ទអសង្ខេយ្យ** មានព្រះពុទ្ធ **៥,០០០** អង្គ។

**ពុទ្ធបណិធាន**

ព្រហ្មទេវញ្ច សម្ពុទ្ធំ, គោតមំ លោកនាយកំ;
អញ្ញេសំ លោកនាថានំ, សង្ខ្យា តេហិ នោ ពហូ។

*ការគប់រកនៃព្រះលោកនាថទាំងឡាយដទៃច្រើន (ព្រោះអាស្រ័យ) ព្រះសម្ពុទ្ធព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធព្រះនាមគោតម ដែលជាព្រះលោកនាយក យើងខ្ញុំ (បានសម្តែងហើយ) ។*

*(យសោធរាបមុខអដ្ឋារសភិក្ខុនីសហស្សអបទាន បិដកលេខ ៧៦ ទំព័រ ១៩៧ តែមានការប្រែផ្សេង)*

*កាលនន្ទអសង្ខេយ្យកន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា**សុនន្ទៈ**។*

*ក្នុងសុនន្ទអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ៩,០០០ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា (ដែលកើតហើយៗ ក្នុងសម័យកាលព្រះពុទ្ធទាំងនោះ) បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ(ត្រឹមតែ)**មនោបណិធាន**(ប៉ុណ្ណោះ)។*

*កាលសុនន្ទអសង្ខេយ្យកន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា **បឋវី-អសង្ខេយ្យ** ឬ **បថវីអសង្ខេយ្យ**។*

*ក្នុងបឋវីអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ១០,០០០ ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ**មនោបណិធាន**។*

*កាលបឋវីអសង្ខេយ្យ កន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា**មណ្ឌ-អសង្ខេយ្យ**។*

*ក្នុងមណ្ឌអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ១១,០០០ ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ**មនោបណិធាន**។*

*កាលមណ្ឌអសង្ខេយ្យ កន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា* ***ធរណីអសង្ខេយ្យ។***

*ក្នុងធរណីអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ២០,០០០ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ*មនោបណិធាន។

*កាលធរណីអសង្ខេយ្យ កន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា* ***សាគរអសង្ខេយ្យ។***

*ក្នុងសាគរអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ៣០,០០០ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ*មនោបណិធាន។

*កាលសាគរអសង្ខេយ្យ កន្លងផុតទៅ មានអសង្ខេយ្យដទៃឈ្មោះថា* ***បុណ្ឌរិកអសង្ខេយ្យ។***

*ក្នុងបុណ្ឌរិកអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធទាំងឡាយ៤០,០០០ព្រះអង្គកើតឡើង។ ព្រះពោធិសត្វនិងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបានធ្វើ*មនោបណិធាន។

*ព្រះសម្មាសម្ពុទ្ធទាំងឡាយ ១២៥,០០០ព្រះអង្គ ស្តេចឧប្បត្តិឡើង ក្នុង៧អសង្ខេយ្យនេះ ដោយប្រការដូច្នេះ។*

*ព្រះពោធិសត្វនិងព្រះនាងយសោធរា (ដែលកើតហើយៗ ក្នុងសម័យកាលព្រះពុទ្ធទាំងនោះ) បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ ១២៥,០០០ព្រះអង្គនោះ ហើយបានធ្វើ(ត្រឹមតែ)*មនោបណិធាន*(ប៉ុណ្ណោះ)។*

**ពុទ្ធបណិធាន**

*នេះឈ្មោះថា៧អសង្ខេយ្យ ដែលជាសេចក្តីប្រាថ្នាដោយចិត្ត។*

*ព្រោះហេតុនោះ ទើបលោកពោលទុកថា៖*

នន្ទោ សុនន្ទោ បឋវី, មណ្ឌោ ធរណី សាគរោ;
បុណ្ឌរីកោ ឥមេ សត្ត, អសង្ខេយ្យា បកាសិតា;
មនសា បត្ថនា មយ្ហំ, និទ្ទិដ្ឋាសង្ខ្យេយ្យា ឥមេ។
តម្ហិ នន្ទេ អសង្ខ្យេយ្យេ, នគរេ ការកញ្ចកោ;
អតិទេវោ នាម នាមេន, រាជា អាសឹ មហព្វលោ។
អហំ តេន សមយេន, ចាសាទស្ស បរេ ឋិតោ;
សិរិគុត្តោ នាម អមច្ចោ, និសិន្នោ បុរតោ មម;
ឧក្ខិបិត្វា ទក្ខិណាពាហុ, ទស្សេសិ លោកនាយកំ។
អយញ្ច ខោ មហារាជ, ព្រហ្មទេវោ តថាគតោ;
ភាសេន្តោ វីជិយា មគ្គេ, បស្សថេតំ បុនប្បុនំ។
តត្ថ បត្វា វិចិន្តេសិ, សុត្វា នច្ចស្សភាសិតំ;
ពុទ្ធោ ពុទ្ធោតិ ចិន្តេន្តោ, តំ តំ ពុទ្ធាវ លោកយឹ។
និស្វានាហំ ព្រហ្មពុទ្ធំ, បញ្ចវន្តំ ជុតិន្ធរំ;
ចាសាទា ចាតយិត្វាន, អត្តានំ បឋវី តលេ។
មម សទ្ធានុភាវេន, តិដ្ឋាមិ បទ្មមត្ថកោ;
តតោហំ ឱតរិត្វាន, អគមំ យេន ចក្ខុមា។
បូជេសឹ ជាតិបុប្ផេហិ, តេជវន្តំ មហាយសំ;
ការេត្វា តីណិ បុច្ឆានិ, តំ មាលម្បិស្ស បូជយឹ។
សត្ថុរតនចុណ្ណេហិ, បូជយិត្វា តថាគតំ;
អភិវន្ទឹ ព្រហ្មទេវំ, **បឋមំ បត្ថនា មម។**

តម្ហិ នន្ទេ អសង្ខ្យេយ្យេ, អជិការំ អហំ ការិ;
បញ្ចពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
សុនន្ទម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
នវពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
បបរិម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
ទសពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
តម្ហិ មណ្ឌេ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
ឯកាទសសហស្សានំ, មហាទានំ បវត្តយឹ។
ធរណិម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
វីសពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
សាគរម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
តឹសពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
បុណ្ឌរីកម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ ការឹ;
ចត្តាលីសសហស្សានំ, ពុទ្ធានំ បវត្តយឹ។
ឯត្តកានំ មហេសីនំ, មនសា បត្ថនា មយ្ហំ;
ទានេន មេ សមោ នត្ថិ, ឯសា មេ ទានំ ចារមី។
សតសហស្សានិ ចេវ, វីសតិសហស្សានិ ច;
អថោ បញ្ចសហស្សានិ, សព្វពុទ្ធា ហិ បណ្ឌិតា។

*អសង្ខេយ្យទាំង៧នេះ លោកបានប្រកាសទុកថា នន្ទអសង្ខ្យេយ្យ១ សុនន្ទអសង្ខេយ្យ១ បបរីអសង្ខេយ្យ១ មណ្ឌអសង្ខេយ្យ១ ធរណីអសង្ខេយ្យ១ សាគរអសង្ខេយ្យ១ បុណ្ឌរីកអសង្ខេយ្យ១។*

**ពុទ្ធបណិធាន**

*អសង្ខេយ្យទាំង៧នេះ ត្រូវបានលើកសម្តែង ពីសេចក្តីប្រាថ្នាដោយចិត្ត របស់តថាគត។*

*ក្នុងនន្ទអសង្ខេយ្យនោះ ព្រះរាជា ព្រះនាមថាអតិទេវៈ ទ្រង់មានពលានុភាពច្រើន សោយរាជសម្បត្តិ នៅក្នុងករកណ្ឌនគរ។*

*សម័យនោះ តថាគត នៅលើប្រាសាទ អាមាត្យឈ្មោះសិរិគុត្ត អង្គុយគាល់ខាងមុខតថាគត បានលើកដៃស្តាំឡើង ហើយចង្អុលបង្ហាញ តថាគត ឱ្យមើលព្រះលោកនាយកថា* ***បពិត្រមហារាជ ព្រះតថាគតនេះ ព្រះនាមព្រហ្មទេវៈ ទ្រង់បញ្ចេញរស្មី នៅកណ្តាលផ្លូវ សូមព្រះអង្គទស្សនា ព្រះតថាគតនោះឱ្យរឿយៗចុះ។***

*តថាគត បិតនៅក្នុងទីនោះ ស្តាប់ពាក្យរបស់សិរិគុត្តអាមាត្យហើយ ក៏គិតផ្សេងៗ គឺកាលតថាគតគិតថា* ពុទ្ធោ ពុទ្ធោ ***ព្រះពុទ្ធ ព្រះពុទ្ធ*** *ហើយសម្លឹងមើលព្រះពុទ្ធអង្គនោះប៉ុណ្ណោះ។*

*គ្រាបានឃើញព្រះពុទ្ធព្រហ្មទេវៈ ដែលទ្រង់ជាអ្នកមានបញ្ញា ទ្រទ្រង់នូវភាពរុងរឿង តថាគត ក៏ភ្ញាត់ធ្លាក់អំពីប្រាសាទមកលើដី។*

*តែថា ដោយអានុភាពសទ្ធា របស់តថាគត ទើបតថាគត បានឈរលើផ្កាឈូក តថាគត ចុះចាកផ្កាឈូក រួចបានចូលគាល់ព្រះពុទ្ធដែលទ្រង់មានព្រះនេត្រ ទតមកតថាគត។*

*តថាគត បានបូជាព្រះពុទ្ធ ដោយបុប្ផជាតិទាំងឡាយ និងបានធ្វើផ្កាឈើ៣ប្រភេទ ថ្វាយបូជានូវកម្រងផ្កានោះ ដល់ព្រះមានព្រះភាគ ដែលជាអ្នកមានតេជះ និងមានយសដ៏ធំ។*

គ្រាបូជាព្រះតថាគតដោយគ្រឿងលម្អិត ដែលសម្រេចដោយរតនៈ៧ប្រការហើយ តថាគតបានថ្វាយបង្គំព្រះពុទ្ធព្រហ្មទេវៈ **នេះជាសេចក្ដីប្រាថ្នាលើកដំបូងរបស់តថាគត។**

ក្នុង**នន្ទអសង្ខេយ្យ**នោះ តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៥,០០០អង្គ។

ក្នុង**សុនន្ទអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៩,០០០អង្គ។

ក្នុង**បឋវីអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ ១០,០០០អង្គ។

ក្នុង**មណ្ឌអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ ១១,០០០អង្គ។

ក្នុង**ធរណីអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ២០,០០០អង្គ។

ក្នុង**សាគរអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៣០,០០០អង្គ។

ក្នុង**បុណ្ឌរីកអសង្ខេយ្យ** តថាគត បានធ្វើអធិការទុកហើយ តថាគតបានញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៤០,០០០អង្គ។

សេចក្ដីប្រាថ្នាដោយចិត្ត របស់តថាគត បានធ្វើទុកហើយ ក្នុងសម្នាក់ព្រះពុទ្ធ អ្នកស្វែងរកគុណធំ មានប្រមាណប៉ុណ្ណោះ បុគ្គលដែលស្មើនឹងតថាគតដោយទានរមែងមិនមាន នេះជាទានបារមីរបស់តថាគត។

**ពុទ្ធបណិធាន**

*ព្រះសម្មាសម្ពុទ្ធទាំងឡាយ គ្រប់ព្រះអង្គ ដែលមានចំនួន១២៥,០០០ព្រះអង្គ សុទ្ធតែជាបណ្ឌិត។*

ចិន្តិតំ សត្តាសង្ខ្យេយ្យន្តិ បទស្ស វណ្ណនា សមត្តា។

*ការពណ៌នាបាទគាថាថា* ចិន្តិតំ សត្តាសង្ខ្យេយ្យំ *នេះ ចប់ដោយបរិបូណ៌ហើយ។*

**មនោបណិធានកថា ចប់៕**

# ជំពូកទី៣
# អតិទូរេនិទាន (វចីបណិធាន)

## មានមួយនិទានកថា

# ព្រះបាទសាគលចក្កពត្តិរាជ

# សេចក្ដីប្រាថ្នាជាព្រះពុទ្ធដោយវាចា

# ក្នុងព្រះពុទ្ធសាសនា

# វចីបណិធាន មាន៩អសង្ខេយ្យ
# ឈ្មោះថា អតិទូរេនិទាន

## ក្នុងកំណើតជា ព្រះបាទសាគលចក្កពត្តិរាជ

## សេចក្តីប្រាថ្នាជាព្រះពុទ្ធ

## ដោយបញ្ចេញវាចាលើកទី ១

## ចំពោះព្រះភក្ត្ររបស់

## ព្រះសម្មាសម្ពុទ្ធព្រះនាម បុរាណសក្យមុនី



នេះកាល ព្រះបាទសាគលចក្កពត្តិរាជ
គឺជាសេចក្តីប្រាថ្នាជាព្រះពុទ្ធ ដោយបញ្ចេញវាចាលើកទី ១
ចំពោះព្រះភក្ត្ររបស់ ព្រះសម្មាសម្ពុទ្ធព្រះនាម បុរាណសក្យមុនី

## នវាសង្ខ្យេយ្យវាចិកកថា

*ការពណ៌នាបទថា ប្រកបដោយវាចា៩អសង្ខេយ្យក្នុងបទថា នវាសង្ខ្យេ-យ្យវាចិកំ នេះ មានសេចក្តីដូចតទៅៈ*

សព្វភទ្ទោ សព្វផុល្លោ, សព្វរតនោ ឧសភក្ខន្ធោ;
មានិភទ្ទោ ច បទុមោ, ឧសភោ ច ខន្ធុត្តមោ។
សព្វមាលោអសង្ខ្យេយ្យោ, ជាមោតិ បវុច្ចតិ;
វចីភេជា បត្ថជា មយ្ហំ, និទ្ទិដ្ឋាសង្ខ្យេយ្យា ឥមេ។

*អសង្ខេយ្យទាំងឡាយណា ដែលត្រូវពោលថាអសង្ខេយ្យ ឈ្មោះថា សព្វភទ្ទអសង្ខេយ្យ១ សព្វផុល្លអសង្ខេយ្យ១ សព្វរតនអសង្ខេយ្យ១ ឧសភក្ខន្ធ-អសង្ខេយ្យ១ មានិភទ្ទអសង្ខេយ្យ១ បទុមអសង្ខេយ្យ១ ឧសភអសង្ខេយ្យ១ ខន្ធុ-ត្តមអសង្ខេយ្យ១ សព្វមាលអសង្ខេយ្យ១, អសង្ខេយ្យទាំងឡាយនេះ ត្រូវបាន សម្តែងពីសេចក្តីប្រាថ្នា ដោយការបញ្ចេញវាចារបស់តថាគត។*

*បណ្តាបទទាំងនោះ បទថា សព្វភទ្ទោ បានដល់ ឈ្មោះថា សព្វភទ្ទ-អសង្ខេយ្យ ជាអសង្ខេយ្យខាងដើមរបស់អសង្ខេយ្យទាំង៩នោះ។*

# សាគលចក្កវត្តិរាជវត្ថុ

## រឿង ព្រះបាទសាគលចក្រពត្តិ

*បានឮមកថា ក្នុងកាលនោះ ព្រះពោធិសត្វរបស់យើងទាំងឡាយ កាលត្រាច់រង្គាត់ អន្ទោលវិលវល់ស្លាប់កើតក្នុងទេវលោក និងមនុស្សលោក ក្នុងសុញ្ញកប្បជាអនេក ហើយបានកើតក្នុងមនុស្សលោក ក្នុងអត្តភាពមួយ។*

*រួចបានបួសជាឥសី ចម្រើនបានបឋមជ្ឈាន ហើយបានកើតក្នុងព្រហ្មលោក ក្នុងជាន់មហាព្រហ្ម ដែលមានអាយុ១កប្ប។*

*លុះចុតិ ចាកអត្តភាពនោះហើយ ដោយអានុភាពនៃសុចរិតក្នុងភពមុន ក៏បានកើតក្នុងរាជត្រកូលនៃនគរ**ធញ្ញវតី** ក្នុងកប្បមួយ ឈ្មោះ**សារមណ្ឌ** ដែលមានព្រះពុទ្ធ៤ព្រះអង្គត្រាស់ដឹង ក្នុងអសង្ខេយ្យឈ្មោះថា**សព្វភទ្ទ**នោះ។*

*ក្នុងថ្ងៃថ្វាយព្រះនាម ព្រះញាតិវង្សានុវង្សទាំងឡាយ បានថ្វាយព្រះនាមព្រះអង្គថា **សាគលកុមារ**។*

*កាលដែលព្រះវររាជបិតា ទ្រង់សោយទិវង្គតទៅហើយនោះ **សាគលកុមារ** ក៏បានទទួលរាជាភិសេកជាព្រះរាជា ទ្រង់មិនញុំាង**ទសពិធរាជធម៌**[២៩] ឱ្យកម្រើក គឺព្រះអង្គសោយរាជ្យប្រកបដោយធម៌។*

---

[២៩] ***ទសពិធរាជធម៌*** *(ទៈ សៈពិធៈរាជៈ ធ័រ, ឬតាមទម្លាប់ថា ទស់សៈពិត--)* ន. *(បា. ទសវិធ + រាជធម្ម) រាជធម៌ ១០យ៉ាង គឺធម៌ ១០ ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង ។ ទសពិធរាជធម៌នោះគឺ* ***១-ទានៈ*** *ការធ្វើអំណោយ;* ***២-សីលៈ*** *ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ មួយដង់មួយកាល;* ***៣-បរិច្ចាគៈ*** *ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ;* ***៤-អាជ្ជវៈ*** *មានសេចក្ដីត្រង់;* ***៥-មទ្ទវៈ*** *មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា;* ***៦-តបៈ*** *ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ (ម.*

**ពុទ្ធបណិធាន**

*បន្តអំពីនោះមក ព្រះបាទសាគលរាជ បានញុំាង**ចក្កវត្តិវត្ត** ដែលបុរោហិតឱ្យសិក្សា បានពេញបរិបូណ៌ ហើយក្នុងថ្ងៃឧបោសថ ទ្រង់កក់សីសៈ ជាអ្នកសមាទានឧបោសថ ស្តេចឡើងកាន់ប្រាសាទជាន់លើ គង់ប្រថាប់ពិចារណាសីលរបស់ខ្លួន។*

*លំដាប់នោះ **ចក្ករ័តន៍**ជាទិព្វ ដែលបរិបូណ៌ដោយកាំ១,០០០ មានកង់និងដុំ មានអាការៈប្រកបគ្រប់យ៉ាង ដែលកើតអំពីឧតុ ដោយអំណាចកម្មជាបច្ច័យ របស់ព្រះរាជា មកអំពីទិសខាងកើត។*

*បន្ទាប់ពីចក្ករ័តន៍នោះ **ហត្ថិរ័តន៍**បានកើតឡើងមកអំពីត្រកូលឧបោសថ។*

*បន្ទាប់ពីហត្ថិរ័តន៍នោះ **អស្សរ័តន៍**បានកើតឡើងមកអំពីត្រកូលវលាហកៈ។*

*បន្ទាប់ពីអស្សរ័តន៍នោះ **មណិរ័តន៍**បានកើតឡើង មកអំពីភ្នំវេបុល។*

*បន្ទាប់ពីមណិរ័តន៍នោះ **ឥត្ថិរ័តន៍**បានកើតឡើងមកអំពីឧត្តរកុរុទ្វីប។*

*បន្ទាប់ពីឥត្ថិរ័តន៍នោះ **គហបតិរ័តន៍**បានកើតឡើងក្នុងជម្ពូទ្វីបនេះ។*

*រាជបុត្រច្បងរបស់ព្រះអង្គ ក៏បានឡើងជា**បរិនាយករ័តន៍**។*

*ព្រះបាទសាគលនោះ ជាធម្មិក ជាធម្មិករាជ ជាអ្នកឈ្នះជាប្រក្រតី មានមហាសមុទ្រទាំង៤ ជាទីបំផុត មានជនបទរឹងមាំ ទ្រង់បរិបូណ៌ដោយរតនៈ៧ប្រការ។*

---

*៣. តបៈ ឬ តបះ ផង); **៧-អក្កោធនៈ** មិនកម្តៅក្រហាយអ្នកដទៃ; **៨-អវិហឹសា** មិនបៀតបៀនអ្នកដទៃ; **៩-ខន្តិ** មានសេចក្តីអត់ធន់; **១០-អវិរោធនៈ** មិនបំពានលើធម៌លើច្បាប់ ។ ច្រើនប្រើកាត់ខ្លីត្រឹមតែ ទសពិធ ឬ ទសពិធធម៌ ។*

ព្រះអង្គឈ្នះដោយធម៌ មិនប្រើអាជ្ញា មិនប្រើសស្ត្រា ទ្រង់គ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុត ទ្រង់សោយសិរីសម្បត្តិ ជា**ស្តេចចក្រពត្តិ**(៣០) ដែលជាធំលើទ្វីបធំទាំង៤។

គ្រានោះ ព្រះតថាគត ព្រះនាមបុរាណសាក្យមុនី បានបំពេញបារមីទាំងឡាយ អស់១៦អសង្ខេយ្យ និងមួយសែនកប្ប ហើយបានកើតក្នុងរាជត្រកូលដូចគ្នានឹងស្តេចចក្រពត្តិ ក្នុងកប្បមួយដែលមានឈ្មោះថាសារមណ្ឌៈ ក្នុងសព្វភទ្ទអសង្ខេយ្យនោះ។

ព្រះអង្គគ្រប់គ្រងផ្ទះអស់៩,០០០ឆ្នាំ ទ្រង់ឃើញនិមិត្តទាំង៤ ហើយចេញសាងមហាភិនេស្ក្រមណ៍ តាំងសេចក្តីព្យាយាមអស់កន្ទះខែ បានសម្រេចព្រះសព្វញ្ញុតញ្ញាណ។

ពេលនោះ ព្រះមានព្រះភាគ ទ្រង់ប្រកាសធម្មចក្ក ដែលព្រះពុទ្ធគ្រប់ព្រះអង្គមិនលះបង់(៣១) ហើយក្នុងកាលនោះ មហាប្រឹថពីត្រូវតេជះ នៃការ

---

(៣០)**ចក្កវត្តិ** ឬ **ចក្រពត្តិ** មាន ៣ ប្រភេទគឺៈ

១-**បទេសចក្កវត្តិ** ប្រទេសចក្រពត្តិ គឺជាស្តេចគ្រងរាជ្យលើប្រទេសនីមួយៗ។

២-**ទីបកចក្កវត្តិ** ទ្វីបចក្រពត្តិ គឺជាស្តេចគ្រងរាជ្យលើទ្វីបមួយ។

៣-**មហិស្សរចក្កវត្តិ** (មហាចក្រពត្តិ) គឺជាស្តេចគ្រងរាជ្យលើទ្វីបទាំង ៤ (ក្នុងព្រះត្រៃបិដកហៅត្រឹម ចក្កវត្តិ ឬចក្រពត្តិ ប៉ុណ្ណោះ)។ *(គម្ពីរលោកទីបកសារ បរិច្ឆេទទី៨)* តែក្នុងទីនេះ ព្រះបាទ**សាគលចក្រពត្តិ** ទ្រង់ជា**មហិស្សរចក្កវត្តិ (មហាចក្រពត្តិ)**។

(៣១) ក្នុងអដ្ឋកថាទាំងឡាយ ហៅស្ថានទី ដែលព្រះពុទ្ធ គ្រប់ព្រះអង្គមិនលះបង់ថា **អវិជហិតដ្ឋាន** ឬ **អចលចេតិយដ្ឋាន។** ស្ថានទីដែលព្រះពុទ្ធទាំងឡាយ គ្រប់ព្រះអង្គ ទ្រង់មិនលះបង់ ឬ **ស្ថានទី ដែលមិនផ្លាស់ប្តូរមាន៤យ៉ាងគឺៈ**

១. ពោធិបល្លង្កោ ពោធិបល្ល័ង្ក

២. ធម្មចក្កប្បវត្តនដ្ឋានំ កន្លែងសម្តែងធម្មចក្កប្បវត្តនសូត្រ

**ពុទ្ធបណិធាន**

សម្ដែងធម្មចក្កប្បវត្តនសូត្រ របស់ព្រះមានព្រះភាគសន្ធាប់ហើយ ក៏កម្រើក រំពើកញាប់ញ័រ ភ្នំសិនេរុរាជក៏ឱនចុះ អច្ឆរិយភាពជាអនេក បានប្រាកដឡើង។

នៅពេលដែលមហាប្រឹថពី កម្រើកញាប់ញ័រនោះ ចក្ករ័តន៍ របស់ស្ដេចចក្រពត្តិ ក៏បានឃ្លាតចាកទីតាំងពីកន្លែង ដែលអាមាត្យទាំងឡាយដាំសសរ២ ដើម នៅសងខាងនៃចក្ករ័តន៍នោះ ដោយយកខ្សែមួយ ចងនៅខាងមុខខ្នងកង់ នៃផ្នែកខាងលើចក្ករ័តន៍ ដើម្បីឱ្យចក្ករ័តន៍ តាំងនៅចន្លោះសសរទាំងពីរ។

ព្រោះអាស្រ័យផែនដីរញ្ជួយ ចក្ករ័តន៍ក៏កម្រើកញាប់ញ័រ ហើយខ្នងកង់នៃចក្ករ័តន៍ របូតធ្លាក់ទៅខាងក្រោមនៃសសរទាំងពីរ។

ចក្កបាលក៏ ជាអ្នករក្សាចក្ករ័តន៍ ឃើញហេតុការណ៍នោះហើយ ក៏ទៅក្រាបបង្គំទូលថ្វាយព្រះរាជា។

ព្រះរាជា ស្ដាប់រឿងនោះរួច មានព្រះទ័យតក់ស្លុត ទើបសួរហោរ ដែលជាអ្នកទាយនិមិត្តទាំងឡាយថា៖

"ព្រះរាជា អាមាត្យនៃព្រះរាជា និងប្រជាជនទាំងឡាយ នាំគ្នាបូជាចក្ករ័តន៍នេះជាប្រចាំ ហើយឥឡូវនេះ ព្រោះហេតុអ្វីទើបបានជាចក្ករ័តន៍នេះឃ្លាតទៅ តើនឹងមានអន្តរាយដល់ជីវិត ឬអន្តរាយដល់រាជសម្បត្តិរបស់

---

៣. ទេវោរោហណកាលេ សង្កស្សនគរទ្វារេ បឋមក្កមចេតិយដ្ឋានំ

*កន្លែង ដែលព្រះពុទ្ធយកព្រះបាទជាន់ជាដំបូងជិតទ្វារនគរសង្កស្ស ក្នុងកាលដែលទ្រង់ចុះចាកទេវលោក*

៤. ជេតវនេ គន្ធកុដិយា ចត្តារិ មញ្ចចេតិយដ្ឋានានិ

*កន្លែងតម្កល់ជើងគ្រែទាំងបួនក្នុងព្រះគន្ធកុដិនៅវត្តជេតពន។*

*(មធុរត្ថវិលាសិនី អដ្ឋកថា ខុទ្ទកនិកាយ ពុទ្ធវំស ពុទ្ធបកិណ្ណកកថា)*

*យើងឬ"?*

*ហោរាចារ្យទាំងឡាយ ក្រាបទូលថា៖*

*"បពិត្រមហារាជ ចក្កវ័តន៍ រមែងកម្រើកឃ្លាតចាកទី ដោយហេតុពីរយ៉ាង គឺ៖*

១. រញ្ញោ តិជិវត្តនេន *ដោយការចូលទិវង្គត របស់ព្រះរាជា*

២. តថាគតេ សម្មាសម្ពុទ្ធេ លោកេ ឧប្បន្នេន

*ដោយការកើតឡើង របស់ព្រះតថាគតជាព្រះ*

*សម្មាសម្ពុទ្ធ ក្នុងលោក។*

*បពិត្រមហារាជ អន្តរាយមិនប្រាកដដល់ព្រះអង្គទេ, ព្រះសម្មាសម្ពុទ្ធព្រះនាមសាក្យមុនី បានកើតឡើងក្នុងលោក, កិត្តិសព្ទដ៏ល្អរបស់ព្រះមានព្រះភាគនោះ បានផ្សព្វផ្សាយទៅយ៉ាងនេះថា៖*

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា។

ឥតិបិ សោ ភគវា អរហំ *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* **អរហំ** *ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ។*

សម្មាសម្ពុទ្ធោ *ទ្រង់ព្រះនាមថា* **សម្មាសម្ពុទ្ធោ** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ។*

*វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា* ***វិជ្ជាចរណសម្បន្នោ*** *ព្រោះព្រះអង្គបរិបូណ៌ដោយ****វិជ្ជា៣ វិជ្ជា៨*** *និង* ***ចរណៈ១៥***[៣២]*។*

---

[៣២]-*វិជ្ជា ៣ គឺ*

| | |
|---|---|
| *១- បុព្វេនិវាសានុស្សតិវិជ្ជា* | *វិជ្ជាដឹងកំណើតក្នុងជាតិមុនៗ* |
| *២- ចុតូបបាតវិជ្ជា ឬ ទិព្វចក្ខុ* | *វិជ្ជាដឹងនូវចុតិ បដិសន្ធិ របស់មនុស្សសត្វ* |
| *៣- អាសវក្ខយវិជ្ជា* | *វិជ្ជាធ្វើឱ្យអស់អាសវៈ។* |

*- វិជ្ជា ៨ យ៉ាង គឺះ*

| | |
|---|---|
| *១- វិបស្សនាវិជ្ជា* | *វិជ្ជាពិចារណានូវនាម និងរូប* |
| *២- មនោមយិទ្ធិវិជ្ជា* | *វិជ្ជាឫទ្ធិសម្រេចបានតាមចិត្ត* |
| *៣- ឥទ្ធិវិធវិជ្ជា* | *វិជ្ជាសម្តែងឫទ្ធិផ្សេង* |
| *៤- ទិព្វសោតវិជ្ជា* | *វិជ្ជាបានត្រចៀកទិព្វ* |
| *៥- បុព្វេនិវាសានុស្សតិវិជ្ជា* | *វិជ្ជាដឹងកំណើតក្នុងជាតិមុន* |
| *៦- ចេតោបរិយញ្ញាណវិជ្ជា ឬ បរចិត្តវិជ្ជា* | *វិជ្ជាដឹងនូវចិត្តអ្នកដទៃ* |
| *៧- ទិព្វចក្ខុវិជ្ជា* | *វិជ្ជាបានភ្នែកទិព្វ* |
| *៨- អាសវក្ខយវិជ្ជា* | *វិជ្ជាធ្វើឱ្យអស់អាសវៈ។* |

*-ចរណៈ ១៥ មានបីពួក គឺះ*

*១-សីលចែកជា ៤ យ៉ាងគឺះ*

*១- សីលសំវរៈ សង្រួមកាយវាចាតាមសិក្ខាបទនៃសីល និច្ចសីល ឧបោសថសីល អតិរេកសីល និង ចតុបារិសុទ្ធិសីល។*

*២- ឥន្ទ្រិយសំវរៈ សង្រួមក្នុងឥន្ទ្រីយ៍ទាំង ៦ គឺចក្ខុន្ទ្រីយ៍ សោតិន្ទ្រីយ៍ ឃានិន្ទ្រីយ៍ ជិវ្ហិន្ទ្រីយ៍ កាយិន្ទ្រីយ៍ និងមនិន្ទ្រីយ៍។*

| | |
|---|---|
| *៣- ភោជនេ មត្តញ្ញុតា* | *ដឹងប្រមាណក្នុងអាហារភោជន។* |
| *៤- ជាគរិយានុយោគៈ* | *ប្រកបរឿយៗ ក្នុងការភ្ញាក់រឭក។* |

*២-ព្រះសទ្ធម្មមាន ៧ យ៉ាងគឺះ*

| | |
|---|---|
| *១- សទ្ធា* | *ជឿគុណព្រះរតនត្រ័យ* |
| *២- ហិរិ* | *ខ្មាសបាប* |
| *៣- ឱត្តប្បៈ* | *ខ្លាចបាប* |
| *៤- ពាហុសច្ចៈ* | *ភាពជាអ្នករៀនចេះចាំច្រើន* |

*សុគតោ ទ្រង់ព្រះនាមថា* ***សុគតោ*** *ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន។*

*លោកវិទូ ទ្រង់ព្រះនាមថា* ***លោកវិទូ*** *ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក។*

*អនុត្តរោ ទ្រង់ព្រះនាមថា* ***អនុត្តរោ*** *ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន។*

*បុរិសទម្មសារថិ ទ្រង់ព្រះនាមថា* ***បុរិសទម្មសារថិ*** *ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន។*

*សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា* ***សត្ថាទេវមនុស្សានំ*** *ព្រោះព្រះអង្គ ជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ។*

*ពុទ្ធោ ទ្រង់ព្រះនាមថា* ***ពុទ្ធោ*** *ព្រោះព្រះអង្គ ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង។*

*ភគវា ទ្រង់ព្រះនាមថា* ***ភគវា*** *ព្រោះព្រះអង្គមានដំណើរឆ្ពោះទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ។*

*ដោយការកើតឡើង នៃព្រះសម្មាសម្ពុទ្ធអង្គនេះ ទើបចក្កវត្តន៍ឃ្លាតចាកទី ដូច្នេះមិនមានអន្តរាយដល់ព្រះអង្គទេ"។*

---

| | |
|---|---|
| *៥- វិរិយៈ* | *ព្យាយាម* |
| *៦- សតិ* | *រឭកដឹង* |
| *៧- បញ្ញា* | *ប្រាជ្ញាដឹងខុសត្រូវ។* |

*៤-ឈានមាន ៤ យ៉ាងគឺៈ ១-បឋមជ្ឈាន, ២-ទុតិយជ្ឈាន, ៣-តតិយជ្ឈាន, ៤-ចតុត្ថជ្ឈាន។*

*ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់មានសរីរៈ ដែលបីតិទាំង៥ ប្រការ ពាល់ត្រូវជានិរន្តរ៍ហើយ ទ្រង់ត្រាស់នឹងពួកហោរថាៈ*

"ពុទ្ធោតិ តុម្ហេ វទេថ, ពុទ្ធោតិ អម្ហេ វទាមសេ;
ពុទ្ធោតិ តុម្ហេ វទេថ, ពុទ្ធោតិ អម្ហេ វទាមសេ"។

*"អ្នកទាំងឡាយពោលថា* **ពុទ្ធោ** *យើងក៏ពោលថា* **ពុទ្ធោ** *ដែរ*
*អ្នកទាំងឡាយពោលថា* **ពុទ្ធោ** *យើងក៏ពោលថា* **ពុទ្ធោ***ដែរ"។*

*ព្រះរាជា ត្រាស់សួរ អស់វារៈបីដងថាៈ*

*"ឥឡូវនេះ ព្រះភគវានោះ គង់នៅទីណា"?*

*បណ្តាហោរទាំងនោះ មានហោរម្នាក់ជាបណ្ឌិត មានបញ្ញាឈ្លាសវាងវៃ ដណ្តាប់សំពត់ឱ្យឈាងស្មាម្ខាង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋ ទៅកាន់ព្រះរាជ-ឧទ្យាន ដែលមានឈ្មោះថា***មិគាជិនៈ** *ផ្គងអញ្ជលីលើសិរសា ក្រាបទូលស្ថានទីប្រថាប់ របស់ព្រះមានព្រះភាគ ថ្វាយព្រះរាជាថាៈ*

"ឯស ពុទ្ធោ មហារាជ, លោកជេដ្ឋោ អនុត្តរោ;
លោកេ ចាសមោ ជេដ្ឋោ, មហេសី អគ្គបុគ្គលោ។
សព្វញ្ញូ ពុទ្ធោ ភគវា, សក្យមុនីតិ វិស្សុតោ;
និស្សាយិមំ ឧញ្ញវតីំ, មិគាជិនវនេ វសិ"។

*"បពិត្រមហារាជ ព្រះពុទ្ធអង្គនោះ ទ្រង់ប្រាកដល្បីទូទៅថា ព្រះអង្គជាព្រះលោកនាថ ទ្រង់ប្រសើរ មិនមានបុគ្គលស្មើក្នុងលោក ទ្រង់ជាចម្បងជាអ្នកស្វែងរកគុណដ៏ធំ ជាអគ្គបុគ្គល។*

*ព្រះអង្គ ជាព្រះសព្វញ្ញុពុទ្ធ ជាព្រះភគវា ទ្រង់នាមថា* ***សក្យមុនី*** *ទ្រង់ប្រថាប់គង់នៅមិគាជិនឧទ្យាន ដែលអាស្រ័យនៅក្នុងធញ្ញវតីនគរនេះ"។*

*ព្រះរាជាសាគល ទ្រង់ដឹងថា ព្រះដ៏មានព្រះភាគ គង់ប្រថាប់នៅមិគាជិន-ឧទ្យាន ដែលអាស្រ័យនឹងធញ្ញវតីនគរនេះ ទ្រង់មានសេចក្ដីប្រាថ្នា ចង់ឃើញព្រះដ៏មានព្រះភាគក្រៃលែង ទើបត្រាស់ថា៖*

*"បើដូច្នោះ យើងទាំងឡាយនឹងទៅថ្វាយបង្គំ ព្រះភគវន្តសម្មាសម្ពុទ្ធ"។*

*ត្រាស់ដូច្នេះហើយ ទ្រង់ឱ្យគេកាន់យកប្រទីប ធូប គ្រឿងក្រអូប និងកម្រងផ្កាជាដើម រួចយាងចេញទៅ ដោយអានុភាព នៃសិរីរបស់ស្ដេចចក្រពត្តិដ៏ធំ មួយអន្លើដោយសេនាដង្ហែប្រមាណ១២យោជន៍ ចូលទៅកាន់មិគាជិន-ឧទ្យាន។*

*ព្រះរាជា បានឃើញព្រះតថាគត ដែលប្រដាប់ដោយ****មហាបុរិសលក្ខណៈ ៣២****ប្រការ និងបរិបូណ៌ដោយ****អនុព្យញ្ជនៈ៨០*** *ទ្រទ្រង់នូវសិរី ទ្រង់រុងរឿង ទ្រង់ដូចជាបណ្ដាញរស្មី ដែលផ្សាយទៅ ទ្រង់មិនមានអ្វីប្រៀប ទ្រង់មាន****ឆព្វណ្ណរង្សី****[៣៣] គឺចែងចាំងឡោមព័ទ្ធ ហាក់ដូចជាព្រះចន្ទ្រពេញវង់ ក្នុងថ្ងៃពេញបូណ៌មី និងហាក់ដូចជាព្រះអាទិត្យ ក្នុងពេលថ្ងៃត្រង់ ទ្រង់គង់ប្រថាប់លើពុទ្ធាសនៈដែលប្រដាប់តាក់តែងហើយ។*

---

[៣៣] ***ឆព្វណ្ណរង្សី*** (ន.) [*ឆ័ព-ព័ណ-ណៈរ័ងសី*] (បា.) (*ឆព្វណ្ណរំសិ*) *រស្មី ៦ ព័ណ៌ គឺ****ខៀវ, លឿង, ក្រហម, ស, ហង្សបាទ, ផ្ទេក (ពន្លឺពេជ្រ)****; និយាយចំពោះតែរស្មីនៃព្រះសព្វញ្ញុពុទ្ធ, តាមទម្លាប់ច្រើនហៅថា ឆព័ណ្ណរង្សី ប៉ុន្តែគង់សរសេរជា ឆព្វណ្ណរង្សី ដូច្នេះដែរ ។* មានបាលីប្រែថា

| | | | |
|---|---|---|---|
| ១. នីលរស្មិ | *រស្មីពណ៌ខៀវ,* | ២. បីតរស្មិ | *រស្មីពណ៌លឿង,* |
| ៣. លោហិតរស្មិ | *រស្មីពណ៌ក្រហម,* | ៤. ឱទាតរស្មិ | *រស្មីពណ៌ស* |
| ៥. មញ្ជិដ្ឋរស្មិ | *រស្មីពណ៌ហង្សបាទ,* | ៦. បភស្សររស្មិ | *រស្មីពណ៌ផ្ទេក។* |

**ពុទ្ធបណិធាន**

*គ្រាឃើញហើយ ព្រះរាជាកើតសេចក្តីប្លែកចិត្តយ៉ាងអស្ចារ្យក្រៃលែង កាលសម្លឹងមើលឆព្វណ្ណរង្សីទាំងឡាយ ទ្រង់យាងចូលទៅថ្វាយបង្គំដោយ* **បញ្ចង្គប្រតិស្ឋាន** *ទ្រង់ក្រាបសិរសាទៀបព្រះ***យុគលបាទ** *ដែលវិចិត្រដោយកង់ចក្ររបស់ព្រះសាស្តា ទ្រង់សម្លឹងមើលពុទ្ធសិរី កាលនឹងស្ញើចសរសើរ ទើបត្រាស់យ៉ាងនេះថា៖*

"សុទិដ្ឋំ វត មេ ទិដ្ឋំ, បស្សិតព្វញ្ច បស្សិតំ;
សផលំ ជីវិតំ មយ្ហំ, យំ បស្សាមិ តថាគតំ។
ន តេ សមោ កោចិ មនុស្សលោកេ, សមោបិ តេ នត្ថិ ច ទេវលោកេ;
សទិសោបិ តេ នត្ថិ ច ព្រហ្មលោកេ, តមេកនាថំ អសមំ នមាមិ"។

*"ខ្ញុំព្រះអង្គ បានឃើញព្រះតថាគតអង្គណា ដែលខ្លួនឃើញល្អហើយ និងបានជួបវត្ថុ ដែលគួរជួបហើយ ជីវិតរបស់ខ្ញុំព្រះអង្គ មានផលហើយ។ ព្រះតថាគតអង្គនោះ មិនមានបុគ្គលស្មើ ក្នុងមនុស្សលោក មិនមានបុគ្គលស្មើ សូម្បីក្នុងទេវលោក មិនមានបុគ្គលស្មើ សូម្បីក្នុងព្រហ្មលោក ខ្ញុំព្រះអង្គសូមនមស្ការព្រះ***ឯកនាថ** *ដែលមិនមានបុគ្គលស្មើនោះ"។*

*លំដាប់នោះ ស្តេចចក្រពត្តិព្រះនាមសាគល ទ្រង់មានព្រះកាយ និងចិត្តត្រូវបីតិដ៏ធំពាល់ត្រូវហើយ ដោយការទស្សនាព្រះរូបរបស់ព្រះសាស្តា ទ្រង់បានគិតយ៉ាងនេះថា* ***យើងបានសម្បត្តិស្តេចចក្រពត្តិដែលដូចជាសម្បត្តិរបស់សត្វក្នុងអត្តភាពនេះ ព្រោះយើងបានឲ្យទាន ព្រោះសីលដែលយើងបានរក្សាល្អហើយ, ព្រះតថាគតព្រះនាមថា សក្យមុនី ទ្រង់ញ៉ាំងខ្លួនព្រះអង្គឲ្យរួចផុតចាកសំសារទុក្ខមុនហើយ បានត្រាស់ជាព្រះពុទ្ធ បន្ទុះព្រះសព្វញ្ញុតញ្ញាណហើយ***

***ញុំាងវេនេយ្យសត្វទាំងឡាយឲ្យរួចផុត យ៉ាងណា ក្នុងអនាគតកាល សូម្បីយើងក៏នឹងញុំាងខ្លួនឯងឲ្យរួចផុតចាកសំសារទុក្ខ បានត្រាស់ដឹងជាព្រះពុទ្ធ បន្ទុះព្រះសព្វញ្ញុតញ្ញាណហើយ នឹងញុំាងវេនេយ្យសត្វទាំងឡាយឲ្យរួចផុត ដូចព្រះពុទ្ធអង្គនេះ យ៉ាងនោះដែរ។***

*គ្រាព្រះរាជាគិតយ៉ាងនេះហើយ ទ្រង់សរសើរព្រះតថាគត រួចស្ដេចក្រោកឡើងធ្វើប្រទក្សិណ យាងចូលកាន់នគរធញ្ញវតី ដែលដូចជា* ***តិទសបុរី*** *គឺឋានត្រ័យត្រិង្ស។*

*លំដាប់នោះ ព្រះរាជាបានបញ្ជាទេវតាទាំងឡាយ ទៅនាំខ្លឹមចន្ទន៍ក្រហម ដែលដល់ព្រមដោយក្លិន និងពណ៌ អំពីព្រៃហិមពាន្ត ទ្រង់កសាងប្រាសាទ១០០,០០០ខ្នង ដែលសម្រេចដោយខ្លឹមចន្ទន៍ក្រហមនោះ, ទ្រង់បញ្ជាឱ្យសាងគន្ធកុដិ១០០,០០០ខ្នង មណ្ឌប១០០,០០០ខ្នង ទីសម្រាកពេលយប់១០០,០០០ខ្នង ទីសម្រាកពេលថ្ងៃ១០០,០០០ខ្នង ស្ពានទីចង្ក្រម១០០,០០០កន្លែង ជន្តាឃរៈជាអគ្គិសាលា ឬរោងភ្លើង១០០,០០០ខ្នង សាលាធាន់១០០,០០០ខ្នង ខ្លោងទ្វារ១០០,០០០។*

*គ្រាទ្រង់សាងប្រាសាទជាដើម ដែលសមគួរដល់ព្រះមានព្រះភាគ គង់ប្រថាប់នៅយ៉ាងនេះហើយ ទ្រង់ឱ្យកសាងកំពែង ដែលគួរជាទីមនោរម្យ ឱ្យដាក់ទ្វារ ឱ្យធ្វើ* ***កប្បិយភណ្ឌៈ*** *ដល់សង្ឃ។*

*កាលវិហារ ត្រូវសាងស្រេចហើយ ទ្រង់មានបរិស័ទ ជាបរិមណ្ឌល៣៦យោជន៍ឡោមព័ទ្ធហើយ ដើម្បីអារាធនាព្រះដ៏មានព្រះភាគ ស្ដេចយាងទៅកាន់*

**ពុទ្ធបណិធាន**

សម្មាក់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋ ទ្រង់ក្រោកឡើងផ្គង អញ្ជលីលើសិរសា មានព្រះរាជបន្ទូលនឹងព្រះដ៏មានព្រះភាគថា៖

"បពិត្រព្រះអង្គដ៏ចម្រើន ប្រាសាទទាំងឡាយជាដើម ខ្ញុំព្រះអង្គបានធ្វើហើយ ដើម្បីឧទ្ទិសចំពោះព្រះអង្គ។

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាអនុគ្រោះដល់ខ្ញុំព្រះអង្គ ហើយទទួលប្រាសាទជាដើម ទាំងឡាយនោះ"។

ព្រះភគវា ទ្រង់ទទួលដោយតុណ្ហីភាព។

លំដាប់នោះ ព្រះរាជាសាគលចក្រពត្តិ ទ្រង់យាងព្រះដ៏មានព្រះភាគ មួយអន្លើដោយបរិវារដ៏ច្រើន យាងចូលទៅកាន់ព្រះវិហារ។

គ្រាចូលទៅហើយ ទ្រង់អង្គាសភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារ ដ៏ប្រណីត ដោយព្រះហស្ត របស់ព្រះអង្គ។

ក្នុងវេលា ដែលព្រះពុទ្ធ និងភិក្ខុសង្ឃ សោយស្រេចហើយ ទ្រង់បូជាដោយគ្រឿងបូជាទាំងឡាយ ដែលស្រេចដោយរតនៈ៧ប្រការ ទ្រង់បានច្រូចទឹក ថ្វាយប្រាសាទ១០០,០០០ខ្នង ជាដើម ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទ្រង់ក្រាបចុះទៀបព្រះបាទរបស់ព្រះដ៏មានព្រះភាគ បញ្ចេញ **វចីភេទធ្វើបណិធាន**យ៉ាងនេះថា៖

" ភន្តេ ឥមិនា បុញ្ញកម្មេន យថា ត្វំ គោតមោ សក្យបុង្គវោ នាម ពុទ្ធោ ភវសិ, តថាហមបិ គោតមោ សក្យបុង្គវោ នាម ពុទ្ធោ ភវេយ្យំ"។

"បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គ ជាព្រះពុទ្ធ ព្រះនាមថា គោតមោ

សក្យបុង្គវោ យ៉ាងណា ដោយបុញ្ញកម្មនេះ ខ្ញុំព្រះអង្គក៏គប្បីបានជាព្រះពុទ្ធ មានព្រះនាមថា គោតមោ សក្យបុង្គវោ យ៉ាងនេះដែរ"។

ព្រះចៅស្តេចចក្រពត្តិព្រះនាមសាគល បានត្រាស់គាថាទាំងនេះ ទៀតថា៖

"យថា ច ត្វមបិ ជាថ, ពុទ្ធោ ពោធេសិ ចាណិនំ;
តថេវាហំ ពុទ្ធោ លោកេ, ពោធយិស្សាមិ ចាណិនំ។
យថា ច ត្វមបិ ជាថ, មុត្តោ មោចេសិ ចាណិនំ;
តថេវ មុត្តោហំ សំសារា, មោចយិស្សាមិ ចាណិនំ។
យថា ច ត្វមបិ ជាថ, តិណ្ណោ តារេសិ ចាណិនំ;
តថេវ តិណ្ណោ សំសារា, តារយិស្សាមិ ចាណិនំ"។

"បពិត្រព្រះលោកនាថ ដូចយ៉ាងថា សូម្បីព្រះអង្គទ្រង់បានត្រាស់ដឹងហើយ ទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យត្រាស់ដឹងផង យ៉ាងណា ខ្ញុំព្រះអង្គបានត្រាស់ដឹងហើយក្នុងលោក ក៏នឹងញ៉ាំងសត្វទាំងឡាយឲ្យត្រាស់ដឹងយ៉ាងនោះដែរ។

បពិត្រព្រះលោកនាថ ដូចយ៉ាងថា សូម្បីព្រះអង្គរួចផុតហើយ ទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យរួចផុតផង យ៉ាងណា ខ្ញុំព្រះអង្គបានរួចផុតចាកសំសារវដ្តហើយ ក៏នឹងញ៉ាំងសត្វទាំងឡាយឲ្យរួចផុត យ៉ាងនោះដែរ។

បពិត្រព្រះលោកនាថ ដូចយ៉ាងថា សូម្បីព្រះអង្គឆ្លងផុតហើយ ទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យឆ្លងផុតផង យ៉ាងណា ខ្ញុំព្រះអង្គបានឆ្លងផុតចាកសំសារវដ្តហើយ ក៏នឹងញ៉ាំងសត្វទាំងឡាយឲ្យឆ្លងផុត យ៉ាងនោះដែរ ។"

**ពុទ្ធបណិធាន**

*ព្រះបាទសាគល បានធ្វើ **វចីបណិធាន** យ៉ាងនេះ។*

*លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះនឹងព្រះរាជាថាៈ*

*"បពិត្រមហារាជ ឈ្មោះថា ការស្វែងរកពុទ្ធការកធម៌ ជាអំពើធ្វើបាន ដោយក្រ បើព្រះអង្គប្រាថ្នាជាព្រះពុទ្ធ សូមស្តាប់អំពើដែលធ្វើបានដោយ ក្រ ទាំងឡាយនោះចុះ។*

*បពិត្រមហារាជ បុគ្គលណា ប្រើជើងទាំងពីរជាន់ញាំញីផ្ទៃចក្រវាល ១០,០០០ ដែលពេញដោយភ្លើងឆេះក្តៅ ហើយទៅដល់ត្រើយ បុគ្គល នោះរមែងដល់ភាពជាព្រះពុទ្ធ។*

*ឬថា បុគ្គលណា ប្រើជើងទាំងពីរជាន់ញាំញីផ្ទៃចក្រវាល១០,០០០ ដែល ពេញដោយអណ្តាតភ្លើង និងរងើកភ្លើង ហើយទៅដល់ត្រើយ បុគ្គល នោះរមែងដល់ភាពជាព្រះពុទ្ធ។*

*ឬថា បុគ្គលណា ប្រើជើងទាំងពីរជាន់ញាំញីផ្ទៃចក្រវាល ១០,០០០ ដែលពេញដោយភ្នំភ្លើង ហើយទៅដល់ត្រើយ បុគ្គលនោះរមែងដល់ ភាពជាព្រះពុទ្ធ។*

*ឬថាបុគ្គលណា ហែលឆ្លងផ្ទៃចក្រវាល១០,០០០ ដែលពេញដោយទឹក ក្តៅ ប្រៀបដូច**លោហកុម្ភីនរក** ហើយទៅដល់ច្រាំង បុគ្គលនោះរមែង ដល់ភាពជាព្រះពុទ្ធ។*

*ឬថា បុគ្គលណា ប្រើជើងទាំងពីរ ជាន់ញាំញីផ្ទៃចក្រវាល១០,០០០ ដែលពេញដោយខ្សាច់ក្តៅ ដែលឆេះកើតជាភ្លើងក្តៅ ហើយទៅដល់ ត្រើយ បុគ្គលនោះរមែងដល់ភាពជាព្រះពុទ្ធ។*

ឬថា បុគ្គលណា កាប់ធ្លារផ្ទៃចក្រវាល១០,០០០ ដេរដាសដោយគុម្ពឫស្សី ដែលមានបន្លា ញាំញី ហើយទៅដល់ត្រើយ បុគ្គលនោះរមែងដល់ភាព ជាព្រះពុទ្ធ។

ឬថា បុគ្គលណា ប្រើជើងទាំងពីរ ជាន់ញាំញីផ្ទៃចក្រវាល១០,០០០ ដែលពេញដោយមុខកាំបិត ហើយទៅដល់ត្រើយ បុគ្គលនោះរមែងដល់ ភាពជាព្រះពុទ្ធ។

ឬថា បុគ្គលណាកាប់ផ្ទៃចក្រវាល១០,០០០ ដោយលំពែង ដែលពេញ ដោយផ្ទៃកាំបិត ហើយប្រើជើងជាន់ផ្ទៃចក្រវាល ដែលដេរដាសដោយ មុខកាំបិត រួចទៅដល់ត្រើយ បុគ្គលនោះរមែងដល់ភាពជាព្រះពុទ្ធ"។

ព្រះរាជាសាគលចក្រពត្តិ ត្រាស់ទូលតបថា៖

"**ទុក្ករកម្ម** ដែលព្រះអង្គ បានត្រាស់ហើយនេះ មិនមែនជាអំពើលំបាក សម្រាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គនឹងលូនទៅដោយទ្រូងខាងលើផេះក្តៅ ជាដើមនោះ ហើយអាចទៅដល់ត្រើយទាំងនោះបាន។

ប្រសិនបើសព្វញ្ញុតញ្ញាណ មាននៅខាងក្រោម **មហាអវីចិនរក**សោត ខ្ញុំ ព្រះអង្គនឹងមុជចុះទៅ ហើយកាន់យកសព្វញ្ញុតញ្ញាណនោះ ការធ្វើនេះ ជាភារៈរបស់ខ្ញុំព្រះអង្គ"។

លំដាប់នោះព្រះភគវា ពិចារណាដោយ**អនាគតំសញ្ញាណ** ឃើញការ មិនមានអន្តរាយនៃបណិធាន របស់ព្រះរាជា ទ្រង់ជ្រាបថា **កន្លងទៅ១៣ អសង្ខេយ្យ និង១សែនកប្បអំពីកប្បនេះទៅ ព្រះរាជាអង្គនេះនឹងបានត្រាស់ជា**

**ពុទ្ធបណិធាន**

*ព្រះពុទ្ធ ដូចជាតថាគតដែរ និងមានព្រះនាមថាគោតម នៅក្នុងកប្បមួយឈ្មោះភទ្ទកប្ប ដែលប្រដាប់ដោយព្រះពុទ្ធ៥អង្គ។*

*រូបព្រះពុទ្ធបុរាណសក្យមុនី ត្រាស់ថា៖*

*"បពិត្រមហារាជ បើព្រះអង្គប្រាថ្នាសព្វញ្ញុតញ្ញាណ ចូរព្រះអង្គបំពេញបារមីទាំង៣០ប្រការគឺ បារមី១០ ឧបបារមី១០ បរមត្ថបារមី១០ និងមហាបរិច្ចាគ៥ ដែលព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ធ្លាប់បានបំពេញហើយ។*

*បារមី១០ តើដូចម្ដេច ?*

*បារមី១០ គឺ៖*

១.ទានបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺទាន

២.សីលបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺសីល

៣.នេក្ខម្មបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺនេក្ខម្មៈ

៤.បញ្ញាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺបញ្ញា

៥.វីរិយបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺវីរិយៈ

៦.ខន្តិបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺខន្តី

៧.សច្ចបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺសច្ចៈ

៨.អធិដ្ឋានបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺអធិដ្ឋាន

៩.មេត្តាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺមេត្តា

១០.ឧបេក្ខាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺឧបេក្ខា។

*មហាបរិច្ចាគ៥ តើដូចម្ដេច ?*

**មហាបរិច្ចាគ៥ គឺៈ**

១. ធនបរិច្ចាគោ *ការបរិច្ចាគទ្រព្យ*

២. បុត្តបរិច្ចាគោ *ការបរិច្ចាគបុត្រ*

៣. ទារបរិច្ចាគោ *ការបរិច្ចាគប្រពន្ធ*

៤. អង្គបរិច្ចាគោ *ការបរិច្ចាគអវយវៈ*

៥. ជីវិតបរិច្ចាគោ *ការបរិច្ចាគជីវិត។*

*បពិត្រមហារាជ ព្រោះហេតុដែលជនទាំងឡាយ កាលប្រាថ្នាភាពជាព្រះពុទ្ធ មិនបំពេញបារមីទាំងឡាយ១០ និងមិនបរិច្ចាគមហាបរិច្ចាគ៥នោះទេ ឈ្មោះថាបានជាព្រះពុទ្ធរមែងមិនមាន ព្រោះដូច្នោះ ចូរព្រះអង្គបំពេញបារមី១០នេះឱ្យពេញ និងចូរបរិច្ចាគមហាបរិច្ចាគ៥ នេះចុះ״។*

*ព្រះពោធិសត្វ ស្តាប់ពុទ្ធដីកានោះហើយ ទ្រង់កើតបីតិសោមនស្ស ហាក់ដូចជាបានសព្វញ្ញុតញ្ញាណក្នុងថ្ងៃស្អែក រួចទ្រង់បាចសាចរោយរាយរតនៈ៧ប្រការ មួយអន្លើដោយឥស្សរិយយស នៃស្តេចចក្រពត្តិក្នុងព្រះពុទ្ធសាសនា ហើយព្រះអង្គបួស សិក្សារៀនសូត្រចេះចាំព្រះត្រៃបិដក ញុំាងឈាន និងអភិញ្ញាឱ្យកើតឡើង ជាអ្នកមានឈានមិនសាបសូន្យ ក្នុងពេលអស់ព្រះជន្មបានកើតក្នុងព្រហ្មលោក។*

*សូម្បីក្នុងគ្រានោះ ព្រះនាងយសោធរាថេរី បានជាឥត្ថិរ័តន៍របស់ព្រះបាទសាគលចក្រពត្តិ ព្រះនាងជាមិត្តសម្លាញ់ក្នុងការបំពេញបារមី និងបាទ-បរិចារិកា[៣៤]។*

---

[៣៤] **បាទបរិចារិកា** ( ន. ) *[បាទៈបរិចា រិកា ប្អ--ប៉ៈ រិ--]  ( សំ., បា. ) ស្ត្រីអ្នកបម្រើជិតជើង (ភរិយា); ច្រើននិយាយក្លាយជា :  បាទបរិចាក ។*

## ពុទ្ធបណិធាន

*ក្នុងសព្វកប្បអសង្ខេយ្យនោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ៤៩,៩៩៩ព្រះអង្គ សូម្បីដទៃ*[៣៥] *កើតឡើង។ ព្រះពោធិសត្វរបស់យើងទាំងឡាយ និងព្រះនាងយសោធរា ជាអ្នកមានឆន្ទៈស្មើគ្នា មានសេចក្តីពេញចិត្តដូចគ្នា បានញ៉ាំងមហាទានរួមគ្នាឱ្យប្រព្រឹត្តទៅក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ មានព្រះពុទ្ធបុរាណគោតមជាដើម ហើយបានធ្វើវចីភេទ (ការបញ្ចេញវាចា) និងធ្វើ* ***វាចាបណិធានដើម្បីពុទ្ធត្តៈ*** *(ភាពជាព្រះពុទ្ធ) និង* ***ពោធិសត្តបរិចារិកត្តៈ*** *(ភាពជាអ្នកបម្រើព្រះពោធិសត្វ, ភាពជាកន្សែរសារពេជ្ររបស់ព្រះពោធិសត្វ)។*

តេន វុត្តំ អបទានេ– *ព្រោះហេតុនោះ ទើបព្រះនាងពោលទុកអបទានថា៖*

ព្រហ្មទេវញ្ច សម្ពុទ្ធំ,      គោតមំ លោកនាយកំ;
អញ្ញេសំ លោកនាថានំ,      សង្គមំ តេ ពហុំ មយា។

*ខ្ញុំមានការគប់រកព្រះលោកនាថទាំងឡាយ ដទៃច្រើនអង្គ (ព្រោះអាស្រ័យ) នូវព្រះសម្ពុទ្ធ ព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធព្រះនាមគោតម ដែលជាព្រះលោកនាយក។*

*(យសោធរាថេរិយាបទាន បិដកលេខ ៧៦ ទំព័រ ១៧៩ តែមានការប្រែផ្សេង)*

ព្រហ្មទេវញ្ច សម្ពុទ្ធំ,      គោតមំ លោកនាយកំ;
អញ្ញេសំ លោកនាថានំ,      សង្គមំ តេហិ នោ ពហុ។

*ការគប់រកនៃព្រះលោកនាថទាំងឡាយដទៃច្រើន (ព្រោះអាស្រ័យ) ព្រះសម្ពុទ្ធព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធព្រះនាមគោតម ដែលជាព្រះលោកនាយក យើងខ្ញុំ (បានសម្តែងហើយ) ។*

*(យសោធរាបមុខអដ្ឋារសកិក្ខុនីសហស្សអបទាន បិដកលេខ ៧៦ ទំព័រ ១៩៧ តែមានការប្រែផ្សេង)*

---

[៣៥] ***<u>បញ្ជាក់៖</u> ព្រះសម្មាសម្ពុទ្ធទាំងឡាយ៤៩,៩៩៩ព្រះអង្គសូម្បីដទៃ*** *នេះ បើរាប់ទាំងព្រះសម្មាសម្ពុទ្ធបុរាណសក្យមុនីគោតម ផង ក្នុងសព្វកប្បអសង្ខេយ្យមានព្រះពុទ្ធកើតឡើង ៥០,០០០អង្គ។*

*កាលសព្វភទ្ទអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***សព្វផុល្លអសង្ខេយ្យ****, ក្នុងសព្វផុល្លអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ៦០,០០០អង្គ កើតឡើង។ ព្រះពោធិសត្វ និងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបញ្ចេញវចីភេទ និងធ្វើវាចាបណិធាន។*

*កាលសព្វផុល្លអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***សព្វរតនអសង្ខេយ្យ****, ក្នុងសព្វរតនអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ៧០,០០០អង្គ កើតឡើង។*

*កាលសព្វរតនអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***ឧសភក្ខន្ធអសង្ខេយ្យ****, ក្នុងឧសភក្ខន្ធអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ៨០,០០០អង្គ កើតឡើង។*

*កាលឧសភក្ខន្ធអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***មានិភទ្ទអសង្ខេយ្យ****, ក្នុងមានិភទ្ទអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ៩០,០០០អង្គ កើតឡើង។*

*កាលមានិភទ្ទអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***បទុមអសង្ខេយ្យ****, ក្នុងបទុមអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ២០,០០០អង្គ កើតឡើង។*

*កាលបទុមអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***ឧសភអសង្ខេយ្យ****, ក្នុងឧសភអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ១០,០០០អង្គ កើតឡើង។*

*កាលឧសភអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា* ***ខន្ធុត្តមអសង្ខេយ្យ****, ក្នុងខន្ធុត្តមអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ៥,០០០អង្គ កើតឡើង។*

**ពុទ្ធបណិធាន**

*កាលខន្ធុត្តមអសង្ខេយ្យនោះកន្លងផុតទៅ មានអសង្ខេយ្យដទៃ ឈ្មោះថា**សព្វមាលអសង្ខេយ្យ**, ក្នុងសព្វមាលអសង្ខេយ្យនោះ មានព្រះសម្មាសម្ពុទ្ធ ២,០០០អង្គ កើតឡើង។ ព្រះពោធិសត្វ និងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយនោះ ហើយបញ្ចេញវចីភេទ និងធ្វើវាចាបណិធាន។*

*ដោយប្រការដូច្នេះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ៣៨៧,០០០អង្គ កើតឡើងក្នុង៩អសង្ខេយ្យ នេះ ឈ្មោះថា **នវាសង្ខេយ្យវាចក:**។*

*ព្រះពោធិសត្វ និងព្រះនាងយសោធរា បានថ្វាយមហាទានក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ ដែលកើតឡើងក្នុងរវាង៩អសង្ខេយ្យ ហើយបញ្ចេញវចីភេទ (ការពោលដោយវាចា) និងធ្វើ**វាចាបណិធានដើម្បីពុទ្ធត្ត:** (ភាពជាព្រះពុទ្ធ) និង**ពោធិសត្តបរិចារិកត្ត:** (ភាពជាអ្នកបម្រើព្រះពោធិសត្វ, ភាពជាកន្សៀសារពេជ្ជរបស់ព្រះពោធិសត្វ)។*

*ព្រោះហេតុនោះ ទើបលោកពោលទុកថា៖*

"សព្វភទ្ទោ សព្វផុល្លោ, សព្វរតនោ ឧសភក្ខន្ធោ;
មាណិភទ្ទោ ច បទុមោ, ឧសភោ ច ខន្ធុត្តមោ។
សព្វមាលោ អសង្ខ្យេយ្យោ, នវមោតិ បវុច្ចតិ;
វចីភេទប្បត្តនា មយ្ហំ, និទ្ទិដ្ឋា នវាសង្ខ្យេយ្យា។
សព្វភទ្ទេ អសង្ខ្យេយ្យេ, រាជា អាសិ មហាប្ពលោ;
នគរេ ធញ្ញវតិយា, សាគលោ នាម ខត្តិយោ។
ស សំសាគរន្តំ បបរឹ, វដ្ឋំ ការេមហំ តទា។
ចតុនីបេហិ រតនេហិ, សន្តប្បេត្វា មហាជនំ;
ឧប្បន្នភាវំ ពុទ្ធស្ស, សុត្វាបិ បសីទយឹំ។

ពុទ្ធស្ស សន្តិកំ គន្ត្វា, តស្ស ធម្មំ សុណិំ តទា;
សាធុការំ បវត្តេសិំ, មហាទានំ បវត្តយិំ។
បាសាទំ កុដិមណ្ឌបំ, រត្តិដ្ឋានញ្ច ចង្កមំ;
ជន្តាឃរំ ភោជនសាលំ, ការេត្វា ទ្វារកោដ្ឋកំ។
សុវត្តចន្ទនំ សព្វំ, សុវិភត្តំ មនោរមំ;
ទសសតសហស្សានិ, ការបេត្វា ចន្ទនេន;
អទាសិំ សាក្យមុនិនោ, វចីភេទេន បត្តនេ។
“អធិការំ ករិត្វាន, វន្ទិត្វា ឥទមព្រវិំ;
អហំ ពុទ្ធោ ភវិស្សាមិ, គោតមោ សក្យបុង្គវោ។
តទា មេ វចនំ សុត្វា, គោតមោ នាម នាយកោ;
សំឃមជ្ឈេ និសិន្នោវ, ឥទំ វចនមព្រវិ។
ទុក្ករំ ខោ មហារាជ, ពុទ្ធធម្មំ គវេសិតុ;
យទិ ពុទ្ធោ ភវេយ្យាសិ, វីរិយំ ការំ ទុក្ករំ។
កុក្កុឡំ អង្គារំ សេលំ, សន្តត្តំ ជលិតោទកំ;
មរុម្ពំ វេឡុខុរញ្ចេវ, ទសសហស្សេហិ បូរិតំ;
មទ្ទមានោ ចរំ តត្ថ, តតោ ទុក្ករំ ពោធិយា។
យថា ឧទុម្ពរំ បុប្ផំ, គវេសន្តោ នរោ ឥធ;
ន តំ បុប្ផម្បិ លច្ឆតិ, តតោ ពោធិ សុទុលភា។
ពុទ្ធស្ស វចនំ សុត្វា, ភិយ្យោ ចិត្តំ បសីទយិំ;
តស្ស បាទេ នមស្សិត្វា, ឥទំ វចនមព្រវិំ។
“សមតិក្កមេយ្យំ តំ សព្វំ, វីរិជំ កត្វាន ទុក្ករំ;
ឧរសាបិ និបតិត្វាន, បាបុណិស្សាមិ ពោធិយំ។
សចេ តេ ពោធិ អវីចិម្ហិ, និមុជ្ជិត្វាន នាយកោ;
បាបុណិស្សាមិ តំ ពោធិំ, មនោ មេ វជិរូបម”ន្តិ។
តស្ស មេ វចនំ សុត្វា, សម្ពុទ្ធោ ឥទមព្រវិ;
ពុទ្ធការកធម្មានិ, កថេស្សាមិ សុណោហិ មេ។

## ពុទ្ធបណិធាន

"ទុក្ករំ ខោ មហារាជ,　　ពុទ្ធធម្មគវេសនំ;
សចេ ពុទ្ធោ ភវេយ្យាសិ,　　វីរិយំ កាត្វាន ទុក្ករំ។
មនុស្សត្តំ លិង្គសម្បត្តិ,　　ហេតុ សត្ថារទស្សនំ;
បព្វជ្ជា គុណសម្បត្តិ,　　អធិការោ ច ឆន្ទតា;
អដ្ឋធម្មសមោធានា,　　អភិនីហារោ សមិជ្ឈតិ។
ញាណំ សីលញ្ច នេក្ខម្មំ,　　បញ្ញា វីរិយេន បញ្ចមំ;
ខន្តិ សច្ចមធិដ្ឋានំ,　　មេត្តុបេក្ខា ឥមា ទស។
ពុទ្ធការណធម្មា តេ,　　បរិបូរេហិ សព្វទា;
សព្វសត្តហិតត្ថាយ,　　បូរេហិ ទស បារមី"តិ។
តស្ស តំ វចនំ សុត្វា,　　ចក្កវត្តិ មហិទ្ធិកោ;
ហដ្ឋតុដ្ឋោ បមោទិតោ,　　ឥទំ វចនំ មព្រវី។
ភន្តេ ឯតានិ សព្វានិ,　　ការយិស្សាមហំ សទា;
យថា មយ្ហមក្ខាសិ,　　សព្វេ ទុក្ករការិយេ។
តស្ស មេ វចនំ សុត្វា,　　គោតមោ សក្យបុង្គវោ;
ទទ្យំ តណ្ហាធ វីរិយំ,　　មា និវត្ត បរក្កម។
ភវិស្សសិ ត្វំ សម្ពុទ្ធោ,　　លោកេ លោកស្ស នាយកោ;
ទសពុទ្ធការេ ធម្មេ,　　សចេ កាតុ សក្ខិស្សសិ។
សព្វភទ្ទេ អសង្ខ្យេយ្យេ,　　អធិការំ អហំ កតោ;
បណ្ណាសពុទ្ធសហស្សានំ,　　មហាទានំ បវត្តយឹ។
សព្វផុល្លេ អសង្ខ្យេយ្យេ,　　អធិការំ អហំ កតោ;
សដ្ឋិពុទ្ធសហស្សានំ,　　មហាទានំ បវត្តយឹ។
សព្វរតនេ អសង្ខ្យេយ្យេ,　　អធិការំ អហំ កតោ;
សត្តតិពុទ្ធសហស្សានំ,　　មហាទានំ បវត្តយឹ។
ឧសភក្ខន្ធេ អសង្ខ្យេយ្យេ,　　អធិការំ អហំ កតោ;
អសីតិពុទ្ធសហស្សានំ,　　មហាទានំ បវត្តយឹ។
មានិភទ្ទេ អសង្ខ្យេយ្យេ,　　អធិការំ អហំ កតោ;

នវុតិពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
បទុមម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ កតោ;
វីសពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
ឧសភម្ហិ អសង្ខ្យេយ្យេ, អធិការំ អហំ កតោ;
ឆសដ្ឋំ ពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
ខន្ធុត្តមេ អសង្ខ្យេយ្យេ, អធិការំ អហំ កតោ;
បញ្ចពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
សព្វមាលេ អសង្ខ្យេយ្យេ, អធិការំ អហំ កតោ;
ទ្វិដ្ឋំ ពុទ្ធសហស្សានំ, មហាទានំ បវត្តយឹ។
តីណិ សត្តសហស្សានិ, អសីតិសហស្សានិ ច;
អថោ សត្តសហស្សានិ, សព្វេ ពុទ្ធា ហិ បិណ្ឌិតា។
ឯត្តកានំ មហេសីនំ, វចនសា បណិធឹ អហំ;
ជាតេន មេ សមោ នត្ថិ, ឯសា មេ ទានបារមិ៉។

*សព្វភទ្ទអសង្ខេយ្យ១ សព្វផុល្លអសង្ខេយ្យ១ សព្វរតនអសង្ខេយ្យ១ ឧសភក្ខន្ធអសង្ខេយ្យ១ មានិភទ្ទអសង្ខេយ្យ១ បទុមអសង្ខេយ្យ១ ឧសភ-អសង្ខេយ្យ១ ខន្ធុត្តមអសង្ខេយ្យ១ និង សព្វមាលអសង្ខេយ្យ លោកពោលថា ជាអសង្ខេយ្យទី៩។*

*សេចក្តីប្រាថ្នា ដោយការបញ្ចេញវាចារបស់តថាគត ត្រូវលើកសម្តែងឡើង ដោយអសង្ខេយ្យទាំងឡាយ៩ នេះ។*

*ក្នុងសព្វភទ្ទអសង្ខេយ្យ តថាគត គឺជាក្សត្រ ព្រះនាមសាគល ជាព្រះរាជា ដែលមានកម្លាំងច្រើន ក្នុងធញ្ញវតីនគរ ក្នុងកាលនោះ តថាគតគ្រប់គ្រងរាជ្យ ដែលមានផែនដី មានសាគរជាទីបំផុត។*

*តថាគត ញុំាងមហាជន ដែលមកអំពីទ្វីបទាំង៤ ឱ្យឆ្អែតដោយរតនៈ រួចបានស្តាប់ថា ព្រះពុទ្ធឧប្បត្តិហើយ ក៏មានចិត្តជ្រះថ្លា។*

*ក្នុងកាលនោះ តថាគត ទៅកាន់សម្នាក់ព្រះពុទ្ធ បានស្តាប់ពាក្យរបស់ព្រះអង្គ បានឱ្យសាធុការ និងបានថ្វាយមហាទាន។*

*តថាគត ឱ្យសាងប្រាសាទ កុដិ មណ្ឌប ទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ ទីចង្ក្រម រោងភ្លើង សាលាឆាន់ និង ខ្លោងទ្វារ។*

*តថាគត ឱ្យសាងប្រាសាទ១០០,០០០ខ្នង ដែលប្រាសាទទាំងអស់ ត្រូវធ្វើដោយខ្លឹមចន្ទន៍ក្រហម ដែលចែកល្អហើយជាទីមនោរម្យ ថ្វាយដល់ព្រះសាក្យមុនី ហើយបញ្ចេញវាចាប្រាថ្នា។*

*តថាគត បានធ្វើអធិការហើយ ថ្វាយបង្គំក្រាបទូលថា សូមឱ្យខ្ញុំព្រះអង្គបានជាព្រះពុទ្ធមានព្រះនាមថា **គោតមោ សក្យបុង្គវោ**”។*

*គ្រានោះ ព្រះលោកនាយកព្រះនាមគោតម ទ្រង់ប្រថាប់នៅកណ្តាលសង្ឃនោះឯង ស្តាប់ពាក្យរបស់តថាគតហើយ ត្រាស់ព្រះតម្រាស់ថាៈ*

*“បពិត្រមហារាជ ការស្វែងរកពុទ្ធការកធម៌ ធ្វើបានដោយក្រ បើព្រះអង្គប្រាថ្នាជាព្រះពុទ្ធ សូមព្រះអង្គធ្វើវិរិយៈ ដែលគេធ្វើបានដោយក្រផ្សេងៗ។*

*ឧបមាដូចជាដើរជាន់ចក្រវាល១០,០០០ ដែលពេញដោយផេះក្តៅ រងើកភ្លើង ទឹកដែលឆេះ ខ្សាច់ក្តៅ គុម្ពឫស្សីដែលមានបន្លា កាំបិត ហើយទៅដល់ត្រើយ ការស្វែងរកពោធិញាណ ជារបស់ធ្វើបានដោយក្រជាងនោះ។*

*នរជនក្នុងលោកនេះ កាលស្វែងរកផ្កាឧទុម្ពរ រមែងមិនបានយ៉ាងណា*

*ពោធិញាណ ជារបស់កម្រជាងការស្វែងរកផ្កាឧទុម្ពរនោះទៀត"។*

*តថាគត ស្តាប់ព្រះតម្រាស់ របស់ព្រះពុទ្ធនោះហើយ មានចិត្តជ្រះថ្លាក្រៃលែង ឡើងបង្គំព្រះបាទរបស់ព្រះពុទ្ធនោះ ហើយពោលពាក្យនេះថា៖*

*"ខ្ញុំព្រះអង្គនឹងធ្វងឧបសគ្គទាំងអស់ ខ្ញុំព្រះអង្គនឹងធ្វើអំពើដែលធ្វើបានដោយក្រផ្សេងៗ នឹងក្រាបលូនទៅ សូម្បីដោយទ្រូង ដើម្បីនឹងបានសម្រេចពោធិញាណ។*

*បពិត្រព្រះលោកនាយក បើពោធិញាណមានក្នុង**អវីចីនរក**សោត ក៏ខ្ញុំព្រះអង្គនឹងមុជចុះឱ្យដល់ពោធិញាណ, ចិត្តរបស់ខ្ញុំប្រៀបដូចពេជ្រ"។*

*ព្រះសម្ពុទ្ធស្តាប់សម្តីរបស់តថាគតហើយ បានត្រាស់ពាក្យនេះថា៖*

*"តថាគតនឹងសម្តែងពុទ្ធការកធម៌ សូមព្រះអង្គស្តាប់ពុទ្ធការកធម៌នោះចុះ។*

*បពិត្រមហារាជ ការស្វែងរកពុទ្ធការកធម៌ ជាអំពើដ៏កម្រ បើព្រះអង្គគប្បីជាព្រះពុទ្ធ សូមព្រះអង្គធ្វើទុក្ករកម្មដែលមានប្រការផ្សេងៗចុះ។*

*អភិនីហារ រមែងសម្រេច ព្រោះ**អដ្ឋធម្មសមោធាន** ការប្រជុំព្រមនៃធម៌៨ប្រការ គឺ៖*

១.មនុស្សត្តំ *ភាពជាមនុស្ស*

២.លិង្គសម្បត្តិ *ការដល់ព្រម ដោយភេទជាបុរស*

៣.ហេតុ *ហេតុគឺឧបនិស្ស័យត្រូវបានព្រះអរហត្ត និង **ហេតុសម្បទា** ដែលបានធ្វើសេចក្តីប្រាថ្នាដោយ**មនោបណិធាន** និង **វចីបណិធាន**អំពីមុន*

៤.សត្ថារទស្សនំ ការបានជួប បានឃើញព្រះសាស្តា

៥.បព្វជ្ជា ការបំពេញបព្វជ្ជា

៦.គុណសម្បត្តិ ការដល់ព្រមដោយគុណ គឺបានសមាបត្តិ៨ និងអភិញ្ញា៥

៧.អធិការោ អំពើដ៏ក្រៃលែង គឺលះបង់ជីវិត ដើម្បីព្រះពុទ្ធ

៨.ឆន្ទតា ភាពជាអ្នកមានឆន្ទៈ ពេញចិត្តប្រាថ្នាព្រះសព្វញ្ញុតញ្ញាណ។

**ព្រមទាំងបារមី១០** គឺៈ

១.ទានបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺទាន

២.សីលបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺសីល

៣.នេក្ខម្មបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺនេក្ខម្មៈ

៤.បញ្ញាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺបញ្ញា

៥.វិរិយបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺវិរិយៈ

៦.ខន្តិបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺខន្តី

៧.សច្ចបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺសច្ចៈ

៨.អធិដ្ឋានបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺអធិដ្ឋាន

៩.មេត្តាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺមេត្តា

១០.ឧបេក្ខាបារមី គុណជាតិ ដែលនាំឱ្យដល់ព្រះនិព្វានគឺឧបេក្ខា។

សូមព្រះអង្គ បំពេញពុទ្ធករណធម៌ទាំងនោះ ឱ្យពេញបរិបូណ៌សព្វកាល

សូមព្រះអង្គ បំពេញបារមី១០ ដើម្បីជាប្រយោជន៍ ដល់សព្វសត្វ។

ស្តេចចក្រពត្តិដែលមានឫទ្ធិច្រើន ស្តាប់ព្រះតម្រាស់របស់ព្រះពុទ្ធនោះ ហើយ ទ្រង់មានចិត្តត្រេកអររីករាយ ត្រាស់ពាក្យនេះថា៖

"បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើធម៌ទាំងអស់នេះ

ឱ្យសព្វកាល គឺថា ខ្ញុំព្រះអង្គនឹងធ្វើអំពើ ដែលគេធ្វើបាន

ដោយក្រនេះទាំងអស់ ឱ្យដូចព្រះអង្គដែលបានត្រាស់ណែនាំ ដល់ខ្ញុំព្រះ

អង្គ"។

ព្រះពុទ្ធគោតមសក្យបុង្គវោ បានស្តាប់ពាក្យរបស់តថាគតហើយ ទើប ត្រាស់ថា៖

"ចូរព្រះអង្គផ្តង់សេចក្តីព្យាយាមឱ្យមាំចុះ កុំបែរត្រឡប់ឡើយ ចូរយាង

ទៅមុខចុះ។

បើព្រះអង្គ អាចធ្វើនូវពុទ្ធការកធម៌ទាំង១០នេះ ព្រះអង្គនឹងបានជាព្រះ

សម្ពុទ្ធ ជាលោកនាយកក្នុងលោក"។

ក្នុងសព្វភទ្ទអសង្ខេយ្យ តថាគត បានធ្វើអធិការទុកហើយ តថាគតបាន

ញុំាងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៥០,០០០អង្គ។

ក្នុងសព្វផុល្លអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន

ញុំាងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៦០,០០០ អង្គ។

ក្នុងសព្វរតនអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន

ញុំាងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៧០,០០០អង្គ។

ក្នុងឧសភក្ខន្ធអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន

ញុំាងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៨០,០០០ អង្គ។

**ពុទ្ធបណិធាន**

ក្នុងមានិកទ្ធអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន ញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ ៩០,០០០អង្គ។

ក្នុងបទុមអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន ញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ២០,០០០អង្គ។

ក្នុងឧសភអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន ញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ១០,០០០ អង្គ។

ក្នុងខន្ធុត្តមអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន ញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ៥,០០០ អង្គ។

ក្នុងសព្វមាលអសង្ខេយ្យ តថាគតបានធ្វើអធិការទុកហើយ តថាគតបាន ញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ថ្វាយដល់ព្រះពុទ្ធ២,០០០អង្គ។

ព្រះពុទ្ធទាំងអស់ចំនួន៣៨៧,០០០អង្គ ព្រះពុទ្ធទាំងឡាយនោះសុទ្ធតែ ជាបណ្ឌិត៉។

តថាគត បញ្ចេញវាចាប្រាថ្នាចំពោះព្រះពុទ្ធ ជាមហេសីមានប្រមាណ ប៉ុណ្ណោះ បុគ្គលដែលស្មើនឹងតថាគតដោយទាន រមែងមិនមាន ទាំងនេះជាទាន បារមីរបស់តថាគត។

ការពណ៌នាបាទគាថា ៩វាសង្ខ្យេយ្យវាចិកំ នេះ ចប់បរិបូណ៌ហើយ ។

**ទូរេនិទានកថា ចប់ ៕**

# ជំពូកទី៤
# អវិទូរេនិទាន
# ( កាយវាចាចិត្តបណិធាន )

## និទានកថា

# សុមេធបណ្ឌិតទទួលពុទ្ធព្យាករណ៍

## លើកដំបូង

# អំពីព្រះសម្មាសម្ពុទ្ធទីបង្ករ

# រឿងរ៉ាវខាងក្នុង៤អសង្ខេយ្យ និង១សែនកប្ប

# ឈ្មោះថា អវិទូរេនិទាន

## សុមេធបណ្ឌិតទទួលពុទ្ធព្យាករណ៍

## លើកដំបូង

## អំពីព្រះសម្មាសម្ពុទ្ធទីបង្ករ



ឈ្មោះថា អវិទូរេនិទាន
សុមេធបណ្ឌិត ទទួលពុទ្ធព្យាករណ៍
លើកដំបូង អំពីព្រះសម្មាសម្ពុទ្ធទីបង្ករ

## កាយវាចាមនោបណិធានចតុរសង្ខ្យេយ្យកថា

*ក្នុងពាក្យថា កប្បសតសហស្សានិ ចត្តារិ អសង្ខ្យេយ្យានិ កាយវាចា-មនសាហិ ៤អសង្ខេយ្យ និង១សែនកប្ប ជាការប្រាថ្នាដោយកាយ វាចា ចិត្ត នេះ មានសេចក្តីដូចតទៅនេះ៖*

សេលោ ភាសោ ជេយ្យោ ចេវ, រុចិយោ ច អសង្ខ្យេយ្យោ;
ចត្តារោ តេ អសង្ខ្យេយ្យា, វិជិចាតាតិ វុច្ចរេ។

*អសង្ខេយ្យទាំងឡាយ៤នោះគឺ សេលអសង្ខេយ្យ១ ភាសអសង្ខេយ្យ១ ជេយ្យអសង្ខេយ្យ១ ចុរិយអសង្ខេយ្យ១ ត្រូវបានលោកហៅថា វិនិបាត-អសង្ខេយ្យ។*

*ក្នុងបណ្តាបទទាំងនោះ បទថា សេលោ បានដល់ ឈ្មោះថា សេល-អសង្ខេយ្យ ជាអសង្ខេយ្យខាងដើម នៃអសង្ខេយ្យទាំង៤នោះ។*

*ទីបំផុតនៃសព្វមាលអសង្ខេយ្យ ចូលមកក្នុងសេលអសង្ខេយ្យនោះ ក្នុងកប្បមួយដែលមានឈ្មោះថា**សារមណ្ឌៈ** ព្រះពុទ្ធទាំងឡាយ៤អង្គគឺ **ព្រះពុទ្ធតណ្ហង្ករ១ ព្រះពុទ្ធមេធង្ករ១ ព្រះពុទ្ធសរណង្ករ១ ព្រះពុទ្ធទីបង្ករ១** បានឧប្បត្តិឡើង។*

# ១. តណ្ហង្ករពុទ្ធប្បវត្តិ

## *ការឧប្បត្តិឡើងនៃព្រះពុទ្ធតណ្ហង្ករ*

*បណ្ដាព្រះពុទ្ធទាំង៤អង្គនោះ **ព្រះតណ្ហង្ករពោធិសត្វ** បានបំពេញបារមីទាំងឡាយអស់១៦អសង្ខេយ្យ និង១សែនកប្ប ហើយបានកើតក្នុងព្រះគភ៌នៃទេវី ដែលមានឈ្មោះថា **សុនន្ទា** ជាអគ្គមហេសី របស់ព្រះរាជាព្រះនាមថា **សុនន្ទ** ក្នុងនគរឈ្មោះបុប្ផវតី។*

*ទ្រង់គ្រប់គ្រងផ្ទះអស់១០,០០០ឆ្នាំ បន្ទាប់មក ចេញសាងមហាភិនេស្រ្កមណ៍ ធ្វើមហាបណិធានអស់៧ថ្ងៃ បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ នៅគល់**សត្តបណ្ណិពោធិព្រឹក្ស** (ដើមដើងទា ឬដើមសត្បា)។*

*ព្រះពុទ្ធ**តណ្ហង្ករ** ទ្រង់តាំងនៅរហូតព្រះជន្មាយុ១០០,០០០ឆ្នាំ ទ្រង់ធ្វើពុទ្ធកិច្ចទាំងអស់ហើយ ព្រះអង្គក៏បរិនិព្វានទៅ។*

*ចំណែកព្រះពោធិសត្វ របស់យើងទាំងឡាយ ធ្វើអធិការក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធនោះហើយ តែមិនបានទទួលព្យាករណ៍ លោកចុតិចាកអត្តភាពនោះហើយ បានកើតក្នុងទេវលោក។*

## ២. មេធង្ករពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធមេធង្ករ*

*ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធតណ្ហង្ករទៅ ក្នុងកប្បនោះឯង **ព្រះមេធង្ករពោធិសត្វ** បំពេញបារមីទាំងឡាយពេញបរិបូណ៌ហើយ បានកាន់យកបដិសន្ធិក្នុងផ្ទៃព្រះទេវី ព្រះនាម**យសោធរា** ដែលជាអគ្គមហេសីរបស់ព្រះបាទ**សុទេវៈ** ក្នុង**យឃរនគរ**។*

*ទ្រង់គ្រប់គ្រងផ្ទះអស់១៨,០០០ឆ្នាំហើយចេញសាងមហាភិនេស្រ្កមណ៍ ទ្រង់ធ្វើមហាបណិធានកន្ទះខែ បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ នៅគល់**គីសុក-ពោធិព្រឹក្ស** (ដើមរលួសបាយឬដើមចារ)។*

*ព្រះពុទ្ធ**មេធង្ករ** ទ្រង់តាំងនៅរហូតព្រះជន្មាយុ៩០,០០០ឆ្នាំ ទ្រង់ធ្វើពុទ្ធ-កិច្ចទាំងអស់ហើយ ព្រះអង្គក៏បរិនិព្វានទៅ។*

*ចំណែកព្រះពោធិសត្វ របស់យើងទាំងឡាយ ធ្វើអធិការក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធអង្គនោះរួច តែមិនបានទទួលព្យាកណ៍ លុះលោកចុតិចាកអត្តភាពនោះហើយ ក៏បានកើតក្នុងទេវលោក។*

## ៣. សរណង្ករពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធសរណង្ករ*

*ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធមេធង្ករទៅ ក្នុងកប្បនោះឯង **ព្រះសរណង្ករពោធិសត្វ** បំពេញបារមីទាំងឡាយពេញបរិបូណ៌ហើយ បានកាន់យកបដិសន្ធិក្នុងផ្ទៃព្រះទេវី ព្រះនាម**យសវតី** ដែលជាអគ្គមហេសី របស់ព្រះបាទ**សុមង្គល** ក្នុង**វិបុលនគរ**។*

*ទ្រង់គ្រប់គ្រងផ្ទះអស់៧,០០០ឆ្នាំ ហើយចេញសាងមហាភិនេស្ក្រមណ៍ ទ្រង់ធ្វើមហាបណិធានអស់១ខែ បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ នៅគល់**បាដលិពោធិព្រឹក្ស** (ដើមប្រនៀង)។*

*ព្រះពុទ្ធ**សរណង្ករ** ទ្រង់តាំងនៅរហូតព្រះជន្មាយុ៨០,០០០ឆ្នាំ ទ្រង់ធ្វើពុទ្ធកិច្ចទាំងអស់ហើយ ព្រះអង្គក៏បរិនិព្វានទៅ។*

*ចំណែកព្រះពោធិសត្វ របស់យើងទាំងឡាយ ធ្វើអធិការក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធអង្គនោះរួច តែមិនបានទទួលព្យាករណ៍ លុះលោកចុតិចាកអត្តភាពនោះហើយ ក៏ទៅកើតក្នុងទេវលោក។*

## ៤. ទីបង្ករពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធទីបង្ករ*

*ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធសរណង្ករទៅ ក្នុងកប្បនោះឯង* ***ព្រះទីបង្ករពោធិសត្វ*** *បំពេញបារមីទាំងឡាយពេញបរិបូណ៌ហើយ បានកាន់យកបដិសន្ធិក្នុងផ្ទៃព្រះទេវី ព្រះនាម**សុមេធា** ដែលជាអគ្គមហេសីរបស់ព្រះបាទ**សុទេវៈ** ក្នុង**អមរវតីនគរ**។*

*ទ្រង់គ្រប់គ្រងផ្ទះអស់១០,០០០ឆ្នាំ ទ្រង់ឃើញនិមិត្តទាំង៤ ហើយចេញសាងមហាភិនេស្រ្កមណ៍ ទ្រង់ធ្វើមហាបណិធានអស់១០ខែ បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ នៅគល់**បិប្ផលិពោធិព្រឹក្ស*** (ដើមល្វៀប)។

# សុមេធកថា

## *កថាពោលអំពីសុមេធបណ្ឌិត*

*ក្នុងពេលនោះ ព្រះពោធិសត្វ របស់យើងទាំងឡាយ កើតក្នុងត្រកូលព្រាហ្មណ៍ ដែលមានទ្រព្យច្រើនកោដិ ក្នុង**អមរវតីនគរ**នោះ ញាតិទាំងឡាយដាក់ឈ្មោះឱ្យលោកថា**សុមេធៈ**។*

*កាលមាតាបិតាលាចាកលោកទៅ ព្រះពោធិសត្វលះបង់ទ្រព្យសម្បត្តិទាំងអស់ឱ្យជាទាន ហើយបួសជាឥសី អាស្រ័យនៅនឹង**ធម្មិកបព៌ត** ក្នុងព្រៃហិមពាន្ត បរិភោគតែផ្លែឈើដែលជ្រុះឯង តាំងសេចក្តីព្យាយាម ដោយអំណាចនៃការអង្គុយ ការឈរ និងចង្ក្រម ក្នុងរវាង៧ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចសមាបត្តិ៨ និងអភិញ្ញា៥។*

*ព្រោះហេតុនោះ ទើបលោកពោលថា៖*

"ឯកាសង្ខ្យេយ្យាវសានេ, កប្បោ សារមណ្ឌកោ;
តណ្ហង្ករោ មេធង្ករោ, សរណង្ករោ ទីបង្ករោ;
ពុទ្ធា លោកគ្គនាយកា, ចត្តារោតេ មហាយសា។
តេសំ ចតុន្នំ ពុទ្ធានំ, តណ្ហង្ករស្ស សត្ថុនោ;
សុនន្ទោ នាម សោ រាជា, មាតា តស្ស សុនន្ទិសា;
សត្តបណ្ណាទុមោ ពោធិ, តណ្ហង្ករស្ស សត្ថុនោ។
សុនេហោ នាម សោ រាជា, មាតា តស្ស យសោធរា;
កិំសុកោ តស្ស សោ ពោធិ, មេធង្ករស្ស សត្ថុនោ។

សុមង្គលោ បិតា រាជា, មាតា យសវតី ច សា;
ចាដលិ តស្ស សោ ពោធិ, សរណង្ករស្ស សត្ថុនោ។
អធិការំ ការិត្វាន, បណិធានមការយិំ;
ន លភិំ ព្យាករណំ តេសំ, តិណ្ណំ ពុទ្ធានំ សន្តិកេ។
តេសំ អន្តរយេវ, ឯកោ ពុទ្ធោ អនូបមោ;
ទីបង្ករោ នាម ជិនោ, ឧប្បជ្ជិ លោកនាយកោ”។

*ក្នុងសារមណ្ឌកប្ប ដែលជាទីបំផុតនៃ៤អសង្ខេយ្យ ព្រះពុទ្ធឧប្បត្តិឡើង ៤អង្គគឺ **ព្រះពុទ្ធតណ្ហង្ករ១ ព្រះពុទ្ធមេធង្ករ១ ព្រះពុទ្ធសរណង្ករ១ ព្រះពុទ្ធទីបង្ករ១** ព្រះពុទ្ធទាំង៤អង្គនោះ ជាអគ្គនាយកនៃលោក ទ្រង់មានយសធំ។*

*បណ្ដាព្រះពុទ្ធ ទាំង៤អង្គនោះ ព្រះពុទ្ធ**តណ្ហង្ករ**បរមសាស្ដា ទ្រង់មានព្រះជនក ព្រះនាមថា**សុនន្ទៈ** ព្រះជននី មានព្រះនាមថា**សុនន្ទា** ដើម**សត្តបណ្ណិ** ជាពោធិព្រឹក្ស របស់ព្រះអង្គ។*

*ព្រះពុទ្ធ**មេធង្ករ**បរមសាស្ដា ទ្រង់មានព្រះជនក ព្រះនាមថា**សុទេវៈ** ព្រះជននី ព្រះនាមថា**យសោធរា** ដើម**កឹសុកៈ**ជាពោធិព្រឹក្សរបស់ព្រះអង្គ។*

*ព្រះពុទ្ធ**សរណង្ករ**បរមសាស្ដា ទ្រង់មានព្រះជនក ព្រះនាមថា**សុមង្គលៈ** ព្រះជននី ព្រះនាមថា**យសវតី** ដើម**បាដលិ** ជាពោធិព្រឹក្សរបស់ព្រះអង្គ។ តថាគត បានធ្វើអធិការ បានតាំងបណិធាន តែតថាគតមិនបានទទួលព្យាករណ៍ ក្នុងសម្នាក់ព្រះពុទ្ធទាំង៣ព្រះអង្គនោះទេ។*

*បន្ទាប់ពី ព្រះពុទ្ធទាំង៣អង្គនោះ ព្រះពុទ្ធមួយអង្គ ដែលមិនមានបុគ្គល*

*ប្រៀបស្មើ ទ្រង់ព្រះនាមថា**ទីបង្ករ** ជាព្រះជិនស្រី ជាលោកនាយក ស្ដេចឧប្បត្តិឡើង។*

*មាននគរមួយ ឈ្មោះ**អមរវតី** ជានគរ គួរពិតពិលរមិលមើល ជាទីរីក-រាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយ និងទឹក ទាំងមិនស្ងាត់ ដោយមានសំឡេង១០យ៉ាងគឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម។*

***អមរវតី** ជានគរគឹកកងដោយសំឡេង ដែលប្រកបដោយបាយ និងទឹកថា ចូរស៊ី ចូរផឹក ហើយជានគរសម្បូណ៌ដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងាររគ្រប់យ៉ាង។*

***អមរវតី** ជានគរបរិបូណ៌ដោយកែវ៧ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេចដោយគ្រឿងបរិភោគ និងឧបភោគទាំងពួងដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ។*

*វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរ**ឥតិហាសៈ**[៣៦]ផង ក្នុងធម៌របស់ព្រាហ្មណ៍ផង។*

---

[៣៦]***ឥតិហាស*** ( ន. )  *( សំ., បា. ) ឈ្មោះគម្ពីរព្រាហ្មណ៍និយាយអំពីពង្សាវតារពីព្រេងនាយមានរឿងមហាភារតយុទ្ធជាដើម : គម្ពីរឥតិហាស ។*

*កាលនោះ តថាគត នៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្ដីទុក្ខ ការបែកធ្លាយនៃសរីរៈ ក៏នាំមកនូវសេចក្ដីទុក្ខ ដូចគ្នាសេចក្ដីស្លាប់ ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយក៏នាំមកនូវទុក្ខ អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត។*

*បើដូច្នោះ អាត្មាអញ គួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្ដីត្រូវការ ហើយនឹងចេញទៅ។*

*ផ្លូវនោះនឹងមានពិត ផ្លូវនោះមិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព។*

*កាលបើទុក្ខមាន សុខក៏មានយ៉ាងណា កាលបើភពមាន ការប្រាសចាកភព ដែលបុគ្គលគួរតែប្រាថ្នារក ក៏មានយ៉ាងនោះដែរ។*

*កាលបើក្ដៅមាន ត្រជាក់ដទៃក៏មានយ៉ាងណា កាលបើភ្លើង៣ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នាក៏មាន យ៉ាងនោះដែរ។*

*កាលបើបាបមាន បុណ្យក៏មានយ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នាក៏មាន យ៉ាងនោះដែរ។*

*បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក រួចមិនលាង ទោសនោះមិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមាន ហើយបុគ្គលមិនស្វែងរកស្រះ ដើម្បីលាងនូវកិលេសជា*

មន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺព្រះនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ។
បុរសដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះមិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវ ទោសនោះមិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ។
បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឱ្យពេទ្យព្យាបាលជំងឺនោះ ទោសនោះមិនមែនជាទោសនៃពេទ្យទេ យ៉ាងណាមិញ បុគ្គលត្រូវជំងឺគឺកិលេសបៀតបៀន ហើយដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះមិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ។
បើដូច្នោះ គួរតែអាត្មាអញ លះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ។
បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ព្ធដ៏ក គប្បីជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ អាត្មាអញគួរតែលះកាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ។

*បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសៈ[៣៧] ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្ដីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈ[៣៧] ក្នុងបង្គន់ដូច្នោះឯង។*

*ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ៩ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូក លះបង់ចោលទូកចាស់ ដូច្នោះឯង។*

*បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅយ៉ាងណា កាយនេះក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ។*

*លុះតថាគត គិតឃើញយ៉ាងនេះហើយ ក៏ឱ្យទ្រព្យច្រើនរយកោដិដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត។*

*តថាគត ធ្វើអាស្រម សាងបណ្ណសាលា ក្បែរភ្នំមួយ ឈ្មោះ***ធម្មិក** *ជិតព្រៃហិមពាន្ត។*

---

[៣៧] ***ករីស*** (nt.) dung; excrement. (*បុំ., ន-បុំ.*) [*កិរ+ឦស, ករ+ឦស, កុ+ឥស*] (*អាហារវត្ថុ*)*ដែលជនធ្វើ,-បន្ទោបង់* (*ករីស, អាហារចាស់, ឧច្ចារ, លាមក, គូថ ដូច វច្ចៈ, គូថ*), *វិ.* **ការិយតីតិ ករីសំ។**

*តថាគត និម្មិតនូវទីចង្ក្រម ដែលប្រាសចាក**ទោស៥ប្រការ**[៣៨] នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពលៈដែលប្រកបដោយ**គុណ៨ប្រការ**[៣៩]។*

*តថាគត លះបង់សំពត់សាដកដែលប្រកបដោយ**ទោស៩ប្រការ**[៤០] ក្នុង*

---

[៣៨]**ចង្កមទោស** *ទោសនៃទីចង្ក្រម៥ យ៉ាង៖*

| | |
|---|---|
| បញ្ចិមេ ចង្កមទោសា នាម – | *ឈ្មោះថាទោសនៃទីចង្ក្រមមាន ៥ យ៉ាង ឥតិ គឺ ៖* |
| ១-ថទ្ធវិសមតា | *ផ្ទៃដីរឹងនិងពុំរាបស្មើ,* |
| ២-អន្តោរុក្ខតា | *មានដើមឈើនៅខាងក្នុងទីចង្ក្រម,* |
| ៣-គហនច្ឆន្នតា | *មានសំរាមឬស្លឹកឈើស្មុគស្មាញ,* |
| ៤-អតិសម្ពាធតា | *តូចពេក,* |
| ៥-អតិវិសាលតា | *ធំទូលាយពេក។* |

[៣៩]*អាស្រមបទដែលប្រកបដោយគុណ៨ ប្រការ*

*បទថា* អដ្ឋគុណំ សមុបេតំ *អាស្រមបទដែលប្រកបដោយគុណ៨ ប្រការ គឺប្រកបដោយសុខរបស់សមណៈ ៨ ប្រការ ។*

អដ្ឋិមានិ សមណសុខានិ នាម – *ឈ្មោះថា សមណសុខ ៨ ប្រការនេះ* ឥតិ *គឺ៖*

១-ធនធញ្ញបរិគ្គហាភាវោ *មិនមានការហួងហែងទ្រព្យ មានស្រូវអង្ករជាដើម,*

២-អនវជ្ជបិណ្ឌាចាតបរិយេសនភាវោ *ស្វែងរកតែបិណ្ឌបាតដែលមិនមានទោស,*

៣-និព្វុតបិណ្ឌចាតភុញ្ជនភាវោ *បរិភោគតែបិណ្ឌបាតដែលត្រជាក់,*

៤-រដ្ឋំ បីឡេត្វា ធនសារំ វា សីសកហាបណាទីនិ វា គណ្ហន្តេសុ រាជកុលេសុ រដ្ឋបីឡនកិលេសាភាវោ *មិនមានការបៀតបៀនអំពីព្រះរាជាទាំងឡាយ មានបៀតបៀនដោយកាសុី ឬដោយការរឹបអូសយកទ្រព្យមានតម្លៃនិងកហាបណៈជាដើម,*

៥-ឧបករណេសុ និច្ឆន្ទរាគភាវោ *ប្រាសចាកតម្រេកដោយការពេញចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ,*

៦-ចោរវិលោបេ និព្ភយភាវោ*មិនខ្លាចចំពោះភ័យក្នុងរឿងចោរប្លន់ជាដើម,*

៧-រាជរាជមហាមត្តេហិ អសំសដ្ឋភាវោ *មិនច្រឡូកច្រឡំជាមួយព្រះរាជានិងរាជអាមាត្យជាដើម,*

៨-ចតូសុ ទិសាសុ អប្បដិហតភាវោ *មិនទើសទាក់ក្នុងទិសទាំងបួន ១ ។*

[៤០]*សំពត់សាដកដែលប្រកបដោយទោស៩ប្រការ* **គឺ៖**

១-មហគ្ឃភាវោ *មានតម្លៃច្រើន,*

២-បរបដិពទ្ធតាយ ឧប្បជ្ជនភាវោ *កើតឡើងព្រោះទាក់ទងនឹងអ្នកដទៃ,*

**ពុទ្ធបណិធាន**

*អាស្រមបទនោះ ស្បៀកសំពត់សម្បកឈើ ដែលប្រកបដោយ***គុណ១២ប្រការ**[៤១] *វិញ។*

---

៣-បរិភោគេន លហុំ កិលិស្សនកាភោ *សៅហ្មង់រហ័សព្រោះការប្រើប្រាស់,*

៤-កិលិដ្ឋោ ហិ ដោវិតព្វោ ច រជិតព្វោ ច ហោតិ, បរិភោគេន ជីរណកាភោ *សៅហ្មង ហើយចាំបាច់ត្រូវជួសជុល ត្រូវបោកនិងជ្រលក់ ការដែលចាស់ទៅព្រោះការប្រើប្រាស់នោះ,*

៥-ជិណ្ណស្ស ហិ តុន្នំ វា អគ្គឡទានំ វា កាតព្វំ ហោតិ, បុន បរិយេសនាយ ទុរភិសម្ភវ-កាភោ *សម្រាប់សំពត់ដែលចាស់ហើយ ត្រូវធ្វើការដេរប៉ះ ការដែលបានទទួលដោយការស្វែងរកទៀតក៏លំបាក,*

៦-តាបសបព្វជ្ជាយ អសារុប្បភាភោ *មិនសមនឹងការបួសជាតាបស,*

៧-បច្ចត្ថិកានំ សាធារណភាភោ ឯកោ *ជារបស់ទូទៅ ដល់សត្រូវ,*

៨-យថា ហិ នំ បច្ចត្ថិកា ន គណ្ហន្តិ, ឯវំ គោបេតព្ពោ ហោតិ។ បរិភុញ្ជន្តស្ស វិភូសន-ដ្ឋានភាភោ ឯកោ *ព្រោះត្រូវគ្រប់គ្រងដោយអាការកុំឲ្យសត្រូវកាន់យកបាន និងជាគ្រឿងប្រដាប់ (អលង្ការ) របស់បុគ្គលដែលប្រើប្រាស់,*

៩-គហេត្វា វិចរន្តស្ស ខន្ធភារមហិច្ឆភាភោ *សម្រាប់បុគ្គលដែលត្រាច់ទៅ (ឈ្មោះថា) ជាបុគ្គលប្រាថ្នាច្រើនក្នុងវត្ថុដែលជារបស់ប្រើប្រាស់ប្រចាំខ្លួន។*

(*ជាតកអដ្ឋកថា, អបទានអដ្ឋកថា, ធម្មសង្គណិអដ្ឋកថា*)

[៤១]***សំពត់សម្បកឈើមានអានិសង្ស ១២ ប្រការ គឺ៖***

១-អប្បគ្ឃំ សុន្ទរំ កប្បិយន្តិ អយំ តាវ ឯកោ អានិសំសោ *មានតម្លៃថោក ល្អ និងសមគួរ នេះជាអានិសង្សទី១,*

២-សហត្ថា កាតុំ សក្កាតិ អយំ ទុតិយោ *អាចធ្វើដោយដៃឯង នេះជាអានិសង្សទី២,*

៣-បរិភោគេន សណិកំ កិលិស្សតិ, ដោវិយមានេបិ បបញ្ចោ នត្ថីតិ អយំ តតិយោ *សៅហ្មងយឺតដោយការប្រើប្រាស់ សូម្បីបោកក៏មិនយឺតយូរ នេះជាអានិសង្សទី៣,*

៤-បរិភោគេន ជិណ្ណេបិ សិព្វិតព្វាភាភោ ចតុត្ថោ *សូម្បីចាស់ទៅព្រោះការប្រើប្រាស់ ក៏មិនចាំបាច់ដេរ នេះជាអានិសង្សទី៤,*

៥-បុន បរិយេសន្តស្ស សុខេន ករណភាភោ បញ្ចមោ *កាលស្វែងរកជាថ្មី ក៏ធ្វើបានងាយ នេះជាអានិសង្សទី៥,*

៦-តាបសបព្វជ្ជាយ សារុប្បភាភោ ឆដ្ឋោ *សមគួរដល់ការបួសជាតាបស នេះជាអានិសង្សទី៦,*

៧-បច្ចត្ថិកានំ និរុបភោគភាភោ សត្តមោ *បុគ្គលដែលជាសត្រូវមិនប្រើប្រាស់ នេះជាអានិសង្សទី៧,*

---

៨-បរិភុញ្ជន្តស្ស វិក្ខសនដ្ឋាភាវោ អដ្ឋមោ *កាលប្រើប្រាស់ ក៏មិនជាទីតាំងនៃការប្រដាប់តាក់តែង នេះជាអានិសង្សទី៨,*

៩-ធារណេ សល្លហុកភាវោ នវមោ *កាលស្លៀកដណ្ដប់ ក៏ស្រាល នេះជាអានិសង្សទី៩,*

១០-ចីវរបច្ចយេ អប្បិច្ឆភាវោ ទសមោ *ភាពជាអ្នកប្រាថ្នាតិចក្នុងបច្ច័យគឺចីវរ នេះជាអានិសង្សទី១០,*

១១-វាកុប្បត្តិយា ធម្មិកអនវជ្ជភាវោ ឯកាទសមោ *ការកើតឡើងនៃសំពត់សម្បកឈើ ជារបស់កើតឡើងដោយធម៌ មិនមានទោស នេះជាអានិសង្សទី១១,*

១២-វាកចីរេ នដ្ឋេបិ អនបេក្ខភាវោ ទ្វាទសមោ *កាលសំពត់សម្បកឈើនោះវិនាសទៅ ក៏មិនមានអាល័យ នេះជាអានិសង្ស ទី១២ៗ*

(*ជាតកអដ្ឋកថា, អបទានអដ្ឋកថា, ធម្មសង្គណិអដ្ឋកថា*)

[៤២]***បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ គឺះ***

១-មហាសមារម្ភេន ទព្វសម្ភារេ សមោធានេត្វា ករណបរិយេសនភាវោ ឯកោ អាទីនវោ *ត្រូវស្វែងរកដោយការប្រមូលទព្វសម្ភារយកមកធ្វើ ជាទោសទី ១,*

២-តិណបណ្ណមត្តិកាសុ បតិតាសុ តាសំ បុនប្បុនំ បបេតព្វតាយ និពទ្ធជគ្គនភាវោ ទុតិយោ *ត្រូវជួសជុលជានិច្ច ព្រោះកាលស្មៅ ស្លឹកឈើ និងដីឥដ្ឋជ្រុះមក ត្រូវយករបស់ទាំងនោះចេញ ហើយបន្ថែមរបស់ថ្មីចូលទៅ នេះជាទោសទី ២,*

៣-សេនាសនំ នាម មហល្លកស្ស ចាបុណាតិ, អវេលាយ វុដ្ឋាបិយមានស្ស ចិត្តេកគ្គតា ន ហោតីតិ ឧដ្ឋាបនិយភាវោ តតិយោ *ធម្មតាសេនាសនៈតែងបានដល់បុគ្គលជាថេរៈ (អ្នកចាស់ជាង ) កាលជនដែលចាស់ជាងចូលមក ឲ្យអញក្រោកឡើងក្នុងវេលាមិនសមគួរ ឯកគ្គតាចិត្តក៏មិនមាន ព្រោះដូច្នោះ កាលដែលត្រូវដាស់ឲ្យក្រោកឡើង ទើបជាទោសទី ៣,*

៤-សីតុណ្ហបដិឃាតេន កាយស្ស សុខុមាលករណភាវោ ចតុត្ថោ *ព្រោះកម្ចាត់បង់នូវរងានិងកម្ដៅ ក៏ធ្វើឲ្យរាងកាយចុះខ្សោយ នេះជាទោសទី ៤,*

៥-គេហំ បវិដ្ឋេន យំកិញ្ចិ បាបំ សក្កា កាតុន្តិ គរហាបដិច្ឆាទនភាវោ បញ្ចមោ, *បុគ្គលចូលទៅកាន់ផ្ទះ អាចធ្វើអាក្រក់ណាមួយបាន ព្រោះដូច្នោះ ទីបិទបាំងគួរតិះដៀល ជាទោសទី ៥,*

៦-"មយ្ហ"ន្តិ បរិគ្គហករណភាវោ ឆដ្ឋោ *ការហួងហែងដោយគិតថា នេះជារបស់អញ ជាទោសទី ៦,*

៧-គេហស្ស អត្ថិភាវោ នាម សទុតិយកវាសោតិ សត្តមោ *ធម្មតាការមានផ្ទះ បញ្ជាក់ថាជារបស់បុគ្គលដែលមានភរិយា នេះជាទោសទី ៧,*

**ពុទ្ធបណិធាន**

*កាន់គល់ឈើ ដែលប្រកបដោយ**គុណ១០យ៉ាង**(៤៣)។*

*តថាគត លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់*

---

៨-ឧក្កាមណ្ឌលយរគោឡិកាទីនំ សាធារណតាយ ពហុសាធារណភាវោ អដ្ឋមោ *ជារបស់សាធារណៈដល់ជនច្រើន ព្រោះជាសាធារណៈដល់សត្វមានសុច សង្កើច និងតុកកែជាដើម ជាទោស ទី ៨ ។*

(*ជាតកអដ្ឋកថា, អបទានអដ្ឋកថា, ធម្មសង្គណិអដ្ឋកថា*)

(៤៣)***គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង គឺះ***

១-អប្បសមារម្ភតា ឯកោ គុណោ *មានការខ្វល់ខ្វាយតិច ជាគុណទី១,*

២-ឧបគមនមត្តមេវ ហិ តត្ថ ហោតីតិ អប្បដិជគ្គនតា ទុតិយោ *គ្រាន់តែចូលទៅប៉ុណ្ណោះ ក៏នៅក្នុងទីនោះបាន មិនចាំបាច់បោសសម្អាត ជាគុណទី២,*

៣-តញ្ហិ សម្មដ្ឋម្បិ អសម្មដ្ឋម្បិ បរិភោគផាសុកំ ហោតិយេវ អនុដ្ឋាបនីយភាវោ តតិយោ *ក្នុងទីនោះ ទោះបោសក្តី មិនបោសក្តី ក៏ប្រើប្រាស់បានតាមសប្បាយ មិនចាំបាច់ព្យាយាមខ្វាំងក្លាពេក ជាគុណទី៣,*

៤-គរហំ នប្បដិច្ឆាទេតិ, តត្ថ ហិ ចាបំ ករោន្តោ លជ្ជតីតិ គរហាយ អប្បដិច្ឆាទនភាវោ ចតុត្ថោ, *ទីនោះ បិទបាំងដោយការនិន្ទាមិនបាន ព្រោះកាលបុគ្គលធ្វើអាក្រក់ក្នុងទីនោះ រមែងខ្មាស ព្រោះហេតុនោះ ភាពនៃការមិនបិទបាំងនូវការនិន្ទា ជាគុណទី៤,*

៥-អព្ភោកាសោ វិយ កាយំ ន សន្ថម្ភេតីតិ កាយស្ស អសន្ថម្ភនភាវោ បញ្ចមោ *គល់ឈើដូចគ្នានឹងនៅក្នុងទីវាល ព្រោះមិនញ៉ាំងរាងកាយឲ្យទន់ គឺឲ្យរឹងមាំ ព្រោះដូច្នោះ ទើបជាគុណទី៥,*

៦-បរិគ្គហករណាភាវោ ឆដ្ឋោ *មិនមានភាពនៃការហួងហែង ជាគុណទី៦,*

៧-គេហាលយបដិក្ខេបោ សត្តមោ *ហាមឃាត់នូវសេចក្តីអាល័យក្នុងផ្ទះ ជាគុណទី៧,*

៨-ពហុសាធារណគេហេ វិយ "បដិជគ្គិស្សាមិ នំ, និក្ខមថា"តិ នីហរណាភាវោ អដ្ឋមោ *មិនមានការដែលត្រូវពោលថា "អ្នកចូរចេញសិន ខ្ញុំនឹងបោស" ហើយដេញទៅ ដូចផ្ទះសាធារណៈទូទៅ នេះជាគុណទី៨,*

*៩-*វសន្តស្ស សប្បីតិកភាវោ នវមោ, *បុគ្គលអ្នកនៅក៏បានទទួលនូវបីតិ នេះជាគុណទី៩,*

១០-រុក្ខមូលសេនាសនស្ស គតគតដ្ឋានេ សុលភតាយ អនបេក្ខភាវោ ទសមោ *មិនចាំបាច់អាល័យក្នុងអារម្មណ៍ ព្រោះសេនាសនៈគល់ឈើ រកបានងាយ ទោះទៅក្នុងទីណា ក៏អាចរកបាន នេះជាគុណទី១០។*

ឥមេ ទស គុណេ ទិស្វា រុក្ខមូលំ ឧបគតោស្មីតិ វទតិ *ព្រះមហាសត្វឃើញគុណ ១០ យ៉ាងនេះ ទើបពោលថា តថាគតចូលអាស្រ័យត្រង់គល់ឈើ ដូច្នេះ ។*

(*ជាតកអដ្ឋកថា, អបទានអដ្ឋកថា, ធម្មសង្គណិអដ្ឋកថា*)

*យកផ្លៃឈើជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ។*

*តថាគត ផ្គងព្យាយាមក្នុងអាស្រមបទនោះ ញ៉ាំងយប់ និងថ្ងៃឱ្យកន្លងទៅ ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលៈក្នុងរវាង៧ថ្ងៃ។*

*កាលតថាគត សម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង។*

*កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្រផង តថាគតជាអ្នកឆ្អែតស្កប់ស្កល់ ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែមិនបានឃើញនូវនិមិត្តទាំង៤នោះឡើយ។*

*ពួកមហាជនក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះតថាគតនោះ។*

*សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្ត ត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាស ហើយសួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា៖*

*"មហាជន ត្រេកអរ ស្រស់ស្រាយ រីករាយ ពេញចិត្ត ជម្រះផ្លូវគន្លង ប្រឡាយ ដើម្បីអ្នកណា"?*

*ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា៖*

**ពុទ្ធបណិធាន**

*"ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្លង ប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ"។*

*បីតិ កើតឡើងដល់តថាគត ក្នុងខណៈនោះ ព្រោះតែឮ ពាក្យថា* ***ព្រះពុទ្ធ*** *តថាគតទន្ទេញថា* ***ព្រះពុទ្ធ ព្រះពុទ្ធ*** *ដូច្នេះ ហើយក៏បាននូវសោមនស្ស។*

*តថាគតឋិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា* ***អាត្មាអញនឹងបណ្ដុះពូជកុសលក្នុងបុញ្ញក្ខេត្តនេះ កុំឱ្យខណៈកន្លងទៅទទេឡើយ។***

*លុះគិតដូច្នេះហើយ តថាគតក៏និយាយទៅរកមហាជនថា៖*

*"បើអ្នកទាំងឡាយ ជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឱ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវ ប្រឡាយ ដែរ"។*

*កាលនោះ ពួកជនទាំងនោះ ក៏ឱ្យឱកាសមួយ ដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា* ***ព្រះពុទ្ធ ព្រះពុទ្ធ*** *ដូច្នេះបណ្ដើរ ជម្រះផ្លូវបណ្ដើរ ក្នុងឱកាសនោះ។*

*ក្នុងឱកាសដែលផ្លូវ របស់តថាគត ធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រី ជាអ្នកប្រាជ្ញធំព្រះនាមទីបង្ករ ស្ដេចយាងមកតាមផ្លូវ ជាមួយនឹងព្រះខីណាស្រព៤សែនរូប សុទ្ធតែជាអ្នកបាន* ***អភិញ្ញា៦***[៤២] *ជាតាទិបុគ្គល ប្រាសចាកមន្ទិល។*

*ការក្រោកទទួលព្រះសាស្ដាក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើនក៏*

---

[៤២] ***អភិញ្ញា*** *(ឥ.) [អភិ+ញា+អ+អា-ឥ.] ប្រាជ្ញាជាគ្រឿងដឹងចំពោះ, គុណជាតិគឺបុគ្គលគប្បីដឹងច្បាស់។*

លាន់ឡើងគគ្រឹកគគ្រេង ពួកមនុស្ស និងទេវតា ក៏ត្រេកអរ ញ៉ាំងសាធុការឱ្យប្រព្រឹត្តទៅ។

ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ហើយទេវ-តា និងមនុស្ស ទាំងពីរពួកនេះ បានផ្គងអញ្ជលី ដើរដង្ហែព្រះតថាគតនោះ។

ពួកទេវតា ប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគំតូរ្យតន្ត្រី ជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្ស ទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគតនោះ។

ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវៈ ផ្កាឈូក ផ្កាបរិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាស អំពីទិសតូច ទិសធំ។

ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយលំអិតខ្លឹមចន្ទន៍ទិព្វផងគ្រឿងក្រអូបដ៏ប្រសើរ ទាំងអស់ផង អំពីទិសតូច ទិសធំឰដ៏អាកាស។

ពួកមនុស្ស ដែលឋិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាក្ទម្ពផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេសអំពីទិសតូច ទិសធំ។

តថាគត រំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែក លើភក់ ហើយដេកផ្កាប់មុខ អធិដ្ឋានថាៈ

"សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ"។

កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្តយ៉ាងនេះថា

*បើអាត្មាអញ ប្រាថ្នាដុតកិលេសទាំងឡាយរបស់អញ ក្នុងថ្ងៃនេះក៏បាន តែថាប្រយោជន៍អ្វី អាត្មាអញធ្វើឱ្យជាក់ច្បាស់នូវធម៌ដោយភេទ ដែលគេមិនស្គាល់ក្នុងទីនេះ អាត្មាអញ គប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក និងទេវលោក ឱ្យរួចរំដោះចាកសង្សារ។*

*ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្ដែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក និងទេវលោក។*

*អាត្មាអញ នឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់។*

*តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក និងទេវលោក។*

ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ពាក្យនេះថា៖

"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ។

សត្វនេះ នឹងចេញចាកក្រុង ឈ្មោះ**កបិលពស្តុ**ជាទីរីករាយ តម្កល់ព្យាយាមធ្វើ**ទុក្ករកិរិយា**។

សត្វនេះ អង្គុយទៀបគល់**អជបាលព្រឹក្ស** ទទួលបាយាស ដែលនាង**សុជាតា** ថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹង**នេរញ្ជរា**។

ជិនស្រីនោះ បានទទួលបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ អង្គុយទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិ-មណ្ឌល និងបានត្រាស់ដឹងនូវ**អនុត្តរសម្មោធិញ្ញាណ** ទៀបគល់**អស្សត្ថ-ព្រឹក្ស**។

ព្រះជនិកា មាតារបស់តាបសនេះ នឹងមាននាមថា ព្រះនាង**មាយាទេវី** ព្រះបិតាព្រះនាម**សុទ្ធោទនៈ** ឯតាបសនេះ នឹងមានឈ្មោះថា**ព្រះគោតម**

អគ្គសាវ័កទាំងពីររូប គឺ**កោលិតៈ១ ឧបតិស្សៈ១** ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន  ភិក្ខុជាឧបដ្ឋាក ឈ្មោះ**អានន្ទ** នឹងបម្រើព្រះជិនស្រីនេះ។

អគ្គសាវិកាពីររូប គឺ**នាងខេមា១ នាងឧប្បលវណ្ណា១** ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន។

ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ  ហៅថា**អស្សត្ថ-ព្រឹក្ស**  ឯឧបាសក ជាឧបដ្ឋាក ដ៏ប្រសើរពីររូប គឺ**ចិត្តៈ១ ហត្ថាឡវកៈ១**។

នាង**នន្ទមាតា** និងនាង**ឧត្តរា** ជាឧបដ្ឋាយិកាដ៏ប្រសើរ។

ព្រះគោតម មានយសនោះ មានព្រះជន្ម១០០វស្សា៌។

ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាករណ៍ របស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកនូវគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា **សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ**។

**ពុទ្ធបណិធាន**

*សំឡេងហ៊ោទាំងឡាយក៏ប្រព្រឹត្តទៅ ពួកមនុស្សលោក និងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថាៈ*

*"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះ។*

*ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោមក៏ឈ្មោះថាឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ"។*

*ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើ របស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ។*

*សាវ័កទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវ័កទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ស ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ។*

*កាលព្រះលោកនាយក និងព្រះសង្ឃ កន្លងនូវការឃើញ របស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ។*

*តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយបាមោជ្ជៈផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែនក្នុងកាលនោះ។*

*តថាគត អង្គុយពែនភ្នែន គិតយ៉ាងនេះ ក្នុងកាលនោះថា* ***អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញាហើយ ក្នុងលោកធាតុទាំងមួយពាន់***

**មិនមានពួកឥសីស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ។**

ក្នុងកាលដែលតថាគត អង្គុយពែនភ្នែន គិតយ៉ាងនេះ ពួកមហាព្រហ្ម ដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញ៉ាំងសំឡេងខ្ទាំងឱ្យលាន់ឮថា **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែន នៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ។

ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេងរំភេរ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

ផ្កាទាំងពួង ដែលកើតលើគោក កើតក្នុងទឹកក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុងខណៈនោះ វល្លិ និងឈើទាំងអស់នោះក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។**

កែវទាំងឡាយ ដែលឋិតនៅឰដ៏អាកាសក្តី ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះក៏រុងរឿងក្នុងថ្ងៃនេះ **លោកនឹងបានត្រាស់**

*ជាព្រះពុទ្ធប្រាកដ។*

*គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះក៏លាន់ឮឡើងក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាស ក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*មហាសមុទ្រក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះក៏លាន់កងរំពងក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ភ្លើងក្នុងនរកទាំងមួយម៉ឺនក៏រលត់ ក្នុងខណៈនោះ ភ្លើងទាំងនោះក៏រលត់ក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះក៏បានប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដីក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ពួកផ្កាយទាំងឡាយ ក៏រុងរឿង ផ្កាយនក្ខត្តឫក្ស*[៤៥] *ទាំងឡាយប្រកបដោយព្រះចន្ទខែវិសាខ ក៏រុងរឿងក្នុងមណ្ឌលនៃអាកាស* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*សេចក្តីអផ្សុក មិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេក-អរ ក្នុងខណៈនោះ ពួកសត្វទាំងអស់នោះជាអ្នកត្រេកអរក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*រោគទាំងឡាយដ៏ស្រាលៗក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*រាគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ក្នុងកាលនោះ រាគនិងកិលេស ទាំងអស់នោះក៏ប្រាសចេញទៅក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

---

[៤៥] **នក្ខត្តឫក្ស** ( ន. ) *[ន័ក-ខ័ត-ត: រឹក]* *( សំ., បា. )* (នក្សត្រ "ផ្កាយ" + ឫក្ស "ផ្កាយ"; នក្ខត្ត + ឥក្ក "ផ្កាយ + ផ្កាយ") ផ្កាយទាំងពួងទូទៅ ។ ពេលកំណត់ដោយផ្កាយដែលហោរគន់រក ដើម្បីឲ្យដឹងថា គ្រោះកាចឬគ្រោះជា (តាមហោរាសាស្ត្រ) : *ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តឫក្សដ៏ឧត្តម ...។*

*ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលីក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះក៏ផ្សាយចេញក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះក៏ប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯងក៏ប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរារាំងមិនមានឡើយ កំពែង សន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាសប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*ចុតិ និងឧបបត្តិ មិនមានក្នុងខណៈនោះ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ* ***លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។***

*និមិត្តទាំងនោះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ពួកសត្វពោលថា៖*

"បពិត្រសុមេធតាបស សូមលោកផ្គងព្យាយាម ឱ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា **លោកនឹងបាន** ត្រាស់ជាព្រះពុទ្ធប្រាកដ"។

តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតា ទាំងមួយម៉ឺនចក្រវាលហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះ យ៉ាងនេះថា ៖

ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកា បែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ។

ដុំដី ដែលគេចោល ទៅឰដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ។

ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនឃ្លៀងឃ្លាតអាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ, សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់ប្រាកដយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ប្រាកដដូច្នោះដែរ។

កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យ តែងរះឡើងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ។

សីហៈ ដែលចេញអំពីដំណេក តែងបន្លឺសំឡេងយ៉ាងណា ព្រះបន្ទូល

*របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ។ ការសម្រាលគភ៌ នៃស្ត្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ។*

*បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង១០ ដរាបដល់ធម្មធាតុ"។*

*កាលនោះ តថាគតកំពុងជ្រើសរើសក៏បានឃើញ **ទានបារមី** ជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបូរាណ ធ្លាប់សន្សំមក ហើយទូន្មានខ្លួនឯងថា **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវទានបារមី ជាដំបូងនេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ។***

***ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះចាក់មិនឱ្យសល់ទឹក ហើយទឹកមិនដក់នៅក្នុងក្អមនោះយ៉ាងណា បើអ្នកឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឱ្យទានកុំឱ្យសេសសល់ ឱ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ។***

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ **សីលបារមីទី២** ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវសីលបារមីទី២នេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ។***

សត្វចាមរី កាលឃើញរោមកន្ទុយ ចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ ចូរអ្នកបំពេញនូវសីលទាំងឡាយក្នុងភូមិទាំង៤ ចូររក្សាសីលសព្វកាល ឱ្យដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ។

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ*នេក្ខម្មបារមីទី៣ *ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា* ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវនេក្ខម្មបារមីទី៣នេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ។

បុរស ដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញ៉ាំងសេចក្តីត្រេកអរ ឱ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួចចាកគុកនោះយ៉ាងណា ចូរអ្នកឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភព យ៉ាងនោះដែរ។

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ*បញ្ញាបារមីទី៤ *ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា* ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវបញ្ញាបារមីទី៤នេះឱ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ។

*ភិក្ខុ កាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅយ៉ាងណា បើអ្នកសាកសួរជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមីហើយ នឹងបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ។*

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**វីរិយបារមីទី៥** ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវវីរិយបារមីទី៥នេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ។***

***សត្វសីហៈ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាម ឱ្យមាំមួនក្នុងភពទាំងពួងយ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចពោធិ-ញ្ញាណ មិនខានឡើយ។***

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរកក៏បានឃើញ**ខន្តិបារមីទី៦** ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវខន្តិបារមីទី៦នេះឱ្យមាំ***

មួន អ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណ មិនខានឡើយ។

ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយ របស់ពួកជនទាំងពួងយ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ**សច្ចបារមីទី៧** ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវសច្ចបារមីទី៧នេះឱ្យមាំមួន អ្នកកុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិ-ញ្ញាណ មិនខានឡើយ។

ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក និងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវយ៉ាងណា អ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយយ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។

*កាលនោះ តថាគតកំពុងជ្រើសរើសរកក៏បានឃើញ***អធិដ្ឋានបារមីទី៨** *ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេពធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា* **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន** *ធ្វើនូវអធិដ្ឋានបារមីទី៨នេះឱ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ។*

*ភ្នំថ្ម ឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែលយ៉ាងណា ចូរអ្នកកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាលយ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិ-ញ្ញាណ មិនខានឡើយ។*

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។*

*កាលនោះ តថាគតកំពុងជ្រើសរើសរកក៏បានឃើញ***មេត្តាបារមីទី៩** *ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក រួចទូន្មានខ្លួនឯងថា* **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន** *ធ្វើនូវមេត្តាបារមីទី៩នេះឱ្យមាំមួន ចូរអ្នកកុំឱ្យមានបុគ្គលដទៃស្មើដោយមេត្តាបើអ្នកចង់លុះនូវពោធិញ្ញាណ។*

*ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិលយ៉ាងណា ចូរអ្នកចម្រើនមេត្តាឱ្យស្មើចំពោះមិត្ត និងសត្រូវយ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ។*

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើស រកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។

កាលនោះ តថាគតកំពុងជ្រើសរើសរកក៏បានឃើញ**ឧបេក្ខាបារមីទី១០** ដែលពោធិសត្វទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា **ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើនូវឧបេក្ខាបារមីទី១០នេះ ឱ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណ មិនខានឡើយ។**

**ធម្មតាផែនដី តែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះយ៉ាងណា ចូរអ្នកធ្វើខ្លួនឱ្យដូចជាជញ្ជីងចំពោះសុខ និងទុក្ខសព្វកាលយ៉ាងនោះដែរ លុះអ្នកដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិ-ញ្ញាណ ពុំខានឡើយ។**

ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណឱ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមី១០នោះមិនមានទេ ចូរអ្នកតាំងនៅក្នុងបារមីធម៌ទាំង១០នោះ ឱ្យមាំមួនចុះ។

កាល តថាគតពិចារណានូវបារមីទាំងនេះ ដោយ**សភាវសរសលក្ខណៈ** ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជះនៃធម៌។

ផែនដីកម្រើកបន្លឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាបឬចក្កយន្តប្រេងត្រូវគេគាបរួច រមែងវិលញ័រយ៉ាងណា ផែនដីក៏ញាប់ញ័រយ៉ាងនោះដែរ។

**ពុទ្ធបណិធាន**

បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មានក្នុងទីដែលអង្គាស បរិស័ទទាំងនោះក៏ញាប់ញ័រ ដេកជ្រប់លើផែនដីក្នុងទីអង្គាសនោះ។

ធ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នា បែកខ្ទេចខ្ទីអស់ក្នុងទីនោះ។

ពួកមហាជន មានចិត្តរន្ធត់តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នា ហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ រួចទូលសួរថា៖

"បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ ដូចម្ដេចនឹងមានដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្ដីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដីអន្តរាយនោះចេញ"។

គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញ៉ាំងមហាជនទាំងនោះ ឱ្យយល់ច្បាស់ថា៖

"អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនោះឡើយ។

ដ្បិត តថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកាលជាអនាគត សុមេធបណ្ឌិតនុ៎ះកំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបូរាណធ្លាប់សេពមក។

កាលសុមេធបណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិ ដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុក្នុងលោក និងទេវលោកញាប់ញ័រ"។

*ចិត្តនៃមហាជន ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នាក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្ដងទៀត។*

*គ្រានោះ តថាគតសមាទាននូវពុទ្ធគុណ ធ្វើចិត្តឱ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ។*

*ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ។*

*ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនេះ បាននូវសួស្ដីពោលថា៖*

*"តំណែងដ៏ធំ ដែលលោកប្រាថ្នាហើយ សូមលោកបាននូវ*
*តំណែងនោះ សមគួរតាមប្រាថ្នាចុះ។*
*ចង្រៃទាំងពួង ចូរបរវៀសចៀសចេញទៅ សេចក្ដីសោក និងរោគក៏ចូរចៀសវាងចេញទៅ សេចក្ដីអន្តរាយកុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណ ដ៏ខ្ពង់ខ្ពស់ឆាប់ៗចុះ"។*
*កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កាយ៉ាងណា បពិត្រតាបសមានព្យាយាមធំ ចូរលោកបញ្ចេញផ្កា ដោយពុទ្ធញាណយ៉ាងនោះដែរ។*
*ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង១០យ៉ាងណា បពិត្រតាបសមានព្យាយាមធំ ចូរលោកបំពេញបារមីទាំង១០យ៉ាងនោះ។*
*ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបពោធិមណ្ឌលយ៉ាងណា បពិត្រតាបសមានព្យាយាមធំ ចូរលោកត្រាស់ដឹងទៀបគល់ពោធិ-*

មណ្ឌល នៃព្រះជិនស្រីយ៉ាងនោះ។

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅយ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្រ ឱ្យប្រព្រឹត្តទៅយ៉ាងនោះចុះ។

ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺនយ៉ាងនោះ។

ព្រះអាទិត្យដែលរួចផុតអំពីរាហូ រមែងរុងរឿងដោយកម្តៅយ៉ាងណា ចូរលោករួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ។

ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រយ៉ាងណា ពួកលោក ព្រមទាំងទេវលោក ក៏រមែងប្រជុំ ក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ។

គ្រានោះ សុមេធបណ្ឌិតនុ៎ះ ដែលពួកទេវតានិងមនុស្សទាំងនោះ ស្ញើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង១០ បំពេញបារមីធម៌ទាំងនោះ រួចដើរចូលទៅកាន់ព្រៃធំ។

ចប់សុមេធកថា។

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញ៉ាំងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឱ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករនោះ ជាទីពឹង។

ព្រះតថាគត ទ្រង់ញ៉ាំងបុគ្គលខ្លះ ឱ្យតាំងនៅក្នុងសរណគមន៍ ញ៉ាំងបុគ្គលខ្លះឱ្យតាំងនៅក្នុងសីល៥ និងបុគ្គលដទៃទៀតឱ្យតាំងនៅក្នុងសីល១០។

ព្រះអង្គទ្រង់ប្រទានមគ្គ ដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើ ដល់បុគ្គលខ្លះ។

*ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ៨[៤៦]ដ៏ប្រសើរដល់បុគ្គលខ្លះ ប្រទានវិជ្ជា៣ដល់បុគ្គលខ្លះ អភិញ្ញា៦ដល់បុគ្គលខ្លះ។*

*ព្រះមហាមុនី ទ្រង់ទូន្មានពួកជនដោយន័យ ជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនា នៃព្រះលោកនាថ ជាគុណជាតដ៏ធំទូលាយ។*

*ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះ**ហនុកា** ដូចព្រះចន្ទក្នុងថ្ងៃ១២កើត មានជង្គខ្លួនមូលក្ញុំដូចគោឧសភៈ ទ្រង់ចម្លងពួកជនច្រើនឱ្យរួចចាកទុគ្គតិ។*

*ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ឋិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិត ហើយញ៉ាំងពួកជននោះ ឱ្យត្រាស់ដឹងក្នុងខណៈនោះ។*

*ក្នុងការត្រាស់ដឹងទី១ ព្រះពុទ្ធទ្រង់ញ៉ាំងពួកទេវតា១០០កោដិឱ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី២ ព្រះលោកនាថទ្រង់ញ៉ាំងពួកទេវតា និងមនុស្ស៩០កោដិ ឱ្យត្រាស់ដឹង។*

*កាលព្រះពុទ្ធទ្រង់សំដែងធម៌ ក្នុងភពនៃទេវតា កាលនោះ ពួកទេវតា៩០ពាន់កោដិបានត្រាស់ដឹង នេះជាការត្រាស់ដឹងទី៣។*

*ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត ការជួបជុំសាវ័ក៣ លើក គឺសន្និបាតលើកទី១ មានភិក្ខុសង្ឃ១សែនកោដិ។*

---

[៤៦]**សមាបត្តិ** ( ន. ) *[សៈម៉ាប័ត] ( សំ., បា. ) ការដល់ព្រម; ការបណ្តាលឲ្យកើតមានឡើង; ការសមប្រកប; ការចួបប្រទះ, ការចួបប្រសព្វ; ការបានសម្រេច ។ ព. ពុ. ការចូលឈានតាមលំដាប់ថ្នាក់ទាំង ៨ គឺ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ : ព្រះអរហន្តចូលសមាបត្តិ, ព្រះបច្ចេកពុទ្ធចេញចាកសមាបត្តិ។*

**ពុទ្ធបណិធាន**

*កាលដែលព្រះជិនស្រី ទ្រង់យាងទៅក្នុងទីស្ងាត់ លើកំពូលភ្នំនារទៈ ពួកព្រះខីណាស្រពប្រាសចាកមន្ទិលចំនួន១០០កោដិ មកប្រជុំគ្នា នេះជាសន្និបាតលើកទី២។*

*កាលព្រះមហាមុនីមានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ៩០កោដិ ឰដ៏ភ្នំសុទស្សនៈ នេះជាសន្និបាតលើកទី៣។*

*សម័យនោះ តថាគត ជាតាបសមានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់នូវត្រើយ នៃអភិញ្ញាទាំង៥ ហើយពួកសត្វចំនួន៣ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វនឹងរាប់ថា១ ឬ២ រាប់មិនអស់ឡើយ។*

*សាសនារបស់ព្រះទីបង្ករ មានព្រះដ៏មានភាគជាគុណជាតធំទូលាយ មានជនច្រើនស្គុកស្គម្ភសាយភាយ គឺព្រះអង្គទ្រង់ជម្រះល្អហើយក្នុងកាលនោះ។*

*ពួកព្រះខីណាស្រពចំនួន៤សែនរូប បានលុះអភិញ្ញា៦មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល។*

*ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល។*

*សាសនា របស់ព្រះពុទ្ធទីបង្ករនោះ រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្តខីណាស្រព ជាតាទិបុគ្គលប្រាសចាកមន្ទិលសព្វកាល។*

*នគរ របស់ព្រះសាស្តាព្រះនាមទីបង្ករឈ្មោះរម្មវតី ក្សត្រិយ៍ព្រះនាមសុទេវៈជាព្រះបិតា ព្រះជនិកាព្រះនាមសុមេធា។*

*ព្រះជិនស្រី នៅគ្រប់គ្រងផ្ទះអស់១ម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់មាន៣ខ្នង គឺហង្សប្រាសាទ១ កោញ្ចប្រាសាទ១ មាយុរប្រាសាទ១។*

*ពួកនារី៣សែននាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះ**បទុមា**នោះជាមហេសី ព្រះឱរសព្រះនាមឱសកក្ខន្ធ។*

*ព្រះជិនស្រីឃើញនិមិត្តទាំង៤ ទ្រង់ចេញទៅបួសដោយយានដំរី ទ្រង់ផ្គងព្យាយាមអស់១០ខែឥតខ្ចះ។*

*លុះព្រះមុនី មានព្រះទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ ព្រះមហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ។*

*ព្រះជិនស្រីមានព្យាយាមធំ ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងវត្តនន្ទៈ ទ្រង់គង់ទៀបគល់ច្រេស ធ្វើការញ៉ាំញីតិរ្ថិយ។ ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវ័ក ព្រះសាគតៈជាឧបដ្ឋាករបស់ព្រះសាស្តាទីបង្ករ។*

*នាងនន្ទា និងនាងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាដើមល្បៀប។*

*ឧបាសកឈ្មោះតបុស្សៈ និងភល្លិកៈជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមា និងនាងសោណា ជាឧបដ្ឋាយិកា របស់ព្រះសាស្តាទីបង្ករ។*

*ព្រះមហាមុនីទីបង្ករ មានកម្ពស់៨០ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្សមានផ្ការីកស្គុះស្គាយ រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ១០០យោជន៍ជុំវិញ ព្រះមហេសីនោះមានព្រះជន្ម១សែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញ៉ាំងព្រះសទ្ធម្មឱ្យរុងរឿង ចម្លងមហាជន ញ៉ាំងប្រជុំជនច្រើនឱ្យឆ្លងចាកសង្សារវដ្ត។*

*ព្រះទីបង្ករនោះ និងសាវ័កនិព្វានទៅ ដូចគំនរភ្លើងដែលរុងរឿងរលត់ទៅដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈឮដ៏ព្រះបាទានោះក្តី ក៏រលត់ទៅហើយ សម្បត្តិទាំងអស់ក៏អន្តរធានទៅ ឱហ្ន៎! សង្ខារ ជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្តា ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ។*

**ពុទ្ធបណិធាន**

ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់៣៦យោជន៍ គេសាងទុកក្នុងវត្តនន្ទៈនោះឯង។

គ្រានោះ ពួកជនកសាងព្រះស្តូបកម្ពស់៣យោជន៍ ទៀបគល់ពោធិព្រឹក្ស សម្រាប់បញ្ចុះបាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា។

ចប់ទីបង្ករពុទ្ធវង្ស ។

# ជំពូកទី៥

# និទានកថា

# គោណាគមពុទ្ធប្បាទ
# រហូតដល់
# កស្សបពុទ្ធប្បាទ

## ៥. កោណ្ឌញ្ញពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធកោណ្ឌញ្ញៈ*

*សម័យខាងក្រោយអំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយកព្រះនាម **កោណ្ឌញ្ញៈ** ទ្រង់មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្របសង្កត់បាន។*

*ព្រះអង្គមានការអត់ធន់ប្រៀបដោយធរណី មានសីលប្រៀបដោយសាគរ មានសមាធិប្រៀបដោយភ្នំសុមេរុ មានញាណប្រៀបដោយអាកាស។*

*ព្រះសម្ពុទ្ធទ្រង់ប្រកាសហើយនូវឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ និងមគ្គសច្ចៈ ដើម្បីប្រយោជន៍ដល់សព្វសត្វទាំងឡាយ សព្វកាល។*

*កាលដែលព្រះកោណ្ឌញ្ញៈ ជាលោកនាយក ទ្រង់សំដែងធម្មចក្រ ពួកសត្វប្រមាណ១សែនកោដិ បានសម្រេចមគ្គផលលើកទី១។*

*លំដាប់អំពីនោះ កាលព្រះអង្គទ្រង់សំដែងធម៌ក្នុងសមាគមនៃមនុស្ស និងទេវតា ពួកសត្វប្រមាណ៩០ពាន់កោដិ បានសម្រេចមគ្គផលលើកទី២។*

*កាលព្រះលោកនាយក ទ្រង់សំដែងធម៌ញាំញីពួកតិរ្ថិយ ពួកសត្វ៨០ពាន់កោដិ បានសម្រេចមគ្គផលលើកទី៣។*

*ព្រះមហេសីកោណ្ឌញ្ញៈ មានសាវកសន្និបាត៣លើក គឺសន្និបាតទី១ មានព្រះខីណាស្រពដែលប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់នឹងធឹងចំនួន១សែនកោដិ សន្និបាតទី២ មានព្រះខីណាស្រព១ពាន់កោដិ សន្និបាតទី៣ មានព្រះខីណាស្រព៩០កោដិ។*

ក្នុងសម័យនោះ តថាគតបានកើតជាក្សត្រ មានឈ្មោះថាវិជិតាវី បាន ញ៉ាំងឥស្សរិយយសឱ្យប្រព្រឹត្តទៅ រហូតដល់សមុទ្រជាទីបំផុត។

តថាគត បាននិមន្តព្រះខីណាស្រព១សែនកោដិ ដែលប្រាសចាកមន្ទិល ស្វែងរកនូវគុណដ៏ធំ និងព្រះសម្ពុទ្ធជាទីពឹងដ៏ប្រសើរ របស់សត្វលោក ឱ្យឆាន់ ស្កប់ស្កល់ ដោយម្ហូបចំណីដ៏ថ្លៃថ្លា។

ព្រះសម្ពុទ្ធជាលោកនាយក ព្រះនាមកោណ្ឌញ្ញៈអង្គនោះ ទ្រង់ព្យាករ តថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ បុរសនេះ នឹងបានជា ព្រះពុទ្ធក្នុងលោក។

សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្តី ព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទី នោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។

តអំពីនោះមក សត្វនេះ មានយសច្រើន ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស គឺដើមពោធិ។

ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធនោះ នឹងមានព្រះនាមថាមាយា ព្រះបិតា មានព្រះនាមថាសុទ្ធោទនៈ ឯព្រះពុទ្ធអង្គនេះ មានព្រះនាមថាគោតម ព្រះថេរៈ ឈ្មោះកោលិតៈ១ ឧបតិស្សៈ១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់ រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក

*បម្រើព្រះជិនស្រីអង្គនោះ។*

*ព្រះថេរីឈ្មោះខេមា១ ឈ្មោះឧប្បលវណ្ណា១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។*

*ពោធិព្រឹក្ស របស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។*

*ឧបាសកជាឧបដ្ឋាកដ៏ប្រសើរឈ្មោះចិត្តៈ១ ឈ្មោះហត្ថាឡវកៈ១។*

*ឧបាសិកាជាឧបដ្ឋាយិកាដ៏ប្រសើរ ឈ្មោះនន្ទមាតា១ ឈ្មោះឧត្តរា១។*

*ព្រះគោតមដ៏ទ្រង់មានយសអង្គនោះ មានព្រះជន្ម១០០ ឆ្នាំ។*

*ពួកមនុស្ស និងទេវតា បានស្ដាប់ភាសិតរបស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំនេះហើយ ក៏រីករាយថា បុរសនេះជាពូជពន្ធុកនៃព្រះពុទ្ធ។*

*ពួកមនុស្ស និងទេវតាមួយម៉ឺនចក្រវាល មានសំឡេងហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា៖*

*"យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថកោណ្ឌញ្ញៈអង្គនេះ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគត មិនខាន។*

*ពួកមនុស្ស កាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំយ៉ាងណា យើងទាំងអស់គ្នា បើលះបង់ព្រះជិនស្រីនេះហើយ គង់នឹងបានជួបចំពោះព្រះភក្ត្រនៃព្រះសាស្ដាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ"។*

*តថាគត បានស្ដាប់នូវព្រះតម្រាស់ របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃពេក កាលញ៉ាំងប្រយោជន៍នោះឱ្យសម្រេច បានថ្វាយរាជ-*

*សម្បត្តិដ៏ធំចំពោះព្រះជិនស្រី លុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសម្នាក់របស់ព្រះអង្គ។*

*តថាគត បានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនា មានអង្គ៩ទាំងអស់ ហើយញ៉ាំងសាសនានៃព្រះជិនស្រី ឱ្យរុងរឿង។*

*តថាគត មិនប្រមាទ កាលនៅក្នុងទីនោះ បានសម្រេចអភិញ្ញាបារមី ក្នុងទីអង្គុយ និងទីចង្រ្កម ក៏បានទៅកើតនៅក្នុងព្រហ្មលោក។*

*ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះរម្មវតី មានព្រះបិតាព្រះនាម**សុនន្ទៈ** ព្រះមាតាព្រះនាមនាង**សុជាតាទេវី**។*

*ព្រះអង្គ ទ្រង់គង់នៅក្នុងកណ្តាលផ្ទះអស់១ម៉ឺនឆ្នាំ ឯប្រាសាទដ៏ប្រសើររបស់ព្រះអង្គមាន៣ គឺ រុចិប្រាសាទ១ សុរុចិប្រាសាទ១ សុភប្រាសាទ១។*

*នារី៣សែន មានគ្រឿងប្រដាប់សមរម្យ នារីជាអគ្គមហេសី ព្រះនាម**រុចិទេវី** មានព្រះរាជបុត្រ១ព្រះអង្គ ព្រះនាម**ជីវិតសេន**។*

*ព្រះជិនស្រីឃើញនិមិត្តទាំង៤យ៉ាង ទ្រង់ចេញទៅដោយរថយាន ទៅតាំងសេចក្តីព្យាយាមអស់១០ខែឥតខ្វះ។*

*ព្រះសម្ពុទ្ធព្រះនាមកោណ្ឌញ្ញៈ មានព្រះទ័យស្ងប់រម្ងាប់ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ មានចក្រប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនា ក្នុងមហាវ័នរបស់ពួកទេវតា។*

*ព្រះថេរៈឈ្មោះ**ភទ្ទៈ**១ ឈ្មោះ**សុភទ្ទៈ**១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះ**អនុរុទ្ធ** ជាឧបដ្ឋាករបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ។*

*ភិក្ខុនីឈ្មោះ**តិស្សា**១ **ឧបតិស្សា**១ ជាអគ្គសាវិកា។*

**ពុទ្ធបណិធាន**

*សាលកល្យាណិព្រឹក្ស ជាពោធិរបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ។*

*ឧបាសកឈ្មោះ**សោណៈ**១ និង**ឧបសោណៈ**១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ**នន្ទា** ១ និង**សិរិមា**១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះមហាមុនីអង្គនោះ មានកម្ពស់៨៨ហត្ថ ទ្រង់ល្អល្អះដូចព្រះចន្ទពុំនោះសោតដូចព្រះអាទិត្យ ក្នុងវេលាថ្ងៃត្រង់។*

*ព្រះអង្គមានព្រះជន្មាយុ១ សែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនជាច្រើនឱ្យឆ្លងចាកវាលវដ្តសង្សារ។*

*ផែនដីដ៏វិចិត្រ ដោយព្រះខីណាស្រពទាំងឡាយ ដែលអស់មន្ទិល ព្រះសម្ពុទ្ធអង្គនោះ ទ្រង់រុងរឿងដូចមេឃ ដែលល្អដោយពួកផ្កាយ។*

*ព្រះនាគត្ថេរ ទាំងអម្បាលនោះ មានគុណប្រមាណមិនបាន មានសន្តានមិនកម្រើក បុគ្គលចូលទៅរកបានដោយកម្រ សំដែងនូវឫទ្ធិ ដូចកាលធ្លាក់ចុះនៃផ្ទេកបន្ទោរ ព្រះអរហន្តដ៏មានយសធំទាំងនោះ និព្វានហើយ។*

*ចំណែកឫទ្ធិ របស់ព្រះជិនស្រីនោះ ជាគុណឥតថ្លឹងថ្លៃងបាន សមាធិមានញាណអប់រំហើយ របស់ទាំងអស់វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត។*

*ព្រះកោណ្ឌញ្ញសម្ពុទ្ធ ព្រះអង្គទ្រទ្រង់សិរី ទ្រង់បរិនិព្វានក្នុងនន្ទារាម ពួកមហាជនបានបញ្ចុះព្រះអដ្ឋិរបស់ព្រះអង្គនោះ ក្នុងចេតិយមានកម្ពស់៧យោជន៍ក្នុងនន្ទារាមនោះឯង។*

***ចប់កោណ្ឌញ្ញពុទ្ធវង្ស ។***

# ៦. មង្គលពុទ្ធប្បវត្តិ

## *ការឧប្បត្តិឡើងនៃព្រះពុទ្ធមង្គលៈ*

*កាលខាងក្រោយព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោកនាយកព្រះនាម* **មង្គលៈ** *ទ្រង់កម្ចាត់បង់ងងឹតក្នុងលោក ព្រះអង្គទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌។*

*ពន្លឺរបស់ព្រះអង្គឥតប្រៀបបាន ជាពន្លឺលើសលប់ជាងព្រះជិនស្រីដទៃ គ្របសង្កត់ពន្លឺព្រះចន្ទ និងព្រះអាទិត្យរុងរឿងអស់មួយម៉ឺនលោកធាតុ។*

*ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ប្រកាសសច្ចៈ៤ដ៏ប្រសើរ ពួកសត្វនោះៗ បានផឹករសសច្ចៈ ហើយកម្ចាត់ងងឹតធំ គឺមោហៈ។*

*ព្រះសម្ពុទ្ធអង្គនោះ បានដល់នូវពោធិញ្ញាណ ជាគុណឥតប្រៀបបាន កាលសំដែងធម៌ជាដំបូងពួកសត្វ១សែនកោដិ បានសម្រេចមគ្គផលលើកទី១។*

*ព្រះសម្ពុទ្ធ ទ្រង់សំដែងធម៌ក្នុងសុរិន្ទទេវភព កាលនោះពួកសត្វ១សែនកោដិ បានសម្រេចមគ្គផលលើកទី២។*

*កាលព្រះបាទ***សុនន្ទចក្រពត្តិ** *ទ្រង់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលនោះព្រះសម្ពុទ្ធទ្រង់វាយស្គរគឺព្រះធម៌ ដ៏ប្រសើរខ្ពង់ខ្ពស់។*

*កាលនោះ ពួកជនដែលតាមហែព្រះបាទសុនន្ទៈ មានចំនួន៩០កោដិ ជនទាំងអស់នោះបានជាឯហិភិក្ខុឥតសេសសល់ នោះជាលើកទី៣។*

*ព្រះមង្គលសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត៣លើក គឺសន្និបាតលើកទី១ មានព្រះខីណាស្រព១សែនកោដិ លើកទី២ មានព្រះខីណាស្រព១សែនកោដិ លើកទី៣ មានព្រះខីណាស្រព៩០កោដិ។*

សមាគមក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល សម័យនោះ តថាគតជាព្រាហ្មណ៍ឈ្មោះសុរុចិ។

តថាគត ជាអ្នករៀនមន្តចងចាំមន្ត ដល់នូវត្រើយនៃវេទទាំង៣ ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ហើយបានដល់ព្រះសាស្តា ជាទីពឹង។

តថាគត បានបូជាព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយគ្រឿងក្រអូប និងផ្កាកម្រង លុះបូជាហើយក៏ញុំាងព្រះភិក្ខុសង្ឃ ឱ្យឆាន់ស្កប់ស្កល់ ដោយទឹកដោះគោ។

ព្រះសម្ពុទ្ធព្រះនាមមង្គលៈនោះ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ទ្រង់ទំនាយតថាគតថា ក្នុងរវាងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ បុរសនេះនឹងបានត្រាស់ជាព្រះពុទ្ធ។

សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ តាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែង។

លំដាប់អំពីនោះទៅ ព្រះជិនស្រីមានយសច្រើន នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ឯបុរសនេះ ជាព្រះពុទ្ធព្រះនាមថាគោតម។

ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវ័ក ព្រះថេរៈ

ឈ្មោះអានន្ទ នឹងបានជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនោះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំនឹងបានជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស គឺជាដើមពោធិ។

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងបានជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងបានជាអគ្គឧបដ្ឋាយិកា។

ព្រះគោតម មានយសនោះ ទ្រង់មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា បានឮព្រះពុទ្ធដីកានេះរបស់ព្រះពុទ្ធមិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា **បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ។**

ពួកមនុស្ស និងទេវតាមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា៖

"យើងទាំងឡាយ បើឃ្លាងមគ្គផល ក្នុងសាសនា របស់ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន។

ពួកមនុស្ស កាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំយ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ"។

តថាគត បានស្តាប់ព្រះតម្រាស់ របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី១០។

*ក្នុងកាលនោះ តថាគតបម្រើនបីតិ ថ្វាយផ្ទះរបស់តថាគតចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់ព្រះអង្គ ដើម្បីសម្រេចពោធិញ្ញាណដ៏ប្រសើរ។*

*តថាគត បានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនា មានអង្គ៩ទាំងអស់ហើយ ញុាំងសាសនានៃព្រះជិនស្រី ឱ្យល្អរុងរឿង។*

*តថាគត មិនប្រមាទកាលនៅក្នុងទីនោះ ចម្រើនព្រហ្មវិហារ បានសម្រេចអភិញ្ញាបារមី ហើយក៏បានទៅកើតនៅក្នុងព្រហ្មលោក។*

*ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះឧត្តរៈ មហាក្សត្រទ្រង់ព្រះនាម**ឧត្តរៈ**ជាព្រះបិតា ព្រះមាតាព្រះនាម**ឧត្តរា**។*

*ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងរាជដំណាក់អស់៩ពាន់ឆ្នាំ មានប្រាសាទ៣ដ៏ល្អឧត្តម គឺយសវប្រាសាទ១ សុចិមប្រាសាទ១ សិរិមប្រាសាទ១។*

*មានពួកនារី៣ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ នារីជាអគ្គមហេសីឈ្មោះ**យសវតី** មានព្រះរាជបុត្រឈ្មោះ**សីវលៈ**។*

*ព្រះជិនស្រីទ្រង់ឃើញនិមិត្ត៤ ហើយទ្រង់ចេញទៅដោយយានសេះ តាំងសេចក្តីព្យាយាម អស់៨ខែឥតខ្វះ។*

*ព្រះលោកនាយកព្រះនាមមង្គលៈ មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាម ទ្រង់ប្រសើរជាងសត្វទ្វេបាទ ត្រូវមហាព្រហ្មអារាធនាហើយ ទើបស្តេចត្រាច់ទៅ គឺសំដែងធម៌។*

*ព្រះថេរៈ ឈ្មោះ**សុទេវៈ**១ **ធម្មសេនៈ**១ ជាអគ្គសាវ័ក ព្រះថេរៈ ឈ្មោះ**បលិតៈ** ជាឧបដ្ឋាក របស់ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ។*

*ព្រះថេរីឈ្មោះ**សីវលា**១ និង**អសោកា**១ ជាអគ្គសាវិកា។*

*ដើមឈើត្រាស់ដឹង របស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថា**នាគព្រឹក្ស** ឬដើមខ្លឹង។*

ឧបាសកឈ្មោះ**នន្ទ**:១ **វិសាខ**:១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ **អនុឡា**១ **សុមនា**១ ជាអគ្គឧបដ្ឋាយិកា។

ព្រះមហាមុនី ទ្រង់មានកម្ពស់៨៨ហត្ថ រស្មីច្រើនសែន ផ្សាយចេញអំពីកាយព្រះអង្គ។

ព្រះជន្មាយុរបស់ព្រះអង្គ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ឋិតនៅដរាបនោះ ញុំាំងពួកជនច្រើន ឱ្យឆ្លងវដ្តសង្សារ។

រលកក្នុងសាគរ គេមិនអាចរាប់បាន យ៉ាងណាមិញ សាវ័កទាំងឡាយរបស់ព្រះអង្គ ក៏គេមិនអាចរាប់បាន យ៉ាងនោះដែរ។

ព្រះមង្គលសម្ពុទ្ធ ជាលោកនាយក ទ្រង់បានឋិតនៅដរាបណា មរណៈប្រកបដោយកិលេស មិនមានក្នុងសាសនានៃព្រះអង្គដរាបនោះ ហើយព្រះសម្ពុទ្ធទ្រង់មានយសច្រើនអង្គនោះ ទ្រទ្រង់នូវគប់ភ្លើងគឺព្រះធម៌ ហើយញុំាំងមហាជនឱ្យឆ្លងដ៏រុងរឿង ដូចជាផ្កាយដុះកន្ទុយ ទើបទ្រង់បរិនិព្វាន។

ព្រះសម្ពុទ្ធ ទ្រង់សំដែងនូវសភាពប្រែប្រួលនៃសង្ខារ ដល់ពួកមនុស្ស និងទេវតា រុងរឿងដូចជាគំនរភ្លើង ពុំនោះសោតដូចព្រះអាទិត្យ ដែលទើបនឹងអស្តង្គត។

ព្រះមង្គលសម្ពុទ្ធ ទ្រង់បរិនិព្វានក្នុងឧទ្យានឈ្មោះវេស្សរៈ ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់៣០យោជន៍ មាននៅក្នុងទីនោះឯង។

**ចប់មង្គលពុទ្ធវង្ស ។**

## ៧. សុមនពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធសុមនៈ*

*កាលខាងក្រោយ អំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយកព្រះនាម **សុមនៈ** រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គឧត្តមជាងសព្វសត្វ។*

*កាលនោះ ព្រះអង្គទ្រង់ទូងស្គរគឺអមតៈ ប្រកបដោយស័ង្ខ គឺធម៌ ជាសាសនា របស់ព្រះជិនស្រីមានអង្គ៩ ក្នុងមេខលបុរី។*

*ព្រះសាស្តាអង្គនោះ ទ្រង់ឈ្នះកិលេស ហើយសម្រេចនូវសម្ពោធិញ្ញាណដ៏ប្រសើរ ទ្រង់សាងនគរជាបុរី គឺព្រះសទ្ធម្មដ៏ប្រសើរខ្ពង់ខ្ពស់។*

*ព្រះអង្គទ្រង់សាងផ្លូវធំមិនមានចន្លោះ ជាផ្លូវមិនវៀច ជាផ្លូវត្រង់ មានទទឹងដ៏ធំទូលាយ គឺសតិប្បដ្ឋានដ៏ប្រសើរខ្ពង់ខ្ពស់។*

*ព្រះអង្គទ្រង់លាតសាមញ្ញផល៤*[៤៧] *បដិសម្ភិទា៤*[៤៨] *អភិញ្ញា៦ សមាបត្តិ៨ ក្នុងផ្លូវនោះ។*

---

[៤៧] *ផលនៃសមណភាព ឈ្មោះថា សាមញ្ញផល បានដល់ សោតាបត្តិផល១ សកទាគាមិផល១ អនាគាមិផល១ អរហត្តផល១។*

[៤៨]**បដិសម្ភិទា** ( ន. ) *[ប៉ៈដិសាំភិទា]* *( បា., សំ. )* (ប្រតិ--) *ការបែកប្រាជ្ញាយល់ច្បាស់, ប្រាជ្ញាដែលបែកអាចយល់ធ្លុះធ្លាយឥតទើសទាក់, ប្រាជ្ញាដែលភ្លឺស្វាងអាចពិចារណាយល់ជាក់ប្រាកដភ្លាមៗ នូវហេតុផលនៃកិច្ចការទាំងពួង : កាលដែលព្រះពុទ្ធទ្រង់សម្ដែងធម៌នោះចប់ហើយ ភិក្ខុទាំងឡាយក៏បានសម្រេចអរហត្តផល ព្រមទាំងបដិសម្ភិទាផង។* - បដិសម្ភិទា មាន ៤យ៉ាងគឺ **១-អត្ថប្បដិសម្ភិទា** *ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងអត្ថ;* **២-ធម្មប្បដិសម្ភិទា** *ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងធម៌,* **៣-និរុត្តិប្បដិសម្ភិទា** *ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងនិរុត្តិ (ម. ព. និរុត្តិ*

ពួកសត្វណា មិនមានសេចក្ដីប្រមាទ មិនរីងរូស ប្រកបដោយសេចក្ដីខ្មាសបាប និងសេចក្ដីព្យាយាម ពួកសត្វនោះៗ តែងកាន់យកគុណដ៏ប្រសើរទាំងនេះ តាមសប្បាយ។

ព្រះសាស្ដា ទ្រង់ស្រោចស្រង់មហាជន ដោយសេចក្ដីព្យាយាមនោះយ៉ាងនេះឯង បានញ៉ាំងសត្វ១សែនកោដិ ឱ្យត្រាស់ដឹងលើកទី១។

ព្រះសាស្ដាមានព្យាយាមច្រើន ទ្រង់ឱ្យឱវាទពួកតិរ្ថិយក្នុងកាលណា កាលនោះសត្វ១សែនកោដិ បានសម្រេចគុណវិសេស ក្នុងធម្មទេសនាលើកទី២។

ពួកទេវតា និងមនុស្ស មានសេចក្ដីព្រមព្រៀងគ្នា មានចិត្តស្រួលបួល សួរប្រស្នាក្នុងនិរោធផង សេចក្ដីសង្ស័យផង សេចក្ដីប្រាថ្នាក្នុងចិត្តផង ក្នុងកាលណា កាលនោះពួកសត្វ៩០ពាន់កោដិ បានសម្រេចមគ្គផលលើកទី៣ ក្នុងធម្មទេសនា ជាគ្រឿងបំភ្លឺនូវនិរោធ។

ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត៣លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង។

កាលព្រះដ៏មានព្រះភាគ ទ្រង់ចេញវស្សាហើយ កាលភិក្ខុសង្ឃប្រកាសបវារណាហើយ ព្រះតថាគត ទ្រង់បវារណាដោយភិក្ខុចំនួន១សែនកោដិ នេះជាសន្និបាតលើកទី១។

---

ទៀតផង); ៤-**បដិភាណប្បដិសម្ភិទា** ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងបដិភាណ (ម. ព. បដិភាណ ទៀតផង) ។

**ពុទ្ធបណិធាន**

*ក្នុងការប្រជុំដទៃអំពីនោះមក មានសន្និបាតលើកទី២ នៃព្រះខីណាស្រព ៩០ពាន់កោដិ លើកញ្ញូនបព៌តមិនមានមន្ទិល។*

*កាលសក្កទេវរាជ ចូលមកគាល់ព្រះសម្ពុទ្ធ ជាសន្និបាតលើកទី៣ របស់ព្រះខីណាស្រព៨០ពាន់កោដិ។*

*ក្នុងសម័យនោះ តថាគត កើតជាស្តេចនាគ មានឫទ្ធិច្រើន មានឈ្មោះថា* ***អតុល:*** *ជាអ្នកសន្សំកុសល។*

*កាលនោះតថាគត ចេញអំពីភពនាគ ជាមួយនឹងពួកញាតិ បានទៅបម្រើព្រះជិនស្រី និងព្រះសង្ឃដោយតន្ត្រីទិព្វរបស់នាគ។*

*តថាគត បានញុំាងភិក្ខុសង្ឃ១សែនកោដិ ឱ្យឆ្អែតស្កប់ស្កល់ដោយបាយទឹក និងសំពត់១គូៗ មួយអង្គ ហើយយកព្រះភិក្ខុសង្ឃនោះជាទីពឹង។*

*ព្រះសម្ពុទ្ធ ព្រះនាមសុមន: ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា* ***ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ។***

***សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ទៅតម្កល់សេចក្តីព្យាយាមធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។***

***ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលមកទៀបគល់ពោធិព្រឹក្ស តាមផ្លូវដែលគេចាត់ចែងដ៏ប្រសើរ។***

***លំដាប់តអំពីនោះមក ព្រះសម្ពុទ្ធមានយសច្រើន ទ្រង់ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។***

ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធអង្គនោះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯនាគរាជនេះ នឹងបានត្រាស់ជាព្រះសម្ពុទ្ធព្រះនាមគោតម ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ ជាអ្នកមិនមានអាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថ-ព្រឹក្ស។

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតម ទ្រង់មានយសអង្គនោះ នឹងមានព្រះជន្ម១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា បានស្តាប់ពុទ្ធដីកានេះ របស់ព្រះមហេសី មិនមានបុគ្គលស្មើហើយក៏រីករាយថា នាគរាជនេះនឹងជាពូជពន្លកនៃព្រះពុទ្ធ។

ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ ស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថាៈ

"យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគត មិនខាន ។

*ពួកមនុស្ស កាលធ្វងស្ទឹង បើឃ្វាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយធ្វងស្ទឹងធំយ៉ាងណា យើងទាំងអស់គ្នាបើឃ្វាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ៉ៗ*

*តថាគត បានស្តាប់ព្រះតម្រាស់ របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី១០ៗ*

*ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានទីក្រុងឈ្មោះមេខលៈ មានមហាក្សត្រព្រះនាមសុទត្តៈជាព្រះបិតា មានព្រះមាតាព្រះនាមសិរិមាៗ*

*ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់៩ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺ**ចន្ទ្រប្រាសាទ១ សុចន្ទ្រប្រាសាទ១ វដំសប្រាសាទ១**ៗ*

*ពួកនារី៦៣សែននាក់ មានរូបប្រដាប់សមរម្យ នារីជាអគ្គមហេសីព្រះនាម**វដំសកី** មានព្រះរាជបុត្រព្រះនាម**អនូបមៈ**ៗ*

*ព្រះជិនស្រីឃើញនិមិត្តទាំង៤ហើយ ទ្រង់ចេញបព្វជ្ជាដោយយានដំរី តាំងសេចក្តីព្យាយាមអស់១០ខែឥតខ្វះៗ*

*ព្រះលោកនាយកព្រះនាមសុមនៈ មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាមធំ ត្រូវព្រហ្មអារាធនាក្នុងមេខលបុរី ដ៏ប្រសើរខ្ពង់ខ្ពស់ៗ*

*ព្រះថេរៈឈ្មោះ**សរណៈ**១ **ភាវិតត្តៈ** ១ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះ**ឧទេនៈ** ជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធព្រះនាមសុមនៈ ទ្រង់ស្វែងរកនូវគុណដ៏ធំៗ*

*ព្រះថេរីឈ្មោះ**សោណា**១ **ឧបសោណា**១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធនោះស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ទ្រង់បានត្រាស់ដឹងទៀបគល់នាគ-ព្រឹក្ស។*

*ឧបាសកឈ្មោះ**វរុណៈ**១ **សរណៈ**១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ **ចាលា**១ **ឧបចាលា**១ ជាអគ្គឧបដ្ឋាយិកា។*

*ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់៩០ហត្ថ មានលំអនៃព្រះរូបដូចគ្រឿងបូជាមាស ទ្រង់រុងរឿងក្នុងមួយម៉ឺនលោកធាតុ។*

*ព្រះជន្មាយុរបស់ព្រះអង្គ ៩ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់បិតនៅដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឱ្យឆ្លងវដ្តសង្សារ។*

*ព្រះសម្ពុទ្ធ ទ្រង់ចម្លងពួកសត្វដែលគួរចម្លង ទ្រង់បានដាស់តឿនពួកសត្វដែលគួរដាស់តឿន ហើយទ្រង់បរិនិព្វានដូចព្រះចន្ទ្រអស្តង្គត។*

*ភិក្ខុទាំងឡាយនោះ ជាព្រះខីណាស្រពក្តី ព្រះសម្ពុទ្ធអង្គនោះក្តី ទ្រង់មិនមានបុគ្គលណាស្មើ ទ្រង់បញ្ចេញរស្មីឥតថ្លឹងថ្លែងបាន ព្រះខីណាស្រពដែលមានយសច្រើនទាំងនោះ និព្វានហើយ។*

*ព្រះញាណនោះ ជាគុណឥតមានអ្វីថ្លឹងបានផង រតនៈទាំងនោះ ឥតមានអ្វីថ្លឹងបានផង របស់ទាំងអស់នោះវិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត។*

*ព្រះសុមនសម្ពុទ្ធទ្រទ្រង់យស ទ្រង់បរិនិព្វានក្នុងអង្គារាម។*

*ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់៤យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ។*

ចប់សុមនពុទ្ធវង្ស ។

## ៨. រេវតពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធរេវតៈ*

*កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមសុមនៈមក មានព្រះលោកនាយកព្រះនាម**រេវតៈ** មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រដូចបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ។*

*ព្រះសម្ពុទ្ធអង្គនោះ លុះមហាព្រហ្មអារាធនាហើយ ទ្រង់ប្រកាសធម៌ដ៏កំណត់ដោយខន្ធ និងធាតុ ជាធម៌មិនប្រព្រឹត្តទៅក្នុងភពតូចភពធំ។*

*ក្នុងការសម្ដែងធម៌ នៃព្រះរេវតសម្ពុទ្ធនោះ មានការត្រាស់ដឹងមគ្គផល៣លើក គឺការត្រាស់ដឹងលើកទី១ មិនគប្បីពោលដោយការរាប់ចំនួនបាន។*

*ព្រះមហាមុនីព្រះនាមរេវតៈ ទ្រង់ទូន្មានព្រះបាទអរិន្ទមៈ ក្នុងកាលណា កាលនោះពួកសត្វ១ពាន់កោដិ បានត្រាស់ដឹងមគ្គផលលើកទី២។*

*ព្រះនរាសភៈ ទ្រង់ក្រោកចាកទីពួនសម្ងំអស់៧ថ្ងៃ ហើយទូន្មានពួកមនុស្ស និងទេវតា១រយកោដិ ឱ្យតាំងនៅក្នុងផលដ៏ឧត្តមលើកទី៣។*

*ព្រះសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត៣លើក សុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យរួចស្រឡះដោយប្រពៃ មានចិត្តនឹងធឹង គឺសន្និបាតលើកទី១ កន្លងផុតផ្លូវនៃការរាប់ (រាប់ពុំបាន) សន្និបាតលើកទី២ មានព្រះអរហន្ត១សែនកោដិ។*

*ព្រះអគ្គសាវ័កអង្គណា រកបុគ្គលស្មើគ្មានដោយប្រាជ្ញា ជាអ្នកប្រព្រឹត្តតាមធម្មចក្រនៃព្រះសម្ពុទ្ធអង្គនោះ កាលនោះ ព្រះអគ្គសាវ័កនោះមានព្យាធិ*

*ដល់នូវការសង្ស័យក្នុងជីវិត ហើយពួកព្រះអរហន្ត ចូលទៅគាល់ព្រះមុនី ដើម្បីសាកសួរអាពាធរបស់ព្រះអគ្គសាវ័កនោះ មានចំនួន១សែនកោដិ នេះជាសន្និបាតលើកទី៣។*

*សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះ***អតិទេវៈ** *បានចូលទៅគាល់ព្រះរេវតសម្ពុទ្ធ ហើយបានយកព្រះអង្គជាទីពឹង។*

*តថាគត បានសរសើរសីល សមាធិ និងបញ្ញាគុណ ដ៏ប្រសើររបស់ព្រះអង្គ ហើយបានថ្វាយសំពត់ឧត្តរាសង្គៈតាមកម្លាំង។*

*ព្រះសម្ពុទ្ធព្រះនាមរេវតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា* **ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបាន** *ត្រាស់ជាព្រះពុទ្ធ។*

*សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា។*

*សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។*

*ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេបានចាត់ចែងហើយ។*

*លំដាប់អំពីនោះមក ព្រះទ្រង់យសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះមាតាបង្កើត នៃព្រះសម្ពុទ្ធអង្គនោះព្រះនាមមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម។*

ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស។

ឧបាសក ឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះនាមគោតម ទ្រង់យសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ ។

ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយត្រេកអរថា ព្រាហ្មណ៍នេះ នឹងបានជាពូជពន្ធកនៃព្រះពុទ្ធ ។

ពួកមនុស្ស ព្រមទាំងទេវតា មួយម៉ឺនលោកធាតុ ស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា៖

"ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនា របស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគត មិនខាន។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំយ៉ាងណា យើងទាំងអស់គ្នាបើឃ្លាងព្រះ

*ជិនស្រីអង្គនេះ គង់នឹងបានជួបក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ៉ៗ*

*តថាគត បានស្តាប់ព្រះតម្រាស់ របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឱ្យត្រេកអរក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី១០ៗ*

*កាលនោះ តថាគតនឹកឃើញ ហើយបានអប់រំពុទ្ធការកធម៌នោះ ទាំងបានបំពេញនូវពុទ្ធការកធម៌នេះ តាមគួរដល់សេចក្តីប្រាថ្នានៃតថាគតៗ*

*ព្រះ**រេវតសម្ពុទ្ធ** ទ្រង់ស្វែងរកនូវគុណដ៏ធំ មានទីក្រុងឈ្មោះ**សុធញ្ញកៈ** មានព្រះមហាក្សត្រព្រះនាម**វិបុលៈ**ជាព្រះបិតា មានព្រះមាតាព្រះនាម**វិបុលា**ៗ*

*ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់៦ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្មមាន៣ គឺ**សុទស្សនប្រាសាទ**១ **រតនគ្ឃិប្រាសាទ**១ **អាវេឡប្រាសាទ**១ ដែលគេស្អិតស្អាងហើយៗ*

*ពួកនារី៣៣សែននាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសីព្រះនាម**សុទស្សនា** មានព្រះរាជបុត្រព្រះនាម**វរុណៈ**ៗ*

*ព្រះជិនស្រីទ្រង់ឃើញនិមិត្ត៤យ៉ាង ហើយទ្រង់ចេញបព្វជ្ជាដោយរថយាន ហើយតាំងសេចក្តីព្យាយាមអស់៧ខែឥតខ្វះៗ*

*ព្រះសម្ពុទ្ធទ្រង់ព្រះនាមរេវតៈ ជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់ញុំាងចក្រឱ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ទ្រង់ឈ្នះមារ ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់គង់នៅក្នុងវរុណារាមៗ*

*ព្រះថេរៈឈ្មោះ**វរុណៈ**១ **ព្រហ្មទេវៈ**១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះ**សម្ភវៈ** ជាឧបដ្ឋាក របស់ព្រះរេវតសម្ពុទ្ធទ្រង់ ស្វែងរកនូវគុណដ៏ធំៗ*

**ពុទ្ធបណិធាន**

*ព្រះថេរីឈ្មោះ**ភទ្ទា**១ **សុភទ្ទា**១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធឥតមានបុគ្គលស្មើអង្គនោះ ទ្រង់បានត្រាស់ដឹងទៀបដើមខ្នឹង។*

*ឧបាសកឈ្មោះ**វរុណៈ**១ **សរភៈ**១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ**បាលា**១ **ឧបបាលា**១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់៨០ហត្ថ ទ្រង់ញុំាងទិសទាំងពួង ឱ្យភ្លឺរុងរឿងដូចទង់ជ័យ របស់ព្រះឥន្ទ្រដ៏ខ្ពង់ខ្ពស់ ហើយកម្រងរស្មីដ៏ប្រសើរ កើតក្នុងសរីរៈនៃព្រះអង្គ ផ្សាយចេញ១យោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់។*

*ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ៦ម៉ឺនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឱ្យឆ្លងចាកវដ្តសង្សារ។*

*ព្រះសម្ពុទ្ធ ទ្រង់សំដែងកម្លាំងនៃព្រះពុទ្ធ ហើយទ្រង់ប្រកាសអមតធម៌ក្នុងលោក ព្រះអង្គមិនមានសេចក្តីប្រកាន់ ទ្រង់បរិនិព្វាន ព្រោះអស់ឧបាទានដូចភ្លើងដែលអស់កំញម។*

*ព្រះកាយរបស់ព្រះអង្គនោះ មានពណ៌ដូចកែវ ព្រះធម៌របស់ព្រះអង្គមិនមានអ្វីស្មើដូចទេ របស់ទាំងអស់វិនាសសូន្យទៅ សង្ខារទាំងពួងទទេពិត។*

*ព្រះវេវតសម្ពុទ្ធ ទ្រទ្រង់យសអង្គនោះ ទ្រង់មានបុណ្យច្រើន ទ្រង់បរិនិព្វានហើយ ព្រះធាតុរបស់ព្រះអង្គបានសាយភាយទៅ ក្នុងប្រទេសនោះដោយចំណែកៗ។*

***ចប់រេវតពុទ្ធវង្ស។***

# ៩. សោភិតពុទ្ធប្បវត្តិ

## ការឧប្បត្តិឡើងនៃព្រះពុទ្ធសោភិតៈ

*កាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមរេវតៈមក មានព្រះលោកនាយកព្រះនាម**សោភិតៈ** មានព្រះហឫទ័យតម្កល់ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹម។*

*ព្រះជិនស្រីអង្គនោះ ទ្រង់ញ៉ាំងបំណងក្នុងព្រះទ័យ ឱ្យប្រព្រឹត្តទៅក្នុងដំណាក់របស់ព្រះអង្គ។*

*ទ្រង់បានសម្រេចសម្ពោធិញ្ញាណ ដោយសព្វគ្រប់ ហើយទ្រង់សំដែងព្រះធម្មចក្រ ខាងលើរាប់អំពីអវិចីនរកឡើងទៅ ខាងក្រោមរាប់អំពីភវគ្គព្រហ្មចុះមកក្នុងចន្លោះនេះ ពេញដោយបរិស័ទតែម្យ៉ាង ក្នុងការសំដែងធម្មទេសនា។*

*កាលព្រះសម្ពុទ្ធ ទ្រង់សំដែងព្រះធម្មចក្រ ដល់បរិស័ទនោះ ការត្រាស់ដឹងធម៌លើកទី១ គេមិនគប្បីពោល ដោយការរាប់ចំនួនបានឡើយ។*

*លំដាប់អំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់សំដែងធម៌ក្នុងទីសមាគមនៃមនុស្ស និងទេវតា មានពួកបរិស័ទ៩ម៉ឺនកោដិ ត្រាស់ដឹងធម៌លើកទី២។*

*មួយវិញទៀត កាលនោះ ព្រះរាជបុត្រជាក្សត្រព្រះនាមជយសេន បានដាំសួនរេរថ្វាយព្រះសម្ពុទ្ធ ហើយព្រះចក្ខុមសម្ពុទ្ធ ទ្រង់ប្រកាសការបូជានៃព្រះបាទជយសេននោះ ហើយសំដែងធម្មទេសនា ក្នុងកាលនោះ មានបរិស័ទ១ពាន់កោដិ ត្រាស់ដឹងធម៌លើកទី៣។*

*ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត៣*

លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺកាលព្រះរាជា ព្រះនាមឧគ្គតៈអង្គនោះទ្រង់ថ្វាយទាន ចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងនរជន ក្នុងវេលាថ្វាយទាននោះ មានព្រះអរហន្ត១រយកោដិ និមន្តមកប្រជុំគ្នា នេះជាសន្និបាតលើកទី១។

មួយវិញទៀត មានពួកបរិស័ទថ្វាយទាន ចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងពួកនរជន ក្នុងកាលនោះមានពួកបរិស័ទ៩០កោដិ មកប្រជុំគ្នា នេះជាសន្និបាតលើកទី២។

ព្រះជិនស្រី ទ្រង់គង់ក្នុងទេវលោក ហើយស្ដេចចុះចាកទេវលោកក្នុងកាលណា កាលនោះមានពួកបរិស័ទ៨០កោដិ មកប្រជុំគ្នា នេះជាសន្និបាតលើកទី៣។

សម័យនោះ តថាគត កើតជាព្រាហ្មណ៍ឈ្មោះ**សុជាតៈ** កាលនោះ តថាគត និមន្តព្រះពុទ្ធ និងសាវ័កឱ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក។

ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា **ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ។**

**សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្ដីព្យាយាមធ្វើទុក្ករកិរិយា។**

**សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។**

**ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា**

រួចចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ។

លំដាប់អំពីនោះមក ព្រះជិនស្រីទ្រង់យសធំអង្គនោះ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធអង្គនោះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ព្រាហ្មណ៍នេះនឹងបានជាព្រះពុទ្ធព្រះនាមគោតម។

ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំនឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនោះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ មិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្មាយុ១០០ ឆ្នាំ។

ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសោភិតសម្ពុទ្ធឥតមានបុគ្គលស្មើ ព្រះសម្ពុទ្ធទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយក៏រីករាយថា ព្រាហ្មណ៍នេះជាពូជពន្ធកនៃព្រះពុទ្ធ។

**ពុទ្ធបណិធាន**

ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា៖

"ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំយ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសម្ពុទ្ធអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ"។

ចំណែកតថាគត លុះបានស្តាប់ ព្រះពុទ្ធដីការបស់ព្រះសម្ពុទ្ធអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ហើយបានធ្វើនូវប្រាជ្ញាឱ្យខ្ពង់ខ្ពស់ ដើម្បីសម្រេចប្រយោជន៍នោះ។

ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះសុធម្មៈ ព្រះមហាក្សត្រព្រះនាមសុធម្មៈជាព្រះបិតា ព្រះមាតាព្រះនាមសុធម្មា ព្រះសោភិតសម្ពុទ្ធអង្គនោះ ទ្រង់គ្រប់គ្រងដំណាក់អស់៩ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ គឺកុមុទប្រាសាទ១ នឡិនីប្រាសាទ១ បទុមប្រាសាទ១។

ពួកនារី៤ពាន់នាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសីឈ្មោះកិមិលា មានព្រះរាជបុត្រឈ្មោះសីហៈ។

ព្រះសម្ពុទ្ធខ្ពង់ខ្ពស់ជាងបុរស ទ្រង់ឃើញនិមិត្ត៤យ៉ាង ហើយស្តេចចេញទៅទ្រង់ព្រះផ្នួសដោយប្រាសាទ ទៅប្រព្រឹត្តបធានចារៈអស់៧ថ្ងៃ។

ព្រះសោភិតសម្ពុទ្ធ ជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងសុធម្ម-ឧទ្យានដ៏ប្រសើរ។

ព្រះថេរៈឈ្មោះអសមៈ១ សុនេត្តៈ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអនោមៈ ជាឧបដ្ឋាករបស់ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ។

ព្រះថេរី ឈ្មោះនកុលា១ សុជាតា១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធអង្គនោះកាលត្រាស់ដឹង ទ្រង់ត្រាស់ដឹងទៀបដើមខ្ទឹង។

ឧបាសកឈ្មោះរម្មៈ១ សុនេត្តៈ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនកុលា១ ចិត្តា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះមហាមុនី ទ្រង់មានកម្ពស់៥៨ហត្ថ ទ្រង់ញុំាងទិសទាំងពួងឱ្យភ្លឺរុងរឿង ដូចព្រះអាទិត្យរះឡើង។

ព្រៃធំ ដែលមានផ្កាឈើរីកល្អ ដែលអប់ដោយគ្រឿងក្រអូបផ្សេងៗយ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ តែងអប់ដោយក្លិនក្រអូប គឺសីល ក៏យ៉ាងនោះដែរ។

ធម្មតាសាគរ គេតែងមិនឆ្អែត ដោយការរមិលមើលយ៉ាងណា ពាក្យប្រដៅ របស់ព្រះសម្ពុទ្ធអង្គនោះ គេមិនឆ្អែតដោយការស្តាប់ ក៏យ៉ាងនោះដែរ។

ព្រះអង្គមានព្រះជន្ម ៩ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គគង់នៅជរាបអស់កាលប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជន ឱ្យឆ្លងវដ្តសង្សារ។

ព្រះអង្គ និងសាវ័ក ទ្រង់ឱ្យឱវាទ និងប្រៀនប្រដៅចំពោះជនដ៏សេសហើយញុំាងជនទាំងនោះឱ្យមានព្យាយាមដុតកម្តៅកិលេសដូចភ្លើង រួចបរិនិព្វាន។

**ពុទ្ធបណិធាន**

*ព្រះសម្ពុទ្ធស្មើដោយព្រះពុទ្ធ ឥតមានបុគ្គលស្មើអង្គនោះក្តី ពួកសាវ័កទាំងនោះ ដែលដល់នូវកម្លាំងក្តី របស់ទាំងអស់នេះក៏វិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត។*

*ព្រះសោភិតសម្ពុទ្ធដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងសីហារាម ព្រះធាតុរបស់ព្រះអង្គ សាយភាយទៅក្នុងប្រទេសនោះ តាមចំណែកៗ។*

*ចប់សោភិតពុទ្ធវង្ស ។*

## ១០. អនោមទស្សិពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធអនោមទស្សី*

*កាលជាខាងក្រោយ អំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាម **អនោមទស្សី** ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន។*

*ព្រះសម្ពុទ្ធ ទ្រង់កាត់ចំណងទាំងអស់ កម្ចាត់បង់ភពទាំង៣ រួចសម្ដែងផ្លូវសម្រាប់ដើរឆ្ពោះទៅរកនិព្វាន មិនវិលត្រឡប់វិញ ចំពោះទេវតា និងមនុស្ស។*

*ព្រះអនោមទស្សីអង្គនោះ ទ្រង់មិនរំភើបដូចជាសាគរ គេគ្របសង្កត់បានដោយក្រដូចជាភ្នំ ទ្រង់មានគុណរកទីបំផុតគ្មានដូចជាអាកាស មានព្រះកាយរីកពេញដូចជាស្ដេចឈើ។*

*ពួកសត្វ គ្រាន់តែឃើញព្រះសម្ពុទ្ធអង្គនោះ ក៏មានសេចក្ដីត្រេកអរ សត្វទាំងនោះលុះបានស្ដាប់មធុរវាចា ដែលលាន់ឮក៏បានដល់អមតនិព្វាន។*

*កាលនោះ ការត្រាស់ដឹងធម៌របស់ព្រះអង្គ ក៏ធំទូលាយផ្សាយទៅ ចំនួនពួកសត្វ១រយកោដិបានត្រាស់ដឹង ក្នុងការសម្ដែងធម៌លើកទី១។*

*លំដាប់អំពីនោះមក កាលព្រះសម្ពុទ្ធបង្អុរចុះនូវភ្លៀងគឺធម៌ ក្នុងអភិសម័យ ពួកសត្វ៨០កោដិបានត្រាស់ដឹង ក្នុងការសម្ដែងធម៌លើកទី២។*

*តអំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់បង្អុរចុះគ្រាប់ភ្លៀង គឺធម៌ ទ្រង់ញ៉ាំងពួកសត្វឱ្យឆ្អែតស្កប់ស្កល់ដោយធម៌ ពួកសត្វ៧៨កោដិ បានសម្រេចមគ្គផលលើកទី៣។*

*ព្រះអនោមទស្សីអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត*

៣លើក ដែលសុទ្ធតែជាព្រះអរហន្ត បានសម្រេចអភិញ្ញាពលៈ រីកពេញដោយវិមុត្តិ គឺសន្និបាតលើកទី១ កាលនោះ មានព្រះអរហន្ត៨សែន ដែលមានសេចក្តីស្រវឹង និងសេចក្តីវង្វេងលះបង់ហើយ មានសន្តានស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង។

សន្និបាតលើកទី២ មានព្រះអរហន្ត៧សែន ដែលមិនមានទីទួលគឺកិលេស ប្រាសចាកធូលីគឺកិលេស ទាំងមានសន្តានស្ងប់រម្ងាប់ មានចិត្តនឹងធឹង។

សន្និបាតលើកទី៣ មានព្រះអរហន្ត៦សែន ដែលបានសម្រេចអភិញ្ញា-ពលៈ មានទុក្ខរំលត់ហើយ មានព្យាយាមដុតកម្តៅកិលេស។

សម័យនោះ តថាគត កើតជាយក្សមានឫទ្ធិច្រើន ជាធំជាងពួកយក្សច្រើនកោដិ ក្នុងវសវត្តិទេវលោក។

កាលនោះ តថាគត បានចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរអង្គនោះ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយអង្គាសព្រះលោកនាយក និងព្រះសង្ឃ ឱ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក។

ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធ ទ្រង់ព្យាករតថាគតថា

**ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ យក្សនេះ នឹងបានត្រាស់ជាព្រះពុទ្ធ។**

**សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា។**

**សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ រួចហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។**

**ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយក៏ចូលទៅឯជិតគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។**

តអំពីនោះមក ព្រះជិនស្រីមានយសច្រើន ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត នៃព្រះសម្ពុទ្ធនោះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ យក្សនេះ នឹងបានជាព្រះពុទ្ធព្រះនាមថាគោតម។

ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំនឹងបានជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទនឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងបានជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះអនោមទស្សីមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា **យក្សនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ។**

ពួកមនុស្ស និងងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា៖

"ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តានេះ ក្នុងកាលជាអនាគតមិនខាន។

**ពុទ្ធបណិធាន**

*ពួកមនុស្ស កាលឆ្ងងស្ទឹង បើឃ្វាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំយ៉ាងណាពួកយើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះពុទ្ធអង្គនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ៉ៗ*

*ចំណែកតថាគត លុះបានស្ដាប់ព្រះពុទ្ធដីកា របស់ព្រះអនោមទស្សីអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត បានអធិដ្ឋានទូវវត្តតទៅទៀត ដោយការបំពេញបារមីទាំង១០ៗ*

*ព្រះសាស្ដាព្រះនាម***អនោមទស្សី** *មាននគរឈ្មោះចន្ទវតី មហាក្សត្រព្រះនាមយសវាជាព្រះបិតា ព្រះមាតាព្រះនាមយសោធរាៗ*

*ព្រះអនោមទស្សីអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់១ម៉ឺនឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ គឺសិរីប្រាសាទ១ ឧបសិរីប្រាសាទ១ វឌ្ឍប្រាសាទ១ សម្រាប់ព្រះអង្គៗ*

*ពួកនារី២ម៉ឺន៣ពាន់នាក់ មានរូបប្រដាប់សមរម្យ នារីជាអគ្គមហេសីនោះព្រះនាមសិរិមា មានព្រះរាជបុត្រព្រះនាមឧបសាលៈៗ*

*ព្រះជិនស្រីទ្រង់បានឃើញនូវនិមិត្ត៤យ៉ាង ហើយស្ដេចចេញទៅដោយរ*[៤៩] *(គ្រែស្នែង) ទ្រង់តាំងសេចក្ដីព្យាយាមអស់១០ខែឥតខ្វះៗ*

---

[៤៩] **រ** ( ន. ) *( ស. )(វ្ហ អ. ថ. រ៉) យានមួយប្រភេទ មានគ្រែ, ដងស្នែង, ដំបូល សម្រាប់ឥស្សរជនថ្នាក់ខ្ពស់ជិះ មានមនុស្សសែង : គង់លើ-រ, ជិះរ*(មានប្រើច្រើនតែក្នុងសម័យពីដើម); *រ. ស. ព្រះ រ រ ធម្មតា; (ព្រះសិវិកា ឬ ព្រះទីន័ងសិវិកា រមានក្បាច់រចនាវិចិត្រ) ៗ*

ព្រះអនោមទស្សីមហាមុនី មានព្រះទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ដែលព្រហ្មអារាធនាហើយ ទ្រង់សំដែងធម្មចក្រក្នុងសុទស្សនឧទ្យានដ៏ឧត្តម។

ព្រះថេរៈឈ្មោះនិសភៈ១ អនោមៈ១ ជាអគ្គសាវ័ក ឯព្រះថេរៈឈ្មោះ វរុណៈ ជាឧបដ្ឋាក របស់ព្រះសាស្ដា ព្រះនាមអនោមទស្សីនោះ។

ព្រះថេរីឈ្មោះសុន្ទរា១ សុមនា១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអជ្ជុនព្រឹក្ស (ដើមអង្គ្រង)។

ឧបាសកឈ្មោះនន្ទិវឌ្ឍ១ សិរិវឌ្ឍ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ ឧបលា១ បទុមា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះមហាមុនី មានកម្ពស់៥៨ហត្ថ ពន្លឺនៃព្រះអង្គផ្សាយចេញទៅ ដូចជាព្រះអាទិត្យរះឡើង។

ព្រះអង្គ មានព្រះជន្មាយុ១សែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឱ្យឆ្លងវដ្តសង្សារ ហើយពាក្យជាប្រធាន គឺសាសនារីកល្អហើយ ដោយពួកព្រះអរហន្តជាតាទិបុគ្គល ប្រាសចាករាគៈ ប្រាសចាកមន្ទិល សាសនារបស់ព្រះជិនស្រីល្អរុងរឿង។

ឯព្រះសាស្ដាអង្គនោះ មានយសរាប់មិនបានក្តី គូនៃសាវ័កទាំងនោះ មានគុណថ្លឹងមិនបានក្តី របស់ទាំងនោះវិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត។

ព្រះជិនស្រី ជាសាស្ដាព្រះនាមអនោមទស្សី ទ្រង់បរិនិព្វានក្នុងធម្មារាម ឯព្រះស្តូបបញ្ចុះព្រះធាតុ របស់ព្រះជិនស្រីនោះ មានកម្ពស់២០ យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ។

**ចប់អនោមទស្សិពុទ្ធវង្ស ។**

## ១១. បទុមពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធបទុមៈ*

*ក្នុងកាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមអនោមទស្សីមក មានព្រះសម្ពុទ្ធព្រះនាម**បទុមៈ** ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម។*

*សីលនៃព្រះអង្គ ឥតមានសីលនៃបុគ្គលដទៃស្មើ ទាំងសមាធិក៏រកទីបំផុតគ្មាន ព្រះញាណដ៏ប្រសើរនឹងរាប់ពុំបាន ទាំងវិមុត្តក៏មិនមានឧបមា។*

*កាលដែលព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គនោះមានតេជះថ្មីងមិនបាន ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ មានការត្រាស់ដឹងនូវធម៌បីលើក ដែលជាគ្រឿងបន្សាត់បង់នូវងងឹតដ៏ធំ គឺព្រះពុទ្ធ ទ្រង់ញ៉ាំងសត្វ១០០កោដិឱ្យត្រាស់ដឹងក្នុងការត្រាស់ដឹងលើកទី១ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ញ៉ាំងសត្វ៩០កោដិឱ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងលើកទី២។*

*មួយទៀត ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ទូន្មានព្រះឱរសរបស់ព្រះអង្គក្នុងកាលណា កាលនោះពួកសត្វ៨០កោដិ បានត្រាស់ដឹងលើកទី៣។*

*ព្រះពុទ្ធព្រះនាមបទុមៈជាមហេសី មានសាវកសន្និបាត៣លើក គឺសន្និបាតលើកទី១ មានភិក្ខុ១សែនកោដិ។*

*កាលកឋិនចីវរកើតឡើងហើយ ក្នុងសម័យជាទីក្រាលនូវកឋិន ភិក្ខុទាំងឡាយបានដេរនូវចីវរ ដើម្បីប្រគេនព្រះធម្មសេនាបតី។ ក្នុងកាលនោះ ភិក្ខុទាំងបីសែនរូបនោះ សុទ្ធតែប្រាសចាកមន្ទិល មានអភិញ្ញា៦ មានឫទ្ធិច្រើន*

ជាអ្នកមិនចាលចាញ់បានមកប្រជុំគ្នា នេះជាសន្និបាតលើកទី២។

មួយវិញទៀត ព្រះពុទ្ធព្រះនាមបទុមៈអង្គនោះ ទ្រង់ប្រសើរជាងពួកនរៈ ស្ដេចចូលទៅកាន់លំនៅក្នុងព្រៃធំ ក្នុងកាលនោះមានភិក្ខុ២សែនរូបជួបជុំគ្នា នេះជាសន្និបាតលើកទី៣។

សម័យនោះ តថាគត កើតជា**សីហៈ** គ្របសង្កត់លើពួកម្រឹគ បានឃើញព្រះជិនស្រី ព្រះអង្គកំពុងចម្រើនទូវវិវេកក្នុងព្រៃធំ ហើយតថាគត បានថ្វាយបង្គំនូវព្រះបាទទាំងគូដោយសិរ្ស ហើយធ្វើប្រទក្សិណព្រះអង្គ រួចបន្លឺឡើងនូវសីហនាទអស់៣ដង បានបម្រើព្រះជិនស្រីអស់៧ថ្ងៃ។

ព្រះតថាគត ទ្រង់ចេញចាកសមាបត្តិដ៏ប្រសើរអស់៧ថ្ងៃ ហើយទ្រង់ព្រះចិន្តាដោយព្រះហឫទ័យ រួចទ្រង់ប្រមូលមកនូវភិក្ខុចំនួន១កោដិ ហើយកាលនោះ ព្រះមហាវីរៈនោះទ្រង់ព្យាករ ក្នុងកណ្ដាលភិក្ខុសង្ឃទាំង១កោដិនោះថា

**ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ សត្វសីហៈនេះ នឹងបានជាព្រះពុទ្ធ។**

**សត្វនេះ នឹងចេញអំពីក្រុងកបិលពស្ដុជាទីរីករាយ ហើយតាំងសេចក្ដីព្យាយាមធ្វើទុក្ករកិរិយា។**

**សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។**

**ព្រះជិនស្រីអង្គនោះ នឹងសោយនូវមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្ដេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេជម្រះហើយ។**

**លំដាប់អំពីនោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើនូវការប្រទក្សិណពោធិ-**

មណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត នៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមគោតម។

ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ នឹងបានជាអគ្គសាវ័ក សុទ្ធតែមិនមាន អាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ។

ព្រះនាងខេមា១ ព្រះនាងឧប្បលវណ្ណា១ មិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថ-ព្រឹក្ស។

ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា ១នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះជន្មាយុនៃព្រះគោតម មានយសអង្គនោះ កំណត់១០០ឆ្នាំ។

ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ របស់ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ រកបុគ្គលស្មើគ្មាន ក៏មានចិត្តត្រេកអរថា សត្វសីហៈនេះ ជាពូជពន្លកនៃព្រះពុទ្ធ។

សំឡេងហ៊ោឡើងក៏ប្រព្រឹត្តទៅ ឯមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនោះ ពុំខាន។

មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងនូវកំពង់ ក្នុងទីចំពោះមុខ

គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរយ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ"។

ឯតថាគត លុះបានស្តាប់ព្រះបន្ទូលរបស់ព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមៈនោះហើយ ក៏ញុំាំចិត្តឱ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង១០។

ព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរចម្បកៈ មានមហាក្សត្រព្រះនាមអសមៈជាបិតា មានព្រះមាតាព្រះនាមអសមា។

ព្រះសម្ពុទ្ធព្រះនាមបទុមៈនោះ នៅគ្រប់គ្រងផ្ទះអស់១ម៉ឺនឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ខ្នង គឺនន្ទប្រាសាទ១ វសុប្រាសាទ១ យសត្តរប្រាសាទ១។

មាននារី៣ម៉ឺន៣ពាន់រូប សឹងតាក់តែងល្អ ឯនារីជាអគ្គមហេសីនោះឈ្មោះនាងឧត្តរា មានព្រះរាជឱរសព្រះនាមរម្មៈ។

ព្រះជិនស្រីទ្រង់បានឃើញនូវនិមិត្ត៤យ៉ាង ហើយស្តេចចេញមហាភិនិស្ក្រមដោយយានគឺរថ ទ្រង់តម្កល់នូវព្យាយាមអស់៨ខែគត់។

ព្រះសម្ពុទ្ធព្រះនាមបទុមៈ ជាលោកនាយក ជាមហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរឈ្មោះធនញ្ជៈ។

ភិក្ខុឈ្មោះសាលៈ១ ឧបសាលៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះវរុណៈ ជាឧបដ្ឋាក របស់ព្រះពុទ្ធ ព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ។

ព្រះនាងរាធា១ ព្រះនាងសុរាធា១ ជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹង នៃព្រះដ៏មានព្រះភាគនោះ ហៅថាមហា-

**ពុទ្ធបណិធាន**

*សោណៈ ឬដើមម្រុំ។*

*ឧបាសកឈ្មោះសកិយៈ១ ឈ្មោះអសមៈ១ ជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះរុចិ១ ឈ្មោះនន្ទិមារា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះសម្ពុទ្ធព្រះនាមបទុមៈ ជាមហាមុនី ទ្រង់មានកម្ពស់៥៨ហត្ថ កម្រង់រស្មីនៃព្រះមហាមុនីអង្គនោះ តែងផ្សាយចេញសព្វទិស ទាំងឥតមានអ្វីស្មើ។*

*រស្មីព្រះចន្ទ្រ រស្មីព្រះអាទិត្យ រស្មីកែវមុនី រស្មីទាំងអស់នោះ ក៏សាបសូន្យទៅ ព្រោះប៉ះនឹងពន្លឺរបស់ព្រះជិនស្រីដ៏ឧត្តម ។*

*ព្រះជន្មាយុ របស់ព្រះមហាមុនីនោះ ១ សែនឆ្នាំ ជាកំណត់ ព្រះមហាមុនីអង្គនោះ កាលទ្រង់ព្រះជន្មនៅជរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ ។*

*ព្រះមហាមុនីអង្គនោះ ទ្រង់ញុំាងសត្វដែលមានឥន្ទ្រិយចាស់ក្លា ឲ្យត្រាស់ដឹង មិនមានសេសសល់ ទ្រង់ប្រៀនប្រដៅសត្វទាំងឡាយដែលសេសសល់ ទ្រង់បរិនិព្វានទៅជាមួយនឹងសាវ័ក ។*

*ព្រះមហាមុនីអង្គនោះ ទ្រង់លះបង់នូវសង្ខារទាំងពួង ដូចជាពស់ដែលលះបង់នូវសំណកចាស់ ឬដូចជាដើមឈើជម្រុះនូវស្លឹកចាស់ ហើយទ្រង់បរិនិព្វានទៅ ដូចជាអណ្តាតប្រទីបដូច្នោះ ។*

*ព្រះសាស្តា ព្រះនាមបទុមៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងធម្មារាម មានព្រះធាតុផ្សាយទៅ ក្នុងប្រទេសនោះ ៗ ។*

***ចប់បទុមពុទ្ធវង្ស។***

## ១២. នារទពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធនារទៈ*

*ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមៈមក មានព្រះសម្ពុទ្ធព្រះនាម**នារទៈ** ទ្រង់ឧត្តមជាងសត្វជើង២ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម។*

*ព្រះអង្គនោះជាព្រះរាជបុត្រច្បង ជាព្រះរាជឱរស ជាទីស្រឡាញ់របស់ស្តេចចក្រពត្តិ ទ្រង់បានពាក់នូវកែវមណី និងគ្រឿងអាភរណៈ ហើយស្តេចចូលទៅកាន់ឧទ្យាន។*

*ក្នុងឧទ្យាននោះ មានដើមឈើ១ដើមឈ្មោះមហាសោណព្រឹក្ស ជាឈើសមរម្យធំល្អស្អាត ព្រះសម្ពុទ្ធស្តេចទៅដល់នូវដើមឈើនោះហើយ ទ្រង់គង់ខាងក្រោមដើមឈើនោះ។*

*ព្រះញាណប្រសើររកទីបំផុតគ្មាន មានឧបមាដូចកែវវជីរ បានកើតឡើងដល់ព្រះអង្គក្នុងទីនោះ ព្រះអង្គពិចារណានូវសង្ខារទាំងឡាយ ដោយព្រះញាណនោះ ដូចជាបុគ្គលដែលផ្វារឡើងនូវភាជនៈ។*

*ក្នុងទីនោះ ព្រះអង្គទ្រង់បន្សាត់នូវកិលេសទាំងពួង មិនឱ្យសេសសល់ ហើយបានសម្រេចនូវពោធិញ្ញាណទាំងអស់ផង នូវ**ពុទ្ធញ្ញាណទាំង១៨**[៥០]ផង។*

---

[៥០] ***ពុទ្ធញ្ញាណ ១៨*** *គឺ មគ្គញាណ៤ ផលញាណ៤ អសាធារណញាណ៦ (អាសយានុសយញាណ, ឥន្ទ្រិយបរោបរិយញាណ, យមកបាដិហារិយញាណ, មហាករុណាសមាបត្តិញាណ, សព្វញ្ញុតញ្ញាណ, អនាវរណញាណ)។ (ពុទ្ធវំសអដ្ឋកថា, បាថិកវគ្គ-ដីកា)*

*ម្យ៉ាងទៀត **ពុទ្ធញ្ញាណ ១៨** គឺ ទុក្ខញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, ទុក្ខសមុទយញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, ទុក្ខនិរោធញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, ទុក្ខនិរោធគាមិនីបដិបទាញ្ញាណ ឈ្មោះថាពុទ្ធ-*

**ពុទ្ធបណិធាន**

*លុះព្រះអង្គសម្រេចនូវសម្ពោធិញាណហើយ ទើបទ្រង់សម្ដែងនូវធម្មចក្រ សត្វ១សែនកោដិបានត្រាស់ដឹងជាដំបូង។*

*ព្រះមហាមុនី ទូន្មានស្ដេចនាគឈ្មោះមហាទោណៈ ក្នុងកាលនោះទ្រង់ពន្យល់នូវពួកមនុស្ស និងទេវតា ហើយធ្វើនូវបាដិហារ្យ។*

*ក្នុងកាលនោះ ទេវតា និងមនុស្សទាំងឡាយ៩០ពាន់កោដិ បានផ្ចង់ផុតនូវសេចក្ដីសង្ស័យទាំងអស់ ក្នុងការប្រកាសនូវធម៌នោះ នេះជាការត្រាស់ដឹងលើកទី២។*

*ព្រះមហាវីរៈ ទ្រង់ទូន្មាននូវបុត្របង្កើតរបស់ព្រះអង្គ ក្នុងកាលណា កាលនោះពួកសត្វចំនួន៨០ពាន់កោដិ បានត្រាស់ដឹងក្នុងលើកទី៣។*

*ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣លើក គឺសន្និបាតលើកដំបូង មានពួកព្រះអរហន្តប្រមាណ១សែនកោដិ។*

*ព្រះសម្ពុទ្ធ ទ្រង់ប្រកាសពុទ្ធគុណ និងនិទាន ក្នុងកាលណា កាលនោះព្រះអរហន្តប្រមាណ៩០ពាន់កោដិ បានប្រាសចាកមន្ទិលមកប្រជុំគ្នា នេះជាសន្និបាតលើកទី២។*

---

*ញាណ ១, អត្ថប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, ធម្មប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, និរុត្តិប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, បដិភាណប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, ឥន្ទ្រិយបរោបរិយត្តញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, សត្តាសយានុសយញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, យមកប្បាដិហិរញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, មហាករុណាសមាបត្តិញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, សព្វញ្ញុតញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១, អនាវរណញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ទាំង ១៤ នេះ ឈ្មោះថាពុទ្ធញ្ញាណ ។ បណ្ដាពុទ្ធញ្ញាណទាំង ១៤ នេះ ញាណ ៨ ខាងដើម ទូទៅដល់ពួកសាវ័ក ឯញាណ ៦ (ខាងចុង) មិនទូទៅដល់ពួកសាវ័កឡើយ។ (បិដក ភាគ ៦៩ ទំព័រទី២៩៩-៣០០)*

នាគរាជឈ្មោះវេរោចនៈ បានថ្វាយទានដល់ព្រះសាស្តាក្នុងកាលណា ក្នុងកាលនោះពួកសាវ័កជាបុត្រ នៃព្រះជិនស្រីប្រមាណ៨០សែនបានមកប្រជុំគ្នា នេះជាសន្និបាតលើកទី៣។

សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមក្លៀវក្លា បានដល់ត្រើយនៃអភិញ្ញាទាំង៥ អាចត្រាច់ទៅតាមអាកាសបាន។

គ្រានោះ តថាគត បានញ៉ាំងព្រះសម្ពុទ្ធ ដែលស្មើដោយព្រះពុទ្ធមិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទ ឱ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ហើយបូជាដោយខ្លឹមចន្ទន៍។

ខណៈនោះ ព្រះនារទៈជាលោកនាយកអង្គនោះ ទ្រង់បានព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ តាបសនេះ នឹងបានជាព្រះពុទ្ធក្នុងលោក។

សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីរីករាយ តម្កល់នូវសេចក្តីព្យាយាម ហើយធ្វើទុក្ករកិរិយា។

សត្វនេះ នឹងគង់ទៀបគល់នៃអជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ រួចចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ នឹងសោយនូវមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលមកទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ។

លំដាប់នោះ ព្រះពុទ្ធទ្រង់មានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត របស់ព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះព្រះនាមគោតម។

ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទៈ នឹងបម្រើព្រះជិនស្រីនេះ។

នាងខេមា១ នាងឧប្បលវណ្ណា១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ ទាំងមានចិត្តតាំងមាំនឹងបានជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះជន្មាយុរបស់ព្រះគោតម មានយសអង្គនោះ កំណត់១០០ឆ្នាំ។

ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះរបស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ក៏ត្រេកអរថា ជដិលនេះ ជាពូជពន្ធកនៃព្រះពុទ្ធ។

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថាៈ

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ។

មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងនូវកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ បើយើងទាំងអស់គ្នា ឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក៏យ៉ាងនោះដែរ"។

តថាគត បានឮព្រះពុទ្ធដីកា នៃព្រះពុទ្ធអង្គនោះហើយ ក៏ញុំាងចិត្តឱ្យរីករាយដោយក្រៃលែង បានអធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង១០។

ព្រះពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះធញ្ញវតី មហាក្សត្រព្រះនាមសុទេវៈជាព្រះបិតា ព្រះមាតាព្រះនាមអនោមា។

ព្រះនារទៈនោះ នៅគ្រប់គ្រងផ្ទះអស់៩ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ខ្នងគឺជិតប្រាសាទ១ វិជិតប្រាសាទ១ អភិរាមប្រាសាទ១។

មាននារីបីបួនពាន់រូប សុទ្ធសឹងស្អិតស្អាងល្អ ព្រះនារីដែលជាអគ្គមហេសីព្រះនាមវិជិតសេនា ឯព្រះរាជបុត្រព្រះនាមនន្ទុត្តរៈ។

ព្រះពុទ្ធជាបុរសរត្នដ៏ប្រសើរ ទ្រង់ទតឃើញនូវនិមិត្តទាំង៤ ហើយ ស្តេចចេញមហាភិនិស្ក្រម ដោយការយាងទៅដោយព្រះបាទផ្ទាល់ ហើយទ្រង់ប្រព្រឹត្តព្យាយាម អស់៧ថ្ងៃ។

ព្រះនារទៈជាលោកនាយក ជាមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយទើបទ្រង់ញុំាងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរឈ្មោះធនញ្ជៈ។

**ពុទ្ធបណិធាន**

ភិក្ខុឈ្មោះភទ្ទសាលៈ១ ឈ្មោះជិតមិត្តៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះរោសេដ្ឋៈ ជាឧបដ្ឋាករបស់ព្រះសម្មុទ្ធនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ។

នាងឧត្តរា១ នាងផគ្គុនី១ ជាអគ្គសាវិកា។

ឧបាសក ឈ្មោះឧគ្គរិន្ទៈ១ ឈ្មោះវសភៈ១ ជាអគ្គឧបដ្ឋាក។

ឧបាសិកា ឈ្មោះឥន្ទវរី១ ឈ្មោះគណ្ឌី១ ជាអគ្គឧបដ្ឋាយិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាមហាសោណព្រឹក្ស។

ព្រះមហាមុនី ទ្រង់មានកម្ពស់៨៨ហត្ថក្រពុំ មានព្រះរូបស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស បានញុំាងលោកធាតុ ទាំងមួយម៉ឺនឱ្យភ្លឺរុងរឿង។

ព្រះកាយរបស់ព្រះអង្គ មានរស្មីប្រមាណ១ព្យាម តែងផ្សាយទៅកាន់ទិសតូចទិសធំ និងផ្សាយទៅកាន់ទីប្រមាណ១យោជន៍ ទាំងថ្ងៃទាំងយប់ ជានិរន្តរ៍សព្វៗកាល។

សម័យនោះ ជនទាំងឡាយពួកខ្លះ នៅក្នុងប្រមាណ១យោជន៍ដោយជុំវិញ ត្រូវរស្មីទាំងឡាយ នៃព្រះពុទ្ធគ្របសង្កត់ហើយ មិនបាច់អុជភ្លើងគប់ ឬអុជភ្លើងប្រទីបទាំងឡាយឡើយ។

ព្រះជន្មាយុកំណត់៩ម៉ឺនឆ្នាំគត់ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនដ៏ច្រើនឱ្យឆ្លងចាកសង្សារ ។

អាកាសដ៏វិចិត្រ រុងរឿងដោយផ្កាយទាំងឡាយយ៉ាងណា សាសនារបស់ព្រះនារទៈអង្គនោះ រុងរឿងដោយព្រះអរហន្តទាំងឡាយក៏យ៉ាងនោះដែរ។

ព្រះពុទ្ធព្រះនាមនារទៈ ប្រសើរជាងពួកនរៈអង្គនោះ ទ្រង់ធ្វើស្ពាន គឺព្រះធម៌ឱ្យមាំ ដើម្បីចម្លងនូវជនទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹក គឺសង្សារ ហើយបរិនិព្វាន។

ព្រះពុទ្ធ ស្មើដោយព្រះពុទ្ធ ដែលគ្មានបុគ្គលស្មើអង្គនោះក្តី ព្រះខីណាស្រពទាំងឡាយ មានតេជៈថ្វីងពុំបានទាំងអម្បាលនោះក្តី ក៏បរិនិព្វានបាត់បង់អស់ របស់ទាំងពួងក៏អន្តរធានអស់ ឱហ្ន៎! សង្ខារទាំងពួងជារបស់សោះសូន្យពិត។

ព្រះនារទៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងព្រះសុទស្សនបុរី ព្រះស្តូបដ៏ប្រសើរមានកម្ពស់ប្រមាណ៤យោជន៍។

ចប់នារទពុទ្ធវង្ស។

## ១៣. បទុមុត្តរពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធបទុមុត្តរៈ*

*ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាម**បទុមុត្តរៈ** ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើបឧបមាដូចសាគរ ទ្រង់កើតឡើងក្នុងកប្បណា កប្បនោះឈ្មោះមណ្ឌកប្ប ប្រជុំជនមានកុសលដុះឡើងហើយ តែងកើតក្នុងកប្បនោះ។*

*កាលព្រះដ៏មានព្រះភាគព្រះនាម**បទុមុត្តរៈ** ទ្រង់សំដែងនូវព្រះធម៌ជាដំបូង សត្វទាំងឡាយប្រមាណ១សែនកោដិ ក៏បានត្រាស់ដឹងនូវមគ្គផល។*

*លំដាប់តអំពីនោះមក កាលព្រះបរមសម្ពុទ្ធព្រះនាមបទុមុត្តរៈបង្អុរចុះនូវធម៌ ទ្រង់ញ៉ាំងពួកសត្វឱ្យឆ្អែតស្កប់ស្កល់ ពួកសត្វប្រមាណ៣ម៉ឺន៧ពាន់ បានត្រាស់ដឹងក្នុងលើកទី២។*

*ក្នុងកាលដែលព្រះមហាវីរបុរស ស្ដេចចូលទៅរកព្រះបាទអានន្ទជាបិតា លុះស្ដេចចូលទៅកាន់សម្នាក់ព្រះបិតាហើយ ទ្រង់ទូងស្គរ គឺអមតធម៌។ កាលស្គរ គឺអមតធម៌ ដែលព្រះអង្គទ្រង់ទូងហើយ ភ្លៀងគឺធម៌ក៏ធ្លាក់ចុះ ក្នុងកាលនោះ ពួកសត្វប្រមាណ៥លាន បានត្រាស់ដឹងក្នុងលើកទី៣។*

*ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ទូន្មានពន្យល់ ចម្លងនូវពួកសត្វទាំងពួង បានចម្លងហើយនូវប្រជុំជនជាច្រើន។*

*ព្រះសាស្ដាព្រះនាមបទុមុត្តរៈ មានសាវកសន្និបាត៣លើក គឺសន្និបាតលើកទី១ មានព្រះខីណាស្រពប្រមាណ១សែនកោដិ។*

*កាលព្រះសម្ពុទ្ធស្មើដោយអតីតព្រះពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់គង់លើភ្នំវេភារបព៌ត ក្នុងកាលនោះជាសន្និបាតលើកទី២ មានព្រះខីណាស្រពប្រមាណ៩០ពាន់កោដិ។*

*កាលព្រះសម្ពុទ្ធចៀសចេញចាកស្រុកចាកនិគម និងដែនទៅកាន់ទីចារិកម្តងទៀត នេះជាសន្និបាតលើកទី៣ មានព្រះខីណាស្រពប្រមាណ៨០ពាន់កោដិ។*

*សម័យនោះ តថាគត ជាជដិលអ្នកនៅក្នុងដែន តថាគតបានថ្វាយសំពត់និងភត្តដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន។*

*ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅកណ្តាលនៃភិក្ខុសង្ឃ ហើយទ្រង់ព្យាករតថាគតថា **ក្នុងកប្បទី១សែន អំពីកប្បនេះ ជដិលនេះនឹងបានជាព្រះពុទ្ធមួយអង្គ។***

*សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីត្រេកអរ តម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា។*

*សត្វនេះ នឹងអង្គុយទៀបនៃគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។*

*ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែង។*

*លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់មានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះមាតាបង្កើត នៃព្រះសម្ពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯព្រះសម្ពុទ្ធអង្គនេះព្រះនាមគោតម។*

*ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ ជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។*

**នាងខេមា១ នាងឧប្បលវណ្ណា១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈមានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ។**

**ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។**

**ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។**

**នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។**

**ព្រះជន្មាយុ របស់ព្រះគោតមដ៏មានយសអង្គនោះ កំណត់១០០ឆ្នាំ។**

ទេវតា និងមនុស្សទាំងឡាយ លុះបានស្ដាប់ព្រះបន្ទូលនេះ នៃព្រះសម្ពុទ្ធរកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ក៏ត្រេកអរថា **ជដិលនេះជាពូជពន្លកនៃព្រះពុទ្ធ។**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតាមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះគោតមនេះ។

មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរយ៉ាងណា យើងទាំងអស់គ្នាបើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ"។

តថាគត បានឮព្រះបន្ទូលនៃព្រះសម្ពុទ្ធអង្គនោះហើយ បានអធិដ្ឋានវត្តដ៏លើសលប់ឡើងទៅ បានធ្វើនូវព្យាយាមដ៏ខ្ពង់ខ្ពស់មាំមួន ដោយការបំពេញនូវបារមីទាំង១០។

ក្នុងកាលនោះ តិត្ថិយទាំងពួងអាក់អន់តូចចិត្ត វិនាសខ្ចាត់ខ្ចាយ បរិស័ទពួកខ្លះ នៃតិត្ថិយទាំងនោះ មិនបម្រើតិត្ថិយទាំងនោះ ក៏នាំគ្នាចៀសចេញចាកដែនទៅ។

តិត្ថិយទាំងពួង មកប្រជុំគ្នាក្នុងទីនោះ ហើយបានចូលទៅក្នុងសម្នាក់នៃព្រះពុទ្ធ (ហើយពោលថា) បពិត្រព្រះមហាវីរៈ សូមព្រះអង្គជាទីពឹងពំនាក់ (នៃយើងខ្ញុំទាំងឡាយ) បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គជាទីរឭក ។

ព្រះពុទ្ធទ្រង់អនុគ្រោះ ទ្រង់ប្រកបដោយករុណា ទ្រង់ស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងតិត្ថិយទាំងអស់ ដែលមកប្រជុំហើយ ឱ្យឋិតនៅក្នុងសីល៥។

សាសនារបស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈនោះ មិនរឹករវ៉ ជាសាសនាសូន្យចាកពួកតិត្ថិយយ៉ាងនេះ សាសនានោះវិចិត្រហើយដោយព្រះអរហន្តទាំងឡាយ ជាអ្នកស្ទាត់ជំនាញ ជាតាទិបុគ្គល។

ព្រះសាស្តាព្រះនាមបទុមុត្តរៈ មានព្រះនគរឈ្មោះហង្សវតី មានមហាក្សត្រព្រះនាមអានន្ទៈជាព្រះបិតា មានព្រះមាតាព្រះនាមសុជាតា។

ព្រះអង្គ ទ្រង់នៅគ្រប់គ្រងផ្ទះអស់៩ពាន់ឆ្នាំ ប្រាសាទទាំងឡាយដ៏ប្រសើរមាន៣ខ្នង គឺនារីប្រាសាទ១ ពាហនប្រាសាទ១ យសវតីប្រាសាទ១។

មាននារីបីបួនពាន់នាក់តែងល្អ ឯនារីដែលជាអគ្គមហេសីឈ្មោះវសុលទត្តា ព្រះរាជបុត្រព្រះនាមឧត្តរៈ។

ព្រះជិនស្រីប្រសើរជាងបុរស ទ្រង់ឃើញនូវនិមិត្តទាំង៤យ៉ាងហើយ ស្តេចចេញទៅដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាមអស់៧ថ្ងៃ។

ព្រះបទុមុត្តរសម្ពុទ្ធ ជានាយក ជាមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរឈ្មោះមិថិលា។

**ពុទ្ធបណិធាន**

*ភិក្ខុឈ្មោះទេវិលៈ១ ឈ្មោះសុជាតៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសុមនៈ ជាឧបដ្ឋាក របស់ព្រះសាស្តាព្រះនាមបទុមុត្តរៈ។*

*ភិក្ខុនីឈ្មោះអមិតា១ ឈ្មោះអសមា១ ជាអគ្គសាវិកា។*

*ឧបាសកឈ្មោះអមិតៈ១ ឈ្មោះតិស្សៈ១ ជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះហត្ថា១ សុចិត្តា១ ជាអគ្គឧបដ្ឋាយិកា។*

*ឈើ សម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថាសលឡ-ព្រឹក្ស (ដើមស្រល់)។*

*ព្រះសម្ពុទ្ធមហាមុនីទ្រង់មានកម្ពស់ ៥៨ ហត្ថក្រពុំ មានព្រះអង្គដ៏ល្អល្អះ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។*

*ទ្វារក្តី គន្ទឹះទ្វារក្តី ជញ្ជាំងក្តី ឈើក្តី ភ្នំធំក្តី ជាគ្រឿងរាំងរាំងនៃព្រះសម្ពុទ្ធនោះ ក្នុងទីប្រមាណ ១២ យោជន៍ ដោយជុំវិញ មិនមានឡើយ ។*

*ព្រះជន្មាយុ មានកំណត់ ១ សែនឆ្នាំ កាលព្រះសម្ពុទ្ធនោះ ទ្រង់ព្រះជន្មា-យុនៅដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ លុះទ្រង់ចម្លងជនជាច្រើនហើយ កាត់នូវសេចក្តីសង្ស័យទាំងពួង ហើយបរិនិព្វានជាមួយនឹងសាវ័ក ដូចជាគំនរភ្លើងដែលឆេះរុងរឿង ហើយរលត់ទៅដូច្នោះ ។*

*ព្រះពុទ្ធជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះអង្គ មានកម្ពស់ ១២ យោជន៍ (ដែលគេសាងហើយ) ក្នុងនន្ទារាមនោះ ។*

***ចប់បទុមុត្តរពុទ្ធវង្ស ។***

## ១៤. សុមេធពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធសុមេធៈ*

*ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈមក មានព្រះពុទ្ធព្រះនាម**សុមេធៈ** ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រីដ៏ប្រសើរឧត្តម ជាងលោកទាំងមូល។*

*ព្រះអង្គមានព្រះនេត្រថ្លាស្អាត មានព្រះភក្ត្រល្អល្អះ មានព្រះសរីរៈធំ មានព្រះសរីរៈត្រង់ល្អ មានព្រះតេជៈ ទ្រង់ស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងសត្វទាំងឡាយច្រើនឱ្យរួចចាកចំណង។*

*កាលណា ព្រះពុទ្ធទ្រង់បានដល់នូវពោធិញ្ញាណដ៏ឧត្តម សព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងនគរឈ្មោះសុទស្សនៈ ។*

*ក្នុងកាលសំដែងធម៌ទេសនា នៃព្រះពុទ្ធព្រះនាមសុមេធអង្គនោះ មានការត្រាស់ដឹង៣លើក គឺការត្រាស់ដឹងទី១ មានពួកសត្វប្រមាណ១សែនកោដិ។*

*តមកទៀត ការត្រាស់ដឹងទី២ មានពួកសត្វប្រមាណ៩០ពាន់កោដិ ក្នុងគ្រាដែលព្រះជិនស្រីទ្រង់ទូន្មានយក្ស ឈ្មោះកុម្ភកណ្ណៈ។*

*តមកទៀត ការត្រាស់ដឹងទី៣ មានពួកសត្វ៨០ពាន់កោដិ ក្នុងគ្រាដែលព្រះសម្ពុទ្ធ មានយសរាប់មិនបាន ទ្រង់ប្រកាសនូវសច្ចៈទាំង៤ប្រការ។*

*ព្រះសុមេធមហេសី មានសាវកសន្និបាត៣លើក ដែលសុទ្ធតែជាព្រះខីណាស្រពប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺក្នុងកាលដែលព្រះជិនស្រី ស្តេចចូលទៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណាស្រព ១០០កោដិ បានមកប្រជុំ នេះជាសន្និបាតលើកទី១។*

**ពុទ្ធបណិធាន**

*តមកទៀត សន្និបាតលើកទី២ មានភិក្ខុប្រមាណ៩០កោដិ មកប្រជុំក្នុងកាលក្រាលកឋិនលើភ្នំទេវកូដ។*

*តមកទៀត សន្និបាតលើកទី៣ មានភិក្ខុប្រមាណ៨០កោដិមកប្រជុំក្នុងកាលព្រះទសពល ស្ដេចទៅកាន់ចារិក។*

*សម័យនោះ តថាគតកើតជាមាណពឈ្មោះ**ឧត្តរៈ** តថាគតបានសន្សំទ្រព្យទុកក្នុងផ្ទះ ប្រមាណ ៨០ កោដិ ។*

*តថាគតថ្វាយទ្រព្យទាំងអស់ ឥតមានសេសសល់ដល់ព្រះលោកនាយកព្រមទាំងព្រះសង្ឃ ហើយបានយកព្រះលោកនាយកនោះ ជាទីពឹង បានពេញចិត្តចំពោះបព្វជ្ជា ។*

*គ្រានោះ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ហើយព្យាករតថាគតថា ក្នុងកប្បទី ៣០ ពាន់ មាណពនេះ នឹងបានជាព្រះពុទ្ធ (មួយអង្គ) ។*

*សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីរីករាយ ហើយតម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា។*

*សត្វនេះ នឹងអង្គុយនូវទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។*

*ព្រះជិនស្រីអង្គនោះ នឹងសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្ដេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ។*

*លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស។*

ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះព្រះនាមគោតម។

ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនោះ។

នាងខេមា១ នាងឧប្បលវណ្ណា១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះជន្មាយុ ព្រះគោតមមានយសនោះ មានកំណត់១០០ឆ្នាំ។

ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ នៃព្រះមហេសី មិនមានបុគ្គលស្មើ ក៏មានចិត្តត្រេកអរថា មាណពនេះជាពូជពន្ធកនៃព្រះពុទ្ធ។

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ។

មនុស្សទាំងឡាយ កាលធ្វងស្ទឹង បើឃ្វាងកំពង់នៅទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរយ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ៕

តថាគត បានស្តាប់ព្រះបន្ទូលនៃព្រះសម្ពុទ្ធអង្គនេះរួច បានញ៉ាំងចិត្តឱ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តដ៏លើសលប់ ដោយការបំពេញនូវបារមី១០។

តថាគត បានរៀននូវព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនៈដែលមានអង្គ៩ទាំងអស់ ហើយញ៉ាំងសាសនា នៃព្រះជិនស្រីឱ្យល្អរុងរឿង។

តថាគត ជាអ្នកមិនប្រមាទក្នុងសាសនានោះ កាលតថាគតនៅក្នុងទីអង្គុយ ទីឈរ និងទីដើរ ក៏បានដល់អភិញ្ញាបារមី ហើយទៅកើតក្នុងព្រហ្មលោក។

ព្រះសម្ពុទ្ធព្រះនាមសុមេធៈជាមហេសី មានព្រះនគរឈ្មោះសុទស្សនៈ ព្រះមហាក្សត្រព្រះនាមសុទត្តៈជាព្រះបិតា ព្រះមាតាបង្កើតព្រះនាមសុទត្តា។

ព្រះសុមេធសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់៩ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ខ្នង គឺសុចន្ទប្រាសាទ១ កញ្ចនប្រាសាទ១ សិរិវឌ្ឍប្រាសាទ១។

មាននារីប្រមាណ១៦ពាន់រូប សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារីដែលជាអគ្គមហេសីនោះព្រះនាមសុមនា ព្រះរាជបុត្រព្រះនាមបុនព្វៈ។

ព្រះជិនស្រី ទ្រង់ឃើញនូវនិមិត្ត៤យ៉ាងហើយ ស្តេចចេញទៅដោយហត្ថិយាន ទ្រង់តម្កល់ព្យាយាមអស់៨ខែគត់។

ព្រះលោកនាយក ព្រះនាមសុមេធៈ ជាមហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុទស្សនៈ។

ភិក្ខុ ឈ្មោះសរណៈ១ ឈ្មោះសព្វកាមៈ១ ជាអគ្គសាវ័ករបស់ព្រះសុមេធៈដែលទ្រង់ស្វែងរកនូវគុណដ៏ធំអង្គនោះ ភិក្ខុជាឧបដ្ឋាកឈ្មោះសាគរៈ។

*ភិក្ខុនីឈ្មោះរាមា១ ឈ្មោះសុរាមា១ ជាអគ្គសាវិកា។*

*ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគនោះ ហៅថានិម្ពព្រឹក្ស (ដើមស្ដៅ)។*

*ឧបាសកឈ្មោះឧរុវេលៈ១ ឈ្មោះយសវៈ១ ជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះយសា១ ឈ្មោះសិរិវា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថក្រពុំ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចព្រះចន្ទរុងរឿងកន្ទង់ពួកផ្កាយ។*

*កែវមណីរបស់ស្ដេចចក្រពត្តិ ភ្លឺរុងរឿងអស់ទីប្រមាណ ១ យោជន៍ យ៉ាងណា រតនៈគឺពន្លឺនៃព្រះមានព្រះភាគនោះ តែងផ្សាយទៅកាន់ទីប្រមាណ ១ យោជន៍ ដោយជុំវិញ ក៏យ៉ាងនោះដែរ។*

*ព្រះជន្មាយុមានកំណត់ ៩ ម៉ឺនឆ្នាំគត់ ព្រះសុមេធៈអង្គនោះ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ។*

*ព្រះពុទ្ធសាសនានេះ កុះករដោយពួកព្រះអរហន្ត ដែលមានវិជ្ជា៣ និង អភិញ្ញា៦ ដល់នូវកម្លាំង ជាតាទិបុគ្គល។*

*ព្រះអរហន្តទាំងពួងនោះ សឹងតែមានយសរាប់មិនបាន សុទ្ធតែរួចផុតហើយ មិនមានឧបធិទាំងអស់ ព្រះអរហន្តទាំងនោះ មានយសធំ បានសំដែងនូវពន្លឺគឺព្រះញាណ ហើយបរិនិព្វានទៅ។*

*ព្រះពុទ្ធព្រះនាមសុមេធៈ ជាព្រះជិនស្រីប្រសើរ ទ្រង់បរិនិព្វាន ក្នុងមេធារាម ព្រះធាតុផ្សាយទៅ ក្នុងប្រទេសទាំងឡាយនោះៗ។*

**ចប់សុមេធពុទ្ធវង្ស ។**

## ១៥. សុជាតពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធសុជាតៈ*

*ក្នុងមណ្ឌកប្បនោះឯង ព្រះសម្មាសម្ពុទ្ធជានាយក ព្រះនាម**សុជាតៈ** ទ្រង់មានព្រះហនុកាដូចជាចង្កានៃរាជសី ទ្រង់មានព្រះសុរង់ដូចជាកគោឧសភៈ ទ្រង់មានព្រះគុណាប្រមាណមិនបាន គេគ្របសង្កត់មិនបាន។*

*ព្រះសម្ពុទ្ធដ៏បរិសុទ្ធ ប្រាសចាកមន្ទិលដូចជាព្រះចន្ទ មានតេជះដូចជាព្រះអាទិត្យ ភ្លឺរុងរឿងដោយព្រះសិរីសព្វៗកាល យ៉ាងនេះ។*

*ព្រះសម្ពុទ្ធទ្រង់ដល់នូវពោធិញ្ញាណដ៏ប្រសើរសព្វគ្រប់ហើយ ទ្រង់ញ៉ាំងព្រះធម្មចក្រ ឱ្យប្រព្រឹត្តទៅក្នុងព្រះនគរឈ្មោះសុមង្គលៈ។*

*កាលព្រះលោកនាយកព្រះនាមសុជាតៈ ទ្រង់សំដែងនូវធម៌ដ៏ប្រសើរ សត្វទាំងឡាយចំនួនប្រមាណ៨០កោដិ បានសម្រេចមគ្គផល ក្នុងធម៌ទេសនាជាដំបូង។*

*កាលណា ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់មានយសរាប់មិនបាន ស្ដេចចូលទៅកាន់ព្រះវស្សា ក្នុងទេវលោក កាលនោះ ការត្រាស់ដឹងនូវធម៌ លើកទី ២ មានពួកសត្វ ៣៧ សែន។*

*កាលណា ព្រះពុទ្ធព្រះនាមសុជាតៈ រកបុគ្គលស្មើគ្មាន ស្ដេចចូលទៅកាន់សម្នាក់ព្រះរាជបិតា កាលនោះ ការត្រាស់ដឹងនូវធម៌ លើកទី ៣ មានពួកសត្វ ៦០ សែន។*

*ព្រះសុជាតមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ជាតាទិបុគ្គល ជាអ្នកដល់នូវអភិញ្ញា និងពលៈ ជាអ្នកមិនដល់ (នូវការកើត) ក្នុងភពតូច និងភពធំ គឺព្រះអរហន្តទាំងនោះ មានប្រមាណ៦០សែន បានមកប្រជុំ ជាសន្និបាតលើកដំបូង។*

*តមកទៀត ការប្រជុំក្នុងកាលដែលព្រះជិនស្រីទ្រង់ចុះចាកឋានទេវលោកនេះ ជាសន្និបាតលើកទី២ មានព្រះខីណាស្រពចំនួន៥០ សែន។*

*អគ្គសាវកណារបស់ព្រះពុទ្ធ ព្រះនាមសុជាតៈនោះបានចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរៈ អគ្គសាវកនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធមួយអន្លើដោយភិក្ខុប្រមាណ៤ សែនរូប (នេះជាសន្និបាតលើកទី៣) ។*

*សម័យនោះ តថាគត ជា***ស្តេចចក្រពត្តិ***មានកម្លាំងច្រើន ជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅក្នុងអាកាសបាន*(៥១)*។*

---

(៥១) *ស្តេចចក្រពត្តិមានឫទ្ធិ ៤ យ៉ាងគឺៈ*

១-អភិរូបោ *រូបស្អាត*

២-ទីឃាយុកោ *អាយុវែង*

៣-អប្បាពាធោ *មិនមានរោគ*

៤-បិយោ អហោសិ មនាបោ *ជាទីស្រឡាញ់ជាទីពេញចិត្តនៃជនច្រើន។*

*(ទី.២/១៤៥។ កំ.ទី.១៧/១៥-១៦។ ទី.ដី.១/២៩២។ សី.អភិនវ.២/២២៩-២៣០។ ម.ដី.៣/១៦៨។)*

*ឫទ្ធិ ៤ យ៉ាងរបស់ស្តេចចក្រពត្តិ (មួយបែបទៀត)*

១-ឧបរិចរោ អាកាសគាមី *ត្រាច់ទៅខាងលើ ដើរលើអាកាសបាន*

២-ចត្តារោ នំ ទេវបុត្តា ចតូសុ ទិសាសុ ខគ្គហត្ថា រក្ខន្តិ *មានទេវបុត្រ៤អង្គកាន់ព្រះខ័ននៅចាំរក្សាក្នុងទិសទាំង៤*

៣-កាយតោ ចន្ទនគន្ធោ វាយតិ *មានក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយ*

៤-មុខតោ ឧប្បលគន្ធោ *មានក្លិនឧប្បលផ្សាយចេញអំពីមាត់។*

*(ជា.ដ្ឋ.៣/៤៣១។ សី.អភិនវ.២/២៣០។)*

*ឫទ្ធិ ៤ យ៉ាង របស់ស្តេចចក្រពត្តិ (មួយបែបទៀត)*

១-អភិរូបភាវោ *ភាពជាអ្នកមានរូបស្អាត*

**ពុទ្ធបណិធាន**

តថាគត បានថ្វាយនូវរាជសម្បត្តិជាច្រើន ក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្តម ទាំង ៧ ប្រការ ចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់នៃព្រះសម្ពុទ្ធអង្គនោះ ។

អារាមិកជនទាំងឡាយ ក្នុងជនបទ បានប្រមូលមកនូវស្លួយសាអាករ ជាបច្ច័យ ទីដេក ទីអង្គុយ ហើយនាំចូលទៅថ្វាយដល់ព្រះភិក្ខុសង្ឃ ។

កាលនោះ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់ព្យាករតថាគតថា ក្នុងទីបំផុតនៃកប្ប៣០ពាន់ ស្តេចចក្រពត្តិអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ជាធំក្នុងមួយម៉ឺនលោកធាតុ។

សត្វនេះ នឹងស្តេចចេញចាកក្រុងកបិលពស្តុជាទីរីករាយ ហើយតម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលនូវមធុបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ នឹងសោយនូវមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែង។

លំដាប់នោះ ព្រះមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

---

២-សមវេចាតិនិយា គហាណិយា សមណ្ណាគតភាវោ *ភាពជាអ្នកបរិបូរណ៍ដោយភ្លើងក្រពះដែលអាចធ្វើឲ្យអាហាររលាយស្មើល្អ*

៣-យាវតាយុកម្បិ សកលលោកស្ស ឧស្សជាតិត្តិកភាវោ *ភាពជាអ្នកដែលត្រូវគេគយគន់មើលទៅមិនគួរឲ្យធុញ សម្រាប់មនុស្សមួយពិភពលោក*

៤-អាកាសចារិកាវោ *ភាពជាអ្នកអាចត្រាច់ទៅមកតាមអាកាស។*

*(សី.អភិនវ.២/២៣០)*

*ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះព្រះនាមគោតម។*

*ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ។*

*នាងខេមា១ នាងឧប្បលវណ្ណា១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា។*

*ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស។*

*ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ ជាអគ្គឧបដ្ឋាក។*

*នាងនន្ទមាតា១ នាងឧត្តរា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះជន្មាយុ នៃព្រះគោតមដ៏ទ្រង់យសអង្គនោះ មានកំណត់១០០ឆ្នាំ។*

មនុស្ស និងទេវតាទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ នៃព្រះពុទ្ធរកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ត្រេកអរថា ស្តេចចក្រពត្តិអង្គនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ។

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគតពួកយើងទាំងអស់គ្នា គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះពុំខាន។

ពួកមនុស្ស កាលឆ្លងស្ទឹងបើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យក កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ពួកយើងទាំងអស់គ្នាបើឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគតគង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ"។

តថាគត បានស្ដាប់នូវព្រះបន្ទូល នៃព្រះពុទ្ធនោះហើយ បានញុំាងសេចក្ដីរីករាយឱ្យកើតដោយក្រៃលែង ហើយបានអធិដ្ឋាននូវវត្តដ៏លើសលប់ដោយការបំពេញនូវបារមីទាំង១០។

តថាគត បានរៀននូវព្រះសូត្រផង ព្រះវិន័យផង សត្ថុសាសនា ដែលមានអង្គ៩ទាំងអស់ផង ហើយបានញុំាងសាសនានៃព្រះជិនស្រី ឱ្យល្អរុងរឿង។

កាលតថាគត នៅក្នុងសាសនានោះជាអ្នកមិនប្រមាទ បានចម្រើននូវភាវនាដ៏ប្រសើរ ហើយបានដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក។

ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះសុមង្គលៈ ព្រះមហាក្សត្រព្រះនាមឧគ្គតៈជាព្រះបិតា ព្រះមាតាព្រះនាមបភាវតី។

ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់៩ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើររបស់ព្រះពុទ្ធនោះ មាន៣ខ្នង គឺសិរិប្រាសាទ១ ឧបសិរិប្រាសាទ១ ចន្ទ-ប្រាសាទ១។

មាននារី ប្រមាណ២ម៉ឺន៣ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារីដែលជាអគ្គមហេសីព្រះនាមសិរិនន្ទា ព្រះរាជបុត្រព្រះនាមឧបសេនៈ។

ព្រះជិនស្រី ទ្រង់ឃើញនូវនិមិត្ត៤យ៉ាង ហើយស្ដេចចេញទៅ ដោយយានសេះ តម្កល់នូវព្យាយាមអស់៩ខែគត់។

*ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាលោកនាយក ជាមហាវីរៈ ត្រូវព្រហ្ម អារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុមង្គលៈ។*

*ភិក្ខុឈ្មោះសុទស្សនៈ១ ឈ្មោះសុទេវៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះនារទៈ ជាឧបដ្ឋាកនៃព្រះពុទ្ធព្រះនាមសុជាតៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ។*

*ភិក្ខុនីឈ្មោះនាគា១ ឈ្មោះនាគសមានា ១ ជាអគ្គសាវិកា។*

*ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគនោះ ហៅថាមហាវេឡុ-ព្រឹក្ស (ដើមឫស្សីធំ)។*

*ឫស្សីនោះមានដើមតាន់ មិនមានប្រហោង មានស្លឹកច្រើន ជាឫស្សីមានដើមត្រង់ មានដើមធំ គួររមិលមើល ជាទីរីករាយនៃចិត្ត។*

*ជាឫស្សីតែមួយដើម លូតលាស់ឡើងហើយ ឯមែកក៏បែកចេញអំពីដើម នោះជា៥មែក ឫស្សីនោះជាឈើល្អដូចជាបាច់ នៃកន្ទុយក្ងោក ដែលគេចងល្អ ហើយដូច្នោះ។*

*ឫស្សីនោះជាឫស្សីឥតបន្លា ឥតប្រហោង មានមែកត្រសុំត្រសាយ ដេរ ដាសដោយមែក មានម្លប់ត្រឈៃជាទីរីករាយនៃចិត្ត។*

*ឧបាសកឈ្មោះសុទត្តៈ១ ឈ្មោះចិត្តៈ១ ជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះនាងសុភទ្រា១ នាងបទុមា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះជិនស្រីអង្គនោះ ទ្រង់មានកម្ពស់៥០ហត្ថក្រពុំ ទ្រង់ប្រកបដោយ អាការៈប្រសើរគ្រប់យ៉ាង ទ្រង់ប្រកបដោយគុណទាំងពួង។*

*រស្មីនៃព្រះសម្ពុទ្ធអង្គនោះ ស្មើដោយរស្មីនៃព្រះពុទ្ធ ដែលមិនមានបុគ្គល ស្មើ តែងផ្សាយចេញទៅក្នុងទីជុំវិញ ព្រះសម្ពុទ្ធនោះមានព្រះគុណប្រមាណមិន*

**ពុទ្ធបណិធាន**

បាន មានព្រះគុណថ្លឹងមិនបាន មិនមានឧបមា ដោយសេចក្តីឧបមាទាំងឡាយឡើយ ។

ព្រះជន្មាយុមានកំណត់៩០ពាន់ឆ្នាំគត់ ព្រះពុទ្ធអង្គនោះ កាលទ្រង់គង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនជាច្រើនឱ្យឆ្លងចាកសង្សារ។

ក្នុងកាលនោះ សាសនារបស់ព្រះពុទ្ធនោះ ដ៏វិចិត្រដោយព្រះអរហន្តទាំងឡាយ ដូចជារលកក្នុងសាគរ ឬដូចជាផ្កាយក្នុងអាកាស។

សាសនានេះ កុះករដោយព្រះអរហន្តទាំងឡាយ ដែលមានវិជ្ជា៣ និងអភិញ្ញា៦ លោកដល់នូវកម្លាំងជាតាទិបុគ្គល។

ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធរកបុគ្គលស្មើគ្មាន គុណទាំងឡាយនោះជាគុណថ្លឹងពុំបាន ធម្មជាតិទាំងពួង ក៏អន្តរធានអស់ ឱហ្ន៎ !សង្ខារទាំងពួងជារបស់សោះសូន្យទទេ។

ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងសេលារាម ព្រះចេតិយរបស់ព្រះសាស្តា មានកម្ពស់៣គាវុត ដែលគេសាងក្នុងសេលារាមនោះ ។

ចប់សុជាតពុទ្ធវង្ស ។

## ១៦. បិយទស្សិពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធបិយទស្សី*

*ក្នុងកាលជាខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសុជាតៈមក មានព្រះពុទ្ធទ្រង់ព្រះនាម**បិយទស្សី** ជាសយម្ភូ ជាលោកនាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ។*

*ព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានយសប្រមាណមិនបាន ទ្រង់រុងរឿងដូចជាព្រះអាទិត្យ ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់ញ៉ាំងធម្មចក្រទាំងពួងឱ្យប្រព្រឹត្តទៅ។*

*ព្រះពុទ្ធនោះ មានតេជៈថ្លឹងមិនបាន មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វប្រមាណ ១ សែនកោដិ ។*

*ទេវរាជព្រះនាមសុទស្សនៈ គាប់ព្រះហឫទ័យនឹងមិច្ឆាទិដ្ឋិ ព្រះសាស្តាកាលទ្រង់បន្ទោបង់នូវទិដ្ឋិ នៃសុទស្សនទេវរាជនោះ ទ្រង់បានសំដែងធម៌ ។*

*ក្នុងកាលនោះ ការប្រជុំជនច្រើនថ្លឹងមិនបាន ជាការប្រជុំធំ ឈ្មោះថាត្រាស់ដឹង ទី ២ មានពួកសត្វ ៩ ពាន់កោដិ ។*

*ក្នុងកាលណា ព្រះពុទ្ធ ព្រះអង្គជាសារថី ទូន្មាននូវនរៈ ទ្រង់ទូន្មាននូវដំរីឈ្មោះពោណមុខៈ ក្នុងកាលនោះ ឈ្មោះថាត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ កោដិ ។*

*ព្រះបិយទស្សីអង្គនោះ មានសាវកសន្និបាត ៣ លើក គឺសន្និបាត លើកទី ១ មានពួកព្រះអរហន្តមួយសែនកោដិ ។*

**ពុទ្ធបណិធាន**

*តពីនោះមក ព្រះខីណាស្រពទាំងឡាយ ជាអ្នកប្រាជ្ញ ចំនួន ៩០ ពាន់កោដិ បានមកប្រជុំព្រមក្នុងទីជាមួយគ្នា នេះជាសន្និបាតលើកទី ២ ក្នុងសន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ កោដិ ។*

*សម័យនោះ តថាគត កើតជាមាណពឈ្មោះកស្សបៈ ជាអ្នកស្វាធ្យាយមន្ត្ត ចង់ចាំមន្ត្ត ដល់នូវត្រើយនៃត្រ័យវេទ។*

*តថាគត បានស្តាប់ធម៌របស់ព្រះពុទ្ធ ព្រះនាមបិយទស្សីនោះហើយ បានញ៉ាំងសេចក្តីជ្រះថ្លាឱ្យកើតឡើង តថាគតបានសាងនូវសង្ឃារាម ដោយទ្រព្យប្រមាណ១សែនកោដិ។*

*តថាគត បានថ្វាយអារាមដល់ព្រះពុទ្ធអង្គនោះហើយ មានចិត្តរីករាយ មានចិត្តសង្វេគ បានសមាទានព្រះត្រ័យសរណគមន៍ និងសីល៥ ធ្វើឱ្យមាំមួន។*

*ព្រះពុទ្ធអង្គនោះ ទ្រង់គង់ក្នុងកណ្តាលសង្ឃហើយ ទ្រង់បានព្យាករតថាគតថា* ***មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី១,៨០០។***

***សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីរីករាយ ទៅតម្កល់ការព្យាយាម ហើយធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយទ្រង់ចូលទៅកាន់ស្ទឹងនេរញ្ជរា។***

***ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយនូវមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ។***

លំដាប់នោះព្រះមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើត នៃព្រះពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះព្រះនាមគោតម។

ព្រះភិក្ខុឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ។

នាងខេមា១ នាងឧប្បលវណ្ណា១ ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគនោះ គេហៅថាអស្សត្ថ-ព្រឹក្ស។

ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា ១ជាអគ្គឧបដ្ឋាយិកា។

ព្រះជន្មាយុនៃព្រះគោតមអង្គនោះ មានកំណត់១០០ឆ្នាំ។

ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះនៃព្រះមហេសីរកបុគ្គលស្មើគ្មាន ក៏ត្រេកអរថា មាណពនេះ ជាពូជពន្ធកនៃព្រះពុទ្ធ។

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុក៏ទះដៃ សើចក្អាកក្អាយ ធ្វើអញ្ជលី នមស្ការផងថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់បានសម្រេចមគ្គផលចំពោះព្រះភក្ត្រនៃព្រះគោតមនេះមិនខាន។

មនុស្សទាំងឡាយ កាលបើនឹងឆ្លងស្ទឹង បើឃ្លាងនូវកំពង់ក្នុងទីចំពោះមុខហើយ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរយ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ"។

លុះតថាគត បានស្ដាប់ព្រះបន្ទូល នៃព្រះពុទ្ធអង្គនេះហើយ បានញុំាងចិត្តឱ្យជ្រះថ្លាដោយក្រៃលែង ហើយអធិដ្ឋាននូវវត្តដ៏លើសលប់ ដោយការបំពេញនូវបារមីទាំង១០។

ព្រះសាស្ដាព្រះនាមបិយទស្សី មានព្រះនគរឈ្មោះសុធញ្ញៈ មានព្រះមហាក្សត្រព្រះនាមសុទត្តៈជាព្រះបិតា មានព្រះមាតាព្រះនាមសុចន្ទា។

ព្រះពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់៩ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ខ្នង គឺសុនិម្មលប្រាសាទ១ វិមលប្រាសាទ១ គិរិគូហាប្រាសាទ១។

មាននារីប្រមាណ៣៣ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អ ឯនារីជាអគ្គមហេសីនោះ ព្រះនាមនាងវិមលា ព្រះរាជបុត្របង្កើតព្រះនាមកញ្ចនាវេឡៈ។

ព្រះជិនស្រីជាបុរសដ៏ប្រសើរ ទ្រង់ឃើញនូវនិមិត្ត៤យ៉ាងហើយ ស្ដេចចេញទៅដោយយាន គឺរថ ហើយទ្រង់ប្រព្រឹត្តនូវសេចក្ដីព្យាយាមអស់៦ខែគត់។

ព្រះមហាមុនីព្រះនាមបិយទស្សី ជាព្រះមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧសកឧទ្យាន ជាទីរីករាយនៃចិត្ត។

ភិក្ខុឈ្មោះបាលិតៈ១ ឈ្មោះសព្វទស្សី១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសោភិតៈ ជាឧបដ្ឋាកនៃព្រះសាស្តាព្រះនាមបិយទស្សី។

ភិក្ខុនីឈ្មោះសុជាតា១ ឈ្មោះធម្មទិន្នា១ ជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ គេហៅថាកកុធព្រឹក្ស (ដើមថ្ងាន់)។

ឧបាសកឈ្មោះសន្ទកៈ១ ឈ្មោះធម្មិកៈ១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនាងវិសាខា១ ឈ្មោះធម្មទិន្នា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះពុទ្ធអង្គនោះ ទ្រង់មានយសរាប់មិនបាន មានលក្ខណៈដ៏ប្រសើរ៣២ប្រការ មានកម្ពស់៨០ហត្ថ ទ្រង់ប្រាកដដូចជាស្តេចនៃឈើឈ្មោះសាលព្រឹក្ស។

រស្មីនៃភ្លើង រស្មីនៃព្រះចន្ទ និងរស្មីនៃព្រះអាទិត្យ ប្រាកដដូចជារស្មី នៃព្រះពុទ្ធមហេសី ដែលរកបុគ្គលស្មើគ្មាននោះ មិនមានឡើយ ។

ព្រះសម្ពុទ្ធ ជាទេវតាដ៏ប្រសើរអង្គនោះ មានព្រះជន្មាយុនៅជរាបនោះគឺព្រះចក្ខុសម្ពុទ្ធ ទ្រង់ឋិតនៅក្នុងលោក អស់ ៩០ ពាន់ឆ្នាំ ។

ព្រះពុទ្ធដែលមិនមានបុគ្គលស្មើអង្គនោះក្តី គូនៃសាវ័កទាំងអម្បាលនោះក្តី មានគុណថ្លឹងពុំបាន របស់ទាំងអស់នោះ អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួងជារបស់សោះសូន្យទទេ ។

**ពុទ្ធបណិធាន**

*ព្រះពុទ្ធព្រះនាមបិយទស្សី ជាព្រះមុនីដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអស្សត្ថារាម ព្រះស្តូបនៃព្រះជិនស្រីអង្គនោះ មានកម្ពស់ ៣ យោជន៍ (គេបានសាងហើយ) ក្នុងអស្សត្ថារាមនោះ ។*

*ចប់បិយទស្សិពុទ្ធវង្ស។*

# ១៧. អត្ថទស្សិពុទ្ធប្បវត្តិ

## *ការឧប្បត្តិឡើងនៃព្រះពុទ្ធអត្ថទស្សី*

*ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធ ព្រះនាម**អត្ថទស្សី** មានយសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។*

*ព្រះសម្ពុទ្ធត្រូវព្រហ្មអារាធនាហើយទើបទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ហើយញ៉ាំងមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ ឲ្យឆ្អែតដោយទឹកអម្រឹត។*

*ព្រះលោកនាថអង្គនោះ មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹង លើកទី ១ មានពួកសត្វចំនួន ១ សែនកោដិ ។*

*ការត្រាស់ដឹង លើកទី ២មានពួកសត្វចំនួន ១ សែនកោដិ ក្នុងកាលដែលព្រះពុទ្ធ ព្រះនាមអត្ថទស្សី ទ្រង់ត្រាច់ទៅកាន់ទេវចារិក ។*

*តមក ការត្រាស់ដឹង លើកទី ៣ មានពួកសត្វចំនួន ១ សែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សំដែងព្រះធម៌ ក្នុងសម្នាក់បិតា ។*

*ព្រះមហេសីអង្គនោះ មានសាវកសន្និបាត (ការជួបជុំសាវ័ក) ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ គឺសន្និបាត លើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៩៨ ពាន់អង្គ សន្និបាតលើកទី ២ មានពួកព្រះខីណាស្រព ចំនួន៨៨ ពាន់អង្គ ។*

*សន្និបាតលើក ៣ មានពួកព្រះខីណាស្រព ចំនួន៧៨ ពាន់អង្គ សុទ្ធតែមានព្រះទ័យផុតស្រឡះ ឥតប្រកាន់ ប្រាសចាកមន្ទិល ជាអ្នកស្វែងរកនូវគុណដ៏ធំ ។*

**ពុទ្ធបណិធាន**

*ក្នុងសម័យនោះ តថាគត កើតជា*ជដិលឈ្មោះសុសិមៈ *មានតបៈដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី។*

*តថាគត បាននាំយកផ្កាមន្ទារវៈ ផ្កាឈូក និងផ្កាបរិច្ឆត្តកព្រឹក្សជាទិព្វអំពីទេវលោក មកបូជាចំពោះព្រះសម្ពុទ្ធ។*

*ឯព្រះពុទ្ធជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បានព្យាករតថាគតថា* តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បទី ១,៨០០។

*សត្វនេះ នឹងចេញអំពីបុរីជាទីរីករាយឈ្មោះកបិលពស្តុ តម្កល់ព្យាយាមហើយធ្វើទុក្ករកិរិយា។*

*សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។*

*ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរារួចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។*

*លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈ ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះនាមជននី នៃព្រះពោធិសត្វនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ បុរសនេះ នឹងជាព្រះពុទ្ធព្រះនាមគោតម។*

*ព្រះកោលិតៈ១ ឧបតិស្សៈ១ នឹងជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈអស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទនឹងបម្រើព្រះជិនស្រីអង្គនេះ។*

*ព្រះខេមាថេរី១ ព្រះឧប្បលវណ្ណាថេរី១ ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។*

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស។

គហបតីឈ្មោះចិត្តៈ១ គហបតីឈ្មោះហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ។

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថាៈ

"បើយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្រ្ត នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្រ្ត នៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគត យ៉ាងនោះដែរ"។

លុះតថាគត បានស្តាប់ភាសិត នៃព្រះលោកនាថអង្គនោះហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី១០ប្រការ។

**ពុទ្ធបណិធាន**

*ព្រះមហេសីព្រះនាមអត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រព្រះនាមសាគរៈជាព្រះបិតា មានព្រះជននីព្រះនាមសុទស្សនា។*

*ព្រះអត្ថទស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់៩ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ៣ខ្នង គឺប្រាសាទឈ្មោះអមរគិ១ ប្រាសាទឈ្មោះសុរគិ១ ប្រាសាទឈ្មោះគិរិពាហនៈ១។*

*នារី៣៣ពាន់រូបសឹងប្រដាប់យ៉ាងសមសួន ព្រះនារីជាអគ្គមហេសីនោះព្រះនាមវិសាខា ព្រះរាជបុត្រព្រះនាមសេលៈ។*

*ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត៤យ៉ាងហើយ ទ្រង់ស្ដេចចេញទៅដោយយានសេះ តម្កល់នូវព្យាយាមអស់៨ខែគត់។*

*ព្រះអត្ថទស្សី មានយសធំ មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ថ្លៃថ្លា។*

*ព្រះមហេសីព្រះនាមអត្ថទស្សី មានអគ្គសាវ័ក២អង្គ គឺព្រះសន្តៈ១ ព្រះឧបសន្តៈ១ មានភិក្ខុជាឧបដ្ឋាកឈ្មោះអភយៈ។*

*មានព្រះថេរីឈ្មោះធម្មា១ ឈ្មោះសុធម្មា១ ជាអគ្គសាវិកា។*

*ឈើ សម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ គេហៅថា ចម្បក-ព្រឹក្ស។*

*ឧបាសកឈ្មោះនកុឡៈ១ ឈ្មោះនិសភៈ១ ជាអគ្គឧបដ្ឋាក។*

*នាងមកិលា១ នាងសុនន្ទា១ ជាអគ្គឧបដ្ឋាយិកា។*

*ឯព្រះពុទ្ធអង្គនោះទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មានកម្ពស់៨០ហត្ថ ទ្រង់រុងរឿងហាក់ដូចដើមសាលរាជព្រឹក្ស ឬដូចព្រះចន្ទពេញវង់។*

រស្មីជាប្រក្រតីនៃព្រះពុទ្ធអង្គនោះ ច្រើនរយកោដិ តែងផ្សាយទៅកាន់ទិសទាំង១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយ១យោជន៍សព្វៗកាល។

ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួងជាអ្នកប្រាជ្ញ មានបញ្ញាចក្ខុ ទ្រង់ឋិតនៅក្នុងមនុស្សលោកអស់១សែនឆ្នាំ។

ព្រះពុទ្ធនោះ ទ្រង់សំដែងពន្លឺថ្មីងពុំបាន ញុំាងមនុស្សលោកព្រមទាំងទេវលោកឱ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញម។

ព្រះអត្ថទស្សីជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមារាម មានការសាយកាយទៅនៃព្រះធាតុ ក្នុងប្រទេសទាំងឡាយនោះៗ។

ចប់អត្ថទស្សិពុទ្ធវង្ស។

## ១៨. ធម្មទស្សិពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធធម្មទស្សី*

*ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាម**ធម្មទស្សី** មានយសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញុំាងមនុស្សលោក និងទេវលោកឱ្យរុងរឿង។*

*ការត្រាស់ដឹងលើកទី១ មានពួកសត្វប្រមាណ១សែនកោដិ ក្នុងការញុំាងធម្មចក្រឱ្យប្រព្រឹត្តទៅ នៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះថ្វីងមិនបាន។*

*ការត្រាស់ដឹងលើកទី២ មានសត្វចំនួន៩០កោដិ ក្នុងកាលដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ទូន្មានឥសីឈ្មោះសញ្ជយៈ។*

*ការត្រាស់ដឹងលើកទី៣ មានសត្វចំនួន៨០កោដិ ក្នុងកាលដែលសក្កទេវរាជ និងបរិស័ទ ចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក។*

*ព្រះធម្មទស្សីនោះ ជាទេវតាក្រៃលែងជាងទេវតា មានសាវកសន្និបាត៣លើក សុទ្ធតែជាព្រះខីណាស្រព មានមន្ទិលទៅប្រាសហើយ មានព្រះទ័យស្ងប់ប្រកបដោយតាទិគុណ។*

*សន្និបាតលើកទី១ មានព្រះខីណាស្រព១ពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ចូលទៅកាន់វស្សាក្នុងអារាមឈ្មោះសរណៈ។*

*សន្និបាតលើកទី២ មានព្រះខីណាស្រព ចំនួន១រយកោដិ ក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ ស្ដេចចុះចាកទេវលោក មកកាន់មនុស្សលោក។*

*មួយទៀត សន្និបាតលើកទី៣ មានព្រះខីណាស្រពចំនួន៨០កោដិ ក្នុងវេលាដែលព្រះពុទ្ធ ទ្រង់ប្រកាសនូវធុតង្គគុណទាំងឡាយ។*

*ក្នុងសម័យនោះ តថាគត កើតជា**ព្រះឥន្ទ្រឈ្មោះបុរិន្ទទៈ** បានបូជាព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រីទិព្វ។*

ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្ដាលពួកទេវតា ហើយព្យាករតថាគតថា ក្នុងកប្បទី១,៨០០ទេវរាជនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ។

សត្វនេះ នឹងចេញពីបុរីជាទីត្រេកអរឈ្មោះកបិលពស្តុ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា។

ព្រះពុទ្ធជិនស្រីអង្គនោះ បានសោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់ទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ។

លំដាប់អំពីនោះ ព្រះជិនស្រីមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះជននី នៃព្រះតថាគតនេះ ព្រះនាមមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ទេវរាជនេះនឹងបានជាព្រះពុទ្ធព្រះនាមគោតម។

ព្រះថេរៈ ឈ្មោះកោលិតៈ១ ឧបតិស្សៈ១ នឹងជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។

ព្រះខេមាថេរី១ ព្រះឧប្បលវណ្ណាថេរី១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។

ដើមឈើ សម្រាប់ត្រាស់ដឹង នៃព្រះដ៏មានព្រះភាគអង្គនោះហៅថា អស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តៈ១ ឈ្មោះហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសីឥតមានបុគ្គលស្មើ ក៏រីករាយថា **ព្រះឥន្ទនេះ ជាពូជពន្ធកនៃព្រះពុទ្ធ។**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុនាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន។

ពួកមនុស្ស កាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមក្នុងកាលជាអនាគត មិនខានយ៉ាងនោះឯង"។

តថាគត លុះបានស្តាប់នូវភាសិត នៃព្រះជិនស្រីអង្គនោះហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង១០។

ព្រះសាស្តាព្រះនាមធម្មទស្សី មានទីក្រុងឈ្មោះសោរណៈ មានព្រះមហាក្សត្រព្រះនាមសរណៈជាព្រះបិតា មានព្រះជននីព្រះនាមសុនន្ទា។

ព្រះធម្មទស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់៨ពាន់ឆ្នាំ ទ្រង់មានប្រាសាទ៣ខ្នង គឺប្រាសាទឈ្មោះអរជៈ១ ប្រាសាទឈ្មោះ វិរជៈ១ ប្រាសាទឈ្មោះសុទស្សនៈ១។

ពួកនារី៤០ពាន់រូប សឹងប្រដាប់ខ្លួនយ៉ាងសមសួន ព្រះនារីជាអគ្គមហេសីឈ្មោះវិចិកោលី ព្រះរាជបុត្រឈ្មោះបុញ្ញវឌ្ឍនៈ។

ព្រះធម្មទស្សីជាបុរសដ៏ប្រសើរ ទ្រង់ឃើញនិមិត្ត៤ ហើយទ្រង់ចេញទៅទាំងប្រាសាទ ទៅប្រព្រឹត្តព្យាយាមអស់៧ខែគត់។

ព្រះពុទ្ធព្រះនាមធម្មទស្សី ប្រសើរជាងពួកជន មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឱ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន។

ព្រះសាស្តាព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ១ ព្រះបុស្សទេវត្ថេរ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរជាឧបដ្ឋាក។

ព្រះខេមាថេរី១ ព្រះសច្ចនាមាថេរី១ ជាអគ្គសាវិកា។

ដើមឈើ សម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ គេហៅថា តិម្ពជាលព្រឹក្ស។

សុភទ្ទគហបតី១ កដិស្សហគហបតី១ ជាអគ្គឧបដ្ឋាក។

នាងសាឡិសា ១ នាងកឡិស្សា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់មានកម្ពស់៨០ហត្ថ ទ្រង់រុងរឿងក្រៃលែងដោយតេជះ ក្នុងមួយម៉ឺនលោកធាតុ។

ដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយល្អ ផ្ទេកបន្ទោរលើអាកាស ព្រះអាទិត្យនាថ្ងៃត្រង់រុងរឿងល្អ យ៉ាងណាមិញ ព្រះពុទ្ធអង្គនោះ ទ្រង់រុងរឿងល្អយ៉ាងនោះ។

ព្រះពុទ្ធអង្គនោះ ទ្រង់មានតេជះប្រៀបពុំបាន មានជីវិតដ៏ស្មើល្អ ព្រះពុទ្ធមានបញ្ញាចក្ខុ ទ្រង់ឋិតនៅក្នុងលោកអស់១សែនឆ្នាំ។

ព្រះពុទ្ធអង្គនោះ និងសាវ័ក ទ្រង់សំដែងរស្មី ធ្វើសាសនាមិនឱ្យមានមន្ទិល ដូចព្រះចន្ទកាលរុងរឿងឰដ៏អាកាស ហើយបរិនិព្វាន។

ព្រះធម្មទស្សី ទ្រង់មានព្យាយាមធំ ទ្រង់បរិនិព្វានក្នុងអារាមឈ្មោះកេសៈ ព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធអង្គនោះឯង មានកម្ពស់៣យោជន៍។

**ចប់ធម្មទស្សិពុទ្ធវង្ស។**

## ១៩. សិទ្ធត្ថពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធសិទ្ធត្ថៈ*

*ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយកព្រះនាម**សិទ្ធត្ថៈ** ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង។*

*ព្រះសិទ្ធត្ថៈអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណហើយ ចម្លងមនុស្ស និងទេវតា បន្ទុរភ្លៀងគឺព្រះធម៌ ហើយញ៉ាំងមនុស្ស និងទេវតាឱ្យរលត់ទុក្ខ។*

*ព្រះអង្គមានតេជះប្រៀបពុំបាន ទ្រង់មានការត្រាស់ដឹង៣លើក គឺការត្រាស់ដឹងលើកទី១ មានពួកសត្វមួយសែនកោដិ។*

*តមក ការត្រាស់ដឹងលើកទី២ មានពួកសត្វ៩០កោដិ ក្នុងកាលព្រះសម្ពុទ្ធ ទ្រង់ទូងស្គរ គឺធម៌ ក្នុងដែនឈ្មោះភីមៈ។*

*ការត្រាស់ដឹងលើកទី៣ មានពួកសត្វ៩០កោដិ ក្នុងកាលដែលព្រះពុទ្ធ ប្រសើរជាងជនអង្គនោះ ទ្រង់សំដែងធម៌ទៀបក្នុំឈ្មោះវេភារៈ។*

*ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានសាវកសន្និបាត៣លើក សុទ្ធតែព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រាកដដោយតាទិគុណ។*

*ឋានៈ គឺសន្និបាតទាំង៣លើក ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលនោះ មានចំនួន១រយកោដិម្តង ៩០កោដិម្តង ៨០កោដិម្តង។*

*សម័យនោះតថាគត ជាតាបសឈ្មោះ**មង្គលៈ** មានតេជះខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំងនៃអភិញ្ញា។*

*តថាគត បាននាំផ្លែព្រីងមកថ្វាយព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះសម្ពុទ្ធ ទ្រង់ទទួលយកហើយ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា **ចូរអ្នកទាំងឡាយ***

មើលជដិលតាបស ដែលមានតេជះខ្ពង់ខ្ពស់នេះចុះ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បទី៩៤ អំពីកប្បនេះទៅ។

សត្វនេះ នឹងចេញពីបុរីឈ្មោះកបិលពស្តុជាទីរីករាយ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា រួចស្តេចត្រឡប់ចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវប្រសើរដែលគេចាត់ចែងហើយ។

លំដាប់នោះព្រះជិនស្រីទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះជននី នៃព្រះគោតមនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោ-ទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម។

ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈមានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។

ខេមាថេរី១ ឧប្បលវណ្ណាថេរី១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈមានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។

ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានជោគនោះ ហៅថាអស្សត្ថព្រឹក្ស។

ចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្មាយុមួយរយឆ្នាំ។

មនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសីឥតមានបុគ្គលស្មើក៏រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ។

**ពុទ្ធបណិធាន**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់ទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានយ៉ាងណា ពួកយើងទាំងអស់ បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ"។

តថាគត លុះស្តាប់ភាសិតនៃព្រះពុទ្ធព្រះនាមសិទ្ធត្ថៈនោះហើយ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង១០។

ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានទីក្រុងឈ្មោះវេភារៈ មានព្រះមហាក្សត្រព្រះនាមឧទេនៈជាព្រះបិតា មានព្រះជននីព្រះនាមសុផស្សា។

ព្រះសិទ្ធត្ថៈនោះ គ្រប់គ្រងគេហដ្ឋានអស់មួយម៉ឺនឆ្នាំ មានប្រាសាទដ៏ប្រសើរ៣ខ្នង គឺកោកាសប្រាសាទ១ ឧប្បលប្រាសាទ១ កោកនុទប្រាសាទ១។

នារី៤៨.០០រូប សឹងមានខ្លួនតាក់តែងល្អ នារីជាអគ្គមហេសីព្រះនាមសុមនា មានព្រះរាជបុត្រព្រះនាមអនុបមៈ។

ព្រះជិនស្រីទ្រង់ឃើញនិមិត្ត៤យ៉ាង ក៏ចេញទៅដោយរ តម្កល់នូវព្យាយាមអស់១០ខែគត់។

ព្រះលោកនាយកព្រះនាមសិទ្ធត្ថៈ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន។

ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានព្រះសម្ពលត្ថេរ១ ព្រះសុមិត្តត្ថេរ១ ជា

*អគ្គសាវ័ក ភិក្ខុឈ្មោះរេវតៈ ជាឧបដ្ឋាក។*

*ព្រះសីវលាថេរី១ ព្រះសុភមាថេរី១ ជាអគ្គសាវិកា។*

*ដើមឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះគេហៅថា កណ្ណិការព្រឹក្ស។*

*សុប្បិយគហបតី១ សមុទ្ទគហបតី១ ជាអ្នកបម្រើដ៏ប្រសើរ។*

*រម្មាឧបាសិកា១ សុរម្មាឧបាសិកា ១ ជាស្រីបម្រើដ៏ប្រសើរ។*

*ព្រះពុទ្ធអង្គនោះទ្រង់មានកម្ពស់៦០ហត្ថ ទ្រង់ខ្ពស់ដល់អាកាស ប្រាកដដោយគ្រឿងបូជាមាស ទ្រង់រុងរឿងអស់មួយម៉ឺនលោកធាតុ។*

*ព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលថ្លឹងបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានចក្ខុបិតនៅក្នុងលោកអស់១សែនឆ្នាំ។*

*ព្រះពុទ្ធអង្គនោះ និងសាវ័ក ទ្រង់សំដែងពន្លឺភ្លឺត្រចះ ហើយញុំាងសាវ័កឱ្យសាយកាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ហើយបរិនិព្វាន។*

*ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមារាម ព្រះស្តូបដ៏ប្រសើរនៃព្រះអង្គនោះ មានកម្ពស់៤យោជន៍ ប្រតិស្ឋាននៅក្នុងអនោមារាមនោះឯង។*

**ចប់សិទ្ធត្ថពុទ្ធវង្ស។**

## ២០. តិស្សពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធតិស្សៈ*

*ក្រោយពីព្រះពុទ្ធព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធព្រះនាម**តិស្សៈ** ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់មិនបាន ទ្រង់មានសេចក្តីអាណិតអាសូរ មានព្យាយាមធំ មានចក្ខុ ទ្រង់កើតឡើងក្នុងលោក កម្ចាត់បង់ងងឹតអន្ធការ ញ៉ាំងលោកនេះនិងទេវលោក ឱ្យភ្លឺស្វាងហើយ។*

*ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិប្ញីងពុំបាន មានសីលសមាធិប្ញីងពុំបាន ព្រះអង្គសម្រេចនូវបារមីក្នុងធម៌ទាំងពួង ហើយទ្រង់ញ៉ាំងចក្រគឺធម៌ឱ្យប្រព្រឹត្តទៅ។*

*ព្រះពុទ្ធនោះ ទ្រង់បញ្ចេញព្រះសូរសៀងដ៏ជ្រះស្អាតល្អ ក្នុងលោកធាតុមួយម៉ឺន ពួកសត្វទាំងមួយរយកោដិ សឹងបានត្រាស់ដឹងក្នុងការសំដែងធម៌លើកទី១។*

*ការត្រាស់ដឹងលើកទី២ មានពួកសត្វ៩០កោដិ។*

*ការត្រាស់ដឹងលើកទី៣ មានពួកសត្វ៦០កោដិ ពេលនោះព្រះសម្ពុទ្ធនោះទ្រង់ដោះមនុស្ស និងទេវតាដែលមកដល់ ឱ្យរួចចាកចំណងគឺមារ។*

*ព្រះតិស្សមហេសី មានសាវកសន្និបាត៣លើក ដែលសុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ។*

សន្និបាតលើកទី១ មានព្រះខីណាស្រពមួយសែនអង្គ។

សន្និបាតលើកទី២ មានព្រះខីណាស្រព៩០សែនអង្គ។

សន្និបាតលើកទី៣ មានព្រះខីណាស្រព៨០សែនអង្គ សុទ្ធតែជាអ្នកអស់អាសវៈ ឥតមានមន្ទិលគឺកិលេស រីកហើយដោយវិមុត្តិ។

គ្រានោះ តថាគត ជាក្សត្រនាម**សុជាតៈ** លះចោលភោគៈដ៏ច្រើន ហើយទៅបួសជាឥសី។

កាលដែលតថាគត បួសស្រេចហើយ ព្រះលោកនាយកទ្រង់កើតឡើង តថាគត កើតមានបីតិព្រោះបានស្តាប់សំឡេងថា ព្រះពុទ្ធ។

តថាគត បានកាន់យកផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និងផ្កាបរិច្ឆត្តកព្រឹក្ស ជាទិព្វ ដោយដៃទាំងពីរដផុះរលាស់ ហើយចូលទៅគាល់។

តថាគត កាន់ផ្កានោះបាំងលើព្រះសិរ្សៈ នៃព្រះជិនស្រីព្រះនាមតិស្សៈ ជាលោកគ្គនាយក ដែលមានបរិស័ទ៤ចោមរោម។

ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្តាលប្រជុំជន ហើយព្យាករតថាគត កាលនោះថា **ក្នុងកប្បទី៩២អំពីមណ្ឌកប្បនេះទៅ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ។**

**សត្វនេះ នឹងចេញពីបុរីឈ្មោះកបិលពស្តុជាទីត្រេកអរ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។**

**សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសត្រង់ទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា។**

**ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។**

*លំដាប់នោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះជននីនៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម។*

*ព្រះកោលិតៈ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។*

*នាងខេមាថេរី១ នាងឧប្បលវណ្ណាថេរី១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។*

*ដើមឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។*

*ចិត្តគហបតី១ ហត្ថាឡវកគហបតី១ ជាអគ្គឧបដ្ឋាក។*

*នន្ទមាតាឧបាសិកា១ ឧត្តរាឧបាសិកា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះគោតមមានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ១០០ឆ្នាំ។*

ពួកមនុស្ស និងទេវតា បានស្ដាប់នូវព្រះពុទ្ធដីកានេះ នៃព្រះមហេសីទ្រង់ឥតមានបុគ្គលស្មើហើយ រីករាយថា **តាបសនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ។**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរសាទរ ធ្វើអញ្ជលី នមស្ការថា៖

"បើយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថអង្គនេះ គង់យើងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន។

ពួកមនុស្ស កាលធ្វងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យក កំពង់ខាងក្រោម ហើយធ្វងស្ទឹងធំបានយ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងអនាគតយ៉ាងនោះដែរ"។

តថាគត លុះបានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះហើយ ធ្វើចិត្តឲ្យរឹតតែជ្រះថ្លាថែមទៀត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០។

ព្រះមហេសីព្រះនាមតិស្សៈ មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រព្រះនាមជនសន្ធៈជាព្រះបិតា មានព្រះជននីព្រះនាមបទុមា។

ព្រះតិស្សនោះ ទ្រង់គ្រប់គ្រងព្រះរាជគេហដ្ឋាន អស់ ៧ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះ គុណសេលៈ ១ ប្រាសាទឈ្មោះ អនាទិយៈ ១ ប្រាសាទឈ្មោះនិសកៈ ១ ។

ពួកនារីចំនួន៣ម៉ឺននាក់ សុទ្ធសឹងតែតាក់តែងខ្លួនល្អ ឯនារីជាអគ្គមហេសីនោះព្រះនាមសុភទ្រា ព្រះរាជបុត្រព្រះនាមអានន្ទ។

ព្រះជិនស្រីទ្រង់ឃើញនិមិត្តទាំង៤ ក៏យាងចេញទៅដោយយានសេះ ទៅតម្កល់ព្យាយាមអស់កន្លះខែគត់។

ព្រះលោកនាយកព្រះនាមតិស្ស ប្រសើរក្នុងលោក មានព្យាយាមធំ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រគឺធម្មឱ្យប្រព្រឹត្តទៅ ក្នុងយសវតីទាយវ័នដ៏ឧត្តម។

ព្រះព្រហ្មទេវត្ថេរ១ ព្រះឧទយត្ថេរ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសមគៈ ជាឧបដ្ឋាកនៃព្រះមហេសី ព្រះនាមតិស្ស។

នាងផុស្សាថេរី១ នាងសុទត្តាថេរី១ ជាអគ្គសាវិកា។

**ពុទ្ធបណិធាន**

*ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានជោគអង្គនោះ ហៅថាអសនព្រឹក្ស (ដើមធ្នង់)។*

*សម្ពលគហបតី១ សិរិគហបតី១ ជាអគ្គឧបដ្ឋាក។*

*កីសាគោតមីឧបាសិកា១ ឧបសេនាឧបាសិកា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះជិនស្រីសម្ពុទ្ធនោះឯង ទ្រង់មានកម្ពស់៦០ហត្ថ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត។*

*ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះ ប្ញឹងពុំបាន ទ្រង់មានព្រះជន្ម មួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុបិតនៅក្នុងលោក។*

*ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័កទ្រង់សោយនូវយសធំ ដ៏ឧត្ដមប្រសើររុងរឿង ដូចគំនរភ្លើង ហើយបរិនិព្វាន ។*

*ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀងដែលបាត់ទៅ ព្រោះខ្យល់ ឬដូចទឹកសន្សើម អស់ទៅ ព្រោះព្រះអាទិត្យ ឬដូចងងឹត បាត់ទៅ ព្រោះប្រទីប ។*

*ព្រះពុទ្ធព្រះនាមតិស្សៈជាព្រះជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបព្រះជិនស្រីអង្គនោះ ពួកមហាជនសាងទុក កម្ពស់ ៣ យោជន៍ ក្នុងនន្ទារាមនោះ។*

***ចប់តិស្សពុទ្ធវង្ស។***

## ២១. បុស្សពុទ្ធប្បវត្ត

### ការឧប្បត្តិឡើងនៃព្រះពុទ្ធបុស្សៈ

*ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តាព្រះនាមបុស្សៈ*[៥៣] *ទ្រង់មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរក្នុងលោក។*

*ព្រះពុទ្ធអង្គនោះ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ ហើយត្រដោះគ្រឿងចាក់ស្រែះធំ (កិលេស) ទ្រង់ញ៉ាំងមនុស្សព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀងទឹកអម្រឹតចុះមក ។*

*កាលព្រះពុទ្ធ ព្រះនាមបុស្សៈញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹង លើកទី ១ មានពួកសត្វ ៨០ សែន ក្នុងមណ្ឌលនៃថ្ងៃនក្ខត្តឫក្ស ។*

*ការត្រាស់ដឹងលើកទី២ មានពួកសត្វ៩០សែន ការត្រាស់ដឹងលើកទី៣ មានពួកសត្វ៨០សែន។*

*ព្រះមហេសីព្រះនាមបុស្សៈ មានសាវកសន្និបាត៣លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ។*

*សន្និបាតលើកទី១ មានព្រះខីណាស្រព៦០សែន សន្និបាតលើកទី២ មានព្រះខីណាស្រព៥០សែន។*

---

[៥៣] *ព្រះត្រៃបិដកច្បាប់ឆដ្ឋសង្គាយនាៈ ព្រះពុទ្ធព្រះនាមផុស្សៈ។*

*សន្និបាតលើកទី៣ មានព្រះខីណាស្រព៩០សែន លោកផុតស្រឡះហើយព្រោះមិនប្រកាន់ មានតំណគឺជាតិកាត់ផ្ដាច់ហើយ។*

*សម័យនោះ តថាគត ជាក្សត្រព្រះនាម**វិជិត:** លះបោលរាជសម្បត្តិដ៏ធំទៅបួសក្នុងសម្នាក់ព្រះពុទ្ធនោះ។*

*ព្រះពុទ្ធជាម្ចាស់ព្រះនាមបុស្ស: ជាលោកគ្គនាយកនោះ ទ្រង់បានព្យាករតថាគតថា **ក្នុងកប្បទី៩២អំពីកប្បនេះទៅ ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធ។***

***សត្វនេះ នឹងចេញអំពីកបិលពស្តុបុរីជាទីរីករាយ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។***

***ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា រួចស្ដេចទៅឯគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។***

***លំដាប់អំពីនោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌ:ដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។***

***ព្រះជននី នៃព្រះពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោ-ទន: ភិក្ខុនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម។***

***ព្រះកោលិត:១ ឧបតិស្ស:១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវ: ប្រាសចាករាគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។***

***ខេមាភិក្ខុនី១ ឧប្បលវណ្ណាភិក្ខុនី១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវ: ប្រាសចាករាគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។***

ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថ-ព្រឹក្ស។

ចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា លុះឮព្រះពុទ្ធដីកា នៃព្រះមហេសី ឥតមានបុគ្គលស្មើហើយ ក៏រីករាយថា **ភិក្ខុនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ។**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងឃ្លាំងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលអនាគតមិនខាន។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានយ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគត យ៉ាងនោះដែរ"។

ចំណែកខាង តថាគត បានស្តាប់ព្រះពុទ្ធដីកា នៃព្រះបុស្សសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឱ្យរីងរឹតតែជ្រះថ្លា ហើយខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង១០ប្រការ។

**ពុទ្ធបណិធាន**

*តថាគត រៀនយកនូវព្រះសូត្រផង ព្រះវិន័យផង ពាក្យប្រៀនប្រដៅព្រះសាស្តា ប្រកបដោយអង្គ៩ទាំងអស់ផង ហើយញុំាងសាសនាព្រះជិនស្រីឱ្យរុងរឿង។*

*តថាគត មិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ខំចម្រើនភាវនា ដែលប្រកបដោយព្រហ្មវិហារ ហើយដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក។*

*ព្រះមហេសីព្រះនាមបុស្ស: មានទីក្រុងឈ្មោះកាសិក: មានព្រះមហាក្សត្រព្រះនាមជ័យសេនជាព្រះបិតា មានព្រះជននីព្រះនាមសិរិមា។*

*ព្រះបុស្ស:នោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់៩ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ៣ខ្នង គឺប្រាសាទឈ្មោះគរុឡ:១ ប្រាសាទឈ្មោះហំស:១ ប្រាសាទឈ្មោះសុវណ្ណតារ:១។*

*ពួកនារី២៣ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនារីជាអគ្គមហេសីព្រះនាមកីសាគោតមី ព្រះរាជបុត្រព្រះនាមអានន្ទ។*

*ព្រះជិនស្រីជាបុរសដ៏ប្រសើរ ទ្រង់ទតឃើញនិមិត្តទាំង៤យ៉ាងហើយចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាមអស់៧ថ្ងៃគត់។*

*ព្រះលោកគ្គនាយកព្រះនាមបុស្ស: មានព្យាយាមធំ ទ្រង់ប្រសើរជាងជនត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្រគឺធម៌ឱ្យប្រព្រឹត្តទៅ នាព្រៃមិគទាយវ័ន។*

*ព្រះសុរក្ខិតភិក្ខុ១ ព្រះធម្មសេនភិក្ខុ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសភិយ្យ: ជាឧបដ្ឋាក នៃព្រះមហេសីព្រះនាមបុស្ស:។*

*នាងចាលាភិក្ខុនី១ នាងឧបចាលាភិក្ខុនី១ ជាអគ្គសាវិកា។*

*ដើមឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថា អាមលកព្រឹក្ស (ដើមកន្ទួតព្រៃ)។*

*អនញ្ញគហបតី១ វិសាខគហបតី១ ជាអគ្គឧបដ្ឋាក។*

*នាងបទុមា១ នាងសិរិនាគា១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះមុនីអង្គនោះមានកម្ពស់៥៨ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះចន្ទពេញវង់។*

*ទ្រង់មានព្រះជន្ម៩០ពាន់ឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនជាច្រើន។*

*ព្រះសាស្ដាអង្គនោះ និងសាវ័ក ទ្រង់មានយសថ្កើងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្លងពួកសត្វជាច្រើន រួចបរិនិព្វាន។*

*ព្រះជិនស្រីដ៏ប្រសើរព្រះនាមបុស្សៈ ទ្រង់ជាសាស្ដា បរិនិព្វានហើយក្នុងសេនារាម ការផ្សាយចេញទៅនៃព្រះធាតុ មានក្នុងប្រទេសទាំងឡាយនោះៗ។*

**ចប់បុស្សពុទ្ធវង្ស។**

## ២២. វិបស្សិពុទ្ធប្បវេទ

*ការឧប្បត្តិឡើងនៃព្រះពុទ្ធវិបស្សី*

*ក្រោយអំពីព្រះពុទ្ធ ព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ ព្រះនាម**វិបស្សី** ដ៏ឧត្តមជាងសត្វជើង ២ ទ្រង់មានចក្ខុកើតឡើងក្នុងលោក។*

*ព្រះអង្គទ្រង់រំលាយស៊ុត គឺអវិជ្ជាចេញ ហើយដល់សម្ពោធិញ្ញាណដ៏ឧត្តម ទ្រង់ចៀសចេញទៅកាន់ពន្ធុមតីបុរី ដើម្បីញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ។*

*ព្រះនាយក ទ្រង់ញ៉ាំងធម៌ គឺចក្រ ឲ្យប្រព្រឹត្តទៅ រួចហើយ ញ៉ាំងខណ្ឌ-រាជកុមារ និងតិស្សកុមារ ទាំងពីរ ឲ្យត្រាស់ដឹង។*

*ការត្រាស់ដឹង លើកទី ១ មានចំនួនសត្វ គេមិនគប្បីពោលដោយការរាប់ឡើយ។*

*តមកទៀត ព្រះពុទ្ធជាម្ចាស់ មានយសរាប់មិនបាន ប្រកាសសច្ចៈទាំង ៤ ក្នុងបុរីនោះ ការត្រាស់ដឹង លើកទី ២ មានពួកសត្វចំនួន ៨ ម៉ឺន ៤ ពាន់។*

*មានមនុស្ស ៨ ម៉ឺន ៤ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមានចក្ខុ ទ្រង់សំដែងធម៌ដល់បព្វជិតទាំងនោះ ដែលមកដល់អារាម។*

*ភិក្ខុទាំងនោះ អាស្រ័យព្រះជិនស្រី កាលទ្រង់សំដែងដោយអាការទាំងពួង ក៏បានសម្រេចនូវធម៌ដ៏ប្រសើរ នេះជាការត្រាស់ដឹង លើកទី ៣។*

*ព្រះមហេសី ព្រះនាមវិបស្សី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រពឥតមានមន្ទិល គឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ។*

*គឺសន្និបាត លើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៦៨ សែន សន្និបាត លើកទី ២ មានពួកព្រះខីណាស្រព ចំនួន ១ សែន។*

*សន្និបាត លើកទី ៣ មានភិក្ខុចំនួន ៨ ម៉ឺន ព្រះសម្ពុទ្ធរុងរឿង ក្នុងកណ្ដាលពួកភិក្ខុនោះ។*

*សម័យនោះ តថាគតកើតជាស្ដេចនាគ ឈ្មោះ**អតុលៈ** មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្លឺ។*

*ក្នុងកាលនោះ តថាគត មានពួកនាគច្រើនកោដិចោមរោម ប្រគំតូរ្យតន្ត្រីដ៏ជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋៈ។*

*លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្តា ដ៏ស្អិតស្អាង ហើយដោយអាភរណៈគ្រប់យ៉ាង ដល់ព្រះអង្គជាធម្មរាជ ។*

*ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្ដាលសង្ឃ ហើយព្យាករតថាគតថា **ក្នុងកប្បទី៩១អំពីមណ្ឌកប្បនេះ ស្ដេចនាគនេះនឹងបានត្រាស់ជាព្រះពុទ្ធ។***

***សត្វនេះ នឹងចេញពីកបិលពស្តុបុរីជាទីត្រេកអរ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។***

*ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។*

*លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះជននី នៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម។*

*ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។*

*នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ។*

*ដើមឈើ ជាទីត្រាស់ដឹងនៃព្រះមានជោគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស។*

*ចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។*

*នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។*

*ព្រះគោតមនោះ មានព្រះជន្មាយុ១០០ឆ្នាំ។*

*ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមហេសីឥតមានបុគ្គលស្មើ ហើយរីករាយថា* ***នាគរាជនេះ ជាពូជពន្លកនៃព្រះពុទ្ធ។***

*សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថាៈ*

*"បើពួកយើង ឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថអង្គនេះ គង់នឹងសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគតជាមិនខាន។*

*ពួកមនុស្ស កាលធ្វងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ"។*

*តថាគត បានស្ដាប់ព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះហើយ ញុំាងចិត្តឱ្យរីងរឹតតែជ្រះថ្លា បានខំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង១០ប្រការ។*

*ព្រះមហេសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះពន្ធុមតី មានព្រះមហាក្សត្រព្រះនាមពន្ធុមៈជាព្រះបិតា មានព្រះមាតាព្រះនាមពន្ធុមតី។*

*ព្រះវិបស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់៨ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ៣ខ្នង គឺប្រាសាទឈ្មោះនន្ទៈ១ ប្រាសាទឈ្មោះសុនន្ទៈ ១ ប្រាសាទឈ្មោះសិរិមៈ១។*

*ពួកនារីចំនួន៤ម៉ឺន៣ពាន់ សឹងមានខ្លួនតាក់តែងល្អ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា ព្រះរាជបុត្រព្រះនាមសមវត្តក្ខន្ធៈ។*

*ព្រះជិនស្រីទ្រង់ឃើញនិមិត្ត៤ ហើយចេញទៅដោយយានរថ តម្កល់ព្យាយាមអស់៨ខែគត់។*

*ព្រះវិបស្សីជាលោកនាយក ទ្រង់មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន។*

*ព្រះរាជកុមារនាមខន្ធៈ១ បុត្រនៃបុរោហិត នាមតិស្សៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាក នៃព្រះមហេសីព្រះនាមវិបស្សី។*

*នាងចន្ទាភិក្ខុនី១ នាងចន្ទមិត្តាភិក្ខុនី១ ជាអគ្គសាវិកា។*

**ពុទ្ធបណិធាន**

ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាបាដលិ-ព្រឹក្ស។

បុនព្វសុមិត្តគហបតី១ នាគគហបតី១ ជាអគ្គឧបដ្ឋាក។

នាងសិរិមា១ នាងឧត្តរា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះវិបស្សីលោកនាយក មានកម្ពស់៨០ហត្ថ ពន្លឺព្រះអង្គផ្សាយចេញទៅជុំវិញ៧យោជន៍។

ព្រះពុទ្ធអង្គនោះ ទ្រង់មានព្រះជន្ម៨ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនច្រើនចាកសំសារវដ្ត។

ព្រះអង្គទ្រង់ដោះស្រាយនូវចំណង នៃទេវតា និងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវ ផ្លូវខុស ចំពោះពួកបុថុជ្ជនដ៏សេសទៀតផង។

ព្រះអង្គ និងសាវ័ក ទ្រង់សំដែងពន្លឺហើយបង្ហាញឧបាយ ជាទីទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន។

ព្រះសរីរៈ ដែលមានឫទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រដាប់ហើយដោយលក្ខណៈ គឺចក្រ គង់បាត់បង់ អស់ទៅបាន ឱហ្ន៎ !សង្ខារទាំងអស់ សោះសូន្យទទេតើ ព្រះវិបស្សីជានរៈដ៏ប្រសើរ ទ្រង់មានព្យាយាម បរិនិព្វានហើយក្នុងសុមិត្តារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះអង្គនោះ គេបានសាងទុកកម្ពស់ ៧ យោជន៍ ក្នុងអារាមនោះ។

**ចប់វិបស្សិពុទ្ធវង្ស។**

## ២៣. សិខិពុទ្ធប្បវត្តិ

## *ការឧប្បត្តិឡើងនៃព្រះពុទ្ធសិខី*

*ក្រោយអំពីព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាម**សិខី**ជិនស្រី ទ្រង់ឧត្តមជាងសត្វជើង២ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹមបាន។*

*ព្រះអង្គកម្ចាត់បង់សេនានៃមារ ហើយដល់សម្ពោធិញ្ញាណដ៏ប្រសើរ ញ៉ាំងចក្រគឺធម៌ឱ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីអនុគ្រោះ ដល់ពួកសត្វ។*

*កាលព្រះសិខីជិនស្រីដ៏ប្រសើរ ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី១ មានពួកសត្វចំនួន១សែនកោដិ។*

*កាលព្រះសិខីប្រសើរជាងគណៈ ឧត្តមជាងជន ទ្រង់សំដែងធម៌ដទៃទៀត ការត្រាស់ដឹងលើកទី២ មានពួកសត្វចំនួន៩០ពាន់កោដិ។*

*កាលព្រះសិខី ទ្រង់សំដែងយមកប្បាដិហារ្យ ក្នុងមនុស្សលោក និងទេវលោក ការត្រាស់ដឹងលើកទី៣ មានពួកសត្វចំនួន៨០ពាន់កោដិ។*

*ព្រះមហេសី ព្រះនាមសិខី មានសាវកសន្និបាត៣លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រពឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ។*

*សន្និបាតលើកទី១ មានភិក្ខុចំនួន១សែនរូប។*

*សន្និបាតលើកទី២ មានពួកភិក្ខុចំនួន៨ម៉ឺនរូប។*

*សន្និបាតលើកទី៣ មានភិក្ខុចំនួន៧ម៉ឺនរូបជាសមាគម មិនប្រឡាក់ដោយពួកបុថុជ្ជន ដូចបទុមជាតិ ដែលលូតលាស់នៅក្នុងទឹក។*

*សម័យនោះ តថាគត ជាក្សត្រនាម**អរិន្ទមៈ** បានញ៉ាំងព្រះសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក។*

**ពុទ្ធបណិធាន**

តថាគត បានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់ មិនតិច ហើយថ្វាយយានដំរីដ៏ប្រដាប់ហើយ ដល់ព្រះសម្ពុទ្ធ ។

តថាគតសាងយានដំរី ហើយបង្អោនចូលទៅជិត ឲ្យជារបស់គួរ បំពេញចិត្តរបស់តថាគត ឲ្យតម្កល់នៅមាំ អស់កាលជានិច្ច ។

ព្រះពុទ្ធព្រះនាមសិខី ជាលោកគ្គនាយកនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បទី៣១អំពីមណ្ឌកប្បនេះ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ។

សត្វនេះ នឹងចេញអំពីកបិលពស្តុបុរីជាទីរីករាយ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលយកមធុបាយាសនៅទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះពុទ្ធនេះ នឹងមានព្រះជននីព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះរាជាអង្គនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម។

ព្រះកោលិតៈ១ ព្រះឧបតិស្សៈ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ។

នាងខេមាភិក្ខុនី១ នាងឧប្បលវណ្ណាភិក្ខុនី១ ជាអគ្គសាវិកា សុទ្ធតែមិន

មានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ។

ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស។

ចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងជាអគ្គឧបដ្ឋាក។

នាងនន្ទមាតា១ នាងឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសនោះ មានព្រះជន្ម១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសីឥតមានបុគ្គលស្មើ ហើយរីករាយថា **ព្រះរាជាអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ។**

សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងអនាគតកាល មិនខាន។

ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ខាងលើ គង់ទៅកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងបាន យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ យ៉ាងនោះដែរ"។

ឯតថាគត លុះបានស្តាប់ព្រះពុទ្ធដីកា នៃព្រះអង្គនោះហើយ រឹងរឹតតែធ្វើចិត្តឱ្យជ្រះថ្លាហើយ បានខំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង១០ប្រការ។

ព្រះមហេសីព្រះនាមសិខី មានទីក្រុងឈ្មោះអរុណវតី មានព្រះមហា-

ក្សត្រព្រះនាមអរុណៈជាព្រះបិតា មានព្រះជននីព្រះនាមបភាវតី។

ព្រះអង្គ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់៧ពាន់ឆ្នាំ ទ្រង់មានប្រាសាទដ៏ប្រសើរ៣ខ្នង គឺប្រាសាទឈ្មោះសុវណ្ណកៈ១ ប្រាសាទឈ្មោះគិរី១ ប្រាសាទឈ្មោះនារីវាហនៈ១។

ពួកនារីចំនួន២ម៉ឺន៤ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនាងនារីជាអគ្គមហេសីនោះ ព្រះនាមសព្វកាមា ព្រះរាជបុត្រព្រះនាមអតុលៈ។

ព្រះតថាគត ជាបុរសដ៏ឧត្តមទ្រង់ឃើញនិមិត្តទាំង៤ហើយ ចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាមអស់៨ខែគត់។

ព្រះសិខីលោកគ្គនាយក មានព្យាយាមដ៏ធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន។

ព្រះមហេសីព្រះនាមសិខី មានអភិភូភិក្ខុ១ សម្ភវភិក្ខុ១ ជាអគ្គសាវ័កភិក្ខុឈ្មោះខេមង្ករៈ ជាឧបដ្ឋាក។

នាងមខិលាភិក្ខុនី១ នាងបទុមាភិក្ខុនី១ ជាអគ្គសាវិកា។

ដើមឈើ ជាទីត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាបុណ្ឌរីកព្រឹក្ស (ដើមស្វាយស)។

សិរិវឌ្ឍគហបតី១ នន្ទគហបតី១ ជាអគ្គឧបដ្ឋាក។

នាងចិត្តា១ នាងសុចិត្តា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់៧០ហត្ថ ប្រាកដស្មើដោយគ្រឿងមាសមានលក្ខណៈដ៏ប្រសើរ៣២ប្រការ។

ព្រះពុទ្ធជាម្ចាស់អង្គនោះ មានពន្លឺប្រមាណ១ព្យាម ផ្សាយចេញអំពីព្រះ

កាយជានិច្ច ផ្សាយចេញទៅទិសតូច និងទិសធំ ភ្លឺចេញទៅចម្ងាយ៣យោជន៍។

ព្រះមហេសីអង្គនោះ មានព្រះជន្ម ៧ ម៉ឺនឆ្នាំ ព្រះអង្គកាលគង់ធរមាននៅឡើយ បានញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លងត្រើយសំសារវដ្ដ។

ព្រះពុទ្ធនោះ ព្រមទាំងសាវ័ក បង្អុរភ្លៀង គឺធម៌ ស្រោចស្រប់ផ្សើមពួកមនុស្សព្រមទាំងទេវតា ធ្វើឲ្យដល់នូវសភាពក្សេមក្សាន្ត ហើយបរិនិព្វាន។

ព្រះសរីរៈបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ប្រការ គង់បាត់បង់សូន្យ ទាំងអស់ ឱ! សង្ខារទាំងពួង ជារបស់ទទេ ទទេតើ ។

ព្រះសិខីសម្ពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអស្សារាម ព្រះស្តូបដ៏ប្រសើរ នៃព្រះអង្គនោះ គេសាងទុក កម្ពស់ ៣ យោជន៍ ក្នុងទីនោះឯង។

ចប់សិខីពុទ្ធវង្ស។

# ២៤. វេស្សភូពុទ្ធប្បវត្តិ

## *ការឧប្បត្តិឡើងនៃព្រះពុទ្ធវេស្សភូ*

*ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាម**វេស្សភូ** ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក។*

*ព្រះជិនស្រីនោះ កាលជ្រាបច្បាស់នូវលោកទាំង៣នេះ ដែលឆេះសព្វដោយភ្លើង គឺរាគៈផង នូវដែននៃតណ្ហាទាំងឡាយផង ទ្រង់កាត់នូវចំណងដូចដំរីដ៏ប្រសើរ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម។*

*ព្រះវេស្សភូជាលោកនាយក ទ្រង់សំដែងធម្មចក្រ មានពួកបរិស័ទចំនួន៨០ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រាជាដំបូង។*

*កាលដែលព្រះលោកជេដ្ឋៈ ប្រសើរជាងពួកនរជន ចៀសចេញទៅកាន់ចារិកក្នុងដែន មានពួកបរិស័ទចំនួន៧០ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រាទី២។*

*ព្រះជិនស្រីអង្គនោះ ទ្រង់បន្ទោបង់នូវមហាទិដ្ឋិ ហើយធ្វើនូវបាដិហារ្យ ពួកមនុស្ស និងទេវតា ក្នុងមួយម៉ឺនលោកធាតុ ព្រមទាំងទេវលោក ក៏បានមកប្រជុំគ្នា។*

*ពួកទេវតា និងមនុស្សចំនួន៦០កោដិ ឃើញហេតុអស្ចារ្យធំចម្លែកជាទីព្រឺរោមហើយ ក៏បានត្រាស់ដឹងក្នុងគ្រាទី៣។*

*ព្រះពុទ្ធព្រះនាមវេស្សភូ ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត៣លើក សុទ្ធតែជាព្រះខីណាស្រពប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺសន្និបាតលើកទី១ មានភិក្ខុចំនួន៨០ពាន់កោដិ។*

*សន្និបាតលើកទី២ មានភិក្ខុចំនួន៧០ពាន់កោដិ។*

*សន្និបាតលើកទី៣ មានពួកភិក្ខុចំនួន៦០ពាន់កោដិ ដែលភ័យតក់ស្លុតអំពីទុក្ខ មានជរាជាដើម ជាឱរសរបស់ព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ។*

*កាលព្រះសម្ពុទ្ធ មិនមានបុគ្គលស្មើអង្គនោះ ទ្រង់សំដែងធម្មចក្រដ៏ឧត្តមសម័យនោះ តថាគត ជាក្សត្រឈ្មោះ**សុទស្សនៈ** បានស្តាប់នូវធម៌ដ៏ប្រសើរហើយ ក៏ពេញចិត្តនឹងផ្នួសយ៉ាងក្រៃលែង បានបូជាព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយបាយទឹក និងសំពត់។*

*តថាគត ញុំាងមហាទានឱ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិលទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែលបរិបូណ៌ដោយគុណ ក្នុងសម្នាក់ព្រះជិនស្រី។*

*តថាគត បរិបូណ៌ដោយអាចារគុណ មានចិត្តតម្កល់ខ្ជាប់ ក្នុងវត្ត និងសីល ស្វែងរកនូវសព្វញ្ញុតញ្ញាណ ត្រេកអរក្នុងសាសនានៃព្រះជិនស្រី។*

*តថាគត ញុំាងសទ្ធា និងបីតិឱ្យកើតឡើង ហើយថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្តា បីតីរបស់តថាគតក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ។*

*ព្រះសម្ពុទ្ធ ទ្រង់ជ្រាបចិត្តមិនវិលត្រឡប់ ហើយទ្រង់ត្រាស់ថា **ក្នុងកប្បទី៣១អំពីកប្បនេះ ក្សត្រនេះនឹងបានត្រាស់ជាព្រះពុទ្ធ។***

***សត្វនេះ នឹងចេញពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។***

***ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាសក្បែរឆ្នេរស្ទឹងនេរញ្ជរា***

ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ។

លំដាប់នោះ ព្រះសម្ពុទ្ធមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះមាតាព្រះពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈស្តេចនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម។

ព្រះថេរៈ២អង្គ គឺកោលិតៈ១ ឧបតិស្សៈ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ។

ព្រះថេរី ឈ្មោះខេមា១ ឧប្បលវណ្ណា១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈមានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ដើមឈើ ជាទីត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តគហបតី១ ហត្ថាឡវកគហបតី១ នឹងបានជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះសម្ពុទ្ធព្រះនាមគោតមមានយសអង្គនោះ មានព្រះជន្ម១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា បានស្តាប់នូវព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធទ្រង់រកបុគ្គលស្មើគ្មាន ស្វែងរកនូវគុណដ៏ធំហើយក៏រីករាយថា ក្សត្រនេះ ជាពូជពន្លកនៃព្រះពុទ្ធ។

ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោ ទះដៃ

អបអរសាទរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។

មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ"។

តថាគត បានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះសាស្តានោះហើយក៏ញុំាងចិត្តឱ្យជ្រះថ្លាក្រៃលែង បានខំអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង១០។

ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះអនោមៈ មានព្រះមហាក្សត្រព្រះនាមសុប្បតិតៈជាព្រះបិតា មានព្រះមាតាព្រះនាមយសវតី។

ព្រះអង្គ គង់នៅគ្រប់គ្រងព្រះដំណាក់អស់៦ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ គឺរុចិប្រាសាទ១ សុរតិប្រាសាទ១ វឌ្ឍកប្រាសាទ១។

ពួកនារីមិនខ្វះពី៣០ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីព្រះនាមសុចិត្តា ព្រះរាជបុត្រព្រះនាមសុប្បពុទ្ធ។

ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម បានឃើញនូវនិមិត្ត៤យ៉ាង ស្តេចចេញទៅទ្រង់ព្រះផ្នួសដោយរ បានប្រព្រឹត្តព្យាយាមអស់៦ខែ។

ព្រះវេស្សភូជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ មានចក្រគឺធម៌

ប្រព្រឹត្តទៅ មានព្យាយាមធំ ឧត្តមជាងពួកជន ត្រូវមហាព្រហ្មអារាធនាហើយក្នុងអរុណារាម។

ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះសោណៈ១ ឧត្តរៈ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះឧបសន្តៈ ជាឧបដ្ឋាក។

ព្រះថេរីឈ្មោះរាមា១ សមានា១ ជាអគ្គសាវិកា។

ឯឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេតែងហៅថា មហាសាលព្រឹក្ស។

ឧបាសកឈ្មោះសោត្ថិកៈ១ រម្មៈ១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះគោតមី១ សិរិមា១ ជាអគ្គឧបដ្ឋាយិកា។

រស្មីមានកម្ពស់ ៦០ ហត្ថ មានឧបមាស្មើដោយប្រាសាទមាស ផ្សាយចេញពីព្រះកាយ ដូចអណ្ដាតភ្លើងលើកំពូលភ្នំ ក្នុងវេលាយប់។

ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំអង្គនោះ មានព្រះជន្មាយុ៦ម៉ឺនឆ្នាំ ព្រះអង្គឋិតនៅអស់កាលត្រឹមនោះ ញុំាងប្រជុំជនជាច្រើនឱ្យឆ្លងចាកសង្សារ។

ព្រះសម្ពុទ្ធអង្គនោះ និងសាវ័ក ញែកធម៌ធ្វើឱ្យពិស្តារ តម្កល់មហាជនក្នុងសំពៅគឺធម៌ ហើយបរិនិព្វាន។

ជនទាំងអស់នោះ វិហារ និងឥរិយាបថ ជារបស់ដែលគេគប្បីរមិលមើលរបស់ទាំងអស់នេះ វិនាសសាបសូន្យអស់ទៅ ឱ!សង្ខារទាំងពួងជារបស់ទទេទទេតើ។

ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមវេស្សភូជាសាស្ដា បរិនិព្វានក្នុងខេមារាមព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ។

**ចប់វេស្សភូពុទ្ធវង្ស។**

## ២៥. កក្កុសន្ធពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធកក្កុសន្ធៈ*

*ក្នុងកាលជាខាងក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាម**កក្កុសន្ធៈ** ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់មិនបាន គេគ្របសង្កត់បានដោយកម្រ ព្រះអង្គរំលើងនូវភពទាំងពួង ដល់នូវបារមីដោយចរិយា ហើយសម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហៈទម្លាយនូវទ្រុង។*

*កាលព្រះកក្កុសន្ធៈ ជាលោកនាយក ញុំាងធម្មចក្រឱ្យប្រព្រឹត្តទៅ មានពួកបរិស័ទចំនួន៤ម៉ឺនកោដិ បានត្រាស់ដឹងក្នុងគ្រាដំបូង។*

*ព្រះកក្កុសន្ធៈ ទ្រង់ធ្វើនូវវិកុព្វនបដិហារ្យជាគូៗ ឰដ៏អាកាស ញុំាងទេវតា និងមនុស្ស៣ម៉ឺនកោដិ ឱ្យត្រាស់ដឹង នេះជាការត្រាស់ដឹងទី២។*

*ក្នុងការប្រកាសនូវចតុស្សច្ចធម៌ នៃព្រះពុទ្ធនោះ មានមនុស្សទេវតា និងយក្សត្រាស់ដឹងនូវធម៌ គេមិនអាចរាប់បាន នេះជាការត្រាស់ដឹងទី៣។*

*ព្រះមានជោគព្រះនាមកក្កុសន្ធៈ មានសាវកសន្និបាតតែមួយដង សុទ្ធតែជាព្រះខីណាស្រពមិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង។*

*សាវ័កសមាគម ក្នុងកាលនោះ មានពួកព្រះខីណាស្រព៤ម៉ឺន ដែលដល់នូវទន្តភូមិគឺភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ ព្រោះអស់ទៅនៃកិលេសមានអាសវៈជាដើម។*

*សម័យនោះ តថាគត ជាក្សត្រឈ្មោះ**ខេមៈ** បានថ្វាយទានដ៏ច្រើនចំពោះព្រះតថាគត និងព្រះសង្ឃជាជិនបុត្ត។*

**ពុទ្ធបណិធាន**

*តថាគត បានចាត់ចែងថ្វាយបាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែម ទាំងអស់នេះ ជារបស់ប្រសើរក្រៃពេក ដែលតថាគតប្រាថ្នាហើយ។*

*ព្រះមុនីកកុសន្ធៈ ជានាយកអង្គនោះទ្រង់ព្យាករតថាគតថា ក្នុងភទ្ទកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ។*

*សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីរីករាយ ហើយតម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា។*

*សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។*

*ព្រះជិនស្រីនោះ នឹងសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរាហើយស្តេចសំដៅទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែង។*

*លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះមាតា នៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ក្សត្រនេះ ជាព្រះពុទ្ធព្រះនាមគោតម។*

*ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ។*

*ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា ១សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវិកា។*

*ឈើ ជាទីត្រាស់ដឹង របស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថាអស្សត្ថ-ព្រឹក្ស។*

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវក១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ។

ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់មិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រអង្គនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ។

ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោ ទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ យើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន។

មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណាមិញ យើងទាំងអស់គ្នាបើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់តែនឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ"។

តថាគត ស្តាប់ព្រះពុទ្ធដីការបស់ព្រះពុទ្ធនោះហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាដោយក្រៃលែង បានអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង១០។

កាលនោះ នគរឈ្មោះខេមវតី ឯតថាគតជាបុរសឈ្មោះខេមៈ ស្វែងរកនូវសព្វញ្ញុតញ្ញាណ បានបួសក្នុងសម្នាក់នៃព្រះពុទ្ធអង្គនោះ។

**ពុទ្ធបណិធាន**

ព្រះពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានអគ្គិទត្ត ព្រាហ្មណ៍ជាព្រះបិតា ព្រះមាតាព្រះនាមវិសាខា។

មហាត្រកូលរបស់ព្រះសម្ពុទ្ធ នៅក្នុងខេមបុរីនោះ ជាត្រកូលប្រសើរបំផុត មានជាតិខ្ពង់ខ្ពស់ មានយសធំជាងមនុស្សទាំងឡាយ។

ព្រះកកុសន្ធៈអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងឃរាវាសអស់៤ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ គឺកាមវឌ្ឍប្រាសាទ១ កាមសុទ្ធិប្រាសាទ១ រតិវឌ្ឍនប្រាសាទ១។

មាននារី៣ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ ព្រះនាមរោចិនី ព្រះរាជបុត្រព្រះនាមឧត្តរៈ។

ព្រះជិនស្រីឃើញនូវនិមិត្តទាំង៤ ទ្រង់ចេញទៅដោយរថយាន តម្កល់ទុកនូវព្យាយាមមិនលើសពី៨ខែ។

ព្រះកកុសន្ធៈជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពួកជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងចក្រឱ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន។

ព្រះកកុសន្ធៈស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះវិធុរៈ១ សញ្ជីវៈ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះពុទ្ធិជៈ ជាឧបដ្ឋាក។

ព្រះថេរីឈ្មោះសាមា១ នាងចម្ប៉ា ១ ជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថា សិរិសព្រឹក្ស (ដើមច្រេស)។

ឧបាសកឈ្មោះអច្ចុគ្គតៈ១ សុមនៈ១ ជាអគ្គឧបដ្ឋាក។

*ឧបាសិកាឈ្មោះនន្ទា១ សុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា។*

*ព្រះមហាមុនី មានកម្ពស់៤០ហត្ថ រស្មីដូចជាមាស ផ្សាយចេញទៅកាន់ទីចម្ងាយ១០យោជន៍ ដោយជុំវិញ។*

*ព្រះមហេសីនោះមានព្រះជន្មាយុ៤ម៉ឺនឆ្នាំ ព្រះអង្គគង់នៅកំណត់ប៉ុណ្ណោះ ទ្រង់ញុាំងប្រជុំជនដ៏ច្រើនឱ្យឆ្លងចាកសង្សារ។*

*ព្រះសម្ពុទ្ធនោះ និងសាវ័ក តាំងពានផ្សារគឺព្រះសទ្ធម្មបន្ទឺឡើងដូចជាសីហនាទចំពោះនរៈ និងនារីទាំងឡាយក្នុងមនុស្សលោក និងទេវលោក ហើយបរិនិព្វាន។*

*ព្រះសម្ពុទ្ធបរិបូណ៌ដោយពាក្យប្រកបដោយអង្គ៨[៥៤] សីលទាំងឡាយមិនធ្លុះធ្លាយ ដាប់មិនដាច់ របស់ទាំងអស់នេះវិនាសសូន្យទៅ ឱ !សង្ខារទាំងពួងជារបស់មិនទៀងទេតើ។*

*ព្រះកកុសន្ធៈ ជាព្រះជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងខេមារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធនោះ មានកម្ពស់ទៅក្នុងអាកាស១គាវុត ក្នុងទីនោះឯង ។*

**ចប់កកុសន្ធពុទ្ធវង្ស។**

---

[៥៤] **អដ្ឋង្គវចនសម្បន្នោ** *អ្នកមានវាចាប្រកបដោយអង្គ៨ គឺ ៖* **វិសដ្ឋោ** *ក្បោះក្បាយ១,* **វិញ្ញេយ្យោ** *គប្បីដឹងបានដោយងាយ១,* **មញ្ជុ** *ទន់ពីរោះ១,* **សវនីយោ** *ស្រួលស្តាប់១,* **ពិន្ទុ** *មូល១,* **អវិសារី** *មិនបែកព្រែក១,* **គម្ភីរោ** *ក្រអួន១,* **និន្នាទិ** *លាន់រំពង១។*

*(ទីឃនិកាយ មហាវគ្គបាឡិ ជនវសភសុត្តំ, មហាគោវិន្ទសុត្តំ, មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសបាឡិ ព្រាហ្មណវគ្គោ, ខុទ្ទកនិកាយ មហានិទ្ទេសបាឡិ សារិបុត្តសុត្តនិទ្ទេសោ)*

## ២៦. កោនាគមនពុទ្ធប្បវត្ត

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធកោនាគមនៈ*

*កាលជាខាងក្រោយអំពីព្រះកកុសន្ធៈមក មានព្រះជិនស្រីសម្ពុទ្ធព្រះនាម**កោនាគមនៈ** ព្រះអង្គឧត្តមជាងសត្វទេ្វបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន។*

*ព្រះសម្ពុទ្ធអង្គនោះ បានបំពេញបារមីធម៌ទាំង១០ កន្លងផ្លូវឆ្ងាយគឺជាតិ លះបង់មន្ទិលទាំងអស់ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម។*

*ព្រះកោនាគមនសម្ពុទ្ធជានាយក ញុំាងធម្មចក្រឱ្យប្រព្រឹត្តទៅ ពួកសត្វចំនួន៣ម៉ឺនកោដិ បានត្រាស់ដឹងដំបូង។*

*កាលទ្រង់ធ្វើបាដិហារិយ៍ ញាំញីពាក្យត្មះតិះដៀលនៃជនដទៃ ពួកសត្វចំនួន២ម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី២។*

*លំដាប់ពីនោះ ព្រះជិនស្រី ធ្វើវិកុព្វនបដិហារិយ៍ ហើយទ្រង់យាងទៅកាន់ទេវបុរី ព្រះសម្ពុទ្ធគង់នៅលើ**បណ្ឌុកម្ពលសិលា**[៥៥] ក្នុងទេវលោកនោះ*

---

[៥៥] **បណ្ឌុកម្ពលសិលា** ( ន. ) *[ប័ន-ឌុក័ម-ព:ល:សិល៉ា]* *( បា., សំ. )* (បាណ្ឌុកម្ពលគិលា) ថ្មមានសម្បុរដូចសំពត់កម្ពលលឿងទុំ; *ជាឈ្មោះថ្មទិព្វជាអាសនៈនៃព្រះឥន្ទនាឋានត្រ័យត្រិង្សសួគ៌ ។ មានតំណាលក្នុងគម្ពីរខាងពុទ្ធសាសនាថា កាលបើព្រះឥន្ទត្រូវការគង់កំសាន្តមួយដងមួយកាលលើផ្ទៃថ្មទិព្វនេះ ផ្ទៃនៃសិលាសនៈនេះទ្រុឌផតចុះត្រឹមពាក់កណ្ដាលព្រះកាយ, កាលព្រះឥន្ទទ្រង់ក្រោកពីទីនេះ ផ្ទៃនៃអាសនៈនេះ ក៏ប៉ោងរាបស្មើដូចប្រក្រតីឡើងវិញ; កាលបើមានហេតុអ្វីមួយប្លែកគួរឲ្យព្រះឥន្ទរំពឹងមើល, ផ្ទៃនៃសិលាសនៈទិព្វនេះ ក៏រឹងក្ដៅឧណ្ហៗខុសពីកាលសព្វដងដែលឥតហេតុ, ព្រះឥន្ទក៏រំពឹងភ្លាមរកហេតុប្លែកនេះ, លុះជ្រាបហើយ ក៏ស្ដេចយាងចុះ*

*ហើយកាលព្រះមុនីសម្ដែងសត្តបករណាភិធម្ម[៩៦] គង់ចាំវស្សាក្នុងទេវលោក ពួកសត្វចំនួនមួយម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី៣។*

*ព្រះពុទ្ធជាទេវតា ទ្រង់ប្រសើរជាងទេវតាអង្គនោះ ទ្រង់មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាព្រះខីណាស្រពប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង។ សាវកសមាគមក្នុងកាលនោះ មានភិក្ខុ៣ម៉ឺន ដែលកន្ទង់ឱឃៈ ផ្ដាច់បង់មច្ចុ។*

*សម័យនោះ តថាគត ជាក្សត្រឈ្មោះ**បញ្ញត:** បរិបូណ៌ដោយមិត្ត និង អាមាត្យ មានពល និងពាហនៈច្រើន។*

*តថាគត ទៅគាល់ព្រះសម្ពុទ្ធ ស្ដាប់ធម៌ដ៏ប្រសើរ ហើយនិមន្តព្រះសង្ឃ និងព្រះជិនស្រី ថ្វាយទានតាមសេចក្ដីប្រាថ្នា។*

*តថាគត បានថ្វាយវត្ថុ៤មុខ គឺសំពត់ចីនប្រទេស១ សំពត់សូត្រ១ សំពត់កម្ពល១ ស្បែកជើងមាស១ ចំពោះព្រះសាស្ដា និង សាវ័ក។*

*ព្រះមុនីនោះ ទ្រង់គង់នៅក្នុងកណ្ដាលសង្ឃ ទ្រង់ព្យាករតថាគតថា*

***មហាបុរសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្ទកប្បនេះ។***

***សត្វនេះ នឹងចេញពីនគរកបិលពស្ដុបុរីជាទីត្រេកអរ តាំងនូវព្យាយាមធ្វើទុក្ករកិរិយា។***

---

*ពីឋានត្រ័យត្រិង្សភ្លាមមកកាន់ឋានមនុស្សឆ្ពោះត្រង់ទីដែលព្រះអង្គត្រូវបំពេញករណីយកិច្ចនោះ; ឬជួនកាលទ្រង់មានព្រះបញ្ជាឲ្យវិស្សុកម្មទេវបុត្រ ចុះមកបំពេញកិច្ចជាតំណាងព្រះអង្គ...។*

*[៩៦] **សត្តប្បករណាភិធម្ម** ( ន. ) [ស័ត-ត័ប-ប៉ៈក:រ៉:--]  ( បា. )(< សត្ត "៧" + បករណ "គម្ពីរ" + អភិធម្ម) គម្ពីរព្រះអភិធម្មទាំង ៧ (ព. ពុ.) ។*

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា។

ព្រះជិនស្រីអង្គនោះ បានសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា រួចស្តេចសំដៅទៅឯពោធិមណ្ឌៈ តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។

លំដាប់នោះ មហាបុរសមានយសធំនឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស។

ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ក្សត្រអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម។

ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ។

ព្រះថេរីឈ្មោះខេមា១ ឧប្បលវណ្ណា១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា។

ឈើ ជាទីត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស។

ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ នឹងជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។

ព្រះគោតមមានយសនោះ មានព្រះជន្មាយុ១០០ឆ្នាំ។

*ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធរកបុគ្គលស្មើគ្មាន ស្វែងរកនូវគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា* ***មហាបុរសនេះជាពូជពន្ធុកនៃព្រះពុទ្ធ។***

*ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោឡើងទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖*

*"បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលអនាគតមិនខាន។*

*មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ បានយ៉ាងណា យើងទាំងអស់គ្នាបើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងអនាគតកាល ក៏យ៉ាងនោះដែរ"។*

*តថាគត ស្តាប់ព្រះពុទ្ធដីកា នៃព្រះសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាដោយក្រៃលែង បានខំអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមីទាំង១០។*

*តថាគត ប្រសើរជាងជន កាលស្វែងរកសព្វញ្ញុតញ្ញាណ បានឱ្យទានលះបង់រាជសម្បត្តិដ៏ធំ ហើយបួសក្នុងសម្នាក់ព្រះជិនស្រី។*

*មាននគរឈ្មោះសោភវតី ក្សត្រព្រះនាមសោភៈ ត្រកូលធំរបស់ព្រះពុទ្ធនៅក្នុងនគរនោះ។*

*ព្រាហ្មណ៍ឈ្មោះយញ្ញទត្ត ជាព្រះបិតា នាងឧត្តរាជាព្រះមាតារបស់ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ ជាសាស្តានោះ។*

**ពុទ្ធបណិធាន**

ព្រះសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងព្រះដំណាក់អស់៣ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន៣ គឺតុសិតប្រាសាទ១ សន្តុសិតប្រាសាទ១ សន្តុដ្ឋ-ប្រាសាទ១។

មាននារីមិនខ្វះពី១ម៉ឺន៦ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីព្រះនាមរុចិគត្តា ព្រះរាជបុត្រព្រះនាមសត្ថវាហៈ។

បុរសដ៏ឧត្តមឃើញនូវនិមិត្ត៤យ៉ាងហើយ ចេញទៅដោយយានដំរី បានប្រព្រឹត្តព្យាយាមអស់៦ខែ។

ព្រះកោនាគមនៈជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រឱ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន។

ព្រះពុទ្ធព្រះនាមកោនាគមនៈដ៏មានយស មានព្រះថេរៈឈ្មោះភិយ្យោសៈ១ ឧត្តរៈ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសោត្ថិជៈ ជាឧបដ្ឋាក។

ព្រះថេរីឈ្មោះសមុទ្ទា១ ឧត្តរា១ ជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងនៃព្រះដ៏មានព្រះភាគអង្គនោះ គេហៅថាឧទុម្ពរ-ព្រឹក្ស (ដើមល្វា)។

ឧបាសកឈ្មោះឧគ្គៈ១ សោមទេវៈ១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះសីវលា១ សាមា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះពុទ្ធនោះមានកម្ពស់៣០ហត្ថ ប្រដាប់ដោយរស្មីយ៉ាងនេះ ដូចជាមាសក្នុងមាត់នៃបាវ។

*ព្រះពុទ្ធមានព្រះជន្មាយុ៣ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គឋិតនៅកំណត់ត្រឹមនោះ ញុំាងប្រជុំជនជាច្រើនឱ្យឆ្លងចាកសង្សារ។*

*ព្រះពុទ្ធអង្គនោះ និងសាវ័ក លើកឡើងនូវធម្មចេតិយ ស្អិតស្អាងដោយសំពត់គឺធម៌ ធ្វើនូវកម្រងផ្កាគឺធម៌ ហើយបរិនិព្វាន។*

*ជនជាសាវ័ក របស់ព្រះពុទ្ធនោះ សំដែងនូវធម៌ដ៏មានសិរី ដល់នូវឫទ្ធិដ៏ធំទូលាយ របស់ទាំងអស់នេះវិនាសសូន្យទៅ ឱ! សង្ខារទាំងពួង ជារបស់ទទេទទេ តើ។*

*ព្រះសម្ពុទ្ធព្រះនាមកោនាគមនៈ បរិនិព្វានក្នុងបព្វតារាម ព្រះធាតុផ្សាយទៅក្នុងទីនោះៗ តាមចំណែក ។*

*ចប់កោនាគមនពុទ្ធវង្ស។*

## ២៧. កស្សបពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធកស្សបៈ*

*កាលខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមកោនាគមនៈមក មានព្រះសម្ពុទ្ធ ព្រះនាម**កស្សបៈ** ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់ធ្វើជាពន្លឺ។*

*ផ្ទះជាឫសនៃត្រកូលព្រះពុទ្ធ ទ្រង់លះបង់ហើយ ទ្រង់ឱ្យទាន គឺបាយ និងទឹក ជាច្រើនដល់យាចកទាំងឡាយ ហើយញ៉ាំងព្រះទ័យឱ្យពេញដល់សម្ពោធិញ្ញាណដ៏ឧត្តម ដូចជាគោឧសភៈ ទម្លាយនូវក្រោល។*

*កាលព្រះកស្សបៈជាលោកនាយក ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ពួកបរិស័ទចំនួន២ម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាដំបូង។*

*កាលព្រះសម្ពុទ្ធយាងទៅកាន់ចារិក ក្នុងទេវលោកអស់៤ខែ ពួកបរិស័ទមួយម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី២។*

*ព្រះសាស្តាធ្វើយមកបាដិហារ្យ និងវិកុព្វនឫទ្ធិ សំដែងនូវញាណធាតុ ពួកបរិស័ទ៥ពាន់កោដិ បានត្រាស់ដឹងជាគ្រាទី៣។*

*ព្រះជិនស្រី សំដែងធម៌ក្នុងសុធម្មទេវបុរី ជាទីរីករាយក្នុងទេវលោកនោះ ញ៉ាំងទេវតា៣ពាន់កោដិឱ្យត្រាស់ដឹង។*

*ក្នុងការសំដែងធម៌ដទៃទៀត ដល់ទេវតាមនុស្ស និងយក្ស ជនទាំងនោះ បានត្រាស់ដឹងរាប់មិនអស់។*

*ព្រះពុទ្ធ ជាទេវតាដ៏ប្រសើរនោះ មានសាវកសន្និបាត តែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រពមិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ហើយការប្រជុំក្នុងកាលនោះ មានភិក្ខុ២ម៉ឺនរូប ដែលមានភពកន្លងហើយ មានចិត្តនឹងធឹងដោយហិរិ និងសីល។*

*កាលនោះ តថាគត ជាមាណពឈ្មោះ**ជោតិបាល** ជាអ្នករៀនមន្តចេះចាំមន្ត ដល់នូវត្រើយនៃវេទទាំង៣។*

*តថាគត ដល់នូវបារមីក្នុងគម្ពីរលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងព្រះសទ្ធម្មផង ឈ្លាសវៃក្នុងផែនដី និងអាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នកមិនមានរោគ។*

*ឧបាសកឈ្មោះឃដិការ ជាឧបដ្ឋាក របស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង និព្វានក្នុងផលទី៣ ឃដិការនាំតថាគត ចូលទៅគាល់ព្រះជិនស្រីព្រះនាមកស្សបៈ តថាគតស្តាប់ធម៌ របស់ព្រះពុទ្ធនោះ ក៏បួសក្នុងសម្នាក់នៃព្រះអង្គ។*

*តថាគត មានព្យាយាមក្លៀវក្លា ឈ្លាសវៃ ក្នុងវត្តតូច និងវត្តធំ មិនមានសេចក្តីសាបសូន្យក្នុងសីល និងសមាធិ ណាមួយឡើយ ញ៉ាំងសាសនា នៃព្រះជិនស្រីឱ្យពេញបរិបូណ៌។*

*សាសនាព្រះសាស្តា មានអង្គ៩ដែលព្រះអង្គសំដែងហើយទាំងប៉ុន្មាន តថាគតបានរៀននូវធម៌ទាំងអស់នោះ រួចញ៉ាំងសាសនាព្រះជិនស្រីឱ្យរុងរឿង។*

*ព្រះពុទ្ធនោះ ឃើញហេតុជាអស្ចារ្យរបស់តថាគត ក៏ទ្រង់ព្យាករថា*

***ជោតិបាលមាណពនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធក្នុងភទ្ទកប្បនេះឯង។***

***សត្វនេះ នឹងចេញពីនគរកបិលពស្តុជាទីរីករាយ តម្កល់សេចក្តីព្យាយាមធ្វើទុក្ករកិរិយា។***

***សត្វនេះ នឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា។***

*សត្វនេះ សោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលសំដៅទៅរកគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ។*

*លំដាប់ពីនោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណទៀបគល់អស្សត្ថព្រឹក្ស។*

*ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម។*

*ព្រះថេរៈឈ្មោះកោលិតៈ១ ឧបតិស្សៈ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងបានជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទជាឧបដ្ឋាក នឹងបម្រើព្រះជិនស្រីអង្គនេះ។*

*ព្រះថេរីឈ្មោះនាងខេមា១ នាងឧប្បលវណ្ណា១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ។*

*ឈើ ជាទីត្រាស់ដឹងរបស់ព្រះដ៏មានជោគអង្គនោះ គេហៅថាអស្សត្ថ-ព្រឹក្ស។*

*ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ នឹងជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា។*

*ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ១០០ឆ្នាំ។*

*ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធរកបុគ្គលស្មើគ្មាន ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ។*

*ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោឡើង*

ទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា៖

"បើពួកយើងឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះក្នុងកាលជាអនាគតមិនខាន។

មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ"។

តថាគត បានស្តាប់ព្រះពុទ្ធដីការបស់ព្រះពុទ្ធអង្គនោះ រួចក៏ញុំាងចិត្តឱ្យជ្រះថ្លាក្រៃលែង បានខំអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមីទាំង១០។

តថាគត កាលបំពេញបារមីយ៉ាងនេះ តថាគត តែងអន្ទោលទៅ វៀរនូវមាយាទអាក្រក់ អំពើដែលបុគ្គលធ្វើដោយកម្រ តថាគតបានធ្វើហើយ ព្រោះហេតុពោធិញ្ញាណ។

នគរឈ្មោះពារាណសី ក្សត្រព្រះនាមកិកី ត្រកូលធំ របស់ព្រះសម្ពុទ្ធនៅក្នុងនគរនោះ។

ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រហ្មទត្តព្រាហ្មណ៍ជាព្រះបិតា ព្រះមាតាព្រះនាមធនវតី។

ព្រះអង្គ គង់គ្រប់គ្រងព្រះដំណាក់អស់២ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺហំសប្រាសាទ១ យសប្រាសាទ១ សិរីចន្ទប្រាសាទ១។

**ពុទ្ធបណិធាន**

នារី១៦ពាន់៣ជង់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ ព្រះនាមសុនន្ទា ព្រះរាជបុត្រព្រះនាមវិជិតសេន។

ព្រះពុទ្ធជាបុរសដ៏ឧត្តម ឃើញនូវនិមិត្តទាំង៤ ក៏បានចេញទៅដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាមអស់៧ ថ្ងៃ (បានត្រាស់ជាព្រះពុទ្ធ)។

ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់ឧត្តមជាងនរជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្រឱ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន។

ព្រះថេរៈឈ្មោះតិស្សៈ១ ភារទ្វាជៈ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសព្វមិត្ត ជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ស្វែងរកនូវគុណដ៏ធំ។

ព្រះថេរីឈ្មោះអនុលា១ ឧរុវេលា១ ជាអគ្គសាវិកា។

ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះដ៏មានជោគនោះ ហៅថានិគ្រោធព្រឹក្ស (ដើមជ្រៃ)។

ឧបាសកឈ្មោះមង្គលៈ១ ឃដិការៈ១ ជាអគ្គឧបដ្ឋាក។

ឧបាសិកាឈ្មោះវិជិតសេនា១ ភទ្រា១ ជាអគ្គឧបដ្ឋាយិកា។

ព្រះសម្ពុទ្ធនោះមានកម្ពស់២០ហត្ថ ដូចជាធ្នូតនៃផ្ទៃកបន្ទោរព្វដ៏អាកាស ឬដូចជាព្រះចន្ទ ដែលផ្កាយចោមរោមហើយ។

ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ២ម៉ឺនឆ្នាំ ព្រះអង្គឋិតនៅត្រឹមនោះ ទ្រង់ញុំាងប្រជុំជនដ៏ច្រើនឱ្យឆ្លងចាកសង្សារ។

ព្រះអង្គនិម្មិតស្រះគឺព្រះសទ្ធម្ម ទ្រង់ប្រទានគ្រឿងលាបគឺសីល ទ្រង់ញុំាងសត្វឱ្យស្លៀកពាក់គឺព្រះធម៌ ទ្រង់ចែកកម្រងផ្កាគឺព្រះធម៌ ទ្រង់តម្កល់ទុកកញ្ចក់មិនមានមន្ទិលគឺព្រះសទ្ធម្ម ចំពោះពួកមហាជនថា ពួកជនណាមួយកាលប្រាថ្នានិព្វាន ចូររមិលមើលគ្រឿងប្រដាប់របស់តថាគតចុះ។

*ព្រះសម្ពុទ្ធនោះឱ្យអាវគឺសីល ឱ្យស្បែកក្រោះគឺឈាន ឱ្យដណ្ដប់ស្បែកគឺព្រះធម៌ ឱ្យកាំបិតស្នៀតដ៏ឧត្តមគឺព្យាយាម ឱ្យខែលគឺសតិ ឱ្យកាំបិតគឺញាណដ៏មុត ឱ្យព្រះខ័នដ៏ប្រសើរគឺធម៌ ឱ្យប្រដាប់សម្រាប់ញាំញីសត្រូវគឺសីល ឱ្យគ្រឿងស្អិតស្អាងគឺវិជ្ជា៣ ឱ្យគ្រឿងពាក់ត្រចៀកគឺផល៤ ឱ្យគ្រឿងអាករណៈគឺអភិញ្ញា៦ ឱ្យគ្រឿងប្រដាប់ជាវិការៈនៃផ្កាគឺព្រះសទ្ធម្ម។*

*ព្រះសម្ពុទ្ធអង្គនោះ និងសាវ័ក ឱ្យឆត្រគឺព្រះសទ្ធម្ម ជាគ្រឿងឃាត់នូវបាប និម្មិតនូវផ្កាមិនមានភ័យ ហើយទើបបរិនិព្វាន។*

*ព្រះសម្មាសម្ពុទ្ធអង្គនោះ ប្រមាណមិនបាន បុគ្គលគ្របសង្កត់បានដោយកម្រ ព្រះធម្មរតនៈនោះ ដែលព្រះអង្គសម្ដែងហើយដោយប្រពៃ ជាធម៌គួរហៅអ្នកផងឱ្យចូលមកមើលបាន។*

*ព្រះសង្ឃរតនៈនោះ លោកប្រតិបត្តិហើយដោយប្រពៃ ជាសង្ឃដ៏ប្រសើររបស់ទាំងអស់នេះវិនាសសោះសូន្យទៅ ឱ!សង្ខារទាំងពួង ជារបស់ទទេទទេតើ។*

*ព្រះជិនស្រីជាសាស្ដា ព្រះនាមមហាកស្សបៈ ទ្រង់បរិនិព្វានក្នុងសេតព្យារាម ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះមានកម្ពស់១យោជន៍ ក្នុងទីនោះ ។*

**ចប់កស្សបពុទ្ធវង្ស។**

<u>**កំណត់ចំណាំ:**</u> *ក្នុងវាង៤អសង្ខេយ្យ ១សែនកប្បនេះ ព្រះពោធិសត្វនៃយើង បានទទួលពុទ្ធព្យាករណ៍អំពីព្រះពុទ្ធ២៤ព្រះអង្គ មានព្រះសម្មាសម្ពុទ្ធទីបង្ករជាដើម មានព្រះសម្មាសម្ពុទ្ធកស្សបជាទីបំផុត។*

# មហាបដិញ្ញា៨ បទ

## *ការប្ដេជ្ញាធំរបស់ព្រះពោធិសត្វ*

*១.តិណ្ណោ តារយេយ្យំ យើងឆ្លងផុតហើយ នឹងឱ្យអ្នកដទៃឆ្លងផុតផង*

*២.មុត្តោ មោចេយ្យំ យើងរួចផុតហើយ នឹងឱ្យអ្នកដទៃរួចផុតផង*

*៣.ពុទ្ធោ ពោធេយ្យំ យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង*

*៤.សុទ្ធោ សោធេយ្យំយើងបរិសុទ្ធហើយ នឹងឱ្យអ្នកដទៃបរិសុទ្ធផង*

*៥.ទន្តោ ទមេយ្យំ យើងទូន្មានបានហើយ នឹងឱ្យអ្នកដទៃទូន្មានបានផង*

*៦.សន្តោ សមេយ្យំ យើងស្ងប់ហើយ នឹងឱ្យអ្នកដទៃស្ងប់ផង*

*៧.អស្សត្ថោ អស្សាសេយ្យំ យើងធូរស្រាលហើយ នឹងឱ្យអ្នកដទៃធូរស្រាលផង*

*៨.បរិនិព្វុតោ បរិនិព្វាបេយ្យំ យើងបរិនិព្វានហើយ នឹងឱ្យអ្នកដទៃបរិនិព្វានផង។*

*__រួបរួមចាកឯកសារនេះ គឺ__*

*-សុត្តន្តបិដកអដ្ឋកថា»ខុទ្ទកនិកាយអដ្ឋកថា»ពុទ្ធវំស-អដ្ឋកថា»រតនចង្កមនកណ្ឌវណ្ណនា*

*-សុត្តន្តបិដកអដ្ឋកថា»ខុទ្ទកនិកាយអដ្ឋកថា»ចរិយាបិដក-អដ្ឋកថា» យុធញ្ជយវគ្គ*

*-សុត្តន្តបិដកដីកា»ទីឃនិកាយដីកា»សីលក្ខន្ធវគ្គ-ដីកា»ព្រហ្មជាលសុត្តវណ្ណនា*

*-សុត្តន្តបិដកដីកា»ទីឃនិកាយដីកា»សីលក្ខន្ធវគ្គ-អភិនវដីកា១»ព្រហ្មជាលសុត្ត*

*-សុត្តន្តបិដកអដ្ឋកថា»ខុទ្ទកនិកាយអដ្ឋកថា»ឧទាន-អដ្ឋកថា»មុចលិន្ទវគ្គ*

*-សុត្តន្តបិដកអដ្ឋកថា»ខុទ្ទកនិកាយអដ្ឋកថា»ឥតិវុត្តក-អដ្ឋកថា»ទុកនិបាត*

# ជំពូកទី៦
# គោតមពុទ្ធប្បាទ និង យសោធរាថេរី

## និទានកថា

## ព្រះសម្មាសម្ពុទ្ធសមណគោតម

## បុព្វចរិយារបស់ព្រះនាងពិម្ពាយសោធរា កន្សែងសារពេជ្ឈ

## បុព្វចរិយារបស់ភិក្ខុនី១ម៉ឺនរូប
## ដែលមានព្រះនាងយសោធរាជាប្រមុខ

## បុព្វចរិយារបស់ភិក្ខុនី១ម៉ឺន៨ពាន់រូប
## ដែលមានព្រះនាងសោធរាជាប្រមុខ

### ធម្មរុចិត្ថេរាបទាន

## ២៨. គោតមពុទ្ធប្បវត្តិ

### *ការឧប្បត្តិឡើងនៃព្រះពុទ្ធគោតម*

*ក្នុងកាលឥឡូវនេះ តថាគត ជាព្រះសម្ពុទ្ធព្រះនាម**គោតម** ចម្រើនក្នុងត្រកូលសក្យៈ តាំងព្យាយាមដល់សម្ពោធិញ្ញាណដ៏ឧត្តម។*

*តថាគត មានចិត្តស្ងប់រម្ងាប់ ត្រូវព្រហ្មអារាធនាហើយ ក៏ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ពួកបរិស័ទ១៨កោដិ បានត្រាស់ដឹងគ្រាដំបូង។*

*លំដាប់តទៅ កាលតថាគត សម្ដែងធម៌ដទៃទៀត ក្នុងការប្រជុំនៃពួកមនុស្ស និងទេវតា ការត្រាស់ដឹងគ្រាទី២ គេមិនគប្បីពោល ដោយការរាប់បានឡើយ។*

*ឥឡូវនេះ តថាគត បានទូន្មានកូនរបស់តថាគត ក្នុងទីនេះការត្រាស់ដឹងគ្រាទី៣ បុគ្គលមិនគប្បីពោល ដោយការរាប់បានឡើយ។*

*ការប្រជុំសាវ័ករបស់តថាគត អ្នកស្វែងរកគុណដ៏ប្រសើរមានតែមួយដង គឺប្រជុំពួកភិក្ខុ១,២៥០ របស់តថាគត។*

*តថាគត រុងរឿង មិនមានមន្ទិល ទៅក្នុងកណ្ដាលនៃសង្ឃ ឱ្យសេចក្ដីប្រាថ្នាទាំងពួង គឺបុគ្គលប្រាថ្នាហើយ ដូចជាកែវមណី ដែលអាចឱ្យសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង។*

*តថាគត ប្រកាសសច្ចៈទាំង៤ ដើម្បីអនុគ្រោះដល់ពួកសត្វដែលប្រាថ្នានូវផល លះបង់នូវតណ្ហៈក្នុងភព ហើយមានពួកសត្វ២សែន បានត្រាស់ដឹងធម៌ ការត្រាស់ដឹងរបស់បុគ្គលមួយនាក់ ឬ២ នាក់ គេមិនអាចរាប់បានឡើយ។*

*សម័យនេះ សាសនានៃតថាគតជាសក្យមុនី បានផ្សាយទៅជាសាសនា*

ដែលទេវតា និងមនុស្ស ដ៏ច្រើន ជាសាសនាស្តុកស្តម្ភ មាំមួន រីកសាយភាយ តថាគតបានពិសោធហើយ ដោយប្រពៃ។

ពួកភិក្ខុជាច្រើនរយ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំគ្រប់រូប តែងតែចោមរោមតថាគតសព្វៗកាល។

ក្នុងកាលឥឡូវនេះឯង ពួកភិក្ខុណាលះបង់ភព ជារបស់មនុស្ស តែភិក្ខុទាំងនោះ មិនទាន់បានអរហត្តផល នៅជាសេក្ខបុគ្គល ពួកភិក្ខុទាំងនោះ ត្រូវអ្នកប្រាជ្ញតិះដៀលបាន។

នរជនទាំងឡាយ កាលសរសើរផ្លូវដ៏ប្រសើរ គឺអដ្ឋង្គិកមគ្គ ត្រេកអរក្នុងធម៌សព្វកាល មានសេចក្តីរុងរឿង អន្ទោលទៅក្នុងសង្សារ នឹងបានត្រាស់ដឹង។

នគររបស់តថាគត ឈ្មោះកបិលពស្តុ ស្តេចជាព្រះបិតាព្រះនាមសុទ្ធោ-ទនៈ ព្រះមាតាបង្កើតរបស់តថាគត ព្រះនាមមាយាទេវី។

តថាគត នៅគ្រប់គ្រងព្រះរាជដំណាក់អស់២៩ឆ្នាំ មានប្រាសាទដ៏ប្រសើរ៣ គឺសុចន្ទប្រាសាទ១ កោកនុទប្រាសាទ១ កោញ្ចប្រាសាទ១។

មាននារី៤ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ នារីជាអគ្គមហេសីព្រះនាមយសោធរា ព្រះរាជបុត្រព្រះនាមរាហុល។

តថាគត ឃើញនិមិត្ត៤យ៉ាងហើយ ក៏ចេញទៅដោយយានសេះ ប្រព្រឹត្តព្យាយាមធ្វើទុក្ករកិរិយាអស់៦វស្សា។

តថាគត ជាព្រះជិនស្រី បានញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅក្នុងព្រៃឥសិប-តនៈ ទៀបក្រុងពារាណសី តថាគតជាគោតមសម្ពុទ្ធ ជាទីពឹងនៃសត្វទាំងពួង។

ភិក្ខុ២រូប ឈ្មោះកោលិតៈ១ ឧបតិស្សៈ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះអានន្ទ ជាឧបដ្ឋាក អ្នកបម្រើផ្ទាល់ របស់តថាគត។

**ពុទ្ធបណិធាន**

*ភិក្ខុនីឈ្មោះខេមា១ ឧប្បលវណ្ណា១ ជាអគ្គសាវិកា។*

*ឧបាសកឈ្មោះចិត្តៈ១ ហត្ថាឡវកៈ១ ជាអគ្គឧបដ្ឋាក។*

*ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ ជាអគ្គឧបដ្ឋាយិកា។*

*តថាគត បានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ទៀបគល់អស្សត្ថព្រឹក្ស។*

*តថាគត មានរស្មីមួយព្យាមសព្វៗកាល មានកម្ពស់១៦ហត្ថ។*

*ក្នុងកាលឥឡូវនេះ តថាគតមានអាយុតិច បានតែ១០០ ឆ្នាំ។*

*តថាគត កាលឋិតនៅអស់កាលនោះ បានញុំាងប្រជុំជនដ៏ច្រើនឱ្យឆ្លងចាកសង្សារ ហើយតម្កល់ទុកគប់ភ្លើងគឺធម៌ ដើម្បីញុំាងជនខាងក្រោយឱ្យបានត្រាស់ដឹងផង។*

*មិនយូរប៉ុន្មានទេ តថាគតព្រមទាំងសង្ឃជាសាវ័ក នឹងបរិនិព្វានក្នុងទីនេះ ដូចជាភ្លើងរលត់ព្រោះអស់អាហារ គឺឧស។*

*អគ្គសាវ័កទាំងគូនេះឯង មានតេជះថ្លឹងពុំបានផង មានយស និងកម្លាំងឫទ្ធិផង តថាគត មានរាងកាយទ្រទ្រង់នូវគុណ វិចិត្រដោយលក្ខណៈដ៏ប្រសើរ៣២ប្រការ។*

*រស្មី៦ពណ៌ ភ្លឺទៅក្នុងទិសទាំង១០ ដូចព្រះអាទិត្យ របស់ទាំងអស់នេះនឹងវិនាសសូន្យទៅ ឱ! សង្ខារទាំងពួងជារបស់ទទេទេតើ។*

***ចប់គោតមពុទ្ធវង្ស។***

## ពុទ្ធបកិណ្ណកកណ្ឌ

### គាថាសម្ដែងអំពីព្រះសម្មាសម្ពុទ្ធ២៩ អង្គ

អបរិមេយ្យិតោ កប្បេ, ចតុរោ អាសុំ វិនាយកា;
តណ្ហង្ករោ មេធង្ករោ, អថោបិ សរណង្ករោ;
ទីបង្ករោ ច សម្ពុទ្ធោ, ឯកកប្បម្ហិ តេ ជិនា។

*ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ មានព្រះពុទ្ធជានាយក៤ព្រះអង្គ គឺព្រះសម្ពុទ្ធព្រះនាមតណ្ហង្ករ១ មេធង្ករ១ សរណង្ករ១ ទីបង្ករ១ ព្រះជិនស្រី ទាំងនោះ ត្រាស់ក្នុងកប្បជាមួយគ្នា។*

ទីបង្ករស្ស អបរេន, កោណ្ឌញ្ញោ នាម នាយកោ;
ឯកោវ ឯកកប្បម្ហិ, តារេសិ ជនតំ ពហុំ។

*ខាងក្រោយអំពីព្រះពុទ្ធទីបង្ករមក ព្រះពុទ្ធជានាយកព្រះនាមកោណ្ឌញ្ញៈ បានត្រាស់តែមួយព្រះអង្គក្នុងកប្បមួយ ញ៉ាំងប្រជុំជនជាច្រើនឱ្យឆ្លងចាកសង្សារ។*

ទីបង្ករស្ស ភគវតោ, កោណ្ឌញ្ញស្ស ច សត្ថុនោ;
ឯតេសំ អន្តរា កប្បា, គណនាតោ អសង្ខិយា។

*កប្បជាចន្លោះ នៃព្រះពុទ្ធ២ព្រះអង្គនុ៎ះ គឺព្រះពុទ្ធទីបង្ករមានព្រះភាគ និងព្រះសាស្ដាព្រះនាមកោណ្ឌញ្ញៈ **ជាកប្បគេមិនអាចរាប់បានឡើយ។***

កោណ្ឌញ្ញស្ស អបរេន, មង្គលោ នាម នាយកោ;
តេសម្បិ អន្តរា កប្បា, គណនាតោ អសង្ខិយា។

*ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមកោណ្ឌញ្ញៈមក មានព្រះពុទ្ធជានាយក ព្រះនាមមង្គលៈទ្រង់ត្រាស់ឡើង **កប្បជាចន្លោះនៃព្រះពុទ្ធទាំង២ ព្រះអង្គនោះ បុគ្គលមិនអាចរាប់បានឡើយ។***

**ពុទ្ធបណិធាន**

មង្គលោ ច សុមនោ ច, រេវតោ សោភិតោ មុនិ;

តេបិ ពុទ្ធា ឯកកប្បេ, ចក្ខុមន្តោ បភង្ករា។

*ព្រះពុទ្ធព្រះនាមមង្គលៈ១ ព្រះសុមនៈ១ ព្រះរេវតៈ១ និងព្រះមុនី ព្រះនាមសោភិតៈ១ ព្រះសម្ពុទ្ធទាំងនោះ មានចក្ខុធ្វើនូវពន្លឺ បានត្រាស់ឡើង ក្នុងកប្បជាមួយគ្នា។*

សោភិតស្ស អបរេន, អនោមទស្សី មហាយសោ;

តេសម្បិ អន្តរា កប្បា, គណនាតោ អសង្ខិយា។

*ខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសោភិតៈមក មានព្រះពុទ្ធ ព្រះនាមអនោមទស្សីជាមហាមុនី ត្រាស់ឡើងក្នុងលោក* ***កប្បជាចន្លោះនៃព្រះពុទ្ធទាំង២អង្គនោះ គេមិនអាចរាប់បានឡើយ។***

អនោមទស្សី បទុមោ, នារទោ ចាបិ នាយកោ;

តេបិ ពុទ្ធា ឯកកប្បេ, តមន្តការកា មុនី។

*ព្រះនាយកព្រះនាមអនោមទស្សី១ ព្រះនាមបទុមៈ១ ព្រះនាមនារទៈ១ ព្រះពុទ្ធជាមហាមុនីទាំងនោះ ទ្រង់ធ្វើនូវទីបំផុតនៃងងឹត ត្រាស់ឡើងក្នុងកប្បជាមួយគ្នា ។*

នារទស្ស អបរេន, បទុមុត្តរោ នាម នាយកោ;

ឯកកប្បម្ហិ ឧប្បន្នោ, តារេសិ ជនតំ ពហុំ។

*ខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះនាយក ព្រះនាមបទុមុត្តរៈកើតឡើងក្នុងកប្បមួយ ញុំាងប្រជុំជនជាច្រើនឱ្យឆ្លងចាកសង្សារ។*

នារទស្ស ភគវតោ, បទុមុត្តរស្ស សត្ថុនោ;

តេសម្បិ អន្តរា កប្បា, គណនាតោ អសង្ខិយា។

*កប្បជាចន្លោះ នៃព្រះពុទ្ធទាំង២ព្រះអង្គនោះ គឺព្រះមានជោគ ព្រះនាមនារទៈ និងព្រះសាស្តាព្រះនាមបទុមុត្តរៈ* **គេមិនអាចរាប់បានឡើយ។**

កប្បសតសហស្សម្ហិ, ឯកោ អាសិ មហាមុនិ;
បទុមុត្តរោ លោកវិទូ, អាហុតីនំ បដិគ្គហោ។

*ក្នុងកប្បទីមួយសែន មានតែព្រះមហាមុនី១ ព្រះអង្គព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវត្រ័យលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ដែលគេនាំមកបូជា។*

តឹសកប្បសហស្សម្ហិ, ទុវេ អាសុំ វិនាយកា;
សុមេធោ ច សុជាតោ ច, ឱរតោ បទុមុត្តរា។

*ក្នុងកប្បទី៣ម៉ឺន ខាងអាយព្រះពុទ្ធបទុមុត្តរៈមក មានព្រះនាយក២ព្រះអង្គ ព្រះនាមសុមេធៈ១ សុជាតៈ១ ត្រាស់ឡើងក្នុងលោក។*

អដ្ឋារសេ កប្បសតេ, តយោ អាសុំ វិនាយកា;
បិយទស្សី អត្ថទស្សី, ធម្មទស្សី ច នាយកា។

*ក្នុងកប្បទី១ពាន់៨រយ ខាងអាយព្រះពុទ្ធព្រះនាមសុជាតៈមក មានព្រះនាយក៣អង្គ ព្រះនាមបិយទស្សី១ អត្ថទស្សី១ ព្រះនាយកធម្មទស្សី១ ត្រាស់ដឹងឡើងក្នុងលោក។*

ឱរតោ ច សុជាតស្ស, សម្ពុទ្ធា ទ្វិបទុត្តមា;
ឯកកប្បម្ហិ តេ ពុទ្ធា, លោកេ អប្បដិបុគ្គលា។

*ព្រះសម្ពុទ្ធទាំងនោះ ឧត្តមជាងសត្វជើង២ ជាព្រះសម្ពុទ្ធរកបុគ្គលប្រៀបផ្ទឹមគ្មានក្នុងលោក បានត្រាស់ដឹងក្នុងកប្បជាមួយគ្នា។*

ចតុន្នវុតិតោ កប្បេ, ឯកោ អាសិ មហាមុនិ;

សិទ្ធត្ថោ សោ លោកវិទូ, សព្វកត្ថោ អនុត្តរោ។

*ក្នុងកប្បទី៩៤អំពីកប្បនេះ មានព្រះមហាមុនីព្រះនាមសិទ្ធត្ថៈតែ១អង្គ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ជាពេទ្យដ៏ប្រសើរ បានត្រាស់ឡើងក្នុងលោក។*

ទ្វេនវុតេ ឥតោ កប្បេ, ទុវេ អាសុំ វិនាយកា;

តិស្សោ បុស្សោ ច សម្ពុទ្ធា, អសមា អប្បដិបុគ្គលា។

*ក្នុងកប្បទី៩២អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធជានាយក២ព្រះអង្គ ព្រះនាមតិស្សៈ១ បុស្សៈ១ រកបុគ្គលស្មើគ្មាន រកបុគ្គលប្រៀបផ្ទឹមគ្មាន បានត្រាស់ឡើងក្នុងលោក ។*

ឯកនវុតិតោ កប្បេ, វិបស្សី នាម នាយកោ;

សោបិ ពុទ្ធោ ការុណិកោ, សត្តេ មោចេសិ ពន្ធនា។

*ក្នុងកប្បទី៩១ អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាលោកនាយក ព្រះអង្គប្រកបដោយសេចក្តីករុណា ទ្រង់ដោះសត្វទាំងឡាយឱ្យរួចចាកចំណង បានត្រាស់ឡើងក្នុងលោក។*

ឯកតឹសេ ឥតោ កប្បេ, ទុវេ អាសុំ វិនាយកា;

សិខី ច វេស្សភូ ចេវ, អសមា អប្បដិបុគ្គលា។

*ក្នុងកប្បទី៣១អំពីភទ្ទកប្បនេះ ព្រះនាយក២ព្រះអង្គព្រះនាមសិខី១ វេស្សភូ១ រកបុគ្គលស្មើគ្មាន រកបុគ្គលផ្ទឹមគ្មាន បានត្រាស់ឡើងក្នុងលោក។*

ឥមម្ហិ ភទ្ទកេ កប្បេ, តយោ អាសុំ វិនាយកា;

កកុសន្ធោ កោណាគមនោ, កស្សបោ ចាបិ នាយកោ។

*ក្នុងភទ្ទកប្បនេះ ព្រះនាយក៣ព្រះអង្គ ព្រះនាមកកុសន្ធៈ១ កោណាគមនៈ១ និងព្រះនាយក ព្រះនាមកស្សបៈ១ បានត្រាស់ឡើងក្នុងលោក។*

អហាមេតរហិ សម្ពុទ្ធោ, មេត្តេយ្យោ ចាបិ ហេស្សតិ;
ឯតេបិមេ បញ្ច ពុទ្ធា, ធីរា លោកានុកម្បកា។

*ក្នុងកាលឥឡូវនេះ មានតថាគតនេះជាព្រះសម្ពុទ្ធ ទៅក្នុងអនាគតកាល និងមានព្រះសម្ពុទ្ធ ព្រះនាមមេត្តេយ្យៈ ព្រះសម្ពុទ្ធទាំង៥ អង្គនេះ ជាអ្នកប្រាជ្ញ អនុគ្រោះស្រង់សត្វលោក។*

ឯតេសំ ធម្មរាជូនំ, អញ្ញេសំនេកកោដិនំ;
អាចិក្ខិត្វាន តំ មគ្គំ, និព្វុតា តេ សសាវកា។

*ព្រះសម្ពុទ្ធអង្គនោះ និងសាវ័ក លុះប្រាប់ផ្លូវរបស់ព្រះពុទ្ធ ជាធម្មរាជទាំងនុ៎ះ ដល់ពួកសត្វដទៃ ជាច្រើនកោដិហើយ ក៏បរិនិព្វាន ។*

ពុទ្ធបកិណ្ណកកណ្ឌំ និដ្ឋិតំ។

*ចប់ពុទ្ធបកិណ្ណកកណ្ឌ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស ពុទ្ធបកិណ្ណកកណ្ឌ បិដកលេខ ៧៧ ទំព័រ ២៣៣។)*

## ពុទ្ធបកិណ្ណកកថាវណ្ណនា

*គាថាទាំងឡាយ១៨មានពាក្យថា* អបរិមេយ្យិតោ កប្បេ, ចតុរោ អាសុំ វិនាយកា *ដូច្នេះជាដើម អ្នកសិក្សាទាំងឡាយ គប្បីជ្រាបថាជា***និគមគាថា** *ជាពាក្យបន្ថែម ដើម្បីសង្ខេបសេចក្តី ដែលព្រះសង្គីតិកាចារ្យទាំងឡាយតាំងទុកហើយ គាថាទាំងឡាយ ដ៏សេសប្រាកដច្បាស់ក្នុងទីទាំងពួង។*

*(មធុរត្ថវិលាសិនី ពុទ្ធវំសអដ្ឋកថា)*

## គាថាសម្តែងអំពីចំនួនព្រះសម្មាសម្ពុទ្ធ ដែលព្រះពោធិសត្វបញ្ញាធិក, សទ្ធាធិក និង វីរិយាធិក បានជួបក្នុងរយៈពេលនៃការបំពេញបារមី

### ១-ព្រះពោធិសត្វជាបញ្ញាធិកបានជួបព្រះពុទ្ធ ចំនួន ៥សែន ១ម៉ឺន ២ពាន់ ២៧អង្គ

ពុទ្ធា អឍុជាមរិយា សុសង្ខេយ្យេ,
ពុទ្ធា អឍិជាសុហាលា ជិសង្ខេយ្យេ;
ពុទ្ធា រិយោ យេ មកុ លក្ខកប្បកោ,
វន្ទាមិ តេ សុរនរកោមេ សមេ ។

*ប្រែលោតប្រយោគ៖*

*ពុទ្ធា រីព្រះពុទ្ធទាំងឡាយ អឍុជាមរិយា ១សែន ២ម៉ឺន ៥ពាន់អង្គ ឧប្បជ្ជន្តិ កើតឡើង សុសង្ខេយ្យេ ក្នុង៧អសង្ខេយ្យ,*

*ពុទ្ធា រីព្រះពុទ្ធទាំងឡាយ អឍិជាសុហាលា ៣សែន ៨ម៉ឺន៧ពាន់អង្គ ឧប្បជ្ជន្តិ កើតឡើង ជិសង្ខេយ្យេ ក្នុង៩អសង្ខេយ្យ,*

*ពុទ្ធា រីព្រះពុទ្ធទាំងឡាយ រិយោ ១២អង្គ ឧប្បជ្ជន្តិ កើតឡើង សយេង្ខេយ្យេ ក្នុង៤អសង្ខេយ្យ,*

*ពុទ្ធា រីព្រះពុទ្ធទាំងឡាយ មកុ ១៥អង្គ ឧប្បជ្ជន្តិ កើតឡើង លក្ខកប្បកោ ក្នុងមួយសែនកប្ប,*

*អហំ រីខ្ញុំ វន្ទាមិ សូមថ្វាយបង្គំ តេ ពុទ្ធេ នូវព្រះពុទ្ធទាំងឡាយនោះ សមេ ដ៏ស្ងប់ហើយសុរនរកោមេ ៥សែន ១ម៉ឺន ២ពាន់ ២៧អង្គ។*

***ប្រែយកសេចក្តី៖***

*ព្រះពុទ្ធទាំងឡាយ ១សែន ២ម៉ឺន ៥ពាន់អង្គ កើតឡើងក្នុង៧ អសង្ខេយ្យ,*

*ព្រះពុទ្ធទាំងឡាយ ៣សែន ៨ម៉ឺន ៧ពាន់អង្គ កើតឡើងក្នុង៩ អសង្ខេយ្យ,*

*ព្រះពុទ្ធទាំងឡាយ ១២អង្គ កើតឡើងក្នុង៤អសង្ខេយ្យ,*

*ព្រះពុទ្ធទាំងឡាយ ១៥អង្គ កើតឡើងក្នុងមួយសែនកប្ប,*

*ខ្ញុំសូមថ្វាយបង្គំ នូវព្រះពុទ្ធទាំងឡាយនោះ ដ៏ស្ងប់ហើយ ៥សែន ១ម៉ឺន ២ពាន់ ២៧អង្គ។*

## ២-ព្រះពោធិសត្វជាសទ្ធាធិកបានជួបព្រះពុទ្ធ ចំនួន ១ លាន ២ ម៉ឺន ៤ ពាន់ ៥៥ អង្គ

ពុទ្ធា អនុនាមកា គយាយំ,
ពុទ្ធា អធិនាយសោសា ជយម្ហិ;
ពុទ្ធា វរ ជេ ឆលិ លក្ខកប្បកេ,
វន្ទាមិ តេ យនទុករនេកោ ។

**ប្រែលោតប្រយោគៈ**

ពុទ្ធា រីព្រះពុទ្ធទាំងឡាយ អនុនាមកា២ សែន ៥ម៉ឺនអង្គ ឧប្បជ្ជន្តិ កើតឡើង គយាយំ ក្នុង ១៤ អសង្ខេយ្យ,

ពុទ្ធា រីព្រះពុទ្ធទាំងឡាយ អធីនាយសោសា៧ សែន ៧ម៉ឺន ៤ ពាន់អង្គ ឧប្បជ្ជន្តិ កើតឡើង ជយម្ហិ ក្នុង ១៨ អសង្ខេយ្យ,

ពុទ្ធា រីព្រះពុទ្ធទាំងឡាយ វរ ២៥ អង្គ ឧប្បជ្ជន្តិ កើតឡើង ជេសង្ខេយ្យេ ក្នុង ៨ អសង្ខេយ្យ,

**ពុទ្ធបណិធាន**

ពុទ្ធា វីព្រះពុទ្ធទាំងឡាយ ឆលិ៣០ អង្គ ឧប្បជ្ជន្តិ កើតឡើង លក្ខកប្បេ ក្នុងមួយសែនកប្ប,

អហំ វីខ្ញុំ វន្ទាមិ សូមថ្វាយបង្គំ តេ ពុទ្ធេ នូវព្រះពុទ្ធទាំងឡាយនោះ ឃមឆុករនេកោ១ លាន ២ ម៉ឺន ៤ពាន់ ៥៥ អង្គ។

**ប្រែយកសេចក្តី៖**

ព្រះពុទ្ធទាំងឡាយ ២ សែន ៥ ម៉ឺនអង្គ កើតឡើង ក្នុង ១៤ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ៧ សែន ៧ ម៉ឺន ៤ ពាន់អង្គ  កើតឡើង ក្នុង ១៨ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ២៥ អង្គ កើតឡើង ក្នុង ៨ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ៣០ អង្គ កើតឡើង ក្នុងមួយសែនកប្ប,

ខ្ញុំសូមថ្វាយបង្គំនូវព្រះពុទ្ធទាំងឡាយនោះ ១ លាន ២ ម៉ឺន ៤ ពាន់ ៥៥ អង្គ ។

**៣-ព្រះពោធិសត្វជាវីរិយាធិកបានជួបព្រះពុទ្ធ**

**ចំនួន ២ លាន ៤ ម៉ឺន ៨ ពាន់ ១០៨ អង្គ**

ពុទ្ធា អធុធាធុធិមា ជរាយំ,
ពុទ្ធា អធិធាជវណាបិ ចាគេ;
តគោសុ ជរា ឆចុ លក្ខកប្បកោ,
អហំ វន្ទាមិ តេ ជញ្ញចាធាភិធារោ ។

**ប្រែលោតប្រយោគៈ**

ពុទ្ធា វីព្រះពុទ្ធទាំងឡាយ អធុធាធុធិមា៥ សែនអង្គ ឧប្បជ្ជន្តិ កើតឡើង ជរាយំ ក្នុង ២៨ អសង្ខេយ្យ,

ពុទ្ធា វីព្រះពុទ្ធទាំងឡាយ អឌ្ឍឆដ្ឋលក្ខានិ ១លាន ៥សែន ៤ ម៉ឺន ៨ ពាន់អង្គ ឧប្បជ្ជន្តិ កើតឡើង ចាគេ ក្នុង ៣៦ អសង្ខេយ្យ,

ពុទ្ធា វីព្រះពុទ្ធទាំងឡាយ ជរា ៤៨ អង្គ ឧប្បជ្ជន្តិ កើតឡើង តក្កោសុ ក្នុង ១៦ អសង្ខេយ្យ,

ពុទ្ធា វីព្រះពុទ្ធទាំងឡាយ ឆចុ៦០ អង្គ ឧប្បជ្ជន្តិ កើតឡើង លក្ខកប្បេ ក្នុងមួយសែនកប្ប,

អហំ វីខ្ញុំ វន្ទាមិ សូមថ្វាយបង្គំ តេ ពុទ្ធេ នូវព្រះពុទ្ធទាំងឡាយនោះ ជញ្ញាចាទាភិឆារេ ២ លាន ៤ ម៉ឺន ៨ ពាន់ ១០៨ អង្គ ។

**ប្រែយកសេចក្ដីៈ**

ព្រះពុទ្ធទាំងឡាយ ៥ សែនអង្គ កើតឡើង ក្នុង ២៨ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ១ លាន ៥សែន ៤ ម៉ឺន ៨ ពាន់អង្គ កើតឡើង ក្នុង ៣៦ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ៤៨ អង្គ កើតឡើង ក្នុង ១៦ អសង្ខេយ្យ,

ព្រះពុទ្ធទាំងឡាយ ៦០ អង្គ កើតឡើង ក្នុងមួយសែនកប្ប,

ខ្ញុំសូមថ្វាយបង្គំនូវព្រះពុទ្ធទាំងឡាយនោះ ២ លាន ៤ ម៉ឺន ៨ ពាន់ ១០៨ អង្គ។

(ចាកគម្ពីរកំពូលបិដក ប្រែដោយលោកគ្រូ ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន)

# សម្ពុទ្ធគាថា
# ធម៌សម្ពុទ្ធេ គឺជាធម៌សម្ដែងចំនួនព្រះពុទ្ធ
# ដែលព្រះពោធិសត្វបញ្ញាធិក, សទ្ធាធិក និង វីរិយាធិកបានជួប

## ១-ចំនួនព្រះពុទ្ធដែលព្រះពោធិសត្វបញ្ញាធិកបានជួប

សម្ពុទ្ធេ អដ្ឋវីសញ្ច, ទ្វាទសញ្ច សហស្សកេ;
បញ្ចសតសហស្សានិ, នមាមិ សិរសា អហំ ។

**ប្រែតាមច្បាប់ចាស់:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨[៥៧] ព្រះអង្គផង ១ ម៉ឺន ២ ពាន់ ព្រះអង្គផង ៥ សែនព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា។

**ប្រែថ្មី:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥ សែន និង ១ ម៉ឺន ២ ពាន់ និង ២៨ ព្រះអង្គ ដោយត្បូង របស់ខ្ញុំព្រះករុណា។

តេសំ ធម្មញ្ច សង្ឃញ្ច, អាទរេន នមាមហំ;
នមក្ការានុភាវេន, ហិត្វា សព្វេ ឧបទ្ទវេ;
អនេកា អន្តរាយាបិ, វិនស្សន្តុ អសេសតោ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

(ឆន្ទោសារត្ថមេទិនី វុត្តោទយាភិនវដីកា បញ្ចមបរិច្ឆេទ-វិសមវុត្តិនិទ្ទេសវណ្ណនា)

---

[៥៧] ដែលរាប់ ២៨ ព្រះអង្គនេះ គឺរាប់ទាំងព្រះពុទ្ធបច្ចុប្បន្ន (ព្រះសមណគោតម)។

## ២-ចំនួនព្រះពុទ្ធដែលព្រះពោធិសត្វសទ្ធាធិកបានជួប

សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច, ចតុវីសតិ សហស្សកេ;
ទសសតសហស្សានិ, នមាមិ សិរសា អហំ ។

**ប្រែតាមច្បាប់ចាស់:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លានព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា ។

**ប្រែថ្មី:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១ លាន និង ២ ម៉ឺន ៤ ពាន់ និង ៥៥ ព្រះអង្គ ដោយត្បូងរបស់ខ្ញុំព្រះករុណា ។

តេសំ ធម្មញ្ច សង្ឃញ្ច, អាទរេន នមាមហំ;
នមក្ការានុភាវេន, ហិត្វា សព្វេ ឧបទ្ទវេ;
អនេកា អន្តរាយាបិ, វិនស្សន្តុ អសេសតោ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

## ៣-ចំនួនព្រះពុទ្ធដែលព្រះពោធិសត្វវីរិយាធិកបានជួប

សម្ពុទ្ធេ នវុត្តរសតេ, អដ្ឋចត្តាឡីស សហស្សកេ;
វីសតិសតសហស្សានិ, នមាមិ សិរសា អហំ ។

**ប្រែតាមច្បាប់ចាស់:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ ព្រះអង្គផង ៤ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លានព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា ។

**ប្រែថ្មី:** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ លាន និង ៤ ម៉ឺន ៨ ពាន់ និង ១០៩ ព្រះអង្គ ដោយត្បូងរបស់ខ្ញុំព្រះករុណា ។

**ពុទ្ធបណិធាន**

តេសំ ធម្មញ្ច សង្ឃញ្ច, អាទរេន នមាមហំ;
នមក្ការានុភាវេន, ហិត្វា សព្វេ ឧបទ្ទវេ;
អនេកា អន្តរាយាបិ, វិនស្សន្តុ អសេសតោ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

*****

**ធម៌សម្ពុទ្ធសូត្រលាន់ៗ　ព្រះពុទ្ធរយពាន់ខ្លះមិនដឹង**

**ជឿជាក់ថាចេះចប់ប៉ុណ្ណឹង　មិនប្រឹងរៀនប្រែបកបរិយាយ។**

**(សេចក្តីរំលឹកដាស់តឿន ជាបទពាក្យ៧ និពន្ធឡើងនៅឆ្នាំ១៩៣១**

**ដោយកវីក្រមង៉ុយ )**

# ប្រវត្តិសង្ខេបរបស់ព្រះនាងពិម្ពាយសោធរា កន្សែសារពេជ្ញ[៥៨]

*ព្រះនាងយសោធរាថេរី ទ្រង់ជាមហាសាវិកាមួយរូប ដែលបានបំពេញបុណ្យបារមីទុកមកហើយអំពីអតីតជាតិ ជាច្រើនអសង្ខេយ្យ ទ្រង់មានរូបឆោមស្រស់ល្អស្អាត គ្មានអ្នកដទៃប្រៀបផ្ទឹមបាននៅក្នុងនគរកបិលពស្តុ ទ្រង់ជាកំពូលនារី ដែលទ្រទ្រង់នូវគុណធម៌ដ៏ខ្ពង់ខ្ពស់ និងទ្រង់ក៏ជាដៃគូរបស់ព្រះមហាបុរសផងដែរ ក្នុងការបំពេញបុណ្យកុសល អស់ជាច្រើនអសង្ខេយ្យកប្ប ហើយទ្រង់បានជាព្រះអរិយសាវិកា ជាឯតទគ្គៈផ្នែកខាងអ្នកបានអភិញ្ញាធំ (***មហាភិញ្ញប្បត្តានំ យទិទំ ភទ្ទកាច្ចានា*** ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ ស្រេចនឹងភទ្ទាកច្ចានា)។*

*ជីវប្រវត្តិ របស់ព្រះនាងយសោធរាថេរី មានសម្ដែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីជាភាសាបាលីនៅក្នុងគម្ពីរ **អង្គុត្តរនិកាយ ឯកនិបាត** ថា៖*

*ព្រះនាងយសោធរាថេរី ទ្រង់បានមកចុះចាប់បដិសន្ធិនៅក្នុងព្រះរាជវាំងរបស់ព្រះបាទសុប្បពុទ្ធ ដោយទ្រង់កើតនៅក្នុងព្រះគភ៌ របស់ព្រះនាងអមិត្តាទេវី ដែលជាព្រះអគ្គមហេសីនៃព្រះបាទសុប្បពុទ្ធ ដែលទ្រង់ជាអ្នកគ្រប់គ្រងក្នុងនគរទេវទហៈ ក្នុងកោលិយវង្ស។*

*ក្រោយពីព្រះនាងទ្រង់បានប្រសូតចាកព្រះគភ៌នៃព្រះមាតាហើយ ព្រះ*

---

[៥៨] *យោងជីវប្រវត្តិពុទ្ធសាវិកា ដែលរៀបរៀងដោយលោកម្ចាស់ **យង់ សុផាត** ប្រធានសមាគមធម្មទានអរិយវង្ស។*

ញាតិទាំងឡាយ ទ្រង់បាននាំគ្នាថ្វាយព្រះនាមដល់ព្រះនាងថា **ភទ្ទាកច្ចានា**។ ការដែលព្រះនាង បានទទួលការថ្វាយព្រះនាមថាភទ្ទាកច្ចានានោះ ពីព្រោះសរីរៈរបស់ព្រះនាងមានព្រះឆវីវណ្ណ មានសម្បុរល្បឿងដូចជាមាស ដោយហេតុនេះ ទើបពួកព្រះញាតិ ថ្វាយព្រះនាមដល់ព្រះនាងថា ភទ្ទាកច្ចានា ព្រោះទ្រង់មានពណ៌នៃព្រះសរីរៈដូចមាស។

បើនៅក្នុង **គម្ពីរខុទ្ទកនិកាយអបទាន** បានពោលទាក់ទងទៅនឹងព្រះនាមរបស់ព្រះនាងថា **ព្រះនាងយសោធរា** ឬ **ព្រះនាងពិម្ពា**។

ព្រះនាងយសោធរា ទ្រង់ជាព្រះភគិនីរបស់ទេវទត្ត និងជាព្រះញាតិផ្នែកខាងព្រះកនិដ្ឋភគិនីរបស់ព្រះលោកនាថ ព្រោះថា ព្រះនាងអមិត្តា ជាព្រះរាជមាតារបស់ព្រះនាងយសោធរា ទ្រង់ជាព្រះកនិដ្ឋភគិនីរបស់ព្រះបាទសុទ្ធោទនៈ ដែលទ្រង់ជាព្រះរាជបិតារបស់ព្រះសម្មាសម្ពុទ្ធ។

ជីវប្រវត្តិបច្ចុប្បន្នជាតិរបស់ព្រះនាងយសោធរា ដែលមានសម្តែងទុកនៅក្នុង អដ្ឋកថាមនោរថបូរណី ដូចមានសេចក្តីថា៖

កាលព្រះនាងទ្រង់ចម្រើនវ័យធំដឹងក្តីហើយ ទ្រង់បានរៀបអភិសេកជាមួយនឹងមហាបុរស គឺព្រះសិទ្ធត្ថរាជកុមារ នៅក្នុងនគរកបិលពស្តុ។ កាលតមក ព្រះនាងក៏ទ្រង់មានព្រះរាជឱរសមួយព្រះអង្គ ព្រះនាមថា **រាហុល**។ ពាក្យថា រាហុល ប្រែថាអន្ទាក់ ព្រោះអាស្រ័យព្រះឧទានរបស់ព្រះមហាបុរស ដែលទ្រង់បានបន្លឺឡើង ក្នុងពេលដែលព្រះរាជឱរសប្រសូតថា **រាហុលំ ជាតំ ពន្ធនំ ជាតំ** ប្រែថា "អន្ទាក់កើតហើយ គ្រឿងចងកើតហើយ" ក្នុងថ្ងៃដែលព្រះរាហុល-

កុមារទ្រង់ប្រសូត ថ្ងៃនោះ គឺជាថ្ងៃដែលព្រះមហាបុរស ទ្រង់ស្ដេចយាងសាង ព្រះផ្នួស ដោយទ្រង់មានព្រះបំណងស្វែងរកអរិយសច្ចធម៌ ដើម្បីទ្រង់ អនុគ្រោះដល់សត្វលោក ដែលកំពុងតែជាប់នៅក្នុងវដ្ដសង្សារនេះ។

កាលព្រះលោកនាយក ទ្រង់បានសម្រេចព្រះសព្វញ្ញុតញ្ញាណ នៅ ក្រោមដើមព្រះសិរីមហាពោធិព្រឹក្ស នៅក្នុងឧរុវេលាសេនានិគម ហើយទ្រង់ធ្វើ ការអនុគ្រោះដល់សត្វលោក ដោយស្ដេចយាងមកអនុគ្រោះដល់អ្នកនគរ កបិលពស្ដុ ថែមទាំងបានធ្វើការសង្គ្រោះដល់ពពួកព្រះញាតិទាំងឡាយ តាម លំដាប់ ដែលមានព្រះបាទសុទ្ធោទនមហារាជជាដើម។

គ្រាដំបូង ដែលព្រះនាងយសោធរា ទ្រង់បានទតឃើញព្រះភគវា ថែម ទាំងបានឱកាសស្ដាប់ធម៌ទេសនានោះ តាមដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាជាតក** នៃ **សន្តិកេនិទាន** ដូចមានសេចក្ដីថាៈ

ថ្ងៃមួយ ព្រះដ៏មានព្រះភាគ ដែលមានភិក្ខុសង្ឃពីរម៉ឺនរូបហែហមជា បរិវារ ស្ដេចយាងចូលទៅបិណ្ឌបាត នៅក្នុងក្រុងកបិលពស្ដុ តែមិនមានអ្នកណា ម្នាក់ទៅក្រាបទូលអារាធនាព្រះទសពលឡើយ។ ព្រះភគវាទើបស្ដេចយាងទៅ គង់ប្រថាប់នៅត្រង់មុខកំពែងព្រះរាជវាំង ព្រះអង្គក៏ទ្រង់ត្រិះរិះបណ្ដើរថា **ព្រះ ពុទ្ធទាំងឡាយក្នុងកាលមុន ស្ដេចយាងមកប្រោសពពួកញាតិ នៅក្នុងព្រះនគរ យ៉ាងណាហ្ន៎?** ពេលនោះ ព្រះអង្គក៏ទ្រង់បានជ្រាបថា ព្រះពុទ្ធក្នុងកាលមុនៗ ព្រះអង្គតែងតែស្ដេចយាងទៅតាមលំដាប់ផ្ទះ ឬលំដាប់ច្រក។

កាលព្រះសម្ពុទ្ធ ទ្រង់ពិចារណាឃើញដូច្នេះហើយ ទើបព្រះសម្មាសម្ពុទ្ធ ស្ដេចយាងទៅតាមលំដាប់។ ព្រោះហេតុនោះ ព្រះអង្គទ្រង់ត្រិះរិះថា សូម្បីឥឡូវ

*នេះ តថាគតគួរតែលើកតម្កើងព្រះពុទ្ធ និងប្រពៃណីរបស់តថាគត ថែមទាំងបានជាគំរូដល់សាវកទាំងឡាយរបស់តថាគត បានបដិបត្តិតាមតថាគត ដែលមានការបំពេញករណីយកិច្ច គឺត្រាច់បិណ្ឌបាត។ កាលព្រះសម្ពុទ្ធ ទ្រង់ពិចារណាឃើញដូច្នេះហើយ ព្រះដ៏មានជោគទើបទ្រង់ស្តេចយាងបិណ្ឌបាតប្រោសដល់វេនេយ្យសត្វ គឺសត្វដែលគួរដល់ការប្រៀនប្រដៅ ដោយព្រះអង្គស្តេចយាងទៅតាមលំដាប់ច្រក ចាប់តាំងពីផ្ទះនៅខាងចុងបំផុតរៀងទៅ ដរាបដល់ព្រះរាជវាំង។*

*គ្រានោះ ដំណឹងដែលព្រះមុនី ទ្រង់ស្តេចយាងបិណ្ឌបាតនោះ ក៏បានផ្សាយចេញទៅថា ព្រះទសពលស្តេចយាងចារិកបិណ្ឌបាត។ លំដាប់នោះ មហាជនជាច្រើន ម្នាក់ៗនាំគ្នាបើកបង្អួច ទោះបីផ្ទះមួយជាន់ក្តី ពីរជាន់ក្តីជាដើម ដោយចង់ឃើញព្រះដ៏មានព្រះភាគស្តេចយាងបិណ្ឌបាត។ សូម្បីព្រះនាងយសោធរា ដែលជាព្រះជននីរបស់ព្រះរាហុល ព្រះនាងក៏ទ្រង់ត្រិះរិះថា* ***បានឮថា ព្រះអយ្យបុត្រស្តេចធ្លាប់យាងទៅដោយគ្រែស្នែងមាសជាដើម ដោយព្រះបរមរាជានុភាពដ៏ធំក្នុងព្រះនគរ តែឥឡូវនេះ ព្រះអយ្យបុត្រ ដាក់ព្រះកេសានិងព្រះមស្សុ ដោយទ្រង់គ្រងសំពត់កាសាវៈ ព្រះហស្តទ្រង់កាន់ដោយបាត្រស្តេចយាងទៅដើម្បីសូមភិក្ខា តើទ្រង់គួរឱ្យចង់មើលទេឬហ្ន៎?***

*ទើបព្រះនាងបើកសីហបញ្ជរ (បង្អួច) ទតមើល ក៏បានឃើញព្រះទសពល ទ្រង់ញ៉ាំងផ្លូវក្នុងនគរឲ្យភ្លឺស្វាង ដោយព្រះរស្មីនៃព្រះសរីរៈដ៏រុងរឿងដោយពុទ្ធសិរីមិនមានប្រមាណ ប្រដាប់ដោយមហាបុរិសលក្ខណៈ៣២ ប្រការលម្អដោយអនុព្យញ្ជនៈ៨០ ដែលតាមហែហមចោមរោមដោយព្រះរស្មី*

*ប្រមាណមួយព្យាម ទើបព្រះនាងសរសើរតាំងអំពីព្រះឧណ្ហីស រហូតដល់ផ្ទៃព្រះបាទដោយគាថា ឈ្មោះថា* ***នរសីហៈ ១០ គាថា*** *មានសេចក្តីដូច្នេះថា ៖*

១- សិនិទ្ធនីលមុទុកុញ្ចិតកេសោ,
សូរិយនិម្មលតលាភិនលាដោ;
យុត្តតុង្គមុទុកាយតនាសោ,
រំសិជាលវិតតោ នរសីហោ។

*ព្រះនរសីហៈ (មហាបុរស) ទ្រង់មានកេសា (សក់) ដ៏ទន់ព័ទ្ធព័ន្ធជាទក្ខិណាវដ្ត មានពណ៌ខ្មៅស្និទ្ធល្អ ទ្រង់មានព្រះនលាដ (គឺថ្ងាស) ដ៏ល្អស្អាតប្រាសចាកមន្ទិលដូចព្រះសុរិយា ទ្រង់មានព្រះនាសា (គឺច្រមុះ) ទន់វែងដ៏សមគួរល្អ ទ្រង់មានព្រះឆព្វណ្ណរង្សីល្អដោយបណ្តាញនៃរស្មី។*

២- ចក្កវរង្កិតរត្តសុបាទោ,
លក្ខណមណ្ឌិតអាយតបណ្ហិ;
ចាមរឆត្តវិភូសិតបាទោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

*(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានព្រះយុគលបាទល្អស្អាតពណ៌ក្រហម មានស្នាមចម្លាក់ក្បាច់កង់ចក្រដ៏ល្អ ទ្រង់មានព្រះបណ្ហិ (គឺកែងជើង) វែងប្រដាប់ដោយព្រះលក្ខណៈ ទ្រង់មានព្រះបាទ (គឺជើង) ប្រដាប់ដោយផ្ចិតចាមរីនិងឆត្រ ព្រះនរសីហៈ មហាបុរសហ្នឹងឯងជាបិតារបស់បុត្ត។*

៣- សក្យកុមារវរោ សុខុមាលោ,
លក្ខណចិត្តិកបុណ្ណសរីរោ;
លោកហិតាយ គតោ នរវីរោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

**ពុទ្ធបណិធាន**

(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់ជាសក្យកុមារដ៏ប្រសើរ ជាសុខុមាលជាតិ ទ្រង់មានព្រះសរីរកាយបរិបូណ៌ល្អវិចិត្រដោយព្រះលក្ខណៈ ទ្រង់ជាវីរបុរស កំពុងយាងទៅដើម្បីប្រយោជន៍ដល់សត្វលោក ព្រះនរសីហៈ មហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត។

៤- អាយតយុត្តសុសណ្ឋិតនាសោ,
គោបខុមោ អភិនីលសុនេត្តោ;
ឥន្ទធនូអភិនីលភមូកោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានព្រះនាសាទូលាយសមល្អ តាំងនៅដោយសភាពស្រស់ស្អាត ទ្រង់មានបខុមៈរោមព្រះនេត្រ ដូចរោមគោ ទ្រង់មានព្រះនេត្រល្អពណ៌នីលខៀវស្រងាត់ ទ្រង់មានព្រះភមុកាចិញ្ចើមល្អ ពណ៌នីលខៀវដូចឥន្ទធនូ ព្រះនរសីហៈមហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត។

៥- បុណ្ណសសង្កនិភោ មុខវណ្ណោ,
ទេវនរាន បិយោ នរនាគោ;
មត្តគជិន្ទវិលាសិតគាមី,
ឯស ហិ តុយ្ហ បិតា នរសីហោ។

(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានសម្បុរព្រះភក្ត្រ ដូចព្រះចន្ទពេញវង់ ទ្រង់ជាទីស្រឡាញ់របស់ទេវតានិងមនុស្សទាំងឡាយ ទ្រង់ជាមនុស្សដ៏ប្រសើរ ទ្រង់មានព្រះដំណើរយាងទៅដោយវិលាសល្អដូចគជសារចុះប្រេង ព្រះនរសីហៈ មហាបុរសហ្នឹងឯងជាបិតារបស់បុត្ត។

៦- សិនិទ្ធសុគម្ភិរមញ្ជុសឃោសោ,
ហិង្គុលពទ្ធុករត្តសុជិវ្ហោ;
វីសតិវីសតិសេតសុទន្តោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានព្រះសូរសៀងដ៏ពីរោះស្និទ្ធ ជ្រាលជ្រៅ ទ្រង់មានព្រះជិវ្ហាក្រហមដូចផ្កាហិង្គុលនិងផ្កាចប្រ៉ា ទ្រង់មានព្រះទន្ត ស ក្រោម២០ លើ២០ រួម៤០ មហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត។

៧- ខត្តិយសម្ភវអគ្គកុលីនោ,
ទេវមនុស្សនមស្សិតបាទោ;
សីលសមាធិបតិដ្ឋិតចិត្តោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

(ព្រះនរសីហៈ មហាបុរសឯណា) មានត្រកូលដ៏ប្រសើរដែលមានសម្ភព ចាកខត្តិយត្រកូល ទ្រង់មានស្នាមព្រះបាទគឺពួកទេវតានិងមនុស្សនមស្ការ ហើយ ទ្រង់មានព្រះទ័យតាំងមាំស៊ប់ក្នុងសីលសមាធិនិងបញ្ញា កំពុងយាងទៅ ដើម្បីប្រយោជន៍ដល់សត្វលោក ព្រះនរសីហៈ មហាបុរសហ្នឹងឯង ជាបិតារបស់ បុត្ត។

៨- វដ្ដសុវដ្ដសុសណ្ឋិតគីវោ,
សីហហនូ មិគរាជសរីរោ;
កញ្ចនសុច្ឆវិឧត្តមវណ្ណោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានព្រះសូរង់មូលល្អតាំងនៅ ដោយសភាពស្រស់ស្អាត ទ្រង់មានហនុចង្កាដូចរាជសីហ៍ ទ្រង់មានព្រះវរកាយ ដូចមិគរាជស្ដេចម្រឹគ ទ្រង់មានព្រះវណ្ណៈដ៏ឧត្តមប្រសើរល្អដូចមាស ព្រះនរសីហៈ មហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត។

៩- អញ្ជនវណ្ណសុនីលសុកេសោ,
កញ្ចនបដ្ដវិសុទ្ធនលាដោ;
ឱសធិបណ្ឌរសុទ្ធសុឧណ្ណោ,
ឯស ហិ តុយ្ហ បិតា នរសីហោ។

*(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់មានព្រះកេសាដ៏ល្អពណ៌ខៀវស្រស់ដូចពណ៌ផ្កាអញ្ចន់ ទ្រង់មានព្រះនលាដថ្ងាសដ៏ល្អបរិសុទ្ធវិសេសដូចផែនផ្ទាំងមាស ទ្រង់មានព្រះឧណ្ណាលោម(រោមប្រជុំចិញ្ចើម) ដ៏ល្អបរិសុទ្ធដូចផ្កាយព្រឹក ព្រះនរសីហៈ មហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត ។*

**១០- កច្ឆតិនិលបថេ វិយ ចន្ទោ,**
**តារគណាបរិវេឋិតរូបោ;**
**សាវកមជ្ឈគតោ សមណិន្ទោ,**
**ឯស ហិ តុយ្ហ បិតា នរសីហោ។**

*(ព្រះនរសីហៈ មហាបុរសឯណា) ទ្រង់ជាស្តេចនៃសមណៈកំពុងយាងទៅក្នុងកណ្តាលនៃពួកសាវក ល្អដូចដួងព្រះចន្ទដែលហែហមដោយហ្វូងតារាកំពុងចរយាត្រាឰដ៏អាកាសវេហាស៍ ព្រះនរសីហៈ មហាបុរសហ្នឹងឯង ជាបិតារបស់បុត្ត ។*

*បន្ទាប់ពីនោះ ព្រះនាងទើបនាំសេចក្តីនោះ ទៅក្រាបបង្គំទូលថ្វាយដល់ព្រះបាទសុទ្ធោទនមហារាជ ដើម្បីឱ្យទ្រង់បានជ្រាបថា **ព្រះរាជបុត្ររបស់ព្រះបិតា ពេលនេះទ្រង់កំពុងតែចារិកបិណ្ឌបាត។***

*គ្រានោះ ព្រះបាទសុទ្ធោទនមហារាជ កាលទ្រង់បានព្រះសណ្តាប់ពាក្យក្រាបបង្គំទូលថ្វាយ របស់ព្រះនាងយសោធរា ជាព្រះរាជសុណិសារួច ទ្រង់ក៏ស្លុតព្រះរាជហឫទ័យ ដោយទ្រង់ចាប់យកព្រះភូសាបណ្តើរ ហើយប្រញាប់យាងចេញទៅយ៉ាងរួសរាន់ ដោយទ្រង់យាងទៅឈរប្រថាប់នៅត្រង់ព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគ ទើបបានត្រាស់ជាមួយព្រះសម្មាសម្ពុទ្ធថា៖*

"បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីបានជាព្រះអង្គធ្វើឱ្យទូលបង្គំខ្មាសគេដូច្នេះ?

តើមានប្រយោជន៍អ្វីទើបបានជាព្រះអង្គស្តេចយាងបិណ្ឌបាត?

បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គឈ្វេងយល់ថាបិតាមិនអាចមានចង្ហាន់បិណ្ឌបាតគ្រប់គ្រាន់ សម្រាប់ភិក្ខុអង្គប៉ុណ្ណេះ ព្រមទាំងព្រះដ៏មានព្រះភាគឬ?"

គ្រានោះ ព្រះភគវា បានត្រាស់តបថា៖

"សូមថ្វាយព្រះពរ ព្រះមហាបពិត្រ ការត្រាច់និមន្តបិណ្ឌបាតជាវង្ស និងជាទំនៀមរបស់តថាគត។"

លំដាប់នោះ ព្រះបាទសុទ្ធោទនមហារាជ ត្រាស់ជំទាស់ថា៖

"បពិត្រព្រះអង្គដ៏ចម្រើន យើងទាំងឡាយមានវង្សតជាប់មកអំពីក្សត្រមហាសម្មតិ និងក្នុងរាជវង្សមិនធ្លាប់មានក្សត្រ សូម្បីត្រឹមតែមួយព្រះអង្គដែលស្តេចយាងទៅដើម្បីសូមភិក្ខាគេទេ"។

គ្រានោះ ព្រះភគវា បានត្រាស់តបថា៖

"សូមថ្វាយព្រះពរមហាបពិត្រ តែវង្សរបស់តថាគត គឺព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ ព្រះកស្សប វង្សនេះឈ្មោះថា **ពុទ្ធវង្ស** (ប្រែថា វង្សរបស់ព្រះពុទ្ធ) ដែលមានព្រះពុទ្ធអង្គដទៃៗរាប់ពាន់អង្គ ទ្រង់ក៏ទ្រទ្រង់ជីវិត គឺរស់នៅដោយការត្រាច់និមន្តបិណ្ឌបាត សូមភិក្ខាគេតែយ៉ាងនេះឯង"។

លំដាប់នោះ ព្រះសម្ពុទ្ធ ទើបត្រាស់២ព្រះគាថា នៅទីកន្លែង ដែលទ្រង់ឈរប្រថាប់នៅក្នុងចន្លោះផ្លូវនោះថា៖

**ពុទ្ធបណិធាន**

"ឧត្តិដ្ឋេ នប្បមជ្ជេយ្យ, ធម្មំ សុចរិតំ ចរេ;
ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។

*"បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង។*

ធម្មំ ចរេ សុចរិតំ, ន តំ ទុច្ចរិតំ ចរេ;
ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។

*បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង។"*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ លោកវគ្គ បិដកលេខ ៥២ ទំព័រ ៥៧)*

*ក្នុងពេលដែលព្រះដ៏មានបុណ្យជាម្ចាស់ ត្រាស់ព្រះគាថាទី១នោះចប់ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានសម្រេចសោតាបត្តិផល ហើយក្នុងពេលដែលព្រះដ៏មានបុណ្យជាម្ចាស់ ត្រាស់ព្រះគាថាទី២នោះចប់ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានសម្រេចសកទាគាមិផល។*

*នៅពេលក្រោយមកទៀត បន្ទាប់ពីព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានព្រះសណ្ដាប់***ធម្មបាលជាតក***[៥៩] ព្រះអង្គក៏បានសម្រេចអនាគាមិផល ហើយមុនពេលព្រះអង្គស្ដេចសោយទិវង្គត ព្រះអង្គបានផ្ទំនៅលើព្រះទែនសិរី-*

---

*[៥៩]សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទសកនិបាត មហាធម្មបាលជាតក បិដកលេខ ៥៩ ទំព័រ ១៨៦។*

សេយ្យាសន៍ ខាងក្រោមស្វេតច្ឆត្រនោះ ក៏បានសម្រេចអរហត្តផល ជាព្រះអរហន្ត ដោយព្រះអង្គមិនត្រូវចាំព្យាយាម ដោយស្តេចយាងចូលព្រៃឡើយ។ តែកាលដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានសម្រេចសោតាបត្តិផលហើយ ទើបទ្រង់ទទួលបាត្រពីព្រះដ៏មានជោគ និងទ្រង់ក្រាបបង្គំទូលអារាធនាព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃ ឱ្យស្តេចយាងទៅកាន់ប្រាសាទ រួចទ្រង់អង្គាស (ប្រគេនភិក្ខាដល់ព្រះសង្ឃ) ដោយមានខាទនីយភោជនីយាហារដ៏ប្រណីត។

ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ស្រីស្នំទាំងពួង ម្នាក់ៗ នាំគ្នាមកថ្វាយបង្គំព្រះមហាបុរស វៀរលែងតែព្រះនាងយសោធរា រាហុលមាតាប៉ុណ្ណោះ ដែលនៅមិនទាន់ព្រមយាងមកថ្វាយបង្គំ។

រីឯស្រីស្នំជាបរិវារ បានក្រាបបង្គំទូលព្រះនាងយសោធរា ថា៖

"សូមព្រះនាងជាម្ចាស់ ស្តេចយាងទៅក្រាបថ្វាយបង្គំព្រះអយ្យបុត្រ ព្រះពរម្ចាស់។"

ព្រះនាងយសោធរា មានព្រះតម្រាស់ថា៖

"ប្រសិនបើគុណ គឺសេចក្តីល្អរបស់ខ្ញុំមាន ព្រះអយ្យបុត្រក៏ស្តេចនឹងយាងមកដល់ទីលំនៅរបស់ខ្ញុំ។

កាលបើព្រះអយ្យបុត្រស្តេចយាងមក ខ្ញុំនឹងថ្វាយបង្គំ។"

គ្រានោះ ព្រះទសពលទ្រង់តាំងព្រះទ័យ នឹងយាងទៅកាន់ប្រាសាទរបស់ព្រះនាងយសោធរា ដើម្បីទ្រង់ធ្វើការអនុគ្រោះដល់ព្រះនាង ដែលទាំងនេះដោយព្រះអង្គត្រិះរិះថា **ព្រះនាងយសោធរា រាហុលមាតា ធ្លាប់ជាអ្នកមានគុណដល់តថាគតច្រើនមក តាំងពីអតីតជាតិ ធ្លាប់បានរួមបំពេញបុណ្យបារមី**

***មកជាមួយគ្នា គុណរបស់ព្រះនាងយសោធរា ដ៏លើសលប់រកប្រមាណមិនបាន ឬរកវត្ថុអ្វី មកប្រៀបផ្ទឹមមិនបាន។*** *ក៏ពុទ្ធការកធម៌ (ធម៌ដែលនាំឱ្យបានត្រាស់ជាព្រះពុទ្ធ) ដែលបានបំពេញមករហូតបានសម្រេចព្រះពោធិញ្ញាណជាព្រះសម្មាសម្ពុទ្ធ ក៏អាស្រ័យព្រះនាងទ្រង់ជួយបំពេញដែរ ទើបជាហេតុឱ្យសម្រេចបរិបូរ ដោយព្រះនាងទ្រង់មានភក្តីភាព យ៉ាងស្មោះស្ម័គ្រជាមួយព្រះពុទ្ធ។*

*ចាប់តាំងអំពីព្រះសាស្តា ស្តេចយាងចេញសាងអភិនេស្ក្រមណ៍ (គឺទ្រង់យាងចេញសាងផ្នួស)។ ចំណែកឯព្រះនាង ក៏ទ្រង់បានគ្រងដណ្តប់កាសាវៈ (សំពត់ជ្រលក់ដោយទឹកអម្ចត់)ដែរ មិនមែនត្រឹមតែប៉ុណ្ណោះ សូម្បីព្រះនាងជ្រាបពីដំណឹងទាក់ទងនឹងពុទ្ធចរិយាវត្តចំណែកដទៃៗរបស់ព្រះពុទ្ធជាដើមថា* ***ព្រះពុទ្ធទ្រង់ផ្ទំលើផែនដី ព្រះនាងក៏ប្រតិបត្តិតាម ប្រសិនបើលោកនាយក ស្តេចមិនយាងទៅរកព្រះនាងទេ ដួងព្រះទ័យរបស់ព្រះនាងនឹងបែកធ្លាយ ព្រោះទុក្ខទោមនស្សតូចព្រះទ័យយ៉ាងខ្លាំង។***

*ព្រះសយម្ភូ បានត្រាស់ជាមួយនឹងអគ្គសាវ័កទាំងពីររូបថា៖*

*"បើរាហុលមាតាមកចាប់ព្រះបាទស្ទាប កុំហាមនាងឡើយ ប្រសិនបើហាមព្រះនាងៗនឹងខូចព្រះទ័យ នឹងសោយពិលាល័យ"។*

*កាលបើព្រះសាស្តាត្រាស់ប្រាប់អគ្គសាវ័កទាំងពីររូបយ៉ាងនេះហើយ ទើបទ្រង់បញ្ចេញព្រះពុទ្ធរង្សីឱ្យភ្លឺដោយរស្មី៦ប្រការ ភ្លឺចាំងចូលទៅក្នុងព្រះសេយ្យាសន៍ កន្លែងរបស់ព្រះនាងយសោធរា ដោយភ្លឺចូលទៅតាមសីហបញ្ជរប្រាសាទ ព្រោះទ្រង់មានបំណងដើម្បីឱ្យព្រះនាងសប្បាយព្រះទ័យ ហើយទើប*

ព្រះអង្គស្តេចយាងចូលទៅក្នុងប្រាសាទរបស់ព្រះនាង ក្នុងខណៈនោះ ទ្រង់យាងគង់លើរតនបល្ល័ង្ក។ ឯពួកស្រីស្នំ បានក្រឡេកឃើញព្រះដ៏មានជោគ ចូលមកគង់ប្រថាប់លើរតនបល្ល័ង្ក ទើបចូលទៅថ្វាយបង្គំទូលព្រះនាងយសោធរាឱ្យទ្រង់បានជ្រាបថា **បពិត្រព្រះនាងម្ចាស់ ឥឡូវនេះ ព្រះមុនី ព្រះអង្គមកគង់លើរតនបល្ល័ង្កហើយ ព្រះពរម្ចាស់។**

គ្រានោះ ព្រះនាងយសោធរា បានស្តាប់ពាក្យក្រាបបង្គំទូលយ៉ាងនោះហើយ ក៏ទ្រង់បានរំសាយសេចក្តីសោក ហើយព្រះនាងស្តេចយាងចូលទៅគាល់ព្រះភគវា ទាំងដែលព្រះនាងទ្រង់ស្លៀកដណ្តប់សំពត់កាសាវៈនោះ ដោយទ្រង់មិនបានទ្រង់គ្រឿងអាភរណៈអ្វីឡើយ ថែមទាំងទ្រង់ដឹកដៃរាហុលកុមារឱ្យស្តេចយាងចូលទៅគាល់ដែរ។

ពេលដែលព្រះនាងស្តេចយាងចូលទៅដល់ ទ្រង់បានស្ទុះទៅក្រសោបព្រះបាទ ព្រះសិរក្រាបចុះថ្វាយបង្គំ ទាំងបានពោលរៀបរាប់ក្រាបទូលថា៖

"ទោសរបស់ខ្ញុំម្ចាស់មានច្រើន ព្រោះជាស្រីកាឡកណ្ណី ទើបព្រះអយ្យបុត្រស្តេចយាងចេញទៅសាងព្រះផ្នួស ដោយព្រះអង្គមិនបានត្រាស់ប្រាប់ខ្ញុំម្ចាស់ឱ្យបានដឹង ដោយលះបង់ខ្ញុំម្ចាស់មិនមានអាល័យមិនមានមេត្តា។

ព្រះអង្គបានស្តេចយាងចេញចាកនិវេសន៍ ដោយស្ងាត់ៗ ក្នុងវេលាពាក់កណ្តាលអធ្រាត្រ ឃើញថាខ្ញុំម្ចាស់ជាអ្នកមានទោសច្រើន ក្នុងថ្ងៃដែលព្រះរាហុលកុមារប្រសូតចាកព្រះគ៌ភនោះនៅមិនទាន់ដឹងខុសត្រូវប្រការ

ណា ឬមិនទាន់បានឃើញមុខបិតាគេនៅឡើយ ព្រះអង្គក៏ស្ដេចយាង ចេញទៅដោយមិនអាល័យ។

បើមើលលក្ខណៈទាយទុកកាលនៅវ័យទារិកាថា **យសោធរាបុត្រី មានបុញ្ញាភិនីហារបុណ្យបារមីធំ សមគួរបានជាអគ្គមហេសីនៃស្ដេចចក្រពត្តិ ពាក្យទស្សន៍ទាយនោះក៏ឃ្លៀងឃ្លាតខុស ត្រឡប់ប្រែប្រួលវិបរិតជាស្រីមេម៉ាយដូចនេះទើបត្រូវជាង ព្រះពរម្ចាស់**"។

កាលព្រះនាងយសោធរា ទ្រង់ត្អូញត្អែររៀបរាប់ផ្សេងៗ ដូចដែលបានពោលរួចមកហើយនោះ ព្រះនាងក៏ទ្រង់បានយកព្រះសិរសាដាក់លើខ្នងព្រះយុគលបាទរបស់ព្រះទសពល។

ចំណែកព្រះបាទសុទ្ធោទនមហារាជ ទើបទ្រង់ក្រាបទូលដល់គុណសម្បត្តិដ៏ប្រសើរ ដែលព្រះនាងយសោធរាទ្រង់មានសេចក្ដីស្នេហា ឬស្មោះត្រង់ជាមួយនឹងព្រះអង្គជានិច្ច ដោយទ្រង់បានរៀបរាប់ការប្រព្រឹត្តប្រតិបត្តិដូចគ្នានឹងព្រះពុទ្ធគ្រប់ប្រការ របស់បុត្រសុណិសារបស់ព្រះអង្គ យ៉ាងនោះថាៈ

"បានឮដំណឹងថា ពេលដែលព្រះពុទ្ធអង្គទ្រង់ស្លៀកដណ្ដប់សំពត់កាសាវៈ ចាប់ដើមអំពីកាលនោះមកព្រះនាងក៏ស្លៀកដណ្ដប់សំពត់កាសាវៈតាមព្រះអង្គដែរ។

លុះបានជ្រាបដំណឹងទៀតថា ព្រះអង្គទ្រង់ផ្ទំលើសេយ្យាសនៈ ព្រះនាងក៏ឈប់ផ្ទំលើមញ្ចាសនៈ គឺក្រាលដោយកន្ទេលឬស្លឹកឈើ។

បន្ទាប់បានជ្រាបដំណឹងទៀតថា ព្រះពុទ្ធអង្គទ្រង់មិនប្រើប្រាស់ផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ព្រះនាងក៏លះបង់លែងប្រើប្រាស់គ្រឿងក្រអូប និង

ផ្កាកម្រងដូចគ្នា។ ក្នុងពេលដែលព្រះអង្គទ្រង់បព្វជ្ជារួចហើយ ព្រះនាងក៏ស្ថិតនៅជាស្រីមេម៉ាយ ដោយមិនយកបុរសដទៃទៀតឡើយ៉។

កាលដែលពពួកព្រះញាតិរបស់ខ្លួនបញ្ជូនរាជសារមកលួងលោមថា នឹងទទួលការបដិបត្តិទំនុកបម្រុងថែរក្សា នាងក៏នៅតែមិនយល់ព្រម ថែមទាំងមិនបានក្រឡេកមើលដល់ពពួកព្រះញាតិទៀតផង សូម្បីត្រឹមតែមួយព្រះអង្គឡើយ ទាំងមិនព្រមទទួលយកគ្រឿងបណ្ណាការ ដែលពពួកក្សត្រដទៃៗ ទ្រង់បញ្ជូនមកឱ្យ បុត្រសុណិសារបស់ញោមមានចិត្តស្មោះនឹងព្រះអង្គ ទាំងនេះរាប់ថា នាងជាអ្នកសម្បូរទៅដោយគុណ ដូច្នេះជាដើម។

គ្រានោះ ព្រះមុនីមានព្រះតម្រាស់តបថា សូមថ្វាយព្រះពរ មហាបពិត្រ ដែលព្រះនាងយសោធរាសុណិសារបស់មហាបពិត្រ ដោយមហាបពិត្រ ទ្រង់បានគ្រប់គ្រងថែរក្សានៅក្នុងពេលនេះ គឺពេលដែលព្រះនាងមានបុណ្យបារមីចាស់ក្លាហើយ ទើបធ្វើឱ្យព្រះនាងមានចិត្តស្មោះត្រង់ ឬមិនលំបាកក្នុងការគ្រប់គ្រងនោះ សូម្បីក្នុងកាលមុន ព្រះសុណិសារបស់មហាបពិត្រ មិនមានអ្នកគ្រប់គ្រងថែរក្សា ដោយនាងបានត្រាច់ទៅតាមជ្រលងភ្នំ នៅមិនទាន់អាចរក្សាខ្លួនឱ្យពិតប្រាកដបាន ព្រោះក្នុងកាលនោះ ព្រះញាណរបស់ព្រះនាងនៅមិនទាន់ចាស់ក្លា សូម្បីតែមានសភាពបែបនេះក៏ដោយ ព្រះទ័យរបស់ព្រះនាង ក៏មានចិត្តស្រឡាញ់ក្នុងតថាគតមិនប្រែប្រួល។

គ្រានោះ ព្រះបាទសុទ្ធោទនមហារាជមានព្រះរាជបំណងដើម្បីចង់ស្តាប់រឿងក្នុងអតីតជាតិ ទើបទ្រង់ក្រាបទូលអារាធនាព្រះសម្មាសម្ពុទ្ធឱ្យទ្រង់ត្រាស់សម្តែងរឿងក្នុងអតីតជាតិនោះ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់លើកយករឿងអតីតក្នុង ***ចន្ទកិន្នរីជាតក*** ដែលមានសម្ដែងទុកក្នុង ***អដ្ឋកថាជាតក*** ដែលជាអដ្ឋកថា អធិប្បាយសេចក្ដីក្នុងព្រះបាលី ចន្ទកិន្នរីជាតក នៅក្នុងគម្ពីរ ***ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត*** ដូចមានសេចក្ដីថា ៖

## ចន្ទកិន្នរីជាតក



ព្រះសាស្ដា កាលស្ដេចគង់នៅវត្តនិគ្រោធារាម ដែលអាស្រ័យនៅនឹង ***នគរកបិលពស្តុ*** ទ្រង់ប្រារព្ធព្រះនាង***រាហុលមាតា*** បានត្រាស់ព្រះ***ធម្មទេសនា*** នេះក្នុង***រាជនិវេសន៍*** មានពាក្យថា ឧបនីយតិទំ មញ្ញេ ដូច្នេះជាដើម។

ជាតកនេះគប្បីពោលតាំងតែ***ទូរេនិទាន***។ តែ***និទានកថា***នេះ រហូតដល់ សីហនាទរបស់ព្រះ***ឧរុវេលកស្សបៈ***ក្នុង***លដ្ឋិវ័ន*** បានពោលទុកហើយក្នុង ***អបណ្ណកជាតក***។ បន្ទាប់ពីនេះទៅ រហូតដល់ព្រះអង្គយាងដំណើរដល់នគរ កបិលវត្ថុ នឹងមានជាក់ច្បាស់ក្នុង***វេស្សន្តរជាតក***។

ព្រះសាស្តាស្តេចប្រថាប់ក្នុងនិវេសន៍របស់ព្រះបិតា ក្នុងវេលាចន្លោះកត្តទ្រង់បានត្រាស់**មហាធម្មបាលជាតក** កាលស្តេចសោយកត្តរួច ព្រះអង្គត្រិះរិះថា តថាគតនឹងគង់ក្នុងនិវេសន៍របស់រាហុលមាតា កាលពោលគុណរបស់នាង នឹងសម្តែងចន្ទកិន្នរីជាតក ដូច្នេះហើយ ស្តេចឱ្យព្រះរាជាកាន់បាត្រ ហើយយាងទៅកាន់និវេសនដ្ឋានរបស់រាហុលមាតា មួយអន្លើដោយព្រះអគ្គសាវកទាំងពីរ។

គ្រានោះ ស្ត្រីរបាំ៤០,០០០ របស់ព្រះនាងពិម្ពា នាំគ្នាមកនៅក្នុងទីចំពោះមុខ (ប្រាសាទ) ក្នុងបណ្តាស្ត្រីរបាំទាំងនោះ ស្ត្រីដែលជាខត្តិយកញ្ញាមាន ១,០៩០រូប។

ព្រះនាងយសោធរានោះ ដឹងដំណើរយាងមករបស់ព្រះតថាគត ហើយប្រាប់ដល់ស្ត្រីទាំងនោះថា សព្វា កាសាវានេវ និវាសេត្ថ **នាងទាំងឡាយចូរស្លៀកសំពត់កាសាវៈ ទាំងអស់គ្នាចុះ។**

ពួកស្ត្រីទាំងនោះ ក៏បានធ្វើតាមយ៉ាងនោះ។

ព្រះសាស្តាយាងមក ហើយប្រថាប់លើអាសនៈ ដែលគេរៀបចំទុក។

លំដាប់នោះ ស្ត្រីទាំងអស់នាំគ្នាយំដោយសំឡេងតែមួយ សំឡេងបរិទេវៈដ៏ធំបានលាន់ឮឡើង។ ចំណែកព្រះនាងរាហុលមាតាយំខ្សឹកខ្សួល អណ្តឺតអណ្តក រួចកាលបន្ទោបង់សេចក្តីសោក ហើយថ្វាយបង្គំព្រះសាស្តា និងគង់ប្រថាប់ដោយសេចក្តីគោរពរាប់អានច្រើនដល់ព្រះរាជា។

ព្រះរាជាប្រារព្ធគុណរបស់ព្រះនាង បានត្រាស់គុណកថារបស់ព្រះនាងដោយប្រការផ្សេងៗថា ៖

**ពុទ្ធបណិធាន**

*បពិត្រព្រះអង្គដ៏ចម្រើន ព្រះសុណិសារបស់ខ្ញុំព្រះអង្គនេះ កាលស្តាប់ថា ព្រះអង្គស្លៀកសំពត់កាសាវៈ ព្រះនាងក៏ស្លៀកសំពត់កាសាវៈដែរ កាលបាន ស្តាប់ថា ព្រះអង្គលះបង់កម្រងផ្កាជាដើម ព្រះនាងក៏លះបង់កម្រងផ្កាជាដើម ដែរ កាលឮថា ព្រះអង្គផ្ទំលើផែនដី ព្រះនាងក៏មានទីដេកលើផែនដីដែរ និង ក្នុងកាលដែលព្រះអង្គចេញបួសហើយនេះ ព្រះនាងជាស្ត្រីមេម៉ាយ មានព្រះ រាជាដទៃបញ្ជូនបណ្ណាការមកស្តីដណ្តឹងព្រះនាង ព្រះនាងក៏មិនកាន់យក បណ្ណាការនោះ ព្រះនាងមានចិត្តមិនប្រែប្រួលក្នុងព្រះអង្គយ៉ាងនេះ។*

*ព្រះសាស្តាត្រាស់ថា* **បពិត្រមហារាជ ឥឡូវនេះ កាលដែលព្រះនាងមាន សេចក្តីស្រឡាញ់ មានចិត្តមិនប្រែប្រួលក្នុងតថាគត ដែលជាអត្តភាពចុងក្រោយ របស់តថាគត ជាអ្នកដែលបុរសដទៃនាំទៅមិនបាននេះ មិនជាអស្ចារ្យទេ។ ព្រះ នាង សូម្បីកើតក្នុងកំណើតសត្វតិរច្ឆាន ក៏មានចិត្តមិនប្រែប្រួលក្នុងតថាគត ជា អ្នកដែលបុរសដទៃនាំទៅមិនបានដូចគ្នាដែរ។**

*ដូច្នេះហើយ ទ្រង់ដែលព្រះរាជាទូលអារាធនាហើយ បាននាំអតីតនិទាន មកថា៖*

*ក្នុងអតីតកាល កាលព្រះបាទ**ព្រហ្មទត្ត**សោយរាជសម្បត្តិក្នុងនគរ* ***ពារាណសី** ពេលនោះ ព្រះមហាសត្វកើតក្នុងកំណើតសត្វកិន្នរ ក្នុងហិមវន្ត- ប្រទេស, កិន្នរី ឈ្មោះ **ចន្ទា** ជាភរិយារបស់ព្រះមហាសត្វនោះ។ កិន្នរ និងកិន្នរី ទាំងពីរនោះ អាស្រ័យនៅលើរជតបព៌ត ដែលមានឈ្មោះថា **ចន្ទបព៌ត**។*

*សម័យកាលនោះ ព្រះរាជាពារាណសីប្រគល់រាជសម្បត្តិឱ្យដល់ពួក អាមាត្យ ទ្រង់ស្លៀកសំពត់កាសាវៈ២ ពាក់អាវក្រោះ និងប្រដាប់ដោយ**បញ្ចាវុធ***

ស្តេចយាងចូលព្រៃហិមពាន្តតែមួយអង្គឯង។ ព្រះរាជា កាលសោយសាច់ម្រឹគរួច ក៏យាងទៅតាមលំដាប់ដល់ស្ទឹងតូចមួយ ហើយយាងឡើងទៅចំណែកខាងលើ។

ក្នុងកាលរដូវភ្លៀង ពួកកិន្នរដែលនៅលើភ្នំចន្ទបព៌ត មិនចុះមកទេ នាំគ្នានៅលើភ្នំប៉ុណ្ណោះ ក្នុង**និទាឃរដូវ**[៦០] ទើបចុះមក។

គ្រានោះ **ចន្ទកិន្នរ** បាននាំភរិយារបស់ខ្លួនចុះមកក្រោម នាំគ្នាលាបគ្រឿងក្រអូបក្នុងទីនោះៗ ហើយបរិភោគលម្អងផ្កា រួចយកត្របកផ្កាមកស្លៀកដណ្តប់ លេងប្រយឹតប្រតោងវល្លិ និងច្រៀងដោយសំឡេងដ៏ពីរោះ រួចក៏បានដល់ស្ទឹងតូចនោះ ហើយចុះក្នុងទឹកន្លែងមួយ រោយរាយបាចសាចផ្កាឈើក្នុងទឹក នាំគ្នាមុជទឹកលេង ទើបស្លៀកដណ្តប់ត្របកផ្កាឈើ ក្រាលអាសនៈផ្កាលើដីខ្សាច់ ដែលមានពណ៌ដូចផែនប្រាក់កាន់យកដំបងឫស្សីមួយអង្គុយលើទីដេក។

បន្ទាប់មក **ចន្ទកិន្នរ**ក៏ផ្លុំឫស្សី ហើយច្រៀងដោយសំឡេងដ៏ពីរោះ។ ចន្ទាកិន្នរី បង្អោនដៃដ៏ទន់ ឈរបិតនៅក្នុងទីមិនឆ្ងាយអំពីស្វាមី រាំផង ច្រៀងផង។

ព្រះរាជាបានស្តាប់សំឡេងរបស់កិន្នរទាំងនោះហើយ កាលចូលទៅជិតទើបដើរសន្សឹមៗ បិតនៅក្នុងទីបិទបាំងមួយ ឃើញកិន្នរទាំងនោះហើយ មានចិត្តប្រតិព័ទ្ធនឹងនាងកិន្នរី រួចគិតថា យើងនឹងបាញ់កិន្នរនេះឱ្យស្លាប់ នឹងសម្រេចការនៅរួមជាមួយនឹងនាងកិន្នរីនោះ ដូច្នេះហើយ ក៏បាញ់ចន្ទកិន្នរ។

---

[៦០] ឈ្មោះរដូវមួយប្រើតាមសុរិយគតិ ជារដូវក្តៅ មាន៩២ថ្ងៃ រាប់ពីត្រឹមថ្ងៃទី២១ ខែមីនា ដល់ថ្ងៃទី២១ ខែមិថុនា។

*ចន្ទកិន្នរនោះដល់នូវទុក្ខវេទនា កាលនឹងបរិទេវៈ ទើបពោល៤គាថា ថាៈ*

ឧបនីយតិទំ មញ្ញេ, ចន្ទេ លោហិតមទ្ទនេ;
អជ្ជ ជហាមិ ជីវិតំ, បាណា មេ ចន្ទេ និរុជ្ឈន្តិ។

*"ម្នាលនាងចន្ទា ជីវិតនេះប្រហែលជាជិតដាច់ហើយ ព្រោះក្រពុលដោយឈាម អញនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់ ។*

ឱសីទិ មេ ទុក្ខំ ហទយំ, មេ ឌយ្ហតេ និតម្មាមិ;
តវ ចន្ទិយា សោចន្តិយា, ន នំ អញ្ញេហិ សោកេហិ។

*ជីវិតរបស់អញជាទុក្ខពៀបចុះហើយ ហឫទ័យរបស់អញក្ដៅណាស់ អញលំបាកក្រៃពេក ព្រោះហេតុនាងចន្ទា កំពុងសោក មិនមែនព្រោះការសោកដទៃទេ។*

តិណមិវ វនមិវ មិលាយាមិ, នទី អបរិបុណ្ណាវ សុស្សាមិ;
តវ ចន្ទិយា សោចន្តិយា, ន នំ អញ្ញេហិ សោកេហិ។

*អញនឹងស្វិតស្រពោនដូចជាស្មៅ (ដែលគេដាក់លើថ្មក្ដៅ) ដូចជាដើមឈើ (ដែលកាត់ផ្ដាច់ឫសហើយ) អញនឹងរីងស្ងួតដូចជាស្ទឹងដែលមានទឹកមិនពេញ ព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។*

វស្សមិវ សរេ បាទេ, ឥមានិ អស្សូនិ វត្តរេ មយ្ហំ;
តវ ចន្ទិយា សោចន្តិយា, ន នំ អញ្ញេហិ សោកេហិ។

*ទឹកភ្នែកទាំងឡាយ របស់អញនេះហូរទៅ ដូចជាភ្លៀងក្បែរជើងភ្នំហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃឡើយ"។*

*ព្រះមហាសត្វ បរិទេវៈដោយគាថាទាំងឡាយ៤នេះហើយ ក៏បាត់បង់ស្មារតី ដួលដេកលើបុប្ផសយនៈ។*

*ព្រះរាជានោះឋិតនៅកន្លែងនោះឯង។*

*ចំណែកនាងចន្ទកិន្នរី កាលព្រះមហាសត្វបរិទេវៈ នាងរវល់តែស្រវឹងដោយសេចក្តីត្រេកអររបស់ខ្លួន ទើបមិនដឹងថាស្វាមីត្រូវព្រួញ ពេលឃើញព្រះពោធិសត្វដួលដេកបាត់បង់ស្មារតី ក៏ពោលពាក្យថា៖*

*"សេចក្តីទុក្ខរបស់ស្វាមីជាទីស្រឡាញ់របស់អញដូចម្តេច?"*

*កាលពិចារណា បានឃើញឈាមដែលហូរចេញអំពីកន្លែងប្រហារ នាងមិនអាចនឹងអត់សង្កត់សេចក្តីសោកដ៏មានកម្លាំង ដែលកើតឡើងក្នុងស្វាមីជាទីស្រឡាញ់ ក៏យំសោកដោយសំឡេងដ៏ខ្លាំង។*

*ព្រះរាជាត្រិះរិះថា **កិន្នរស្លាប់ហើយ** ដូច្នេះទើបចេញមកសម្តែងខ្លួនឡើង។*

*នាងចន្ទាកិន្នរី ឃើញព្រះរាជានោះហើយគិតថា **ស្វាមីជាទីស្រឡាញ់របស់អញ ពិតជាត្រូវអាចោរនេះបាញ់ហើយ** ដូច្នេះហើយ កាលកំពុងញាប់ញ័រ នាងក៏រត់ទៅឈរឋិតលើកំពូលភ្នំ  កាលនឹងជេរប្រទេចព្រះរាជា ទើបពោល៥គាថា ថា៖*

| | |
|---|---|
| ចាចោ ខោសិ រាជបុត្ត, | យោ មេ ឥច្ឆិតំ បតឹ វរាកិយា; |
| វិជ្ឈសិ វនមូលស្មឹ, | សោយំ វិទ្ធោ ឆមា សេតិ។ |

*"រាជបុត្តណាបាញ់នូវប្តី ដែលអញជាអ្នកកំព្រាប្រាថ្នាហើយ រាជបុត្ត (នោះ) អាក្រក់មែន ប្តីរបស់អញដែលត្រូវសរមុតហើយ ដេកលើផែនដីទៀបគល់ឈើ។*

ឥមំ មយ្ហំ ហទយសោកំ, បដិមុញ្ចតុ រាជបុត្ត តវ មាតា;
យោ មយ្ហំ ហទយសោកោ, កិម្បុរិសំ អវេក្ខមានាយ។

*នែរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណានៃអញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមមាតារបស់អ្នកបាននូវសេចក្តីសោក ក្នុងហឫទ័យដូចអញនេះដែរ។*

ឥមំ មយ្ហំ ហទយសោកំ, បដិមុញ្ចតុ រាជបុត្ត តវ ជាយា;
យោ មយ្ហំ ហទយសោកោ, កិម្បុរិសំ អវេក្ខមានាយ។

*នែរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណារបស់អញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមប្រពន្ធរបស់អ្នកបាននូវសេចក្តីសោក ក្នុងហឫទ័យដូចអញនេះដែរ។*

មា ច បុត្តំ មា ច បតិំ, អទ្ទក្ខិ រាជបុត្ត តវ មាតា;
យោ កិម្បុរិសំ អវធិ, អទូសកំ មយ្ហ កាមា ហិ។

*នែរាជបុត្ត បុគ្គលណា បានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឱ្យម្តាយរបស់អ្នក (នោះ) បានឃើញកូនផង សូមកុំឱ្យបានឃើញប្តីផង។*

មា ច បុត្តំ មា ច បតិំ, អទ្ទក្ខិ រាជបុត្ត តវ ជាយា;
យោ កិម្បុរិសំ អវធិ, អទូសកំ មយ្ហ កាមា ហិ។

*នៃរាជបុត្ត អ្នកណាបានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឱ្យប្រពន្ធរបស់អ្នកនោះ បានឃើញកូនផង សូមកុំឱ្យបានឃើញប្តីផង"។*

*ព្រះរាជា កាលនាងចន្ទាកិន្នរីដែលឈរនៅលើកំពូលភ្នំ ជេរប្រទេចដោយគាថាទាំង៥ហើយ កាលនឹងលួងលោមនាង ទើបពោលគាថាថាៈ*

មា ត្វំ ចន្ទេ រោទិ មា សោចិ, វនតិមិរមត្តក្ខិ;

មម ត្វំ ហេហិសិ ភរិយា, រាជកុលេ បូជិតា នារីភិ។

*"ម្នាលនាងចន្ទា មានភ្នែកដូចផ្កានៃតិមិរព្រឹក្សក្នុងព្រៃ នាងកុំយំកុំសោកឡើយ នាងនឹងបានជាអគ្គមហេសីនៃយើង នឹងមាននាងនារីបូជាក្នុងរាជត្រកូល"។*

*ពាក្យថា ម្នាលនាងចន្ទា សេចក្តីថា កាលព្រះមហាសត្វកំពុងបរិទេវៈ ព្រះរាជាបានស្តាប់ឈ្មោះរបស់នាង ទើបពោលយ៉ាងនេះ។ ពាក្យថា នឹងមាននាងនារីបូជាក្នុងរាជត្រកូល សេចក្តីថា នាងនឹងបានជាអគ្គមហេសី ជាធំលើស្ត្រី ១៦,០០០។*

*នាងចន្ទាស្តាប់ពាក្យរបស់ព្រះរាជានោះហើយ ពោលថា* ***អ្នកឯងនិយាយអ្វីនឹងយើង*** *ដូច្នេះកាលនឹងបន្លឺសីហនាទ ទើបពោលអនន្តរគាថា ថាៈ*

អបិ នូនហំ មរិស្សំ, នាហំ រាជបុត្ត តវ ហេស្សំ;

យោ កិម្បុរិសំ អវធិ, អទូសកំ មយ្ហ កាមា ហិ។

*"នៃរាជបុត្រ អ្នកណាបានសម្លាប់នូវកិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ អញស៊ូតែស្លាប់ អញនឹងមិនធ្វើ (ជាប្រពន្ធ) របស់អ្នក (នោះ)ទេ"។*

**ពុទ្ធបណិធាន**

*ព្រះរាជាស្តាប់ពាក្យរបស់នាងហើយ ជាអ្នកលែងមានសេចក្តីស្រឡាញ់ ក៏ពោលគាថាដទៃថា៖*

អបិ ភីរុកេ អបិ ជីវិតុកាមិកេ, កិម្បុរិសិ គច្ឆ ហិមវន្តំ;
តាលីសតគរភោជនា, អញ្ញេ តំ មិគា រមិស្សន្តិ។

*“ម្នាលនាងកិន្នរី ដែលជាស្រីមានសេចក្តីខ្លាចផង ចង់រស់នៅផង នាងជាមេម្រឹគ មានស្លឹកកំញាន និងស្លឹកក្រស្នាជាភោជន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ពួកម្រឹគដទៃនឹងត្រេកត្រអាលចំពោះនាង”។*

*នាងកិន្នរីដឹងថា ព្រះរាជានោះទៅហើយ ក៏ចុះមកឱបត្រកង បីព្រះមហាសត្វឡើងកាន់លើកំពូលភ្នំ ដាក់ឱ្យដេកលើផ្ទៃដីរាប យកសីសៈរបស់ព្រះពោធិសត្វដាក់លើភ្លៅរបស់ខ្លួន កាលយំសោកខ្លាំងៗ ទើបពោល១២គាថា ថា៖*

តេ បព្វតា តា ច កន្ទរា, តា ច គិរិគុហាយោ តថេវ តិដ្ឋន្តិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សំ។

*“ភ្នំទាំងឡាយនោះផង ជ្រោះភ្នំទាំងឡាយនោះផង គុហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

តេ បណ្ណសន្ថតា រមណីយា, វាឡមិគេហិ អនុចិណ្ណា;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សំ។

*យើងទាំងឡាយ រមែងត្រេកត្រអាលជាមួយគ្នា លើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្តេច?*

តេ បុប្ផសន្ថតា រមណីយា, វាឡមិគេហិ អនុចិណ្ណា;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សំ។

*ភ្នំទាំងឡាយនោះ ដេរដាសដោយស្លឹកឈើ គួររីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

អច្ឆា សវន្តិ គិរិវនជនិយោ, កុសុមាភិកិណ្ណសោតាយោ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កាចំ អហំ កស្សំ។

*ស្ទឹងលើភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ មានទឹកដ៏ថ្លា កាលហូរទៅ មានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាត បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

នីលានិ ហិមវតោ បព្វតស្ស, កូដានិ ទស្សនីយានិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កាចំ អហំ កស្សំ។

*កំពូលទាំងឡាយនៃភ្នំហិមវន្តមានពណ៌ខៀវ គួរឱ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

បីតានិ ហិមវតោ បព្វតស្ស, កូដានិ ទស្សនីយានិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កាចំ អហំ កស្សំ។

*កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌លឿង គួរឱ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

តម្ពានិ ហិមវតោ បព្វតស្ស, កូដានិ ទស្សនីយានិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កាចំ អហំ កស្សំ។

*កំពូលទាំងឡាយនៃភ្នំហិមវន្ត មានចុងស្រួច គួរឱ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

សេតានិ ហិមវតោ បព្វតស្ស, កូដានិ ទស្សនីយានិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កាចំ អហំ កស្សំ។

*កំពូលទាំងឡាយនៃភ្នំហិមវន្ត ដែលមានពណ៌ស គួរឱ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

ចិត្រានិ ហិមវតោ បព្វតស្ស, កូដានិ ទស្សនីយានិ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សាំ។

*កំពូលទាំងឡាយនៃភ្នំហិមវន្តដ៏វិចិត្រ គួរឱ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច?*

យក្ខកណាសេវិតេ គន្ធមាទនេ, ឱសធេភិ សញ្ឆន្នេ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សាំ។

*បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកុម្ភទេវតាសេពហើយ ជាភ្នំដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្តេច?*

កិម្បុរិសសេវិតេ គន្ធមាទនេ, ឱសធេភិ សញ្ឆន្នេ;
តត្ថេវ តំ អបស្សន្តី, កិម្បុរិស កថំ អហំ កស្សាំ។

*បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកិន្នរសេពហើយ ជាភ្នំដ៏ដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្តេច”។*

*នាងកាលបរិទេវៈ ដោយគាថាទាំងឡាយ១២នេះហើយ បានយកដៃដាក់លើទ្រូងព្រះមហាសត្វ ក៏ដឹងថាមានកម្តៅ នាងគិតថា* ***ចន្ទកិន្នរនៅមានជីវិត យើងនឹងធ្វើទេវុជ្ឈានកម្ម (ការពោលទោសតិះដៀលទេវតា) ឱ្យជីវិតដល់ចន្ទកិន្នរ*** *ដូច្នេះហើយ ក៏បានធ្វើទេវុជ្ឈានកម្មថា៖*

*"លោកបាលទេវតា មិនមានទេឬ ទៅណាអស់ហើយឬ ស្លាប់អស់ហើយឬ បានជាលោកទាំងនោះមិនរក្សាស្វាមីរបស់ខ្ញុំ?"*

*ដោយកម្លាំងនៃសេចក្ដីសោក របស់នាងចន្ទកិន្នរីនោះ អាសនៈរបស់សក្កទេវរាជ មានអាការក្ដៅ។*

*ស្ដេចសក្កៈបានពិចារណាដឹងហេតុនោះ ក៏យាងមកយ៉ាងរហ័ស ដោយភេទជាព្រាហ្មណ៍ កាន់យកទឹកអំពីកុណ្ឌីមកស្រោចព្រះមហាសត្វ។ ក្នុងពេលនោះឯង ពិសក៏អន្តរធានទៅ ដំបៅបានដុះជិតឡើង សូម្បីកន្លែងដែលត្រូវព្រួញនោះ ក៏មិនប្រាកដ។*

*ព្រះមហាសត្វមានអាការជាសុខក្រោកឡើង។*

*នាងចន្ទា ឃើញស្វាមីជាទីស្រឡាញ់មិនមានរោគដូច្នេះ បានដល់សេចក្ដីសោមនស្ស ថ្វាយបង្គំបាទារបស់សក្កទេវរាជ ហើយពោលអន្តរគាថាថា៖*

វន្ទេ តេ អយិរព្រហ្មេ, យោ មេ ឥច្ឆិតំ បតឹ វរាកិយា;
អមតេន អភិសិញ្ចិ, សមាគតាស្មិ បិយតមេន។

*"បពិត្រព្រហ្មជាម្ចាស់ ខ្ញុំសូមថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់លោក ព្រោះលោកបានស្រោចប្ដី ដែលខ្ញុំជាស្រីកំព្រាប្រាថ្នាហើយដោយទឹកអម្រឹត ដែលជាទីស្រឡាញ់ដោយវិសេស ក្នុងទីដែលលោកជួបគ្នា"។*

*ស្ដេចសក្កៈឱ្យឱវាទដល់កិន្នរទាំងនោះថា* ***ចាប់ពីពេលនេះទៅ កុំចុះពីភ្នំចន្ទបព៌ត មកផ្លូវមនុស្សអី ចូរនៅក្នុងទីនេះប៉ុណ្ណោះ។***

*សក្កទេវរាជពោលឱ្យឱវាទដល់កិន្នរទាំងនោះហើយ ក៏យាងទៅកាន់លំនៅរបស់ខ្លួនវិញ។*

**ពុទ្ធបណិធាន**

*ចំណែកនាងចន្ទាពោលនឹងស្វាមីថា៖*

*"បពិត្រស្វាមី ប្រយោជន៍អ្វីដោយកន្លែង ដែលមានអន្តរាយនេះ មកចុះ យើងនឹងទៅកាន់ចន្ទបព៌ត"។*

*ដូច្នេះហើយ ទើបពោល**ឱសានគាថា**ថា៖*

វិចរាម ទានិ គិរិវនទនិយោ, កុសុមាភិកិណ្ណសោតាយោ;

ទាទុមវសនាយោ, បិយំវទា អញ្ញមញ្ញស្ស។

*"ឥឡូវនេះ យើងទាំងឡាយនឹងត្រាច់ទៅកាន់ស្ទឹងក្បែរភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ ដែលមានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាត ទាំងមានឈើផ្សេងៗដុះហែវិញ យើងទាំងឡាយនឹងពោលនូវពាក្យជាទីស្រឡាញ់ទៅវិញទៅមក"។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា **មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ព្រះនាងក៏មានចិត្តមិនប្រែប្រួលក្នុងតថាគត ជាស្ត្រីដែលបុរសដទៃនាំទៅមិនបានដូចគ្នា** ដូច្នេះហើយ ព្រះអង្គប្រជុំជាតកថា៖*

តទា រាជា ទេវទត្តោ អហោសិ *ព្រះរាជាក្នុងកាលនោះបានមកជាទេវទត្ត*

សក្កោ អនុរុទ្ធោ *សក្កទេវរាជបានមកជាអនុរុទ្ធ*

ចន្ទា *នាងចន្ទាកិន្នរីបានមកជារាហុលមាតា*

ចន្ទកិន្នរោ បន អហមេវ អហោសិំ *ចំណែកចន្ទកិន្នរគឺតថាគតនេះឯង។*

*ចន្ទកិន្នរីជាតក ចប់ ។*

ផល ដែលព្រះលោកនាយក ទ្រង់ប្រោសប្រទានព្រះធម៌ទេសនា ចន្ទកិន្នរីជាតក ធ្វើឱ្យព្រះនាងយសោធរា រំងាប់នូវសេចក្តីសោកសៅ បាននូវបីតិនិងបាមោជ្ជៈ រួចបានស្ថិតនៅក្នុងភូមិរបស់ព្រះសោតាបន្ន ជាព្រះអរិយបុគ្គលថ្នាក់ដំបូង ក្នុងចំណោមព្រះអរិយបុគ្គលទាំងឡាយ ដោយហៅអ្នកបានសម្រេចសោតាបត្តិផលជា ព្រះសោតាបន្ន និងក្រោយពីព្រះនាងយសោធរា ដែលបានសម្រេចសោតាបត្តិផលហើយ ព្រះសយម្ភូទ្រង់ក្រោកចាកអាសនៈ ហើយជៀសចេញទៅ។

ក្នុងថ្ងៃទី៧ រាប់ពីថ្ងៃដែលព្រះសាស្តា ជានាយក ស្តេចយាងមកដល់នគរកបិលពស្តុ ព្រះនាងយសោធរា ទ្រង់បានស្អិតស្អាងព្រះរាហុលកុមារ ដើម្បីទ្រង់បញ្ជូនព្រះរាហុល ឱ្យទៅកាន់សម្នាក់ព្រះមហាមុនី ព្រមគ្នានឹងមានព្រះសវនីយ៍ថា៖

"បារាហុល ចូរមើលនុ៎ះ សមណៈ មានរូបឆោមដូចព្រហ្ម មានសម្បុរដូចមាស ព្រះអង្គមានភិក្ខុសង្ឃ២ម៉ឺនរូបហែហម សមណៈនោះគឺជាព្រះបិតារបស់បុត្រ។

សមណៈនោះមានកំណប់ទ្រព្យច្រើនណាស់ ប៉ុន្តែតាំងពីស្តេចយាងទៅបព្វជ្ជារួច ព្រះមាតាមិនបានឃើញកំណប់ទ្រព្យនោះទេ ដូច្នេះ រាហុលរាជកុមារ ចូរទៅក្រាបបង្គំទូលសូមកំណប់ទ្រព្យនោះថា បពិត្រព្រះបិតាទូលព្រះបង្គំនៅក្មេង តទៅគង់នឹងបានអភិសេកជាស្តេចចក្រពត្តិ។ ទូលព្រះបង្គំជាខ្ញុំត្រូវការទ្រព្យ សូមព្រះបិតាប្រោសប្រទានពរ ដល់ទូលព្រះបង្គំជាខ្ញុំម្ចាស់ ព្រោះថា បុត្រជាម្ចាស់នៃមត៌ករបស់ព្រះបិតា"។

*កាលព្រះរាហុលកុមារ ស្តេចយាងចូលទៅរកព្រះវិជិតមារហើយត្រឡប់ទៅជាមានព្រះហឫទ័យរីករាយទៅវិញ ដោយកើតមានសេចក្តីស្រឡាញ់ចំពោះព្រះបិតា ទាំងត្រាស់យកចិត្តយកថ្លើមព្រះអង្គថា៖*

*"បពិត្រព្រះមហាសមណៈ ឥរិយាបថរបស់ព្រះអង្គគង់នៅជាសុខសប្បាយ"*

*និងបានត្រាស់យ៉ាងដទៃៗ ច្រើនទៀត តាមសមគួរដល់វោហាររបស់ព្រះរាជកុមារ ដែលអាចប្រព្រឹត្តទៅបាន។*

*គ្រានោះ ព្រះសាស្តា ក្រោយពីទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ទើបត្រាស់អនុមោទនា ទើបទ្រង់ក្រោកចាកពុទ្ធាសនៈ ស្តេចយាងចាកចេញទៅ។*

*រីឯព្រះរាហុលកុមារ ក៏ស្តេចយាងទៅតាមព្រះមុនី ព្រមទាំងក្រាបទូលអង្វរថា៖*

*"សូមព្រះបិតា ស្តេចទ្រង់ព្រះរាជទានទ្រព្យឱ្យដល់ទូលព្រះបង្គំជាខ្ញុំព្រះករុណាផង"។*

*ព្រះទសពល មិនបានត្រាស់ឱ្យរាហុលកុមារ ក្នុងខណៈស្តេចយាងត្រឡប់ទៅវិញឡើយ។*

*កាលរាហុលកុមារ ស្តេចយាងទៅជាមួយនឹងព្រះសាស្តា ពួកបរិវារ ក៏មិនអាចក្រាបបង្គំទូលឱ្យស្តេចយាងត្រឡប់មកវិញបាន ហើយជាទីបំផុតព្រះរាហុលកុមារ ក៏បានទៅដល់វត្តនិគ្រោធារាម ព្រមជាមួយនឹងព្រះសយម្ភូ។*

*កាលព្រះទសពលស្តេចយាងទៅដល់វត្តហើយ ទ្រង់ត្រិះរិះថា **កុមារនេះទ្រង់មានបំណងចង់បានទ្រព្យរបស់ព្រះបិតា ប៉ុន្តែទ្រព្យទាំងនោះស្ថិតនៅក្នុងវដ្តៈ ប្រកបដោយសេចក្តីចង្អៀតចង្អល់ច្រើន ដូច្នេះ តថាគតនឹងឱ្យអរិយទ្រព្យ***

*គឺទ្រព្យដ៏ប្រសើរ៧ប្រការ ដែលតថាគតបានមកពីដើមពោធិព្រឹក្សឱ្យដល់គេ ធ្វើឱ្យគេជាម្ចាស់នៃលោកុត្តរទ្រព្យ។*

*រួចទើបព្រះអង្គត្រាស់ហៅព្រះសារីបុត្រដ៏មានអាយុ ហើយត្រាស់ថា៖*

*"សារីបុត្រ ចូរអ្នកបំបួសរាជកុមារនេះឱ្យផងចុះ"។*

*គ្រានោះ ទើបព្រះសារីបុត្រ ចាត់ចែងបំបួសរាហុលកុមារ ឱ្យជាសមណៈ។ ក្នុងពេលនោះ សមណេររាហុល មានអាយុបានត្រឹមតែ៧ខួប ប៉ុណ្ណោះ ថែមទាំងរាប់ថាជាសមណេរដំបូង នៅក្នុងព្រះពុទ្ធសាសនាទៀតផង។*

*លុះព្រះរាហុលកុមារ ទ្រង់ព្រះផ្នួសរួចហើយ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់កើតទុក្ខទោមនស្សយ៉ាងក្រៃលែង ហើយក្នុងកាលដែលព្រះអង្គមិនអាចអត់សង្កត់ព្រះទ័យចំពោះទុក្ខនោះបាន ទើបទ្រង់ក្រាបទូលសូមពរចំពោះព្រះសាស្តាថា៖*

*"បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំបំបួសឱ្យដល់កុលបុត្រដែលមាតាបិតាគេមិនបានអនុញ្ញាតជាមុន"។*

*គ្រានោះ ព្រះលោកនាថទ្រង់ទទួលព្រះរាជតម្រាស់ របស់ព្រះសុទ្ធោទនមហារាជ ដែលទ្រង់ក្រាបទូលសូមពរនោះ។*

*ហេតុ ដែលព្រះនាងយសោធរា ទ្រង់បានសម្រេចព្រះទ័យ ចេញសាងផ្នួសជាភិក្ខុនីនោះ មានរឿងសំដែងប្រាកដទុកនៅក្នុងអដ្ឋកថា**គម្ពីរមនោរថបូរណី** ដូចមានសេចក្តីថា៖*

*កាលតមក ព្រះបាទសុទ្ធោទនៈ ព្រះពុទ្ធបិតាទ្រង់បរិនិព្វានទៅហើយ ព្រះនាងមហាបជាបតិគោតមី ព្រមដោយស្ត្រី៥០០នាក់ទៀត ទ្រង់បានសាងព្រះផ្នួសជាភិក្ខុនី នៅក្នុងសម្នាក់ព្រះសាស្តាហើយ។ ចំណែកព្រះនាងយសោធរារាហុលមាតា និងព្រះនាងជនបទកល្យាណី (ព្រះនាងរូបនិន្ទា) ក៏*

បានស្តេចយាងចេញទៅសាងព្រះផ្នួស នៅក្នុងសម្នាក់ព្រះនាងមហាបជាបតិគោតមីថេរីដែរ។ រាប់តាំងពីពេលដែលព្រះនាងយសោធរា ទ្រង់បានសាងព្រះផ្នួសជាភិក្ខុនីហើយ ព្រះនាងបានប្រាកដព្រះនាមថា **ភទ្ទាកញ្ចនាថេរី**។

ចំណែករឿងដែលព្រះនាងយសោធរាថេរី បានសម្រេចព្រះទ័យចេញសាងព្រះផ្នួស តាមដែលបានសំដែងប្រាកដនៅក្នុងអដ្ឋកថាជាតក ដែលអដ្ឋកថាអធិប្បាយសេចក្តីក្នុង **អព្ភន្តរជាតក** នៃ**គម្ពីរខុទ្ទកនិកាយ ជាតក** ក្នុងអព្ភន្តរវគ្គ ដូចមានសេចក្តីថា៖

**សម័យមួយ ព្រះសាស្តាគង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ត្រាស់ប្រារព្ធរឿងរបស់ព្រះសារីបុត្រ ដែលឱ្យទឹកផ្លែស្វាយដល់ព្រះនាងយសោធរាថេរី ហើយទ្រង់សំដែងអព្ភន្តរជាតកឡើងដូចតទៅថា ៖**

**កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងធម្មចក្រហើយ ស្តេចយាងទៅគង់ប្រថាប់នៅឯកូដាគារសាលា នាព្រៃមហាវ័ន នៅក្នុងក្រុងវេសាលី។ ក្នុងឱកាសនោះ ព្រះនាងមហាបជាបតិគោតមី នាំនាងសាកិយានី៥០០នាក់ ទៅក្រាបទូលបព្វជ្ជាឧបសម្បទា នៅក្នុងសម្នាក់ព្រះភគវាជាម្ចាស់។ កាលបានបព្វជ្ជាឧបសម្បទាហើយ តមកខាងក្រោយ បានស្តាប់នន្ទកោវាទសូត្រ[៦១] ក៏បានសម្រេចព្រះអរហត្ត។**

កាលព្រះសាស្តាជានាយក ទ្រង់គង់ប្រថាប់នៅក្រុងសាវត្ថី ព្រះនាងយសោធរា ទ្រង់ត្រិះរិះថា **ស្វាមីរបស់យើង ទ្រង់សាងផ្នួសហើយបានសម្រេចជាព្រះសព្វញ្ញូ សូម្បីព្រះរាហុលកុមាររបស់យើង ក៏បានទៅបព្វជ្ជានៅក្នុងសម្នាក់របស់ព្រះអង្គដែរ ដូច្នេះ យើងនៅក្នុងព្រះរាជវាំងនេះតទៅទៀត តើមាន**

---

(៦១) **នន្ទកោវាទសូត្រ** បិដកលេខ២៨ ទំព័រ២៧១។

ប្រយោជន៍អ្វី? យើងនឹងបព្វជ្ជា ហើយកាលយើងបព្វជ្ជានោះ យើងនឹងបាន ឃើញព្រះសម្ពុទ្ធ និងបុត្ររបស់យើងជានិច្ចដែរ។

កាលដែលព្រះនាងទ្រង់ត្រិះរិះដូច្នេះហើយ ទើបស្តេចទៅបព្វជ្ជានៅក្នុង សម្នាក់ភិក្ខុនី និងក្រោយពីបានបព្វជ្ជារួចហើយ ព្រះនាងយសោធរាថេរី ក៏បាន ស្តេចយាងទៅនៅក្នុងក្រុងសាវត្ថី ព្រមដោយឧបជ្ឈាយ៍ និងអាចារ្យ។

ថ្ងៃមួយ ព្រះនាងទ្រង់បានទតឃើញព្រះសម្ពុទ្ធជានាយក និងសាមណេរ រាហុល នៅក្នុងសម្នាក់ភិក្ខុនីមួយកន្លែង។

រីឯសាមណេររាហុល បានជ្រាបដំណឹងថា ព្រះមាតាស្តេចយាងមក ទើបនិមន្តទៅសួរសុខទុក្ខព្រះមាតា នៅក្នុងសម្នាក់ភិក្ខុនី ក្នុងខណៈដែលព្រះ នាងយសោធរាភិក្ខុនី កើតរោគចាក់សៀតនៅក្នុងព្រះឧទរ ដូច្នេះ ព្រះនាងមិន បានយាងចេញទៅជួបបានឡើយ ទើបភិក្ខុនីទាំងឡាយ ប្រាប់រឿងអាពាធរបស់ ព្រះនាងយសោធរាភិក្ខុនី ដល់សាមណេររាហុលបានជ្រាប។

នៅពេលដែលសាមណេររាហុល បានជ្រាបរឿងនោះហើយ ទើប ទៅកាន់ទីលំនៅរបស់ព្រះនាងយសោធរាភិក្ខុនីព្រះជននី រួចទូលសួរថា៖

"ញោមនឹងត្រូវការវត្ថុណា សូមទ្រង់ប្រាប់នូវបំណងនោះ ដល់ខ្ញុំព្រះ ករុណា តាមប្រាថ្នាចុះ"។

គ្រានោះ ព្រះនាងយសោធរាភិក្ខុនី ទើបត្រាស់ប្រាប់ឱ្យរាហុលបានជ្រាប ថា៖

"កូនសម្លាញ់ កាលញោមនៅក្នុងប្រាង្គប្រាសាទ បានផឹកទឹកផ្លែស្វាយ លាយនឹងស្ករត្នោត រោគខ្យល់នោះនឹងស្ងប់រំងាប់ទៅ តែឥឡូវនេះ ញោមចារិកបិណ្ឌបាតចិញ្ចឹមជីវិត នឹងបានរបស់នោះមកពីណាបាន?"

លំដាប់នោះ ទើបសាមណេររាហុល ទូលថា៖

"ទូលបង្គំ ខ្ញុំព្រះករុណា នឹងនាំទឹកផ្លែស្វាយលាយនឹងស្ករត្នោត មកថ្វាយញោមមាតា"។

រួចហើយ សាមណេររាហុលក៏ទូលលាចេញទៅ។ ម្យ៉ាងទៀត ធនធានបុគ្គលដែលចាត់ជាសម្បត្តិធំរបស់រាហុលមានច្រើន បានដល់សារីបុត្រ ដែលជាព្រះឧបជ្ឈាយ៍ ព្រះមហាមោគ្គល្លាន ដែលជាអាចារ្យ ព្រះអានន្ទ ដែលជាព្រះបិតុលា ព្រះសម្ពុទ្ធ ព្រះអង្គជាព្រះបិតា។ សូម្បីយ៉ាងនោះ សាមណេររាហុលក៏មិនបានទៅរកអ្នកដទៃ តែបានទៅរកព្រះសារីបុត្រ ដែលជាព្រះឧបជ្ឈាយ៍។ ក្រោយពីព្រះរាហុលបានថ្វាយបង្គំហើយ ក៏នៅស្ងៀម ដោយសម្តែងអាការលំបាកចិត្ត ដរាបប្រាកដឱ្យឃើញច្បាស់ថាមានបញ្ហា។

គ្រានោះ ព្រះសារីបុត្រ បានឃើញអាការនោះហើយ សួរថា៖

"នែ សាមណេររាហុល អ្នកមានហេតុអ្វីឬ បានជាមានទឹកមុខស្រងូតស្រងាត់ មិនស្រស់ស្រាយសោះ?"

រាហុលសាមណេរ តបថា៖

"ព្រះករុណាព្រះឧបជ្ឈាយ៍ ព្រះនាងយសោធរា ដែលជាញោមរបស់ខ្ញុំព្រះករុណា កើតរោគខ្យល់ក្នុងព្រះឧទរ"។

គ្រានោះ ព្រះសារីបុត្រសួរថា៖

"ញោមរបស់អ្នក មានអ្វីរក្សារោគខ្យល់ក្នុងព្រះឧទរ ទើបបានជាសះស្បើយទៅ?"

សាមណេររាហុល តបថា៖

"ញោមរបស់ខ្ញុំព្រះករុណា ដែលអាចជាសះស្បើយរោគក្នុងឧទរនោះទៅបាន ទាល់តែមានទឹកផ្លែស្វាយលាយជាមួយស្ករត្នោត លោកម្ចាស់"។

ទើបព្រះសារីបុត្រ លួងលោមសាមណេររាហុលឱ្យអស់កង្វល់ក្នុងចិត្តថា៖

"អ្នកកុំលំបាកចិត្តអ្វីឡើយ គង់តែនឹងរកទឹកផ្លែស្វាយ លាយជាមួយនឹងស្ករត្នោត បានមិនខានឡើយ"។

លុះថ្ងៃស្អែកពេលព្រឹកឡើង ព្រះសារីបុត្រ បាននាំសាមណេររាហុលចូលទៅកាន់ក្រុងសាវត្ថី ហើយឱ្យសាមណេររាហុលគង់សម្រាកនៅសាលាឆាន់ រីឯខ្លួនលោកបានចូលទៅក្នុងព្រះរាជវាំង។

គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់បានទតឃើញព្រះសារីបុត្រនិមន្តមក ទើបត្រាស់អារាធនាឱ្យព្រះថេរៈគង់លើអាសនៈ។ ក្នុងខណៈនោះ អ្នករក្សាព្រះរាជឧទ្យានបាននាំយកផ្លែស្វាយទុំមួយ ចូលមកថ្វាយដល់ព្រះរាជា។ ព្រះបាទបសេនទិកោសល ទ្រង់ទទួលផ្លែស្វាយទុំនោះហើយ ទ្រង់មានសេចក្តីជ្រះថ្លា ទើបចិតសំបក និងច្របាច់យកទឹកស្វាយ លាយជាមួយនឹងស្ករត្នោតដោយព្រះអង្គឯងផ្ទាល់រួចស្រេចហើយ ទើបទ្រង់យកទៅដាក់ក្នុងបាត្រ រួចទ្រង់យកបាត្រនោះ ទៅប្រគេនព្រះសារីបុត្រ។

កាលព្រះសារីបុត្រ បានទទួលទឹកផ្លែស្វាយ លាយជាមួយស្ករត្នោតរួច ព្រះថេរៈក៏ចម្រើនពរព្រះរាជា ដោយនិមន្តចេញពីព្រះរាជវាំងតម្រង់ទៅកាន់សាលាឆាន់ ហើយបានប្រគល់ទឹកផ្លែស្វាយលាយជាមួយស្ករត្នោតនោះឱ្យដល់សាមណេររាហុល ព្រមគ្នានឹងពោលថា៖

"ណោះ សាមណេរ! ចូរនាំយកទឹកផ្លែស្វាយនេះ ទៅថ្វាយដល់ញោមមាតារបស់អ្នកចុះ"។

គ្រានោះ សាមណេររាហុល បានប្រញាប់នាំយកនូវទឹកផ្លែស្វាយលាយជាមួយនឹងស្ករត្នោត ទៅថ្វាយដល់ព្រះនាងយសោធរាថេរី។

កាលព្រះនាងយសោធរាថេរី បានសោយទឹកផ្លែស្វាយលាយជាមួយនឹងស្ករត្នោតនោះរួចហើយ រោគខ្យល់នៅក្នុងព្រះឧទរក៏ស្ងប់រំងាប់ទៅ។

រីឯព្រះបាទបសេនទិកោសល ទ្រង់បានបញ្ជូនមនុស្សទៅស៊ើបមើលថា ព្រះសារីបុត្រ មិនគង់ឆាន់ទឹកផ្លែស្វាយ ដែលលាយជាមួយស្ករត្នោតក្នុងទីនេះ ចូរអ្នកទៅស៊ើបមើលឱ្យដឹងការពិតថា ព្រះថេរៈនាំទៅឱ្យដល់បុគ្គលណា?

បុរសនោះ បានទៅព្រមគ្នានឹងព្រះសារីបុត្រ រួចកាលបើគេបានដឹងរឿងនោះហើយ ទើបត្រឡប់មកក្រាបបង្គំទូល ឱ្យព្រះបាទបសេនទិកោសល ទ្រង់ជ្រាបវិញ។

កាលព្រះបាទបសេនទិកោសលទ្រង់ជ្រាប ក៏ទ្រង់ត្រឡប់រឭកវិញថា ប្រសិនបើព្រះភគវាទ្រង់នៅគ្រប់គ្រងផ្ទះវិញ ទ្រង់នឹងបានជាស្តេចចក្រពត្តិ ចំណែកព្រះនាងយសោធរានឹងបានជានារីកែវ រីឯព្រះរាហុលនឹងបានជានាយកកែវ ចំណែករាជសម្បត្តិក្នុងចក្រវាលទាំងអស់ នឹងធ្លាក់មកជារបស់ព្រះអង្គ រីឯពួកយើងក៏នឹងត្រាច់ជាប់ទៅតាមបដិបត្តិលោកដែរ តែឥឡូវនេះ លោកទាំងអស់នោះនាំគ្នាទៅសាងផ្នួស និងអាស្រ័យពឹងយើងៗមិនគួរប្រមាទក្នុងការបដិបត្តិ ទំនុកបម្រុងពួកលោកឡើយ។

ចាប់ផ្តើមអំពីពេលនោះមក ទើបព្រះរាជាត្រាស់ឱ្យព្រះរាជទានទឹកផ្លែស្វាយដែលលាយនឹងស្ករត្នោត ឱ្យដល់ព្រះនាងយសោធរាថេរីជាប្រចាំ។

ការដែលព្រះសារីបុត្រ បានថ្វាយទឹកផ្លែស្វាយលាយជាមួយនឹងស្ករត្នោត ឱ្យដល់ព្រះនាងយសោធរាថេរី រឿងនោះក៏បានឮដល់ភិក្ខុទាំងឡាយ។

ថ្ងៃមួយ ភិក្ខុទាំងឡាយបានអង្គុយសន្ទានាគ្នា ក្នុងរឿងរបស់ព្រះសារីបុត្រ ដែលបានធ្វើដូច្នោះនៅក្នុងសាលាធម្មសភាថា៖

"លោកអ្នកមានអាយុទាំងឡាយ បានឮថា ព្រះសារីបុត្រដ៏មានអាយុ ថែទាំ យកចិត្តទុកដាក់ជាមួយនឹងព្រះនាងយសោធរាថេរី ដោយទៅនាំ

យកនូវទឹកផ្លែស្វាយ ដែលលាយជាមួយនឹងស្ករត្នោត ទៅថ្វាយដល់ព្រះនាង"។

គ្រានោះ ព្រះទសពល ស្ដេចពុទ្ធដំណើរដល់សាលាធម្មសភា ទើបត្រាស់សួរថា ៖

"ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបានអង្គុយប្រជុំសន្ទនាគ្នាពីរឿងអ្វី អម្បាញ់មិញ?"

ភិក្ខុទាំងឡាយក្រាបទូលតបថា៖

"បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ពួកខ្ញុំសន្ទនាគ្នាអំពីរឿងព្រះសារីបុត្រ ដែលបាននាំយកទឹកផ្លែស្វាយ លាយជាមួយនឹងទឹកស្ករត្នោត ទៅឱ្យដល់ព្រះនាងយសោធរាថេរី ព្រះអង្គ"។

គ្រានោះ ទើបព្រះសក្យមុនី ទ្រង់ត្រាស់ថា៖

"ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ថែរក្សា យកចិត្តទុកដាក់នឹងព្រះនាងយសោធរាពាហុលមាតា ដោយទឹកផ្លែស្វាយ លាយជាមួយនឹងស្ករត្នោត មិនមែនមានតែក្នុងពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតជាតិ ក៏ព្រះសារីបុត្រ ធ្លាប់បានយកចិត្តទុកដាក់ ចំពោះព្រះនាងយសោធរា ក៏មានដូចគ្នាដែរ"។

រួចហើយព្រះអង្គទ្រង់ត្រាស់នាំយកនូវរឿងអតីតជាតិ មកត្រាស់សម្ដែងថា៖

"ក្នុងអតីតកាល មានស្ដេចមួយព្រះអង្គព្រះនាមព្រហ្មទត្តទ្រង់គង់សោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី។ គ្រានោះព្រះពោធិសត្វកើតនៅក្នុងត្រកូលព្រាហ្មណ៍ ដែលស្ថិតនៅក្នុងតំបន់កាសិកគ្រាម រួចកាលចម្រើនវ័យធំដឹងក្ដី ក៏បានទៅសិក្សាសិល្បវិជ្ជានៅក្នុងនគរតក្កសិលា លុះរៀន

ចប់ បានត្រឡប់មកគ្រប់គ្រងផ្ទះ តែកាលមាតាបិតាស្លាប់អស់ហើយ លោកបានចេញទៅបព្វជ្ជាជាឥសី នៅក្នុងព្រៃហិមពាន្ត បានញ៉ាំង សមាបត្តិ និងអភិញ្ញាឱ្យកើតឡើង។

កាលតមក លោកក៏បានជាអាចារ្យប្រចាំគណៈ មានពួកឥសីជាបរិវារជា ច្រើននាក់។ លុះរយៈកាលកន្លងទៅជាយូរ ឥសីពោធិសត្វ ព្រមដោយ ឥសីជាបរិវារមានសេចក្តីត្រូវការបរិភោគអាហារមានរសជាតិជូរប្រៃ ទើប នាំគ្នាចុះចាកភ្នំ ត្រាច់សញ្ចរទៅតាមលំដាប់ រហូតដល់នគរពារាណសី ថែមទាំងបាននាំគ្នាចូលទៅស្នាក់អាស្រ័យនៅក្នុងព្រះរាជឧទ្យាន។

គ្រានោះ ភពរបស់សក្កទេវរាជ(ព្រះឥន្ទ) កើតអាការញាប់ញ័រ ដោយ អំណាចតេជានុភាពរបស់សីលនៃពួកឥសីទាំងអស់នោះ ហើយព្រះអង្គ ពិចារណាមើលក៏ទ្រង់បានជ្រាបហេតុនោះ ទើបទ្រង់សម្រេចព្រះទ័យថា យើងនឹងព្យាយាមមិនឱ្យពួកតាបសទាំងអស់នោះ បាននៅក្នុងទីនោះ តទៅទៀតទេ ព្រោះកាលតាបសនោះត្រូវរុកកួនឱ្យខ្ចាត់ខ្ចាយចេញពីទី នេះដោយដើររេរា ក៏មិនបានឯកគ្គតាចិត្ត (ចិត្តដែលមានអារម្មណ៍តែ មួយ) ប្រសិនបើយ៉ាងនេះ យើងនឹងបានក្សេមក្សាន្ត ឬសេចក្តីសុខ។

រួចហើយព្រះអង្គ ទ្រង់ពិចារណាថា **យើងនឹងធ្វើឧបាយណាហ្ន៎ ក៏បាន ប្រទះឧបាយដែលនឹងត្រូវប្រើធ្វើឱ្យពួកតាបស ត្រូវគេចចេញពីព្រះរាជ ឧទ្យាន** ហើយព្រះអង្គស្តេចចូលទៅកាន់ដំណាក់សិរីសេយ្យាសនៈ ប្រថាប់នៅក្នុងអាកាស ហើយប្រកាសឱ្យអគ្គមហេសីទ្រង់ជ្រាបថា ព្រះ អង្គជាសក្កទេវរាជ កាលទ្រង់បានចរចា ជាមួយនឹងព្រះនាង ទើបត្រាស់ ពីរព្រះគាថាថា៖

**អព្ភុគ្គតោជាម ឩមោ, យស្ស ឌិព្យមិជំ ឆលំ;**

**កុត្វា ទោហឡិនី នារី, ចក្កវត្តិំ វិជាយតិ។**

"នាងនារីមានបែបចាញ់ផ្ទៃ បានបរិភោគផ្លែឈើ (ស្វាយ) ឈ្មោះអព្ភន្តរៈ ជាទិព្វ ហើយប្រសូត (ព្រះរាជបុត្រ) ជាស្តេចចក្រពត្តិ។

**ត្វម្បិ ភទ្ទេ មហេសីសិ, សា ចាបិ បតិនោ បិយា;**

**អាហរិស្សតិ តេ រាជា, ឥទំ អព្ភន្តរំ ផលំ។**

ម្នាលនាងដ៏ចម្រើន នាងជាមហេសី ទាំងជាទីស្រឡាញ់របស់ព្រះរាជាជាកស្តា ព្រះរាជានឹងនាំផ្លែស្វាយ ឈ្មោះអព្ភន្តរៈនេះ មកដល់នាង"។

សក្កទេវរាជ លុះទ្រង់បានត្រាស់ជាមួយនឹងព្រះរាជទេវីដូច្នេះហើយ ទើបទ្រង់ត្រាស់ថាៈ

"សូមព្រះនាងកុំប្រមាទ ទ្រង់កុំរង់ចាំឱ្យយឺតយូរឡើយ គប្បីក្រាបទូលព្រះរាជា ជាកស្តាក្នុងថ្ងៃស្អែកនេះ"។

ក្រោយពីព្រះអង្គទ្រង់ពោលណែនាំយ៉ាងនេះហើយ ក៏ស្តេចយាងត្រឡប់ទៅកាន់ស្ថានរបស់ព្រះអង្គវិញ។

លុះស្អែកឡើង ព្រះនាងក៏ទ្រង់សម្តែងអាការប្រឈួន ទ្រង់ឱ្យសញ្ញាដល់ពួកស្រីស្នំ ហើយទើបយាងចូលទៅកាន់ក្រឡាព្រះបន្ទំរបស់ព្រះនាង។

គ្រានោះ ព្រះបាទព្រហ្មទត្ត ទ្រង់គង់ប្រថាប់លើកញ្ចនសិង្ហាសនៈ ដែលនៅខាងក្រោមស្វេតច្ឆត្រ បានទតមើលពួកស្រីស្នំ តែមិនបានឃើញអគ្គមហេសី ទើបទ្រង់មានព្រះរាជតម្រាស់សួរពួកស្រីស្នំទាំងនោះថាៈ

"តើព្រះនាងទេវី ទ្រង់គង់ប្រថាប់នៅទីណា ឬទៅណា?"

ពេលនោះ ពួកស្រីស្នំ បានក្រាបបង្គំទូលថាៈ

"ព្រះរាជទេវី ទ្រង់ប្រឈួន ព្រះពរម្ចាស់"។

លំដាប់នោះ ព្រះបាទព្រហ្មទត្ត ស្ដេចបានយាងចូលទៅកាន់ក្រឡាព្រះបន្ទំនៃព្រះរាជអគ្គមហេសី លុះទ្រង់យាងទៅដល់ ព្រះរាជាក៏ទ្រង់យាងគង់ប្រថាប់លើទៃនសយនា ទ្រង់បានស្ទាបព្រះភក្ត្រ ហើយត្រាស់សួរថាៈ

"ព្រះទេវីដ៏ចម្រើន នាងមិនសប្បាយឬ? ឬមានរឿងអ្វី?"

លំដាប់នោះ ព្រះនាងបានក្រាបបង្គំទូលតបថាៈ

"ព្រះពរម្ចាស់ បពិត្រមហារាជ ការមិនផាសុកជទៃរបស់ខ្ញុំម្ចាស់មិនមាន តែខ្ញុំម្ចាស់កើតប្រាថ្នា (កើតរោគចាញ់គភ៌)"។

ព្រះបាទព្រហ្មទត្តត្រាស់សួរថាៈ

"ព្រះទេវីប្រាថ្នាអ្វី?"

ព្រះនាងក្រាបទូលតបថាៈ

"ខ្ញុំម្ចាស់ប្រាថ្នាផ្លែស្វាយអព្ភន្តរ"។

ព្រះរាជាបានត្រាស់សួរថាៈ

"ព្រះទេវីដ៏ចម្រើន ផ្លែស្វាយអព្ភន្តរ មាននៅទីណា?"

ព្រះនាងក៏បានទូលតបដោយព្រះវាចាថាៈ

"សូមព្រះតេជះតម្កល់លើត្បូង ខ្ញុំម្ចាស់មិនបានដឹងថាផ្លែស្វាយអព្ភន្តរមាននៅក្នុងទីណាទេ តែប្រសិនបើខ្ញុំម្ចាស់បានផ្លែស្វាយនោះ ជីវិតរបស់ខ្ញុំម្ចាស់អាចរស់តទៅទៀតបាន តែប្រសិនបើមិនបានទេ ជីវិតរបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់មិនខានឡើយ ព្រះអង្គ"។

គ្រានោះ ព្រះបាទព្រហ្មទត្តទ្រង់ទទួលជានាថាៈ

"ប្រសិនបើយ៉ាងនោះ យើងនឹងឱ្យមនុស្សទៅរកមក ព្រះនាងទេវីកុំបារម្ភឡើយ"។

*ព្រះរាជាបានត្រាស់លួងលោមព្រះនាងទេវីរួច ទ្រង់បានយាងទៅគង់ប្រថាប់លើរាជបល្ល័ង្ក ហើយត្រាស់ព្រះរាជបញ្ជាឱ្យពពួកអាមាត្យ មកចូលគាល់ និងបានត្រាស់សួរថា៖*

*"នែអស់លោកទាំងឡាយ ព្រះទេវីទ្រង់កើតសេចក្តីប្រាថ្នា ចង់បានផ្លែស្វាយអព្ភន្តរ តើយើងគប្បីធ្វើយ៉ាងណាទើបប្រពៃ?"*

*លំដាប់នោះ ពួកអាមាត្យ បានក្រាបបង្គំទូលថា៖*

*"បពិត្រព្រះសម្មតិទេព ដើមស្វាយដែលនៅកណ្តាលដើមស្វាយ ២ ដើមឈ្មោះថា ស្វាយអព្ភន្តរ ពួកទូលបង្គំទាំងឡាយនឹងបញ្ជូនមនុស្សឲ្យទៅកាន់ព្រះរាជឧទ្យាន ឲ្យនាំផ្លែស្វាយអំពីដើមស្វាយដែលនៅចន្លោះដើមស្វាយពីរដើម មកថ្វាយព្រះទេវី"។*

*ព្រះបាទព្រហ្មទត្តត្រាស់ថា៖*

*"ល្អហើយ ចូរទៅនាំយកផ្លែស្វាយអព្ភន្តរមកចុះ"។*

*បន្ទាប់មកព្រះអង្គក៏បានបញ្ជូនមនុស្សឱ្យទៅកាន់ព្រះរាជឧទ្យាន។*

*ចំណែកឯព្រះសក្កទេវរាជ ទ្រង់បានដាក់ឧបាយទុកមករួចជាស្រេចហើយ ទើបទ្រង់បណ្តាលឱ្យផ្លែស្វាយនៅក្នុងព្រះរាជឧទ្យាន អន្តរធានទៅអស់ដែលមើលទៅស្រដៀងនឹងទើបមនុស្សបេះស៊ីអស់ដោយអានុភាពរបស់សក្កទេវរាជ។*

*គ្រានោះ អាមាត្យទាំងឡាយ ដែលត្រូវបានប្រើទៅឱ្យនាំយកនូវផ្លែស្វាយបានដើររកទូទាំងព្រះរាជឧទ្យាន ក៏មិនបានឃើញផ្លែស្វាយ សូម្បីត្រឹមមួយផ្លែទើបនាំគ្នាត្រឡប់មកក្រាបបង្គំទូលព្រះរាជាឱ្យទ្រង់បានជ្រាបថា៖*

*"សូមព្រះតេជះតម្កល់លើត្បូង ក្នុងព្រះរាជឧទ្យានមិនមានផ្លែស្វាយទេព្រះករុណាថ្លៃវិសេស"។*

*ព្រះរាជា ត្រាស់សួរថា៖*

*"នរណាបេះស្វាយបរិភោគអស់?"*

*គ្រានោះ ពួកអាមាត្យក្រាបបង្គំទូលព្រះរាជាថា៖*

*"ច្បាស់ជាពួកតាបស បេះផ្លែស្វាយបរិភោគហើយ ព្រះអង្គ"។*

*ព្រះរាជា ទ្រង់មានព្រះរាជឱង្ការថា៖*

*"ចូរពួកលោកនាំគ្នាដេញពពួកតាបស ឱ្យចេញពីព្រះរាជឧទ្យាន"។*

*ពពួកអាមាត្យ ទទួលព្រះរាជឱង្ការហើយ ទើបនាំគ្នាទៅដេញពួកតាបស ឱ្យចេញពីព្រះរាជឧទ្យាននោះ។*

*រីឯសក្កទេវរាជ ទ្រង់ដល់ទីបំផុតនៃមនោរថ គឺទ្រង់បានសម្រេចតាមសេចក្ដីប្រាថ្នា។*

*ចំណែកព្រះនាងទេវី ទ្រង់ផ្ទំរង់ចាំនៅលើទែនសយនា ដោយព្រះទ័យទ្រង់បំណងចង់សោយផ្លែស្វាយអព្ភន្តរនោះ។*

*ព្រះរាជា កាលទ្រង់ជួបប្រទះផ្លូវដែលមិនគប្បីធ្វើ ទើបទ្រង់ត្រាស់ឱ្យប្រជុំពួកអាមាត្យ និងពួកព្រាហ្មណ៍ ហើយត្រាស់សួរថា៖*

*"ពួកលោកបានជ្រាបទេឬថា ផ្លែស្វាយអព្ភន្តរ មាននៅក្នុងទីណា ល្មមនឹងជួយគ្នា ស៊ើបស្វែងរកផ្លែស្វាយនោះបានឬទេ?"*

*គ្រានោះ ពពួកព្រាហ្មណ៍ បានក្រាបបង្គំទូលថា៖*

*"បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយ បានឮពាក្យតៗគ្នាដូចនេះថា ផ្លែស្វាយអព្ភន្តរ ជាគ្រឿងបរិភោគរបស់ទេវតាមាននៅក្នុងល្អាងមាសនៃព្រៃហិមពាន្ត ព្រះអង្គ"។*

*លំដាប់នោះ ព្រះបាទព្រហ្មទត្ត ត្រាស់សួរតទៅទៀតថា៖*

*"តើអ្នកណា អាចទៅនាំយកផ្លែស្វាយ មកអំពីទីនោះបាន?"*

ពពួកព្រាហ្មណ៍ក្រាបទូលថា៖

"មនុស្សមិនអាចទៅទីនោះបានទេ មានតែសត្វសេកទេ ព្រះករុណាថ្លៃវិសេស"។

ក្នុងសម័យនោះ ក្នុងវាំងស្ដេចមានសេកមួយ មានរាងកាយធំប៉ុនប្រមាណប៉ុនដុំកង់រទេះ បរិបូរណ៍ទៅដោយកម្លាំង ថែមទាំងមានប្រាជ្ញាឈ្លាសវៃក្នុឧបាយទៀតផង។

ព្រះបាទព្រហ្មទត្ត ទើបត្រាស់បញ្ជាឱ្យសត្វសេកនោះមក រួចត្រាស់ថា៖

"សុវបោតិកៈ យើងមានឧបការៈដល់អ្នកច្រើន អ្នកនៅក្នុងទ្រុងមាស ស៊ីរបស់លាយផ្សំជាមួយនឹងទឹកឃ្មុំក្នុងភាជន៍មាស ថែមទាំងផឹកទឹកមានរសជាតិផ្អែម លាយផ្សំជាមួយស្ករត្នោត អ្នកគួរជួយសង្គ្រោះធ្វើកិច្ចម្យ៉ាងឱ្យយើង"។

គ្រានោះ សត្វសេកទូលថា៖

"សូមព្រះតេជះតម្កល់លើត្បូង ព្រះអង្គទ្រង់មានព្រះរាជបំណងវត្ថុណា?"

ព្រះរាជាត្រាស់ថា៖

"នែ៎សុវបោតិកៈ ព្រះទេវីរបស់យើង ទ្រង់កើតសេចក្ដីប្រាថ្នាចង់បានផ្លែស្វាយអព្ពន្តរ ប៉ុន្តែផ្លែស្វាយនោះ មាននៅចន្លោះភ្នំនៃព្រៃហិមពាន្តឯណោះ និងជារបស់បរិភោគនៃទេវតា មនុស្សមិនអាចទៅដល់ទីនោះបានទេ អ្នកគួរទៅនាំយកនូវផ្លែស្វាយអព្ពន្តរ មកពីទីកន្លែងនោះ ឱ្យដល់យើងផង"។

សត្វសេក ក្រាបទូលថា៖

"ព្រះករុណាថ្លៃវិសេស ល្អហើយ ទូលព្រះបង្គំនឹងទៅនាំយកផ្លែស្វាយនោះ មកថ្វាយព្រះរាជាឱ្យទាល់តែបាន"។

បន្ទាប់អំពីនោះ ព្រះបាទព្រហ្មទត្ត បានចាត់ចែងអាហារបរិភោគដល់សត្វសេក ដោយលាយផ្សំជាមួយនឹងទឹកឃ្មុំ ដាក់ក្នុងភាជន៍មាស ថែមទាំងមានទឹកផឹកដែលមានជាតិផ្អែម លាយជាមួយនឹងស្ករត្នោត យកប្រេងដែលគេចម្រាញ់មួយរយដង មកលាបស្លាបសត្វសេក ហើយទ្រង់បីត្រកងដោយព្រះហស្តទាំងគូ ប្រថាប់ឈរនៅត្រង់សីហបញ្ជរ ហើយទ្រង់លែងសត្វសេក ឱ្យហើរទៅលើអាកាស ឆ្ពោះមុខទៅកាន់ព្រៃហិមពាន្ត។

ចំណែកសត្វសេក ក៏បានសម្តែងនូវអាការគោរពចំពោះព្រះរាជាហើយ បានហើរទៅលើអាកាសដរាបដល់ផុតពីដែនរបស់មនុស្ស បានហើរទៅដល់ទីស្នាក់នៅរបស់សត្វសេកទាំងឡាយ ដែលស្ថិតនៅរវាងភ្នំជាន់ទី១នៃព្រៃហិមពាន្ត ហើយសួរពពួកសត្វសេកទាំងអស់នោះថា៖

"ដើមស្វាយឈ្មោះអព្ភន្តរ មាននៅក្នុងទីណា? ករុណាជួយប្រាប់ដល់ខ្ញុំផងចុះ"។

គ្រានោះ ពួកសត្វសេកទាំងនោះតបថា៖

"ពួកខ្ញុំមិនដឹងទេ តែសត្វសេកទាំងឡាយ ដែលនៅក្នុងរវាងជាន់ទី២ គង់នឹងអាចដឹងបាន"។

សត្វសេកសុវបោតិកៈ ស្តាប់ដូច្នោះហើយ ទើបហើរចេញពីកន្លែងនោះទៅកាន់ភ្នំជាន់ទី២ បានឃើញពួកសេក ដែលអាស្រ័យនៅទីនោះ ក៏បានសួរទំនងដូចមុន ប៉ុន្តែសត្វសេកទាំងនោះ មិនបានដឹងពីដើមស្វាយអព្ភន្តរដូចគ្នាដែរ។ ទើបសត្វសេកសុវបោតិកៈ ហើរទៅដោយលំដាប់ រហូតដល់រវាងភ្នំជាន់ទី៧ ទើបបន្តសួរទៅកាន់ពួកសេកទាំងនោះថា៖

"ពួកលោកបានជ្រាបទេថា ដើមស្វាយអព្ភន្តរ មាននៅទីណា?"

ពួកសត្វសេក ដែលនៅអាស្រ័យនៅរវាងភ្នំជាន់ទី៧ តបថា៖

"ដើមស្វាយ ឬផ្លែស្វាយអព្ភន្តរ មាននៅក្នុងរវាងភ្នំនោះ តែជាស្វាយសម្រាប់ជាព្រះស្ងោយ របស់ស្ដេចវេស្សវណ្ណមហារាជ មិនមាននរណាម្នាក់អាចចូលទៅជិតបានឡើយ ព្រោះទីនោះត្រូវបានគេហ៊ុំព័ទ្ធជុំវិញទៅដោយសំណាញ់ដែក៧ជាន់តាំងពីគល់រហូតដល់ចុង មានពួកកុម្ភណ្ឌចំនួន១ពាន់នាក់ចាំថែរក្សា កាលអ្នកឯណាចូលទៅជិតដើមស្វាយនោះ អ្នកនោះក៏ត្រូវពួកយក្សសម្លាប់ ពួកយើងមិនអាចនាំលោកទៅកាន់ទីនោះបានទេ"។

លំដាប់នោះ ទើបសត្វសេកទទួលអាសាព្រះរាជាពោលថា៖

"ទោះបីជាពួកអ្នកមិនហ៊ាននាំយើងក្ដី តែការបង្ហាញប្រាប់នូវផ្លូវឱ្យដល់ខ្ញុំនោះខ្ញុំក៏អរគុណណាស់ទៅហើយ"។

ពួកសត្វសេក ក៏នាំគ្នាបង្ហាញប្រាប់ផ្លូវឱ្យដល់សុវបោតិកៈ ដោយសេចក្ដីករុណា។

គ្រានោះ សត្វសេកអ្នកទទួលយកអាសាព្រះរាជា កាលបើបានដឹងផ្លូវនោះហើយ ទើបហើររហូតទៅដល់ទីនោះ ប៉ុន្តែក្នុងវេលាថ្ងៃ សត្វសេកសុវបោតិកៈមិនបង្ហាញខ្លួនឱ្យនរណាឃើញឡើយ លុះដល់វេលាអធ្រាត្រ រង់ចាំពួកយក្សដែលនៅចាំរក្សាដេកលក់អស់ហើយ ទើបសត្វសេកសុវបោតិកៈហើរចូលទៅជិតដើមស្វាយ ដោយហើរសន្សឹមៗ រួចចុះត្រង់គល់នៃដើមស្វាយម្ខាង ប្រាថ្នានឹងត្បុលចូលតាមគល់ឡើងទៅ តែបានប៉ះនឹងសំណាញ់ដែក ក៏មានសំឡេងលាន់ឮឡើង។

ពេលនោះពួកយក្ស ដែលដេករង់ចាំរក្សាក៏នាំគ្នាភ្ញាក់ឡើង បានឃើញ

*សត្វសេកដែលត្បុលចូលទៅក្នុងសំណាញ់នោះ ទើបនាំគ្នាចាប់ដោយគិតថាជាចោរ រួចប្រឹក្សាគ្នាថានឹងនាំគ្នាដាក់ទោសដល់សត្វសេកនោះយ៉ាងណាទើបជាការល្អ។*

*យក្សមួយ បានបញ្ចេញគំនិតថា យើងគួរនឹងស៊ីសត្វសេកនេះ។*

*យក្សមួយទៀតយល់ថា យើងគួរញីសត្វសេកនេះដោយដៃឱ្យបែកខ្ទេច។*

*យក្សមួយទៀត គិតឃើញថា យើងគួរពុះសត្វសេកនេះចេញជាពីចម្រៀក ហើយអាំងស៊ីល្អជាង។*

*សត្វសេកសុបោតិកៈ បានឮវិធីដាក់ទោសរបស់យក្សទាំងនោះ ក៏មិននឹងភ័យខ្លាចអ្វីឡើយ ថែមទាំងនិយាយទៅកាន់ពួកយក្សទាំងនោះដោយសួរថា៖*

*"ពួកលោកជារាជបុរសរបស់ពួកណា?"*

*យក្សតបថា៖*

*"ពួកយើងជារាជបុរសរបស់ស្តេចវេស្សវ័ណមហារាជ"។*

*ទើបសុវបោតិកៈ ពោលថា៖*

*"ពួកលោកជារាជបុរសរបស់ក្សត្រមួយអង្គ ហើយខ្ញុំ ក៏ជារាជបុរសរបស់មនុស្ស ដែលជាក្សត្រដូចគ្នា ដែលទ្រង់គ្រងរាជសម្បត្តិនៅក្រុងពារាណសី ព្រះអង្គបានត្រាស់ប្រើខ្ញុំមក ដោយរាជបំណងចង់បានផ្លែស្វាយអព្ពន្តរ ខ្ញុំនោះព្រមលះបង់ជីវិតចំពោះក្សត្ររបស់ខ្លួននៅក្នុងព្រះនគរនោះទើបបានជាខ្ញុំមក។*

*អ្នកណាលះបង់ជីវិត ដើម្បីប្រយោជន៍មាតាបិតា ឬម្ចាស់របស់ខ្លួន អ្នកនោះរមែងបានទៅកើតក្នុងស្ថានសួគ៌ ព្រោះដូច្នោះ កាលបើខ្ញុំស្លាប់ ខ្ញុំក៏នឹងផុតចាកកំណើតសត្វតិរច្ឆាននេះហើយនឹងកើតក្នុងទេវលោក"។*

*កាលសុវបោតិកៈ ពោលដូច្នោះហើយ ទើបបន្តទៀតថា៖*

*ភត្តុរត្តេ បរញ្ញត្តោ, យំ ហានមជិតច្ឆតិ;*

*ស្វាហំ អត្តបរិច្ចាគី, លភមានោ ភវាមហំ។*

*"បុគ្គលអ្នកក្លៀវក្លា ស៊ូលះបង់ខ្លួន ប្រឹងប្រែងក្នុងប្រយោជន៍របស់បុគ្គលអ្នកចិញ្ចឹមខ្លួន[៦២] រមែងបាននូវឋានៈណា ខ្ញុំបាននូវឋានៈនោះដែរ"។*

*កាលពួកយក្សបានស្ដាប់ពាក្យរបស់សុវបោតិកៈនោះហើយ ក៏មានចិត្តជ្រះថ្លា ថែមទាំងនិយាយថា៖*

*"សត្វសេកនេះតាំងនៅក្នុងគុណធម៌ ពួកយើងមិនគួរសម្លាប់វាទេ គួរលែងវាឱ្យទៅចុះ"។*

*រួចហើយ ពួកយក្សក៏បានលែងសេកសុវបោតិកៈ និងបានពោលថា៖*

*"យើងលែងអ្នកហើយ ចូរអ្នកទៅឱ្យបានសុខចុះ"។*

*ខណៈនោះ ទើបសុវបោតិកៈ ពោលជាមួយពួកយក្សទាំងនោះថា៖*

*"លោកទាំងឡាយ សូមកុំធ្វើឱ្យខ្ញុំខូចប្រយោជន៍ដែលបានមកឡើយ ចូរឱ្យផ្លែស្វាយមួយផ្លែ មកខ្ញុំផង"។*

*លំដាប់នោះ ពួកយក្សពោលទៅកាន់សុវបោតិកៈវិញថា៖*

*"ការឱ្យស្វាយមួយផ្លែ មិនមែនជានាទីរបស់ពួកយើងទេ ផ្លែស្វាយទាំងឡាយ ដែលមាននៅលើដើមស្វាយនេះ ស្ដេចវេស្សវ័ណ បានមករាប់ទុករួចអស់ហើយ ប្រសិនបើបាត់ទៅតែមួយផ្លែ យើងទាំងអស់គ្នាប្រាកដជាស្លាប់ ព្រោះកាលបើស្ដេចវេស្សវ័ណទ្រង់ក្រោធហើយ ដោយទ្រង់ក្រឡេកមើលត្រឹមតែម្ដង ពពួកកុម្ភណ្ឌប្រមាណមួយពាន់ នឹងត្រូវស្លាប់មួយរំពេចដូចជាគ្រាប់លូ ដែលគេដាក់ក្នុងភាជន៍ដ៏ក្ដៅ ដោយហេតុ*

---

*(៦២) បុគ្គលអ្នកចិញ្ចឹម មាន៣ គឺ មាតា បិតា ស្វាមី។ (អដ្ឋកថា)*

*នេះពួកយើងមិនហ៊ានឱ្យដល់អ្នកទេ តែពួកយើងនឹងប្រាប់អ្នកដែលអាចឱ្យដល់លោកបាន"។*

*ទើបសុវបោតិកៈសួរថា ៖*

*"តើអ្នកណាមួយ ដែលអាចនឹងឱ្យផ្លែស្វាយនោះ ដល់យើងបាន សូមប្រាប់មកចុះ?"*

*ពួកយក្សបានប្រាប់ថា ៖*

*"មានតាបសម្នាក់ឈ្មោះថា* ***ជោតិរស*** *ជាអ្នកបូជាភ្លើងនៅក្នុងបណ្ណសាលាឈ្មោះ**កាញ្ចនបន្តី** ដែលស្ថិតនៅក្នុងចន្លោះភ្នំមាសនោះ។ តាបសជោតិរស ជាកុលុបកៈ គឺអ្នកចូលទៅកាន់ត្រកូល (សំដៅដល់តាបសដែលគេឧបត្ថម្ភ) ដែលវេស្សវ័ណមហារាជតែងតែបញ្ជូនផ្លែស្វាយនោះទៅឱ្យដល់តាបសនោះជានិច្ច) ចូរអ្នកទៅរកតាបសនោះចុះ"។*

*សុវបោតិកៈពោលថា ៖*

*"ល្អហើយ"។*

*ទើបសុវបោតិកៈ ហើរទៅរកជោតិរសតាបស។ កាលទៅដល់បានធ្វើសេចក្តីគោរព រួចហើយទំនៅលើទីកន្លែងមួយដ៏សមគួរ។*

*ពេលនោះ តាបស សួរសត្វសេកថា ៖*

*"អ្នកមកពីណា?"*

*សុវបោតិកៈតបថា ៖*

*"បពិត្រលោកដ៏ចម្រើន ខ្ញុំមកពីសម្នាក់នៃព្រះរាជានៅទីក្រុងពារាណសី លោកដ៏ចម្រើន"។*

*ជោតិរសតាបស សួរតទៅទៀតថា ៖*

*"អ្នកមកទីនេះមានការអ្វី? ឬមានបំណងអ្វីដែរ?"*

សត្វសេកតបថា៖

"ខ្ញុំករុណាមកទីនេះ ដើម្បីចង់បានផ្លែស្វាយអព្ភន្តរ ព្រោះហេតុថា ព្រះរាជទេវីនៃព្រះបាទព្រហ្មទត្ត មានព្រះរាជបំណងចង់សោយផ្លែស្វាយអព្ភន្តរ ទើបទ្រង់ត្រាស់ប្រើខ្ញុំករុណាមកស៊ើបសួរស្វែងរក តែពួកយក្សមិនអាចឱ្យផ្លែស្វាយអព្ភន្តរ ដល់ខ្ញុំករុណាឡើយ ទើបប្រាប់ឱ្យខ្ញុំករុណាមករកលោកម្ចាស់"។

ជោតិរសតាបស ពោលថា៖

"ប្រសិនបើយ៉ាងនោះ ចូរអ្នកនៅរង់ចាំនៅទីនេះសិនចុះ ហើយអ្នកនឹងបានដូចបំណង ដែលអ្នកចង់បាន"។

គ្រានោះ ស្ដេចវេស្សវ័ណមហារាជ ទ្រង់បានបញ្ជូនផ្លែស្វាយឱ្យជោតិរសតាបសចំនួន៤ផ្លែ តែតាបសឆាន់អស់២ផ្លែ ឱ្យទៅសត្វសេកស៊ីមួយផ្លែ។ កាលសត្វសេកស៊ីរួចហើយ តាបសក៏យកផ្លែស្វាយមួយទៀត ដាក់ក្នុងសង្រែក រួចពាក់ត្រង់កសត្វសេក ហើយលែងសត្វសេក ឱ្យហើរត្រឡប់ទៅកាន់ក្រុងពារាណសីវិញ។

សត្វសេក បាននាំយកផ្លែស្វាយនោះ ទៅថ្វាយដល់ព្រះនាងទេវី។ កាលបើព្រះនាងទេវី បានសោយផ្លែស្វាយនោះហើយ ក៏ស្ងប់រំងាប់សេចក្ដីប្រាថ្នាចង់ថែមទាំងមានព្រះទ័យសោមនស្សរីករាយផង។

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រោសប្រទានព្រះធម៌ទេសនា អតីតជាតកនេះរួចហើយ ទើបទ្រង់ប្រជុំនិទានជាតកថា ៖

-ព្រះនាងទេវីក្នុងកាលនោះ បានមកជារាហុលមាតា

**ពុទ្ធបណិធាន**

*-សត្វសេកកាលនោះ បានមកជាព្រះរាហុល*[៦៣]

*-រីឯព្រះបាទព្រហ្មទត្តក្នុងក្រុងពារាណសីកាលនោះ បានមកជាអានន្ទ*

*-ជោតិរសតាបស ដែលបានឱ្យផ្លែស្វាយអព្ភន្តរ បានមកជាសារីបុត្រ*

*-ចំណែកតាបស ដែលនៅក្នុងព្រះរាជឧទ្យាន គឺអង្គតថាគត នេះឯង។*

*អាការប្រឈួន របស់ព្រះនាងយសោធរាថេរី ក្រៅពីការប្រឈួនដោយរោគខ្យល់ចាក់សៀតក្នុងព្រះឧទរ ដូចបានពោលមកនោះ តមកគ្រាមួយ ព្រះថេរីក៏បានប្រឈួន ដោយរោគខ្យល់ក្នុងព្រះឧទរម្តងទៀត ដែលបានសម្តែងនៅក្នុងអដ្ឋកថាជាតក ដែលអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង* ***សុបត្តជាតក***[៦៤] *ក្នុងគម្ពីរខុទ្ទកនិកាយ ជាតក ដូចមានសេចក្តីថា៖*

*គ្រាមួយ ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ប្រារព្ធចង្ហាន់បិណ្ឌបាតស្រូវសាលី ដែលផ្សំជាមួយនឹងរសត្រីឆ្អិន និងទឹកដោះថ្លាថ្មីៗ ដោយព្រះសារីបុត្រ ជួយរកឱ្យដល់ព្រះនាងយសោធរាថេរី។*

*ដូចមានរឿងតទៅទៀតថា ក្នុងសម័យនោះ ព្រះនាងយសោធរាថេរីប្រឈួនដោយរោគខ្យល់ចាក់សៀតក្នុងព្រះឧទរ។*

*គ្រានោះសាមណេររាហុលបានជ្រាបថា ព្រះនាងយសោធរាថេរី ដែលជាព្រះមាតាប្រឈួន ទើបប្រាប់រឿងនេះដល់សារីបុត្រ ដែលជាព្រះឧបជ្ឈាយ៍ថា៖*

---

[៦៣] *អដ្ឋកថា ច្បាប់ឆដ្ឋសង្គាយនា ថា* **សុកោ អានន្ទោ** *សុវបោតក ក្នុងកាលនោះ បានមកជាព្រះអានន្ទ។ ចំណែកព្រះរាជា ព្រះបរមសាស្តាមិនបានព្យាករទេ។*

[៦៤] ***សុបត្តជាតក*** *បិដកលេខ៥៨ ទំព័រ១៧៦។*

"ក្នុងកាលមុន កាលព្រះមាតាបានសោយបាយស្រូវសាលី ដែលផ្សំជាមួយរសត្រីឆ្អិន និងទឹកដោះថ្លាថ្មីៗ ហើយរោគខ្យល់ចាក់សៀតក្នុងព្រះឧទរ ក៏ស្ងប់រំងាប់ទៅ តែឥឡូវនេះ មិនដឹងថាទៅរករបស់ទាំងនោះបានមកអំពីទីណាទេ លោកម្ចាស់?"

លំដាប់នោះ ទើបព្រះសារីបុត្រ ប្រាប់ដល់សាមណេររាហុលថា៖

"ចូរអ្នកទៅនាំព្រះនាងយសោធរាថេរី ឱ្យមកគង់នៅលើសាលាឆាន់"។

ព្រះថេរៈមានថេរវាចារួចហើយ ក៏បាននិមន្តចូលទៅក្នុងព្រះរាជវាំង ដោយឆាប់រហ័ស និងថ្វាយព្រះពរដល់ព្រះបាទបសេនទិកោសល ឱ្យទ្រង់បានជ្រាប។

កាលព្រះបាទបសេនទិកោសល ទ្រង់បានជ្រាបហើយ ទើបទ្រង់ត្រាស់ឱ្យនាយពិសេសចម្អិនព្រះក្រយាស្ងោយ ឱ្យរៀបចំបាយស្រូវសាលី ផ្សំដោយរសត្រីឆ្អិន និងទឹកដោះថ្មីៗ ថ្វាយដល់ព្រះសារីបុត្រ។

កាលព្រះសារីបុត្រ បានទទួលចង្ហាន់បិណ្ឌបាត ត្រូវតាមសេចក្ដីប្រាថ្នារបស់ខ្លួនហើយ ក៏បាននាំត្រឡប់យកមកឱ្យ ដល់សាមណេររាហុលៗទើបបន្តនាំយកទៅថ្វាយដល់ព្រះនាងយសោធរាថេរី សោយព្រះក្រយាស្ងោយ ដែលផ្សំដោយរសត្រីឆ្អិន និងទឹកដោះថ្លាថ្មីៗរួចហើយ  រោគខ្យល់ចាក់សៀតនៅក្នុងព្រះឧទរ ក៏បានស្ងប់រំងាប់ទៅភ្លាមៗ មួយរំពេច។

ចំណែកឯព្រះបាទបសេនទិកោសល ទ្រង់បានបញ្ជូនរាជបុរសឱ្យទៅស៊ើបមើលថា ព្រះសារីបុត្រ នាំចង្ហាន់បិណ្ឌបាត ទៅប្រគេនដល់ភិក្ខុណា ហើយកាលដែលទ្រង់បានជ្រាបថា ការប្រព្រឹត្តទៅយ៉ាងនោះហើយ ចាប់ផ្ដើមអំពីពេលនោះមក ទ្រង់ក៏បានព្រះរាជទានចង្ហាន់បិណ្ឌបាត ដែលមានបាយស្រូវសាលី ផ្សំជាមួយរសត្រីឆ្អិន និងទឹកដោះថ្លាថ្មីៗ ថ្វាយដល់ព្រះនាងយសោធរា-

*ថេរី ជាប្រចាំ គង់ជាហេតុល្អ ដែលធ្វើឱ្យព្រះនាងយសោធរាថេរី មិនមានពេគខ្យល់បៀតបៀនព្រះនាងទៀតឡើយ។*

*ព្រះនាង**យសោធរាថេរី** បានប្រព្រឹត្តធម៌ដរាបដល់សម្រេចនូវមគ្គផលថ្នាក់ខ្ពស់បំផុតនៅក្នុងព្រះពុទ្ធសាសនា ដែលមានសម្តែងនៅក្នុង* **អដ្ឋកថាមនោរថបូរណី** *ថា៖*

*ក្នុងសម័យកាលក្រោយមក ព្រះនាងបានតាំងព្រះទ័យប្រតិបត្តិ ចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ព្រះថេរីក៏បានសម្រេចជាព្រះអរហន្តី ជាព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុត ក្នុងព្រះពុទ្ធសាសនានេះ ទាំងព្រះនាងក៏ទ្រង់ជាអ្នកជំនាញ ក្នុងអភិញ្ញាទាំងឡាយ ដែលព្រះនាងធ្លាប់បានប្រព្រឹត្តមក។*

*ការដឹងភាពអង់អាចរបស់ព្រះថេរី ដែលបានទទួលស្គាល់មកថា ព្រះនាងគង់ប្រថាប់ធ្វើសមាធិតែម្តង ទ្រង់អាចរឭកជាតិ ដែលកន្លងទៅហើយ បានដល់មួយអសង្ខេយ្យកប្ប និងមួយសែនកប្ប ដោយការនឹកម្តងៗ (ឬរឭកក្នុងខណៈចិត្តអភិញ្ញា)។*

*លោកអ្នកដែលបានអភិញ្ញាដ៏ធំ ក្នុងព្រះពុទ្ធសាសនានេះ មានត្រឹមតែ៤រូបប៉ុណ្ណោះ។*

*ចំណែកសាវកដ៏សេសទាំងអស់ នឹងរឭកជាតិក្នុងអតីត បានត្រឹមមួយសែនកប្ប មិនអាចរឭកបាន ហួសជាងនេះទៅទេ។*

*ក្នុងព្រះសាសនា របស់ព្រះភគវានៃយើង មានសាវកដែលជាអ្នកមានអភិញ្ញាធំ អាចរឭកជាតិមុនបានមួយអសង្ខេយ្យកប្ប និងមួយសែនកប្ប មានត្រឹមតែ៤រូបនោះគឺ៖*

*១- ព្រះធម្មសេនាបតីសារីបុត្រ*

*២- ព្រះមហាមោគ្គល្លាន*

*៣- ព្រះពាកុលៈ*

*៤- ព្រះនាងភទ្ទាកច្ចានាថេរី (ព្រះនាងយសោធរាថេរី)។*

*នៅក្នុង* ***អដ្ឋកថាមនោរថបូរណី*** *ក៏បានសម្ដែងផងដែរថាៈ*

*ក្នុងពុទ្ធកាល នៃព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ឧប្បត្តិឡើងក្នុងលោក បើរាប់ថយក្រោយអំពីភទ្ទកប្បនេះទៅ បានមួយសែនកប្ប។*

*គ្រានោះ ព្រះនាងយសោធរាថេរី ទ្រង់ចុះចាប់បដិសន្ធិ នៅក្នុងត្រកូលអ្នកមានធនធានម្នាក់ នៅក្នុងនគរហង្សវតី។*

*កាលនាងចម្រើនវ័យធំដឹងក្ដីហើយ ថ្ងៃមួយ នាងកុលធីតា បានទៅស្ដាប់ព្រះធម៌ទេសនា របស់ព្រះបទុមុត្តរសម្ពុទ្ធ ក៏បានឃើញព្រះអង្គទ្រង់ប្រកាសតែងតាំងភិក្ខុនីមួយរូប ទុកនៅក្នុងតំណែង ឱ្យប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងអ្នកបានអភិញ្ញាធំ នាងក៏នឹកពេញចិត្ត ក្នុងតំណែងដ៏ប្រសើរនោះ ទើបសាងកុសលកម្មផ្សេងៗ ហើយប្រាថ្នាក្នុងតំណែងនោះ។*

*នាងកុលធីតានោះ កាលអស់ជីវិតអំពីជាតិនោះហើយ ក៏បានអន្ទោលទៅកើតជាទេវតា និងមនុស្ស រហូតមួយសែនកប្ប ហើយជាតិចុងក្រោយនេះ នាងបានមកកើតជាព្រះរាជធីតា របស់ព្រះបាទសុប្បពុទ្ធ ព្រះមាតាព្រះនាមអមិត្តា ទ្រង់ជាអ្នកគ្រប់គ្រងនៅក្នុងនគរទេវទហៈ ដូចដែលបានពោលខាងដើមរួចមកហើយ។*

*ជីវប្រវត្តិ របស់ព្រះនាងយសោធរាថេរី ក៏មានសម្ដែងប្រាកដ នៅក្នុង* ***គម្ពីរខុទ្ទកនិកាយ អបទាន*** *បាននិទានពីព្រះបន្ទូល របស់ពុទ្ធសាវិកា ព្រះនាងយសោធរា មានសេចក្ដីថាៈ*

"ព្រះពុទ្ធព្រះនាមទីបង្ករ មានព្យាយាមធំ ជានាយកនៃសត្វលោក បាន កើតហើយក្នុងកប្បទី៤ អសង្ខេយ្យ និងមួយសែនកប្ប រាប់ត្រឡប់ថយ ក្រោយ។

ជនទាំងឡាយក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរបាននិមន្តព្រះតថាគត ហើយជម្រះផ្លូវ ដែលជាទីយាងមក នៃព្រះសម្មាសម្ពុទ្ធព្រះនាមទីបង្ករ នោះ។

កាលនោះ ព្រះអង្គ បានយោនយកកំណើតជាព្រាហ្មណ៍ឈ្មោះ **សុមេធ** តាក់តែងផ្លូវ សម្រាប់ថ្វាយព្រះទីបង្ករ ទ្រង់ឃើញធម៌ទាំងពួង។

រីឯខ្ញុំ(យសោធរាថេរី) ជាកញ្ញា កើតក្នុងត្រកូលព្រាហ្មណ៍ និងមានឈ្មោះ ថា សុមិត្តា បានចូលទៅកាន់ទីប្រជុំនៃជនទាំងឡាយ។

ខ្ញុំបានយកផ្កាឧប្បល (ផ្កាឈូក ផ្កាព្រលិត ឬផ្កាលំចង់) ៨ក្តាប់ ដើម្បីបូជា ព្រះសាស្តា ហើយបានឃើញឥសីដ៏ឧត្តមក្នុងកណ្តាលនៃជន។

កាលនោះ ខ្ញុំបានឃើញព្រះសម្មាសម្ពុទ្ធ ទ្រង់ខានយាងមកទីនោះអស់ កាលដ៏យូរ ហើយទ្រង់មានព្រះហឫទ័យ ប្រកបដោយករុណា ក៏បាន បណ្តាលចិត្តខ្ញុំ ឱ្យត្រេកអរក្រៃលែង និងសម្គាល់ថា**ជីវិតរបស់អាត្មាអញ ប្រកបដោយផល។**

កាលនោះ ខ្ញុំបានឃើញសេចក្តីព្យាយាម ប្រកបដោយផល របស់ឥសី នោះ ទាំងចិត្តរបស់ខ្ញុំក៏ជ្រះថ្លាក្នុងព្រះពុទ្ធដោយកុសលកម្ម ដែលមាន មកក្នុងកាលមុន។

ខ្ញុំ បានញុំាងចិត្តឱ្យជ្រះថ្លាក្រៃលែងចំពោះឥសី ដែលមានចិត្តខ្ពស់ ហើយទូលថា **បពិត្រឥសី ខ្ញុំមិនឃើញនៅក្នុងដៃរបស់លោក មានវត្ថុ ដទៃ ដែលគួរថ្វាយព្រះពុទ្ធនោះទេ ខ្ញុំសូមជូនផ្កាទាំងឡាយដល់លោក។**

*ខ្ញុំ បានទូលថ្វាយលោកឥសីទៀតថា **បពិត្រលោកឥសី ផ្កា៥ក្តាប់ចូរមាន ដល់លោកឥសី ហើយផ្កា៣ក្តាប់ចូរមានដល់ខ្ញុំ បពិត្រលោកឥសី ផ្កាទាំងឡាយ ចូរជារបស់ស្មើគ្នា មួយអន្លើដោយឥសីនោះ ដើម្បីជាប្រយោជន៍ ដល់ពោធិញ្ញាណ របស់ព្រះអង្គ។***

*សុមេធឥសី បានទទួលផ្កាឧប្បលរួចហើយ ក៏បានយកផ្កាយកទៅបូជាចំពោះព្រះទីបង្ករសម្មាសម្ពុទ្ធ ក្នុងកណ្តាលមហាជន ដើម្បីប្រយោជន៍ដល់ព្រះពោធិញ្ញាណ។*

*នៅខណៈនោះ ព្រះទីបង្ករសម្មាសម្ពុទ្ធ ទ្រង់បានព្យាករសុមេធឥសី ក្នុងកណ្តាលមហាជន ហើយព្រះពុទ្ធអង្គ ទ្រង់បានព្យាករនាងសុមិត្តាថា ស្រីនេះ មានចិត្តស្មើគ្នា មានកុសលកម្មស្មើគ្នា មានការធ្វើត្រូវជាទីស្រឡាញ់ពេញចិត្តរបស់លោក នឹងបានជាធម្មទាយាទ មានឫទ្ធិ និងរក្សានូវកុសលធម៌ទាំងឡាយ ដូចជនទាំងឡាយរក្សាទ្រព្យដូច្នោះ”។*

*ជាមួយគ្នានេះដែរ ប្រវត្តិក្នុងអតីតជាតិ របស់ព្រះនាងយសោធរាថេរី ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ក្នុងនិទានទសជាតិ ដែលជាតកទាំងនោះ បានសម្តែងដល់ការសាងបុណ្យបារមីផ្សេងៗ រួមគ្នានឹងព្រះដ៏មានព្រះភាគ កាលដែលព្រះអង្គគង់ជាព្រះបរមពោធិសត្វ ដូចមានសេចក្តីថា៖*

*ជាតក **ព្រះមហាវេស្សន្តរ** ជាជាតក ដែលពោលដល់ការបំពេញនូវទានបារមី របស់ព្រះពោធិសត្វ ដែលនឹងត្រូវបានត្រាស់ដឹងជាព្រះពុទ្ធ នៃការបំពេញបារមី មុននឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។*

*នៅខណៈនោះ ព្រះនាងយសោធរាថេរី បានយកកំណើតជាព្រះនាងមទ្រី និងបានជាព្រះអគ្គមហេសីនៃព្រះវេស្សន្តរ។*

**ពុទ្ធបណិធាន**

*ព្រះនាងទ្រង់មានព្រះទ័យត្រេកអរ ក្នុងការលះបង់គ្រប់យ៉ាង សូម្បីមហាបរិច្ចាគ ជាការលះបង់ដ៏ធំធេងក្រៃលែង របស់ព្រះបរមពោធិសត្វ គឺលះបង់ទ្រព្យ លះបង់អវយវៈ លះបង់បុត្រ និងលះបង់ភរិយា ដើម្បីធ្វើជាទាន ដោយព្រះនាងត្រូវបានធ្វើជាទាន ឱ្យដល់ព្រះឥន្ទ ដែលទ្រង់បានក្លែងភេទ ធ្វើជាព្រាហ្មណ៍ មកសូមព្រះនាង ក៏ព្រះនាងប្រតិបត្តិតាម ហើយក្នុងកាលដែលព្រះវេស្សន្តរ ទ្រង់បរិច្ចាគសត្តកមហាទាន គឺការដែលទ្រង់លះបង់នូវវត្ថុ និងមនុស្ស សត្វ ចំនួន៧០០ មិនថាជាទាសៈ ដំរី សេះជាដើម។*

*ជាតក **ព្រះមហោសថ** ព្រះនាងយសោធរា ទ្រង់បានបដិសន្ធិជានាងអមរា និងបានជាភរិយា របស់មហោសថ ដែលជាអ្នកមានបញ្ញាដ៏ប្រសើរ ហើយក៏ជាជាតក ដែលបានបង្ហាញនូវ **បញ្ញាបារមី** របស់ព្រះពោធិសត្វ។*

*ជាតក **ព្រះមហាជនក** ក្នុងកាលព្រះពោធិសត្វ ព្រះអង្គទ្រង់បំពេញនូវ **វីរិយបារមី** ឯព្រះនាងយសោធរា ទ្រង់បានកើតជា **ព្រះនាងសីវលី** និងបានជាព្រះមហេសី របស់ព្រះជនកពោធិសត្វ។*

*ក្នុងកាលដែលព្រះជនក ទ្រង់លះបង់រាជសម្បត្តិ ចេញសាងព្រះផ្នួស ព្រះនាងសីវលី ក៏ទ្រង់បានយាងចេញទៅសាងព្រះផ្នួសដែរ ថែមទាំងបានញ៉ាំងឈានសមាបត្តិឱ្យកើតទៀតផង រួចនៅពេលដែលព្រះនាងសោយព្រះទិវង្គត ក៏បានទៅកើតនៅព្រហ្មលោក។*

*ជាតក **ព្រះចន្ទកុមារ** ព្រះនាងយសោធរាថេរី ទ្រង់បដិសន្ធិជាព្រះនាងចន្ទទេវី បានជាព្រះអគ្គមហេសីរបស់ចន្ទកុមារ ទ្រង់បានរកឧបាយជួយព្រះជននី របស់ព្រះចន្ទកុមារ ឱ្យផុតពីការសម្លាប់ដើម្បីបូជាយញ្ញ។*

*ព្រះនាងបានប្រកាសលះបង់ព្រះជន្មរបស់ទ្រង់ ហើយទ្រង់ជំទាស់ជាមួយនឹងព្រះបាទឯករាជជនក និងកណ្ឌហាលព្រាហ្មណ៍ អ្នកមានចិត្តអាក្រក់*

ដែលមានបំណងសម្លាប់ព្រះចន្ទកុមារ និងប្រជាជន រួមទាំងសព្វសត្វជាច្រើន រហូតទ្រង់បានទទួលការអភ័យទោស ព្រោះទ្រង់បានសាងគុណ ជាសេចក្ដីល្អ ក្នុងជាតិនោះ ក្នុងការដែលទ្រង់បានបំពេញនូវអំពើជាកុសល រួមគ្នាជាមួយព្រះបរមពោធិសត្វ ក្នុងកំណើតដែលទ្រង់បំពេញនូវខន្តិបារមី។

នៅក្នុងជាតក**ព្រះវិធូរៈ** ព្រះនាងយសោធរាថេរី ទ្រង់បានមកជាភរិយា របស់ព្រះវិធូរបណ្ឌិត ដោយមានឈ្មោះថា នាងអនោជា គឺត្រូវញ៉ាំងចិត្តឱ្យរឹងមាំ នាខណៈព្រាត់ប្រាសចាកស្វាមី ដែលដឹងថា ក្នុងការចាកចេញទៅ ស្វាមីនឹងមិនអាចវិលមកវិញបានឡើយ ដែលក្នុងជាតិនោះ ព្រះបរមពោធិសត្វ ទ្រង់បំពេញនូវ**សច្ចបារមី**។

នៅនាឱកាសចុងក្រោយ របស់ព្រះនាងយសោធរាថេរី មុនពេលព្រះនាងក្រាបបង្គំទូលលាព្រះសម្មាសម្ពុទ្ធ ចូលទៅកាន់ព្រះនិព្វាន ដែលជាទីបរិយោសាននៃជីវិត ព្រះនាងបានមានព្រះវាចា ដូចមានក្នុង**បុព្វចរិយា របស់ព្រះនាងពិម្ពាយសោធរាកន្សែរសារពេជ្ធ, បុព្វចរិយា របស់ភិក្ខុនី១ម៉ឺនអង្គ ដែលមានព្រះនាងយសោធរា ជាប្រមុខ, បុព្វចរិយារបស់ភិក្ខុនី១ម៉ឺន៨ពាន់អង្គ ដែលមានព្រះនាងសោធរា ជាប្រមុខ** ជាដើម។

## យសោធរាថេរិយាបទាន

## បុព្វចរិយារបស់ព្រះនាងពិម្ពា យសោធរា កន្សៃ្យសារពេជ្ជ



ក្នុងសម័យមួយ ក្នុងរាជគហបុរីដែលស្ដុកស្ដម្ភដ៏មាំមួនគួររីករាយ កាលព្រះនរនាយកប្រថាប់នៅញកក្ខំវរេក:។

កាលយសោធរាភិក្ខុនីដែលអាស្រ័យនឹងពួកភិក្ខុនី នៅក្នុងនគរដ៏គួររីករាយនោះ កើតសេចក្ដីត្រិះរិះយ៉ាងនេះថា ៖

ព្រះបាទសុទ្ធោទនមហារាជ ព្រះនាងបជាបតិគោតមី ព្រះមហាថេរៈទាំងឡាយដែលមានអភិញ្ញា និងព្រះថេរីទាំងឡាយដែលមានឫទ្ធិច្រើន។

*អ្នកទាំងអស់នោះ ជាអ្នកមិនមានអាសវៈដូចជាប្រទីប បានទៅហើយ កាន់សន្តិបទ កាលព្រះលោកនាថធរមាននៅ សូម្បីយើងក៏នឹងទៅកាន់សិវបទ គឺព្រះនិព្វាន(ដែរ)។*

*កាលព្រះនាងពិចារណាអាយុរបស់ខ្លួន ឃើញនូវអាយុសង្ខារ ដែលដល់នូវការអស់ក្នុងថ្ងៃនោះឯង។*

*ព្រះនាង**យសោធរា** ជាអ្នកមានឫទ្ធិច្រើន មានបញ្ញាច្រើន កាន់យកនូវបាត្រនិងចីវរ ចេញចាកទីនៅរបស់ខ្លួន មាននាងភិក្ខុនីទាំងឡាយមួយសែនអង្គចោមរោម ហើយចូលទៅគាល់ព្រះសម្ពុទ្ធ ថ្វាយបង្គំព្រះសម្ពុទ្ធ និងលក្ខណៈ គឺចក្រ នៃព្រះសាស្តា អង្គុយក្នុងទីសមគួរ ហើយពោលពាក្យនេះថាៈ*

*"ខ្ញុំមានវស្សា៧៨ឆ្នាំ កន្លងបច្ឆិមវ័យ ខ្ញុំមកដល់ញក វ័យរបស់ខ្ញុំចាស់ណាស់ហើយ ជីវិតរបស់ខ្ញុំតិចណាស់ ខ្ញុំនឹងលះបង់ព្រះអង្គហើយទៅ  ទីពឹងរបស់ខ្លួន ខ្ញុំបានធ្វើហើយ។*

*ក្នុងកាលជាបច្ឆិមវ័យ សេចក្តីស្លាប់កាន់តែរំកិលចូលមកជិត បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំម្ចាស់នឹងដល់នូវបរិនិព្វាន ក្នុងវេលាយប់នៃថ្ងៃនេះ។*

*បពិត្រព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ មិនមាន ខ្ញុំនឹងដល់នូវបុរី ដែលជាទីឥតមានជរា ឥតមានមរណៈ ឥតមានភ័យ មិនមានបច្ច័យតាក់តែងឡើយ។*

*បពិត្រព្រះមហាមុនី ធម្មតាបរិស័ទទាំងឡាយ តែងចូលទៅអង្គុយជិតព្រះសាស្តា ដឹងច្បាស់នូវកំហុស និងសេចក្តីគួរ ក្នុងទីចំពោះព្រះភក្ត្រ។*

បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំម្ចាស់អន្ទោលទៅក្នុងសំសារ សូមក្រាបទូល នូវការភ្ញាំងភ្ញាត់របស់ខ្ញុំចំពោះព្រះអង្គ សូមព្រះអង្គអត់នូវកំហុសនោះ ដល់ខ្ញុំព្រះអង្គ"។

ព្រះមុនិន្ទ ស្តាប់ពាក្យព្រះនាងហើយ ត្រាស់យ៉ាងនេះថា៖

"តថាគត នឹងពោលអ្វីឱ្យក្រៃលែងដល់នាង ដែលដល់ព្រះនិព្វានហើយ នាងជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ នៃតថាគត ចូរនាងសម្តែងនូវឫទ្ធិ ចូរកាត់នូវសេចក្តីសង្ស័យ នៃបរិស័ទទាំងពួងក្នុងសាសនា"។

ព្រះភិក្ខុនី យសោធរា នោះ ស្តាប់ព្រះបន្ទូល របស់ព្រះមុនីហើយ ក្រាបថ្វាយបង្គំព្រះមុនិរាជ ហើយពោលពាក្យនេះថា៖

"បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំឈ្មោះយសោធរា ជាភរិយានៃព្រះអង្គ កាលនៅក្នុងផ្ទះកើតក្នុងត្រកូលសក្យៈ តាំងនៅក្នុងអង្គជាស្ត្រី។

បពិត្រព្រះអង្គមានព្យាយាម ខ្ញុំជាប្រធាននៃស្ត្រីទាំងឡាយមួយសែន៩៦ ជាធំជាងស្ត្រីទាំងពួងក្នុងផ្ទះនៃព្រះអង្គ។

ស្ត្រីទាំងពួងប្រកបដោយគុណ គឺរូប និងមារយាទ តាំងនៅក្នុងបឋមវ័យ សព្វៗកាល គោរពកោតក្រែងខ្ញុំ ដូចជាមនុស្សទាំងឡាយ គោរពកោតក្រែងទេវតា។

ស្ត្រីទាំងនោះ មានពួកនាងកញ្ញាមួយពាន់ ជាប្រធាន មានសុខ និងទុក្ខស្មើគ្នា ក្នុងដំណាក់នៃសក្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទនវ័ន។

បណ្ឌិតទាំងឡាយកន្លងនូវកាមធាតុ ប្រាកដស្មើដោយរូបក្នុងរូបធាតុ វៀរលែងតែព្រះលោកនាយកចេញ មិនមានទេ"។

យសោធរាថេរី ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយសំដែងឫទ្ធិចំពោះព្រះសាស្តា ទាំងសម្តែងឫទ្ធិច្រើន មានអាការៈផ្សេងៗច្រើនយ៉ាង គឺ ធ្វើកាយជាភ្នំចក្រវាល, ក្បាលជាឧត្តរកុរុទ្វីប, ទ្វីបទាំងពីរជាស្លាបទាំងពីរ, ជម្ពូទ្វីបជាសរីរៈ, សមុទ្រខាងត្បូងជាសំណុំកន្ទុយ, ស្មឹងជាបំពង់ស្លាប, ព្រះចន្ទ្រ និងព្រះអាទិត្យជាភ្នែក, ភ្នំមេរុជាកំប៉ោយ, ភ្នំចក្រវាលជាចំពុះ, ដើមព្រីងជាទីប្រជុំ។

រួចហើយ ចូលទៅជិតថ្វាយបង្គំ អង្គុយបក់ព្រះលោកនាយក។ សម្តែងនូវភេទនៃដំរី សេះ ភ្នំ ជលជាតិ ព្រះចន្ទ្រ ព្រះអាទិត្យ ភ្នំមេរុ ភេទ នៃព្រះឥន្ទ្រក៏ដូចគ្នា។

បន្ទាប់មក យសោធរាថេរី ថ្វាយបង្គំព្រះសម្ពុទ្ធ និងទូលថា៖

"បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គ ឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា គ្របនូវលោកធាតុមួយពាន់ ដោយផ្ការីក។

ខ្ញុំនិម្មិតភេទជាព្រហ្ម ហើយសម្តែងធម៌ដ៏សូន្យ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា។

បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយ ទាំងស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណ ដោយសោតធាតុជាទិព្វ។

ខ្ញុំព្រះអង្គដឹងនូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំព្រះអង្គបានជម្រះហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ។

បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថធម៌និរុត្តិ និងបដិភាណកើតឡើងហើយដល់ខ្ញុំ ក្នុងសំណាក់នៃព្រះពុទ្ធ។

**ពុទ្ធបណិធាន**

*បពិត្រព្រះមហាមុនី ការគប់រកព្រះលោកនាថទាំងឡាយ ព្រះអង្គបាន សម្តែងហើយដោយប្រពៃ សេចក្តីកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បី ប្រយោជន៍ដល់ព្រះអង្គ។*

*បពិត្រព្រះមុនី សូមព្រះអង្គរលឹកកុសលកម្មរបស់ខ្ញុំ ដែលមានក្នុងកាល មុន បពិត្រព្រះអង្គមានព្យាយាមធំ បុណ្យខ្ញុំបានសន្សំហើយ ដើម្បី ប្រយោជន៍ដល់ព្រះអង្គ។*

*បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំបានលះបង់នូវអកព្វដ្ឋាន ហាមឃាត់ នូវអនាចារៈ ហើយលះបង់ជីវិត ដើម្បីប្រយោជន៍ដល់ព្រះអង្គ។*

***បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ប្រទានខ្ញុំម្ចាស់អស់ជាតិ មានពាន់នៃ កោដិដ៏ច្រើន ដើម្បីជាកិរិយានៃជនដទៃវិញ ខ្ញុំមិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ។***

***បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់អស់ជាតិ មានពាន់នៃ កោដិដ៏ច្រើន ដើម្បីជាឧបការៈនៃជនដទៃ ខ្ញុំក៏មិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ។***

***បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់អស់ជាតិ មានពាន់នៃ កោដិដ៏ច្រើន ដើម្បីការប្រើប្រាស់នៃជនដទៃ ខ្ញុំមិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ។***

*ខ្ញុំបានលះបង់ជីវិត មានពាន់នៃកោដិដ៏ច្រើន ជនទាំងឡាយ នឹងធ្វើការ រួចចាកភ័យ ខ្ញុំឱ្យនូវជីវិតរបស់ខ្ញុំ។*

បពិត្រព្រះមហាមុនី ខ្ញុំមិនលាក់ទុកនូវគ្រឿងប្រដាប់សម្រាប់អវយវៈ គ្រឿងអលង្ការ សំពត់ដ៏ច្រើន មានប្រការផ្សេងៗ និងកណ្ឌៈរបស់ស្រីប្រុស ដើម្បីជាប្រយោជន៍ដល់ព្រះអង្គ។

បពិត្រព្រះមហាមុនី ការបរិច្ចាគទ្រព្យធន និងស្រូវ ទាំងស្រុក និគម ស្រែ បុត្រ និងធីតា ខ្ញុំក៏បានលះបង់ហើយ។

បពិត្រព្រះអង្គមានព្យាយាមធំ ដំរី សេះ គោ និងខ្ញុំស្រី អ្នកបម្រើ មានចំនួនរាប់មិនបាន ខ្ញុំក៏បានលះបង់ហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ។

ព្រះអង្គប្រឹក្សានូវទានណានឹងខ្ញុំ ខ្ញុំឱ្យនូវទាននោះដល់ស្វាមទាំងឡាយ កាលព្រះអង្គឱ្យទានដ៏ឧត្តម ខ្ញុំមិនឃើញសេចក្ដីតូចចិត្តរបស់ខ្ញុំទេ។

បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំរងទុក្ខច្រើនមានប្រការផ្សេងៗ មានចំនួនរាប់មិនបានក្នុងសំសារដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ ។

បពិត្រព្រះមហាមុនី កាលព្រះអង្គដល់នូវសេចក្ដីសុខ ខ្ញុំត្រេកអរ មួយទៀត ខ្ញុំមិនតូចចិត្តព្រោះទុក្ខទាំងឡាយរបស់ខ្ញុំ ខ្ញុំជាអ្នកត្រេកអរក្នុងទីទាំងពួង ដើម្បីជាប្រយោជន៍នៃព្រះអង្គ។

បពិត្រព្រះមហាមុនី ព្រះអង្គសោយសុខ និងទុក្ខ ត្រាស់ដឹងតាមលំដាប់មគ្គ ហើយដល់នូវពោធិញ្ញាណ រួចនាំមកនូវធម៌។

ខ្ញុំមានការគប់រកព្រះលោកនាថទាំងឡាយ ដទៃច្រើនអង្គ ព្រោះអាស្រ័យនូវព្រះសម្ពុទ្ធ ព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធ ព្រះនាមគោតម ដែលជាព្រះលោកនាយក។

**ពុទ្ធបណិធាន**

បពិត្រព្រះមហាមុនី ការកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បីប្រយោជន៍នៃព្រះអង្គ ខ្ញុំជាអ្នកបម្រើព្រះអង្គ ដែលស្វែងរកនូវពុទ្ធធម៌។

ព្រះពុទ្ធព្រះនាមទីបង្ករ មានព្យាយាមធំ ជានាយកនៃសត្វលោកកើតហើយ ក្នុងបួនអសង្ខេយ្យ និងមួយសែនកប្ប។

ជនទាំងឡាយ នៅក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគតហើយជម្រះផ្លូវជាទីស្តេចមកនៃព្រះទីបង្ករនោះ។

កាលនោះ ព្រះអង្គជាព្រាហ្មណ៍ឈ្មោះសុមេធៈ តាក់តែងផ្លូវសម្រាប់ថ្វាយព្រះពុទ្ធទីបង្ករ ទ្រង់ឃើញធម៌ទាំងពួង កាលស្តេចមកដល់។

កាលនោះ ខ្ញុំជាកញ្ញា កើតក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះនាងសុមិត្តា បានចូលទៅកាន់ទីប្រជុំ។ ខ្ញុំយកផ្កាឧប្បល៨ក្តាប់ ដើម្បីបូជាព្រះសាស្តា បានឃើញឥសីដ៏ឧត្តម ក្នុងកណ្តាលនៃជន។ កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ខានយាងមកអស់កាលយូរ ទ្រង់មានព្រះទ័យប្រកបដោយករុណា ក៏បណ្តាលឱ្យចិត្តត្រេកអរក្រៃលែង ហើយសម្គាល់ថាជីវិតរបស់អាត្មាអញ ប្រកបដោយផល។ កាលនោះ ខ្ញុំបានឃើញសេចក្តីព្យាយាមប្រកបដោយផលរបស់ឥសីនោះ ទាំងចិត្តរបស់ខ្ញុំក៏ជ្រះថ្លាក្នុងព្រះពុទ្ធដោយកុសលកម្ម ដែលមានក្នុងកាលមុន។

ខ្ញុំញ៉ាំងចិត្តឱ្យជ្រះថ្លាក្រៃលែង ក្នុងឥសីមានចិត្តខ្ពង់ខ្ពស់ ហើយទូលថា **បពិត្រឥសី ខ្ញុំមិនឃើញវត្ថុដទៃដែលគួរថ្វាយទេ ខ្ញុំសូមថ្វាយផ្កាទាំងឡាយដល់លោក។**

បញ្ចហត្ថា តវ ហោន្តុ, តយោ ហោន្តុ មមំ ឥសេ;

តេន សច្ចំ សមា ហោន្តុ,            ពោធត្ថាយ តវំ ឥសេ។

***បពិត្រឥសី ផ្កា៥ក្តាប់ ចូរមានដល់លោក ផ្កា៣ក្តាប់ ចូរមានដល់ខ្ញុំ បពិត្រឥសី ផ្កាទាំងឡាយចូរជារបស់ស្មើគ្នា មួយអន្លើដោយឥសីនោះ ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណរបស់ព្រះអង្គ។***

*ឥសី យកផ្កាទាំងឡាយបូជាព្រះពុទ្ធ ជាមហាឥសី មានយសធំ ដែលនៅក្នុងកណ្តាលនៃពួកជន ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណ។*

*ព្រះមហាមុនីព្រះនាមទីបង្ករ មានព្យាយាមធំ ឃើញឥសីមានចិត្តខ្ពង់ខ្ពស់ ទ្រង់ព្យាករក្នុងកណ្តាលនៃជន។*

*ព្រះមហាមុនីព្រះនាមទីបង្ករ ជាអ្នកប្រាជ្ញ ទ្រង់ព្យាករនូវអំពើរបស់ខ្ញុំ ដែលជាស្រីមានភាពត្រង់ ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ*

***ថា ម្នាលមហាឥសី ស្រីនេះនឹងជាអ្នកមានចិត្តស្មើគ្នា មានការងារស្មើគ្នា ជាអ្នកធ្វើការស្មើគ្នា ជាទីស្រឡាញ់ ដោយការងារស្មើគ្នានឹងអ្នក ដើម្បីប្រយោជន៍នៃអ្នក។***

***មួយទៀត ស្រីនេះ នឹងជាអ្នកមានរូបគួរឱ្យរមិលមើលក្រៃលែង គួរឱ្យស្រឡាញ់ពេញចិត្តក្រៃលែង ពោលពាក្យជាទីស្រឡាញ់ ជាអ្នកមានឫទ្ធិ នឹងបានជាញាតិក្នុងធម៌នៃព្រះពុទ្ធនោះ ហើយប្រៀបដូចជនជាម្ចាស់ទ្រព្យ រមែងរក្សាស្មុគ្រ សម្រាប់ដាក់នូវកណ្ឌៈយ៉ាងណា ស្រីនេះនឹងរក្សាធម៌ ជាកុសលទាំងឡាយ ក៏យ៉ាងនោះដែរ។***

*ស្រីនេះ កាលអនុគ្រោះ នូវកុសលធម៌ របស់ព្រះពុទ្ធនោះ នឹងញ៉ាំង បារមីទាំងឡាយឱ្យពេញ នឹងដល់នូវពោធិញ្ញាណ ដូចសត្វសីហៈ លះបង់ទ្រុងដូច្នោះ។*

*ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រះពុទ្ធទ្រង់ព្យាករខ្ញុំ ដោយវាចា ណា ខ្ញុំត្រេកអរចំពោះវាចានោះ ជាអ្នកធ្វើយ៉ាងនោះ។*

*កាលកុសលកម្ម ដែលខ្ញុំធ្វើល្អហើយនោះ ខ្ញុំញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុង កុសលនោះ ហើយបានកំណើតជារបស់នៃទេវតា និងមនុស្សរាប់មិន អស់ ហើយលុះទទួលនូវសេចក្តីសុខ និងទុក្ខ ក្នុងទេវតា និងមនុស្ស ហើយ ដល់មកក្នុងបច្ឆិមភព បានកើតក្នុងត្រកូលសក្យៈ។*

*លំដាប់នោះ ខ្ញុំជាអ្នកមានរូបល្អ មានភោគៈ មានយស និងសីល បរិបូណ៌ ដោយអវយវៈទាំងពួង ជាអ្នកគោរពចំពោះប្តី ក្នុងត្រកូលទាំងឡាយ។ ឯ ចិត្តរបស់ខ្ញុំ ដែលប្រជុំចុះ ក្នុងលោកធម៌ មានលាភ សេចក្តីសរសើរ និង សក្ការៈជាដើម ជាចិត្តមិនដល់ នូវសេចក្តីទុក្ខទេតើ ខ្ញុំនឹងមានភ័យអំពី ណា"។*

*សមដូចជាបន្ទូល ដែលព្រះមានព្រះភាគ បានត្រាស់ចំពោះព្រះរាជា ខាងក្នុងបុរី ដូច្នេះថាៈ*

*"បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គសម្តែងឧបការគុណរបស់នារីនៃ ពួកក្សត្រិយ៍ក្នុងបុរីនោះ គឺនារីធ្វើសេចក្តីទំនុកបម្រុង នារីដឹងសុខនិងទុក្ខ នារីប្រាប់ប្រយោជន៍ និងនារីជាអ្នកអនុគ្រោះ។*

*ដោយសារនារីនោះ តថាគត បានញុំាងមហាទាន ឱ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធ ប្រាំរយកោដិ[៦៥] និងប្រាំបួនរយកោដិ[៦៦] ជាទេវតាក្រៃលែងជាងទេវតា។*

*បពិត្រមហារាជ សេចក្ដីកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ព្រះពុទ្ធទាំងឡាយជានាយក ជាកំពូលនៃលោក ដប់មួយរយកោដិ[៦៧]។*

*តថាគត បានញុំាងមហាទានឱ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត។*

*ព្រះពុទ្ធទាំងឡាយ ពីរពាន់កោដិ[៦៨]ផង បីពាន់កោដិ[៦៩]ផង តថាគត បានញុំាងមហាទានឱ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា។*

---

[៦៥] តត្ថ **បញ្ចកោដិសតា ពុទ្ធាតិ** នន្ទអសង្ខ្យេយ្យេ ព្រហ្មទេវាទិបញ្ចកោដិសតា បញ្ចសហស្សសម្មាសម្ពុទ្ធា ឧប្បន្នា, កោដិសទ្ទោ ហិ ទសសង្ខ្យត្ថវាចកោ, វត្ថកោដិសហស្សាទីតិអាទិសុ វិយ, ជរមុបរិបិ។ ឯតេសំ ទេវទេវានំ មហាទានំ បវត្តយិន្តិ សម្ពន្ធោ។
*កោដិសព្ទក្នុងទីនេះចុះក្នុងអត្ថ ១០ មានន័យថា ១កោដិ=១០ ដូច្នេះ ព្រះពុទ្ធ ៥០០ កោដិ = ៥,០០០ អង្គ (ដែលកើតឡើងក្នុងនន្ទអសង្ខេយ្យ)។*

[៦៦] *ព្រះពុទ្ធ ៩០០ កោដិ = ៩,០០០ អង្គ (ក្នុងសុនន្ទអសង្ខេយ្យ)។*

[៦៧] *ព្រះពុទ្ធ ១,១០០កោដិ = ១១,០០០ អង្គ (ក្នុងមណ្ឌអសង្ខេយ្យ)។*

[៦៨] *ព្រះពុទ្ធ ២,០០០កោដិ = ២០,០០០ អង្គ (ក្នុងធរណីអសង្ខេយ្យ)។*

[៦៩] *ព្រះពុទ្ធ ៣,០០០កោដិ = ៣០,០០០ អង្គ (ក្នុងសាគរអសង្ខេយ្យ)។*

**ពុទ្ធបណិធាន**

បពិត្រមហារាជ សេចក្ដីកសាងដ៏ធំ របស់តថាគត សូមព្រះអង្គស្ដាប់ តថាគត ព្រះពុទ្ធទាំងឡាយបួនពាន់កោដិ[៧០]ផង ប្រាំពាន់កោដិ[៧១]ផង។ តថាគត បានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា បពិត្រមហារាជ សេចក្ដីកសាងដ៏ធំ របស់តថាគត សូមព្រះអង្គ ស្ដាប់តថាគត។

ព្រះពុទ្ធទាំងឡាយ ប្រាំមួយពាន់កោដិ[៧២]ផង ប្រាំពីរពាន់កោដិ[៧៣]ផង តថាគត បានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា។

បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ព្រះពុទ្ធទាំងឡាយ ប្រាំបីពាន់កោដិ[៧៤]ផង ប្រាំបួនពាន់កោដិ[៧៥]ផង។ តថាគត បានញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត។

ព្រះពុទ្ធទាំងឡាយ ជានាយកដ៏ប្រសើរក្នុងលោក មួយសែនកោដិ តថាគតបានញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា។

---

(៧០) ព្រះពុទ្ធ ៤,០០០កោដិ = ៤០,០០០ អង្គ (ក្នុងបុណ្ឌរីកអសង្ខេយ្យ)។

(៧១) ព្រះពុទ្ធ ៥,០០០កោដិ = ៥០,០០០ អង្គ (ក្នុងសព្វភទ្ទ អសង្ខេយ្យ)។

(៧២) ព្រះពុទ្ធ ៦,០០០កោដិ = ៦០,០០០ អង្គ (ក្នុងសព្វផុល្លអសង្ខេយ្យ)។

(៧៣) ព្រះពុទ្ធ ៧,០០០កោដិ = ៧០,០០០ អង្គ (ក្នុងសព្វរតនអសង្ខេយ្យ)។

(៧៤) ព្រះពុទ្ធ ៨,០០០កោដិ = ៨០,០០០ អង្គ (ក្នុងឧសភក្ខន្ធអសង្ខេយ្យ)។

(៧៥) ព្រះពុទ្ធ ៩,០០០កោដិ = ៩០,០០០ អង្គ (ក្នុងមានិភទ្ទអសង្ខេយ្យ)។

បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត

ព្រះពុទ្ធទាំងឡាយ ជានាយកនៃសត្វលោកដទៃទៀត ប្រាំបួនពាន់កោដិ។

តថាគត បានញុំាងមហាទានឱ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត។

ព្រះពុទ្ធជាមហេសី១សែន៨៥កោដិផង ១៨៥កោដិផង ៣៧កោដិផង។

តថាគត បានញុំាងមហាទានឱ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតា ក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់ តថាគត។

ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលប្រាសចាករាគៈ ចំនួនប្រាំបីៗកោដិ

បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត ចំពោះព្រះបច្ចេកពុទ្ធទាំងនុ៎ះ សូមព្រះអង្គស្តាប់តថាគត។

ព្រះខីណាស្រពទាំងឡាយ ជាសាវ័កនៃព្រះពុទ្ធ មានប្រមាណរាប់មិនបាន មានមន្ទិលអស់ហើយ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត ចំពោះព្រះខីណាស្រពទាំងនុ៎ះ សូមព្រះអង្គ ស្តាប់តថាគត។

កាលបុគ្គល អ្នកសន្សំក្នុងធម៌ទាំងឡាយ កាលបុគ្គលអ្នកប្រព្រឹត្តនូវព្រះសទ្ធម្មទាំងឡាយសព្វៗកាល បុគ្គលអ្នកប្រព្រឹត្តធម៌យ៉ាងនេះ តែងដេកជាសុខក្នុងលោកនេះ និងលោកខាងមុខ។

បុគ្គល គប្បីប្រព្រឹត្តធម៌ឱ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះឱ្យជាទុច្ចរិត

ឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌តែងដេកជាសុខក្នុងលោកនេះ និងលោកខាងមុខ។

ខ្ញុំ នឿយណាយក្នុងសង្សារ ហើយចូលទៅកាន់ផ្នួសដោយបរិវារមួយពាន់ លុះបួសហើយ មិនមានសេចក្តីក្រវល់ក្រវាយ។

ខ្ញុំ លះបង់ផ្ទះ ហើយចូលទៅកាន់ផ្នួស មិនទាន់ដល់កន្លះខែផងក៏បានដល់សច្ចៈ៤។ ជនទាំងឡាយជាច្រើននាំចីវរ បិណ្ឌបាត និងទីដេក ទីអង្គុយចូលមក ដូចជារលកក្នុងសាគរ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង។

ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ។ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ នេះខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ។

ខ្ញុំ ដល់នូវសេចក្តីទុក្ខច្រើនប្រការផង នូវសម្បត្តិច្រើនប្រការផង នូវការនោស្អាតផង ហើយបាននូវសម្បទាទាំងពួង។

បុគ្គលណាឱ្យកាយរបស់ខ្លួន ដល់ព្រះពុទ្ធមហេសី ដើម្បីប្រយោជន៍ដល់បុណ្យ សហាយសម្បទា និងចំណែកនៃព្រះនិព្វាន មិនមានបច្ច័យតាក់តែង រមែងមានដល់បុគ្គលនោះ។

*កិលេសជាត ជាអតីតក្តី ជាបច្ចុប្បន្នក្តី ជាអនាគតក្តី អស់រលីងហើយ កម្ម ទាំងពួងរបស់ខ្ញុំអស់ហើយ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំសូមក្រាប ថ្វាយបង្គំព្រះបាទា"។*

*បានឮថា ព្រះយសោធរាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ។*

*ចប់ យសោធរាថេរិយាបទាន។*

**ពុទ្ធបណិធាន**

## យសោធរាបមុខទសតិក្ខុនីសហស្សអបទាន
## បុព្វចរិយា របស់តិក្ខុនី១ម៉ឺនអង្គ
## ដែលមានព្រះនាងយសោធរា ជាប្រមុខ



ក្នុងកប្បទី៤អសង្ខេយ្យ និងមួយសែនកប្ប ព្រះជិនស្រីព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើង។

"ព្រះពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ទ្រង់ព្យាករនូវសុមេធតាបស ផង នាងសុមិត្តាផង ដែលរួមសុខទុក្ខ ជាមួយគ្នា។

ព្រះមហាមុនី ព្រះអង្គឃើញមនុស្សលោក និងទេវលោក ទាំងទ្រង់ស្តេច
ទៅកាន់មនុស្សលោក និងទេវលោក ហើយចូលមកកាន់ទីប្រជុំនៃយើង
ខ្ញុំ ដែលកំពុងសរសើរជនទាំងនោះ។
ប្តីទាំងអស់របស់យើងខ្ញុំ មានក្នុងទីសមាគមជាអនាគត, ប្រពន្ធទាំងអស់
របស់ព្រះអង្គ ជាទីពេញព្រះទ័យនៃព្រះអង្គ ជាអ្នកពោលពាក្យជាទី
ស្រឡាញ់។
ទាន សីល ភាវនាទាំងអស់  យើងខ្ញុំបានអប់រំ ដោយល្អហើយ បពិត្រព្រះ
មហាមុនី វត្ថុទាំងអស់នេះខ្ញុំបានលះបង់ចោល អស់កាលជាយូរអង្វែង
ហើយ។
វត្ថុណាមួយគឺគ្រឿងក្រអូប កម្រងផ្កា គ្រឿងលាប និងប្រទីបជាវិការៈនៃ
កែវ ដែលយើងខ្ញុំបានតម្កល់ទុកហើយ  បពិត្រព្រះមហាមុនី វត្ថុទាំងអស់
នោះ យើងខ្ញុំបានលះបង់ហើយ។
ន័យមួយទៀត អំពើដទៃ និងគ្រឿងបរិភោគ  ជារបស់មនុស្ស ដែលយើង
បានធ្វើហើយ បពិត្រព្រះមហាមុនី របស់ទាំងអស់នុ៎ះ យើងខ្ញុំបានលះ
បង់ចោល អស់កាលយូរអង្វែងហើយ។
បុណ្យ មានប្រមាណច្រើន ដែលយើងបានធ្វើហើយ បានសោយនូវភាព
ជាឥស្សរៈ ត្រាច់រង្គាត់ក្នុងភពតូច ភពធំ អស់សំសារវដ្ត មានជាតិច្រើន។
លុះដល់មកក្នុងបច្ឆិមភព យើងខ្ញុំ បានកើតក្នុងត្រកូលផ្សេងៗគ្នា ក្នុង
លំនៅនៃព្រះសក្យបុត្រ ជាស្រីមានពណ៌សម្បុរ ជាទីប្រាថ្នា បីដូចជាស្រី
ទេពអប្សរ បានដល់នូវយស ដែលជនទាំងពួង ធ្វើសក្ការបូជាហើយ
ដោយលាភដ៏ប្រសើរ បាននូវបាយ និងទឹក ដែលពួកជនរាប់អានសព្វៗ

*កាល។*

*យើងខ្ញុំ លះបង់នូវផ្ទះ ហើយចូលទៅកាន់ផ្នួស មិនទាន់បានដល់កន្លះខែ ក៏បានដល់សេចក្តីរំលត់ទុក្ខ ទាំងអស់គ្នា។*

*យើងខ្ញុំ ជាអ្នកបាននូវបាយ និងទឹកផង នូវសំពត់ និងសេនាសនៈផង បច្ច័យទាំងពួង រមែងមានគ្រប់គ្រាន់ យើងខ្ញុំត្រូវគេធ្វើសក្ការបូជាសព្វកាល។*

*កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់យើងខ្ញុំគាស់រំលើងហើយ យើងខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្នឹង។*

*ឱ! យើងខ្ញុំ មកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ។*

*បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ យើងខ្ញុំ បានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ។*

*បានឮថា ព្រះភិក្ខុនីមួយម៉ឺនរូប មានព្រះនាងយសោធរាភិក្ខុនីមានអាយុជាប្រធាន បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ។*

*ចប់ យសោធរាបមុខទសភិក្ខុនីសហស្សាបទាន ។*

# យសោធរាបមុខអដ្ឋារសភិក្ខុនីសហស្សអបទាន
# បុព្វចរិយា របស់ភិក្ខុនី១ម៉ឺន៨ពាន់អង្គ
# ដែលមានព្រះនាងយសោធរាជាប្រមុខ



*ភិក្ខុនី១៨ពាន់ មាននាងយសោធរាជាប្រធាន ដែលកើតក្នុងត្រកូលសក្យៈ បាននាំគ្នាចូលទៅគាល់ព្រះសម្ពុទ្ធ។*

*ភិក្ខុនីទាំង១៨ពាន់នោះ សឹងមានឫទ្ធិច្រើន នាំគ្នាចូលទៅថ្វាយបង្គំព្រះបាទាព្រះមុនី ក្រាបទូលតាមសមគួរដល់កម្លាំងថា៖*

"បពិត្រព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ នៃយើងខ្ញុំអស់ហើយ បពិត្រព្រះអង្គជានាយក យើងខ្ញុំទាំងឡាយ នឹងទៅកាន់ព្រះបរិនិព្វាន ឈ្មោះអមតៈ ដែលមិនមានអាសវៈ ជាផ្លូវដ៏ស្ងប់រម្ងាប់។

បពិត្រព្រះមហាមុនី កាលពីដើម ពួកភិក្ខុនីទាំងអស់ មានសេចក្ដីភ្លាំងភ្លាត់ ពួកភិក្ខុនីដឹងច្បាស់នូវកំហុស បពិត្រព្រះអង្គជានាយក សូមព្រះអង្គអត់ទោសដល់យើងខ្ញុំ"។

ព្រះពុទ្ធ ត្រាស់ថា៖

"នាងទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់តថាគត ចូរសម្ដែងនូវឫទ្ធិឱ្យទាល់តែកាត់សេចក្ដីសង្ស័យ របស់ពួកបរិស័ទទាំងអស់"។

ភិក្ខុនីទាំងនោះ ទូលថា៖

"បពិត្រព្រះមហាវីរៈ ខ្ញុំម្ចាស់យសោធរា ជាទីពេញព្រះហឫទ័យ ជាទីស្រឡាញ់ គួររមិលមើល បពិត្រមហាវីរៈ ស្ត្រីទាំងពួង ជាព្រះជាយា ក្នុងសម្នាក់របស់ព្រះអង្គ។

បពិត្រព្រះអង្គដ៏មានព្យាយាមធំ បណ្ដាពួកស្រីមួយសែន៩៦រូប ខ្ញុំម្ចាស់ជាប្រធាន ជាឥស្សរៈលើស្រីទាំងពួង ក្នុងព្រះរាជដំណាក់របស់ព្រះអង្គ។

ពួកស្រីទាំងអស់ ជាអ្នកបរិបូណ៌ដោយគុណ គឺរូប និងអាចារៈ នៅក្នុងបឋមវ័យ ពួកស្រីទាំងអស់តែងអបចាយនៈព្រះអង្គ ដូចជាមនុស្សទាំងឡាយ គោរពកោតក្រែងទេវតា។

ពួកស្រីទាំង១៨ពាន់ កើតក្នុងត្រកូលសក្យៈ ក្នុងកាលនោះ ស្រីមួយពាន់ទ្រទ្រង់យស ជាប្រធានជាធំ។

បពិត្រព្រះមហាមុនី ស្រីទាំងឡាយ កន្លងនូវកាមធាតុ ឋិតនៅក្នុងរូបធាតុ ប្រាកដស្មើដោយរូបនៃស្រីទាំងមួយពាន់គ្មានទេ”។

ព្រះថេរីទាំងឡាយ មានឫទ្ធិច្រើន លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយ សម្ដែងឫទ្ធិថ្វាយព្រះសាស្ដា សម្ដែងនូវមហិទ្ធិឫទ្ធិ មានអាការផ្សេងៗដ៏ច្រើន គឺសម្ដែងកាយស្មើនឹងចក្កវាឡ, ឧត្តរកុរុទ្វីបជាក្បាល, ទ្វីបទាំងពីរជាស្លាបទាំងពីរខាង, ជម្ពូទ្វីបជាសរីរៈ, ស្រះខាងត្បូងជាសំណុំកន្ទុយ, ស្មឹងផ្សេងៗ ជាបំពង់ស្លាប, ព្រះចន្ទ្រ និងព្រះអាទិត្យជាភ្នែក, ភ្នំមេរុជាសិរ, ភ្នំចក្កវាឡ និងដើមព្រីង ព្រមទាំងឫស ជាចំពុះ, កាលបក់ហើយ ចូលមកថ្វាយបង្គំ ព្រះលោកនាយក។

កាលនោះ បានសម្ដែងភេទនៃដំរី សេះ ភ្នំ ជលជាតិ ព្រះចន្ទ្រ ព្រះអាទិត្យ ភ្នំមេរុ និងភេទព្រះឥន្ទ។

“បពិត្រព្រះអង្គ មានព្យាយាម មានចក្ខុ យើងខ្ញុំ និងនាងយសោធរា សូមថ្វាយបង្គំព្រះបាទា បពិត្រព្រះអង្គ ជានាយកនៃជន យើងខ្ញុំសម្រេចហើយ ដោយអានុភាព របស់ព្រះអង្គ អស់កាលដ៏យូរ។

បពិត្រព្រះមហាមុនី យើងខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង។

យើងខ្ញុំ ដឹងបុព្វេនិវាសៈ ទិព្វចក្ខុ យើងខ្ញុំជម្រះស្អាតហើយ យើងខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ។

បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិ-សម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃយើងខ្ញុំ កើតឡើង

ហើយ ក្នុងសម្នាក់របស់ព្រះអង្គ។ ការគប់រកនូវព្រះពុទ្ធទាំងឡាយ ដែលជាទីពឹងរបស់សត្វលោក យើងខ្ញុំបានសម្តែងហើយ បពិត្រព្រះមហាមុនី ការកសាងជាច្រើន យើងខ្ញុំបានធ្វើហើយ ដើម្បីប្រយោជន៍ព្រះអង្គ។

បពិត្រព្រះមុនី កុសលកម្មណា ដែលជាកម្មចាស់ របស់ខ្ញុំ សូមព្រះអង្គនឹកនូវកុសលកម្មនោះ បពិត្រព្រះអង្គ មានព្យាយាមធំ បុណ្យទាំងឡាយ យើងខ្ញុំសន្សំហើយ ដើម្បីប្រយោជន៍ព្រះអង្គ។

បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំបានវៀរក្នុងទីមិនគួរ ហើយហាមឃាត់នូវអនាចារ សូម្បីជីវិតយើងខ្ញុំ ក៏បានលះបង់ ដើម្បីប្រយោជន៍ព្រះអង្គ។

ព្រះអង្គ ទ្រង់ប្រទានយើងខ្ញុំ ដើម្បីប្រយោជន៍ជាភរិយា នៃបុគ្គលដទៃវិញអស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្ត ក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ។

ព្រះអង្គ បានប្រទាននូវយើងខ្ញុំ ដើម្បីទំនុកបម្រុងជនដទៃអស់ជាតិ មានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្ត ក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ។

ព្រះអង្គ ទ្រង់ព្រះរាជទាននូវយើងខ្ញុំ ដើម្បីប្រយោជន៍ ដល់ការប្រើប្រាស់នៃជនដទៃ អស់ជាតិមានពាន់ នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំទាំងឡាយ ឥតមានតូចចិត្ត ក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ។

យើងខ្ញុំ បានលះបង់ជីវិតទាំងឡាយ មានពាន់នៃកោដិដ៏ច្រើន គឺធ្វើឱ្យគេ

រួចចាកទុក្ខភ័យ ស៊ូលះបង់ជីវិតនៃខ្លួន។

បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលលាក់ទុកនូវ គ្រឿងប្រដាប់ ដែលជាប់នឹងអង្គ ដូចយ៉ាងសំពត់ផ្សេងៗជាច្រើន ភណ្ឌៈរបស់ស្រី ដើម្បីប្រយោជន៍ព្រះអង្គ។

បពិត្រព្រះមហាមុនី យើងខ្ញុំបានបរិច្ចាគទ្រព្យ និងស្រូវ បានបរិច្ចាគស្រុក និគម ស្រែ កូនប្រុស កូនស្រី។

បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំបានបរិច្ចាគដំរី សេះ គោ ខ្ញុំស្រី អ្នកបម្រើរាប់មិនអស់ ដើម្បីប្រយោជន៍ព្រះអង្គ។

ព្រះអង្គបានប្រឹក្សានឹងយើងខ្ញុំ ដោយទានណា យើងខ្ញុំក៏បានឱ្យទាននោះដល់ស្វាមទាំងឡាយ យើងខ្ញុំមិនបានឃើញនូវសេចក្តីតូចចិត្តចំពោះព្រះអង្គ កាលដែលឱ្យទានដ៏ឧត្តមនោះ សោះឡើយ។

បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំទាំងឡាយ បានទទួលនូវសេចក្តីទុក្ខ មានចំណែកច្រើនជំពូកណាស់ រាប់មិនអស់ក្នុងសំសារ មានចំណែកច្រើន ដើម្បីប្រយោជន៍ព្រះអង្គ។

បពិត្រព្រះមហាមុនី យើងខ្ញុំបានរីករាយ តាមចំណែកបុណ្យ ដែលនាំមកនូវសេចក្តីសុខ ទាំងមិនតូចចិត្ត ចំពោះទុក្ខទាំងឡាយ ជាអ្នកត្រេកអរក្នុងទីទាំងពួង ដើម្បីប្រយោជន៍ព្រះអង្គ។

បពិត្រព្រះមហាមុនី ព្រះសម្ពុទ្ធ ទ្រង់សោយនូវសុខទុក្ខ ហើយដល់នូវការត្រាស់ដឹង នាំមកនូវធម៌ដោយលំដាប់មគ្គ។

ការគប់រក នៃព្រះលោកនាថទាំងឡាយ ដទៃច្រើន ព្រោះអាស្រ័យព្រះ

*សម្ពុទ្ធ ព្រះនាមព្រហ្មទេវៈ និងព្រះសម្ពុទ្ធ ព្រះនាមគោតម ដែលជាព្រះលោកនាយក យើងខ្ញុំបានសម្តែងហើយ។*

*សេចក្តីកសាងដ៏ច្រើននៃយើងខ្ញុំ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ព្រះអង្គ បពិត្រព្រះមហាមុនី យើងខ្ញុំជាស្រីបម្រើរបស់ព្រះអង្គ កាលដែលទ្រង់ស្វែងរកនូវពុទ្ធធម៌។*

*ក្នុងកប្បទី៤អសង្ខេយ្យ និង១សែន ព្រះសម្ពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ជាលោកនាយក ទ្រង់កើតឡើង។*

*ជនទាំងឡាយនៅបច្ចន្តប្រទេស និមន្តព្រះតថាគត មានចិត្តត្រេកអរ នាំគ្នាជម្រះផ្លូវ សម្រាប់យាងមកនៃព្រះតថាគតនោះ។*

*ក្នុងកាលនោះ ព្រះអង្គជាព្រាហ្មណ៍ឈ្មោះ* **សុមេធៈ** *បានចាត់ចែងរៀបចំផ្លូវ ដើម្បីព្រះសម្ពុទ្ធទីបង្ករ ទ្រង់យើញហេតុទាំងពួង ទ្រង់យាងមក។*

*ក្នុងកាលនោះ យើងខ្ញុំទាំងអស់គ្នា កើតក្នុងត្រកូលព្រាហ្មណ៍ បានទៅនាំយកផ្កា ផលុកជាតិ មកកាន់ទីប្រជុំ។*

*ក្នុងសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ មានយសធំ មានព្យាយាមធំនោះ ទ្រង់បានព្យាករនូវសុមេធតាបស ជាឥសីមានចិត្តរីករាយ។*

*កាលព្រះពុទ្ធទីបង្ករ ទ្រង់ប្រកាសកម្មរបស់សុមេធតាបសនោះថា ជាឥសីមានចិត្តរីករាយ ផែនដីក៏កក្រើករំភើបញាប់ញ័រ ក្នុងមនុស្សលោក និងទេវលោក។ ពួកទេវកញ្ញា ពួកមនុស្ស ទាំងយើងខ្ញុំ និងទេវតា សឹងនាំគ្នាបូជាគ្រឿងប្រដាប់ ដែលគួរបូជាផ្សេងៗ ហើយតាំងប្រាថ្នា។*

*ព្រះពុទ្ធជាម្ចាស់ មានព្រះនាមទីបង្ករ ទ្រង់បានព្យាករ ដល់ពួកជនទាំងនោះថា ជនទាំងឡាយណា មានសេចក្តីប្រាថ្នាក្នុងថ្ងៃនេះ ជនទាំងនោះ*

ឈ្មោះថា មានក្នុងទីចំពោះព្រះភក្ត្រ(នៃព្រះពុទ្ធ)។

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះពុទ្ធព្យាករនូវយើងខ្ញុំ ដោយព្រះពុទ្ធដីកាណា យើងខ្ញុំរមែងរីករាយតាមព្រះពុទ្ធដីកានោះ ជាអ្នកធ្វើតាមយ៉ាងនោះ។

ជនទាំងឡាយ បានចាប់កំណើតជាទេវតា និងមនុស្ស រាប់មិនអស់ ហើយញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងព្រះពុទ្ធនោះ ដោយអំណាចនៃកម្មនោះ ដែលខ្លួនធ្វើល្អហើយ។

យើងខ្ញុំ បានសោយសុខទុក្ខក្នុងទេវតាផង មនុស្សផង ដល់មកក្នុងបច្ឆិមភពនេះ បានមកកើតក្នុងត្រកូលសក្យៈ។

យើងខ្ញុំជាអ្នកមានរូបល្អ មានភោគសម្បត្តិច្រើន មានយស និងសីលដ៏ល្អ បរិបូណ៌ដោយអវយវៈសព្វគ្រប់ ជាអ្នកអង់អាចលើស ក្នុងត្រកូលទាំងឡាយ។

ចិត្ត នៃយើងខ្ញុំ ដែលប្រជុំចុះក្នុងលោកធម៌ មានលាភៈ សេចក្ដីសរសើរ និងគ្រឿងសក្ការៈ ជាចិត្តមិនដល់នូវសេចក្ដីទុក្ខទេ តើយើងខ្ញុំ នឹងមានភ័យអំពីណា?

សមដូចជា ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះតម្រាស់នេះ បំពោះស្ដេចខាងក្នុងបុរី ក្នុងកាលនោះដូច្នេះថា៖

"មហារាជបានសម្ដែងនូវឧបការគុណ របស់នារីនៃពួកក្សត្រក្នុងបុរីនោះ គឺនារីមានឧបការៈ នារីរួមសុខទុក្ខ នារីដែលប្រាប់នូវប្រយោជន៍ និងនារីជាអ្នកមានសេចក្ដីអនុគ្រោះ។

បុគ្គល គប្បីប្រព្រឹត្តធម៌ឱ្យជាសុចរិត កុំគប្បីប្រព្រឹត្តធម៌នោះឱ្យជាទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុង

*លោកខាងមុខផង។*

*យើងខ្ញុំ បានលះបង់ផ្ទះហើយ ហើយចូលទៅកាន់ផ្នួស មិនបានដល់កន្ទះខែ ស្រាប់តែយើងខ្ញុំបាននូវសច្ចៈ៤។ ពួកជនដ៏ច្រើន តែងបង្អោនមកនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ និងសេនាសនប្បច្ច័យ ចំពោះយើងខ្ញុំ បីដូចរលកនៃសាគរ។*

*កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់យើងខ្ញុំដកចោលចេញហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្ទឹង។*

*ឱ! យើងខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា៣ យើងខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ យើងខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ។*

*យើងខ្ញុំដល់នូវភាពបរិសុទ្ធ បរិបូណ៌ដោយគុណទាំងពួង តែងបាននូវទុក្ខមានប្រការច្រើន និងសម្បត្តិ មានប្រការច្រើនយ៉ាងនេះឯង។*

*ស្រីទាំងឡាយណា ឱ្យនូវខ្លួនជារបស់ខ្លួន ដល់បុគ្គលស្វែងរកនូវគុណដ៏ធំ ដើម្បីប្រយោជន៍ដល់បុណ្យ ស្រីទាំងឡាយនោះឈ្មោះថា អ្នកបរិបូណ៌ដោយសម្ភាញ់ តែងបាននូវព្រះនិព្វាន មានចំណែកមិនមានបច្ច័យ ប្រជុំតាក់តែង។*

*កម្មជាអតីត ជាបច្ចុប្បន្ន ជាអនាគត នៃយើងខ្ញុំអស់ហើយ កម្មទាំងពួងរបស់យើងខ្ញុំអស់រលីងហើយ បពិត្រព្រះអង្គមានចក្ខុ យើងខ្ញុំសូមថ្វាយបង្គំនូវព្រះបាទា។*

*បុគ្គលណាមានទោស គឺបច្ច័យ ប្រជុំតាក់តែងស្ងប់រម្ងាប់ហើយ ដល់នូវ*

ចំណែកព្រះនិព្វាន ឈ្មោះអមតៈ យើងខ្ញុំនឹងក្រាបទូលដល់ព្រះអង្គនូវបុគ្គលនោះ ឱ្យក្រៃលែងជាងពួកស្រី ដែលពោលពីព្រះនិព្វាន ដូចម្ដេចកើត”។

បានឮថា ព្រះភិក្ខុនី១៨,០០០រូប មានព្រះនាងយសោធរាភិក្ខុនីជាប្រមុខ បានសម្ដែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ។

ចប់ យសោធរាបមុខអដ្ឋារសភិក្ខុនីសហស្សាបទាន ។

**ពុទ្ធបណិធាន**

## យសវតីបមុខអដ្ឋារសតិក្ខុនីសហស្សាបទាន

## (អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន)

*បពិត្រព្រះមហាមុនី យើងខ្ញុំសូមក្រាបទូលថា ភពទាំងពួងនៃយើងខ្ញុំអស់ហើយ តំណនៃភព យើងខ្ញុំបានដោះចេញហើយ អាសវៈទាំងពួងរបស់យើងខ្ញុំមិនមានឡើយ។*

*បពិត្រព្រះមហាមុនី កុសលណាមួយ ដែលយើងខ្ញុំបរិកម្មហើយ ទាំងប្រាថ្នាដោយប្រពៃហើយ គ្រឿងប្រើប្រាស់ យើងខ្ញុំបានឲ្យហើយដើម្បីប្រយោជន៍ព្រះអង្គ។*

*បពិត្រព្រះមហាមុនី គ្រឿងប្រើប្រាស់ យើងខ្ញុំបានឲ្យហើយ ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័កទាំងឡាយ បានប្រាថ្នាហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ។*

*បពិត្រព្រះមហាមុនី កម្មខ្ពស់និងទាប យើងខ្ញុំបានតម្កល់ទុក ដើម្បីពួកភិក្ខុដោយប្រពៃ ការបរិកម្មក្នុងត្រកូលដ៏ខ្ពស់ យើងខ្ញុំបានធ្វើរួចហើយ។*

*នាងខត្តិយកញ្ញាទាំងឡាយ ជាអ្នកបរិបូណ៌ដោយកម្ម ត្រូវកុសលមូលនោះឯង មកដាស់តឿន ហើយកន្ទងនូវធម៌របស់មនុស្ស បានមកកើតក្នុងខត្តិយត្រកូល។*

*កម្មដែលយើងខ្ញុំបានសន្សំ បានធ្វើហើយ ក្នុងជាតិជាមួយគ្នា ក្នុងបច្ឆិមជាតិ យើងខ្ញុំក៏កើតក្នុងខត្តិយត្រកូលជាមួយគ្នា។*

*បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំមានរូបល្អ ទាំងមានភោគសម្បត្តិច្រើន ទាំងមានលាភៈនិងគ្រឿងសក្ការៈ ត្រូវពួកជនបូជាហើយ នៅក្នុងព្រះរាជវាំង បីដូចជានៅក្នុងនន្ទនឧទ្យាននៃពួកទេវតា។*

យើងខ្ញុំទាំងអស់គ្នា នឿយណាយ ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស នៅអាស្រ័យត្រឹមតែ ពីរបីថ្ងៃ ក៏បានដល់ព្រះនិព្វាន។

ជនទាំងឡាយដ៏ច្រើនតែងបង្អោននូវចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ដើម្បីយើងខ្ញុំ បូជានូវគ្រឿងសក្ការៈ ដល់យើងខ្ញុំ សព្វ ៗ កាល។

កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំក៏ដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង។

ឱ ! យើងខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ ប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខត្តិយកញ្ញាភិក្ខុនី ចំនួន ១៨,០០០ រូប មានព្រះនាងយសោធរាភិក្ខុនី ជាប្រធានបានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

យសវតីបមុខអដ្ឋារសភិក្ខុនីសហស្សាបទាន។

(ចប់ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ។)

## ចតុរាសីតិភិក្ខុនីសហស្សអបទាន

## (ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន)

*បពិត្រព្រះមហាមុនី ភិក្ខុនី ៨៤,០០០ កើតក្នុងត្រកូលព្រាហ្មណ៍ មានជើងដៃទន់ល្វន់ ក្នុងបុរីនៃព្រះអង្គ។*

*បពិត្រព្រះមហាមុនី ពួកស្ត្រី កើតក្នុងវេស្សត្រកូល និងសុទ្រត្រកូល ពួកទេវតាពួកនាគ ពួកកិន្នរ ពួកនាងកញ្ញាដ៏ច្រើន ទាំង៤ទ្វីបក្នុងបុរីរបស់ព្រះអង្គ។*

*ពួកស្រីខ្លះ ក៏បានបួស ពួកទេវតាច្រើន ពួកកិន្នរ និងពួកនាគដែលជាអ្នកឃើញធម៌ ទាំងពួងហើយ គង់នឹងបានត្រាស់ដឹង ក្នុងអនាគតកាល។*

*ជនទាំងឡាយនោះ បានទទួលនូវយសទាំងពួង សម្រេចសម្បត្តិទាំងពួង ហើយបាននូវសេចក្តីជ្រះថ្លាក្នុងព្រះអង្គ មុខជានឹងបានត្រាស់ដឹង ក្នុងអនាគតកាល។*

*បពិត្រព្រះអង្គមានព្យាយាមធំ មានចក្ខុ យើងខ្ញុំជាធីតានៃព្រាហ្មណ៍ កើតក្នុងត្រកូលព្រាហ្មណ៍ ប្រកបដោយលក្ខណៈ សូមក្រាបថ្វាយបង្គំព្រះបាទា (របស់ព្រះអង្គ)។*

*ភពទាំងឡាយ យើងខ្ញុំលះបង់ចោលហើយ ឫសគល់នៃតណ្ហា យើងខ្ញុំបានដកចេញហើយ អនុស័យយើងខ្ញុំបានផ្តាច់ផ្តិលហើយ បុញ្ញាភិសង្ខារយើងខ្ញុំបានទម្លាយចេញហើយ។*

*យើងខ្ញុំទាំងអស់មានសមាធិជាអារម្មណ៍ ជាអ្នកស្ទាត់ជំនាញក្នុងសមាបត្តិ នឹងប្រព្រឹត្តនៅដោយការត្រេកអរក្នុងធម៌ ដោយឈានសព្វៗកាល។*

បពិត្រព្រះអគ្គជានាយក តណ្ហាដែលនាំសត្វទៅកាន់ភព អវិជ្ជានិង សង្ខារទាំងឡាយ យើងខ្ញុំបានធ្វើឲ្យអស់ហើយ យើងខ្ញុំយល់ច្បាស់នូវធម៌ ព្រោះដល់នូវបទគឺព្រះនិព្វាន ដែលបុគ្គលឃើញបានដោយកម្រ។

ព្រះសម្ពុទ្ធត្រាស់ថា ៖

"នាងទាំងឡាយ មានឧបការៈដល់តថាគត នាងទៅកាន់ផ្លូវឆ្ងាយ អស់កាលមានរាត្រីវែង នាងទាំងអស់គ្នា ចូរកាត់នូវសេចក្តីសង្ស័យ នៃបរិស័ទទាំង ៤ ហើយទៅកាន់ព្រះនិព្វានចុះ"។

ពួកភិក្ខុនីខ្លះ ថ្វាយបង្គំព្រះបាទានៃព្រះមុនីរួចហើយ ក៏ធ្វើនូវការផ្ទែងឫទ្ធិ សម្តែងនូវពន្លឺ ហើយសម្តែងនូវងងឹតដទៃទៀត។

ពួកភិក្ខុនីខ្លះ សម្តែងព្រះចន្ទ្រនិងព្រះអាទិត្យ ខ្លះសម្តែងសាគរប្រកបដោយត្រី ខ្លះសម្តែងភ្នំសិនេរុ និងភ្នំបរិភ័ណ្ឌ ខ្លះសម្តែង ដើមបារិច្ឆត្តព្រឹក្ស។

ខ្លះសម្តែងភពតាវត្តិង្ស ខ្លះសម្តែងភពឈ្មោះយាមៈដោយឫទ្ធិ ខ្លះនិម្មិតជាទេវតាមានឥស្សរៈធំ នៅក្នុងជាន់តុសិត និងវសវត្តី។

ពួកខ្លះនិម្មិតជាព្រហ្ម សម្តែងទីចង្ក្រមមានតម្លៃច្រើន ខ្លះនិម្មិតភេទជាព្រហ្ម សម្តែងនូវធម៌ដ៏សូន្យ។

លុះពួកស្រីទាំងអស់ បានផ្ទែងឫទ្ធិប្លែកៗ ហើយសម្តែងឫទ្ធិ សម្តែងកម្លាំងថ្វាយព្រះសាស្តារួចហើយ ថ្វាយបង្គំព្រះបាទាព្រះសាស្តាទូលថា

បពិត្រព្រះមហាមុនី យើងខ្ញុំ ជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង។

យើងខ្ញុំដឹងច្បាស់ នូវបុព្វេនិវាស ទិព្វចក្ខុ យើងខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងរបស់យើងខ្ញុំអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះគ្មានឡើយ ។

**ពុទ្ធបណិធាន**

បពិត្រព្រះអង្គមាន ព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្បដិសម្ភិទាផង ក្នុងធម្មប្បដិសម្ភិទាផង ក្នុងនិរុត្តិប្បដិសម្ភិទាផង ក្នុងបដិភាណប្បដិសម្ភិទាផង របស់យើងខ្ញុំ កើតឡើងហើយក្នុងសំណាក់ព្រះអង្គ។

បពិត្រព្រះមហាមុនី ការគប់រកព្រះពុទ្ធទាំងឡាយដែលជាទីពឹងនៃសត្វលោកយើងខ្ញុំបានជួបហើយ យើងខ្ញុំបានកសាងបុណ្យដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ។

បពិត្រព្រះមហាមុនី កម្មណា ដែលយើងខ្ញុំបានធ្វើហើយ ក្នុងកាលមុន សូមព្រះអង្គរឭក នូវកម្មជាកុសលនោះចុះ បពិត្រព្រះមហាវីរៈ បុណ្យទាំងឡាយ យើងខ្ញុំបានសាងសន្សំហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានព្រះមហាមុនីមួយព្រះអង្គព្រះនាមបទុមុត្តរៈ ឯបុរីឈ្មោះហង្សវតី ជាលំនៅនៃត្រកូលព្រះសម្ពុទ្ធ។

ស្ទឹងគង្គាតែងហូរទៅ ក្នុងបុរី ឈ្មោះហង្សវតី តាមទ្វារសព្វ ៗ កាល ពួកភិក្ខុទាំងនោះត្រូវទឹកស្ទឹងបៀតបៀន ក៏ទៅមកមិនបាន។

ភិក្ខុទាំងឡាយនោះ ទៅមិនបាន អស់ពីរថ្ងៃអស់បីថ្ងៃ អស់ ៧ ថ្ងៃ អស់មួយខែ ដរាបទាល់ពេញបួនខែ។

គ្រានោះ មានបុរសជាខ្ញុំមសាររបស់សត្វឈ្មោះជដ្ឋៈ ជាអ្នកនៅក្នុងដែនបានឃើញពួកភិក្ខុ នៅត្រើយខាងអាយ ក៏ឲ្យគេសាងស្ពាន ត្រង់ស្ទឹងគង្គា។

គ្រានោះ បុរសនោះ បានសាងស្ពាននាស្ទឹងគង្គា ដោយតម្លៃមួយសែនកហាបណៈផង បានសាងវិហារក្នុងត្រើយខាងនាយនិងត្រើយខាងអាយ ដើម្បីភិក្ខុសង្ឃផង។

ពួកស្រី ពួកបុរស ពួកត្រកូលខ្ពស់និងទាប ជនទាំងនោះ បានធ្វើស្ពានផង វិហារផង មានភាគស្មើគ្នា ដើម្បីភិក្ខុសង្ឃនោះ។

*ពួកយើងខ្ញុំផង ពួកមនុស្សជាទេវផង ក្នុងនគរ ក្នុងជនបទ មានចិត្តជ្រះថ្លា ជាអ្នកទទួលមត៌កក្នុងធម៌នៃព្រះសម្ពុទ្ធនោះ។*

*ពួកស្រី ពួកប្រុស ពួកកុមារ ពួកកុមារិកាជាច្រើន ជនទាំងនោះ បាននាំគ្នាពោយ រាយដីខ្សាច់ ដល់ស្ថានផង ដល់វិហារផង។*

*ជនទាំងនោះ នាំគ្នាដាំដើមចេក តម្កល់ក្អមពេញដោយទឹក លើកទង់ បោសសំអាតផ្លូវថ្នល់ បូជាធូប គ្រឿងលំអិត កម្រងផ្កា ជាគ្រឿងសក្ការៈថ្វាយព្រះសាស្តា។*

*លុះជនទាំងនោះបានធ្វើស្ថាននិងវិហាររួចហើយ និមន្តព្រះសាស្តាជានាយក ថ្វាយមហាទាន ហើយប្រាថ្នានូវសម្ពោធិញ្ញាណ។*

*ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ជាមហាវីរៈ ជាទីគោរពរបស់សព្វសត្វទាំងឡាយ ទ្រង់បានធ្វើអនុមោទនា ហើយព្យាករថា*

*ក្នុងកប្បទីមួយសែនកន្លងទៅ មានភទ្ទកប្បកើតឡើង បុរសនោះ បាននូវសេចក្តីសុខ ក្នុងភពតូចភពធំ ហើយនឹងដល់ពោធិញ្ញាណ ។*

*ពួកនរៈនារីណាមួយ ដែលបានធ្វើនូវហត្ថកម្ម លុះដល់កាលជាអនាគត ជនទាំងអស់នោះ នឹងមានក្នុងទីចំពោះព្រះភក្ត្រ (នៃព្រះពុទ្ធនោះ) ។*

*ពួកស្រីជាអ្នកបម្រើទាំងអស់នោះរបស់ព្រះអង្គ កើតហើយក្នុងភពនៃទេវតា ព្រោះផលនៃកុសលកម្មនោះផង ព្រោះការតម្កល់ទុកនូវចេតនានោះផង។*

*ជនទាំងនោះ សោយទិព្វសុខរាប់មិនអស់ផង សោយសុខរបស់មនុស្សរាប់មិនអស់ផង ត្រាច់រង្គាត់ក្នុងភពតូចភពធំ អស់កាលជាយូរអង្វែង។*

*ក្នុងកប្បទីមួយសែន អំពីកប្បនេះ កម្មសម្បត្តិ យើងខ្ញុំធ្វើល្អហើយ ក្នុងពួកមនុស្សជាអ្នកល្អិតល្អ ទាំងក្នុងទេវបុរី ដ៏ប្រសើរ ។*

**ពុទ្ធបណិធាន**

យើងខ្ញុំតែងបាននូវរូបល្អ នូវភោគសម្បត្តិនិងយស នូវសេចក្តីសរសើរ សេចក្តីសុខនិងសេចក្តីស្រឡាញ់ ឯកម្មសម្បត្តិទាំងអស់ យើងខ្ញុំធ្វើល្អហើយ។

ដល់មកក្នុងបច្ឆិមភព យើងខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍ មានដៃជើង ទន់ល្វន់ ក្នុងព្រះរាជនិវេសន៍នៃសក្យបុត្រ។

បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលឃើញផែនដី ដែលពួកជនមិនបានប្រដាប់ រៀបចំសព្វកាលផង មិនដែលឃើញដំណើរទៅកាន់ទីមានភក់ផង។

កាលយើងខ្ញុំនៅគ្រប់គ្រងផ្ទះ ពួងជនតែងនាំគ្រឿងសក្ការៈប្រកបដោយកាលទាំងពួង អស់កាលគ្រប់កាល ដោយផលនៃបុព្វកម្មរបស់យើងខ្ញុំ។

យើងខ្ញុំបានលះបង់ផ្ទះ ហើយចូលទៅកាន់ផ្នួស បានធ្វងផ្លូវគឺសំសារវដ្ត ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

ជនទាំងឡាយ តែងនាំនូវចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ឲ្យដល់យើងខ្ញុំ ចំនួនមួយពាន់កហាបណៈអំពីទីនោះ ៗ សព្វៗកាល។

កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង។

ឱ ! យើងខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំ បានធ្វើហើយ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ។

បានឮថា ព្រះព្រាហ្មណកញ្ញាភិក្ខុនី ៨៤,០០០ រូប បានសម្ដែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

(ចប់ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន)។

## ធម្មរុចិត្ថេរាបទាន
## រឿងមេឃតាបស ជាមិត្ររបស់សុមេធបណ្ឌិត




*កាលព្រះជិនស្រីសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករៈ ទ្រង់ព្យាករនូវព្រះសុមេធតាបសថា សុមេធតាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអបរិមេយ្យកប្ប (កប្បរាប់មិនបានអំពីកប្បនេះ)។*

*ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ សុមេធតាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតមៈ។*

*សុមេធតាបសនេះ តម្កល់ទុកនូវសេចក្តីព្យាយាម ហើយធ្វើនូវទុក្ករកិរិយា នឹងបានត្រាស់ដឹងជាព្រះសម្ពុទ្ធ មានយសធំក្រោមម្លប់នៃអស្សត្ថព្រឹក្ស។*

*ភិក្ខុឈ្មោះឧបតិស្សៈ១ ឈ្មោះកោលិតៈ១ នឹងបានជាសាវ័កដ៏ប្រសើរ។*

*ភិក្ខុជាអ្នកឧបដ្ឋាកមាននាមថាអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ។*

*ភិក្ខុនីឈ្មោះខេមា១ ឈ្មោះឧប្បលវណ្ណា១ នឹងបានជាសាវិកាដ៏ប្រសើរ។*

*គហបតីឈ្មោះចិត្តៈ១ ឈ្មោះអាឡវកៈ១ នឹងបានជាឧបាសកដ៏ប្រសើរ។*

នាងខុជ្ជុត្តរា១ នាងនន្ទមាតា១ នឹងបានជាឧបាសិកាដ៏ប្រសើរ។

ដើមឈើ សម្រាប់ត្រាស់ដឹងនៃអ្នកប្រាជ្ញអង្គនេះ គេហៅថាអស្សត្ថ-ព្រឹក្ស។

ពួកមនុស្ស និងទេវតា បានឮព្រះពុទ្ធដីកានេះ នៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ឥតមានបុគ្គលណាស្មើ ក៏មានចិត្តរីករាយ នាំគ្នាធ្វើអញ្ជលីនមស្ការ។

"បពិត្រព្រះមហាមុនី កាលនោះ ខ្ញុំជាមាណពឈ្មោះ**មេឃ** អ្នកសិក្សាប្រពៃ បានឮពាក្យព្យាករណ៍ដ៏ប្រសើរនៃសុមេធតាបស។

ខ្ញុំ ស្និទ្ធស្នាលនឹងសុមេធតាបស មានករុណាជាលំនៅ ខ្ញុំក៏បានបួសតាមតាបស ជាអ្នកមានព្យាយាម ដែលទ្រង់ផ្នួសនោះ។

ខ្ញុំ សង្រួមក្នុងបាដិមោក្ខផង ក្នុងឥន្ទ្រិយទាំង៥ផង មានអាជីវៈដ៏បរិសុទ្ធ មានសតិ ជាអ្នកប្រាជ្ញ ជាអ្នកធ្វើតាមពាក្យប្រៀបប្រដៅ របស់ព្រះជិន-ស្រី។

កាលខ្ញុំនោះ នៅជាមួយបាបមិត្រណាមួយ ក៏បានប្រកបក្នុងអនាចារ ហើយឃ្លាតចាកផ្លូវដ៏ល្អ។

ខ្ញុំ ជាអ្នកលុះក្នុងអំណាចវិតក្កៈ បានចៀសចេញអំពីសាសនា វេលាក្រោយមក ខ្ញុំបានប្រកបដោយបាបមិត្តអាក្រក់នោះទៀត ក៏ប្រព្រឹត្តធ្វើនូវមាតុឃាត។

ខ្ញុំ មានចិត្តប្រទូស្ត បានធ្វើអនន្តរិយកម្ម គឺសម្លាប់មាតា ខ្ញុំច្យុតអំពីអត្ត-ភាពនោះ បានទៅកើតក្នុងមហាអវីចិនរក ក៏អាក្រក់ក្រៃពេក។

ខ្ញុំ ទៅកើតក្នុងអសុរកាយ ដល់នូវសេចក្តីទុក្ខ អន្ទោលទៅអស់កាលជាយូរអង្វែង លែងបានឃើញព្រះសុមេធតាបស ជាអ្នកប្រាជ្ញប្រសើរជាងជន។

ក្នុងកប្បនេះ ខ្ញុំបានកើតជាត្រីសមុទ្រ ឈ្មោះ**តិមិង្គលៈ** បានឃើញសំពៅក្នុងសាគរ ក៏ចូលទៅជិតដើម្បីអាហារ។

ពាណិជទាំងឡាយ បានឃើញខ្ញុំហើយ ក៏មានសេចក្តីភិតភ័យ បាននាំគ្នារំលឹកគុណនៃព្រះពុទ្ធដ៏ប្រសើរថា **គោតមៈៗ** ដូច្នេះ ខ្ញុំក៏បានឮសំឡេងគឹកកងខ្លាំង ដែលពួកពាណិជទាំងនោះ ពោលហើយ។

ខ្ញុំរលឹកឃើញនូវសញ្ញាអំពីដើម តអំពីនោះមក ខ្ញុំធ្វើនូវមរណកាល បានទៅកើតក្នុងកំណើតនៃព្រាហ្មណ៍ ជាត្រកូលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី។

ខ្ញុំ មានឈ្មោះ**ធម្មរុចិ** ជាអ្នកខ្ពើមអើមនូវបាបទាំងពួង មានអាយុ៧ឆ្នាំរាប់អំពីកំណើត បានឃើញព្រះពុទ្ធជាពន្លឺក្នុងលោក។

ខ្ញុំ បានទៅកាន់វត្តជេតពនដ៏ប្រសើរ ហើយចូលកាន់ផ្នួស ចូលទៅជិតព្រះពុទ្ធអស់វារៈ៣ដង រាល់យប់ រាល់ថ្ងៃ។

កាលនោះ ព្រះមុនីបានទតឃើញខ្ញុំហើយ ក៏ត្រាស់ថា នែធម្មរុចិ ចូរអ្នករលឹកតអំពីនោះទៅ។

ខ្ញុំ បានពោលនូវបុព្វកម្ម ដែលខ្លួនខ្ញុំបានអប់រំហើយ ថ្វាយព្រះពុទ្ធជាម្ចាស់ថា៖ ខ្ញុំខានបានឃើញព្រះពុទ្ធ មានបុញ្ញលក្ខណៈច្រើន មានវិសុទ្ធិជាបច្ច័យក្នុងកាលមុន អស់កាលយូរហើយ ទើបតែក្នុងថ្ងៃនេះ ខ្ញុំបានឃើញព្រះកាយ របស់ព្រះអង្គ ដ៏គួររមិលមើល រកបុគ្គលប្រៀបពុំបាន។

ខ្ញុំ បានតម្កល់បុណ្យ ចំពោះព្រះអង្គអស់កាលយូរ កិលេសទាំងឡាយ ខ្ញុំបានឱ្យរីងស្ងួត មិនមានសេសសល់ដោយការរក្សាដ៏ស្អាត ។

បពិត្រមហាមុនី ភ្នែក គឺញាណមិនមានមន្ទិល ខ្ញុំបានជម្រះហើយអស់
កាលយូរ។

ខ្ញុំព្រះអង្គ ប្រកបជាមួយនឹងព្រះអង្គអស់កាលដ៏យូរ មិនវិនាសក្នុង
ចន្លោះថ្មីទៀតអស់កាលដ៏យូរ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គប្រកបព្រម ជាមួយ
នឹងព្រះអង្គម្តងទៀត បពិត្រព្រះគោតមៈ អំពើទាំងឡាយ ដែលខ្ញុំបានធ្វើ
មិនវិនាសឡើយ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ
ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវ
ទន្ទីង។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា៣ ខ្ញុំបានដល់
ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ”។

បានឮថា ព្រះធម្មរុចិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយ
ប្រការដូច្នេះ ។

**គប្បីជ្រាបរឿង ក្នុងអបទានទី៩ នៃវគ្គទី៤៩ ដូចតទៅៈ**

**បទថា តទាហំ មាណវោ អាសឹ** មានសេចក្តីថា សុមេធបណ្ឌិត បាន
ទទួលព្យាករណ៍ អំពីព្រះមានព្រះភាគទីបង្ករក្នុងកាលណា ក្នុងកាលនោះ ខ្ញុំជា
ព្រាហ្មណ៍មាណព មានឈ្មោះថា**មេឃ** បានបួសជាឥសីជាមួយនឹងសុមេធ-
តាបស ហើយបានសិក្សាក្នុងសិក្ខាបទទាំងឡាយ តែដោយការប្រឡូកប្រឡល់
ជាមួយបាបមិត្រណាមួយ ក៏លុះក្នុងអំណាចនៃការត្រិះរិះមិនល្អ ដោយទោស
នៃការសេពគប់ខុស ព្រោះបានធ្វើមាតុឃាតកម្ម ដោយអំណាចមាតុឃាតកម្ម
នោះ ក៏បានសោយទុក្ខ ដោយអណ្តាតភ្លើងជាដើម ក្នុងនរក។

**ពុទ្ធបណិធាន**

*កាលចុតិចាកអត្តភាពនោះហើយបានកើតជា**មហាមច្ឆាឈ្មោះតិមិង្គល**[៧៦] ក្នុងសមុទ្រ ជាអ្នកប្រាថ្នាលេបនាវាដ៏ធំ ដែលកំពុងទៅ ក្នុងកណ្ដាលសមុទ្រ។*

*ពួកពាណិជ ឃើញត្រីនោះហើយភ័យខ្លាច ស្រែកនូវសំឡេងថា*

**អហោ គោតមោ ភគវា** *ឱហ្ន! ព្រះគោតម ដ៏មានព្រះភាគ។*

*លំដាប់នោះ ដោយអំណាច**បុព្វវាសនា** មហាមច្ឆាក៏កើត**ពុទ្ធគារវៈ**។*

---

[៧៦] **ក្នុងមហាសមុទ្រ មានមហាមច្ឆា (ត្រីធំៗ)ច្រើន ដូចជា៖**

-*ត្រី**តិមិ*** មានប្រវែង ២០០ យោជន៍

-*ត្រី**តិមិង្គល*** មានប្រវែង ៣០០ យោជន៍

-*ត្រី**តិមិបិង្គល*** មានប្រវែង ៤០០ យោជន៍

-*ត្រី**តិមិរបិង្គល*** មានប្រវែង ៥០០ យោជន៍

-ត្រី**អានន្ទ** ត្រី**តិមិនន្ទ** ត្រី**អជ្ឈារោហៈ** ត្រី**មហាតិមិ** មានប្រវែង ១,០០០ យោជន៍។

*(សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហានិទានសូត្រ ឧស្សាទនាវណ្ណនា)*

-*ត្រី**តិមិ*** មានប្រវែង ២០០ យោជន៍

-*ត្រី**តិមិង្គល*** មានប្រវែង ៣០០ យោជន៍

-*ត្រី**តិមិរបិង្គល*** មានប្រវែង ៥០០ យោជន៍

-ត្រី**អានន្ទ** ត្រី**តិមិនន្ទ** ត្រី**អជ្ឈារោហៈ** ត្រី**មហាតិមិ** មានប្រវែង ១,០០០ យោជន៍។

*(សារត្ថប្បកាសិនី អដ្ឋកថា សំយុត្តនិកាយ និទានវគ្គ និទានសំយុត្ត ទុក្ខវគ្គ និទានសូត្រ)*

បានឮតៗមកថា ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ នៅក្នុងមហាសមុទ្រ មានមហាមច្ឆា ៦ ក្បាល ។ ក្នុងបណ្ដាមហាមច្ឆាទាំងឡាយនោះ មច្ឆាទាំងឡាយ ៣ នេះគឺ

-មច្ឆាឈ្មោះ **អានន្ទ ១ តិមិនន្ទ ១ អជ្ឈារោហៈ ១** មានប្រវែង ៥០០ យោជន៍។

-មច្ឆាទាំងឡាយ ៣ នេះគឺ **តិមិង្គល ១ តិមិរបិង្គល ១ មហាតិមិរបិង្គល ១** មានប្រវែង ១,០០០ យោជន៍។

សូម្បីមច្ឆាទាំងអស់នោះ ជាសត្វដែលមានថ្ម និងសារាយជាអាហារ។ ប៉ុន្តែខាងក្រោយមក មច្ឆាខ្លះក៏បរិភោគស៊ីនូវត្រី និងសត្វផ្សេងៗជាអាហារ។

*(ជាតកដ្ឋកថា អសីតិនិបាត មហាសុតសោមវណ្ណនា)*

(សម័យខាងក្រោយមក) មហាមច្ឆាចុតិចាកអត្តភាពនោះហើយ បានកើតក្នុងព្រាហ្មណ៍ត្រកូលដែលមានទ្រព្យច្រើនក្នុងនគរសាវត្ថី ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ហើយបួស និងបានសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា។ លោកទៅទីឧបដ្ឋាន៣ ដងរាល់ថ្ងៃ រលឹក(គុណ)ថ្វាយបង្គំព្រះសាស្តា៕

គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងលោកថា **ចិរំ ធម្មរុចិ** ម្នាលធម្មរុចិ អស់កាលដ៏យូរមកហើយ ដូច្នេះ។

**ចប់ ធម្មរុចិត្ថេរាបទាន។**

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថេរាបទាន បំសុកូលវគ្គទី៤៩ បិដកលេខ៧៥ ទំព័រ ១៨៧ និងអដ្ឋកថា)*

**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទាន រមែងឈ្នះអស់ទានទាំងពួង**

**ពុទ្ធបណិធាន ចប់៕**

# ឯកសារយោង


១. ថេរីអបទានទីបនី (៣-កុណ្ឌលកេសីវគ្គ ៨-យសោធរាថេរីអបទានវណ្ណនា)

២. សម្ភារវិបាក

៣. សោតត្ថកីមហានិទាន

៤. ជាតត្ថកីមហានិទាន

៥. សីមវិសោធនី

៦. ជិនកាលមាលីបករណ៍

៧. សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថេរិយាបទាន

៨. ឆដ្ឋសង្គីតិបិដក ខុទ្ទកនិកាយ ពុទ្ធវំសបាឡិ

៩. សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស បិដកលេខ៧៧

១០-សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថេរាបទាន បំសុកូលវគ្គទី ៤៩ បិដកលេខ ៧៥ និង អដ្ឋកថា

១១. មធុរត្ថវិលាសិនី ពុទ្ធវំស-អដ្ឋកថា

១២. ជាតកដ្ឋកថា អដ្ឋកថាជាតក

១៣. ប្រវត្តិពុទ្ធសាវិកា ភាគ១ (យុង សុផាត)

១៤. វចនានុក្រមខ្មែរ (សម្តេចព្រះសង្ឃរាជ ជួន ណាត)

១៥. សទ្ទានុក្រមបាលី-ខ្មែរ

១៦. គម្ពីរកំពូលបិដក

១៧.ឆន្ទោសារត្ថមេទិនី វុត្តោទយាភិនវដីកា បញ្ចមបរិច្ឆេទ-វិសមវុត្តិនិទ្ទេស